ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- សិល្បៈដើម្បីចងចាំ និងអប់រំ
- ស្តូបតម្កល់អដ្ឋិធាតុវត្តព្រៃតាធឹកសង់ថ្មី

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៤៩ ខែឧសភា ឆ្នាំ២០១២

ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៨៩ ខែឧសភា ឆ្នាំ២០១២

## មាតិកា

◆សិល្បៈដើម្បីចងចាំ និងអប់រំ ..........................................១

**ផ្នែកឯកសារ**

◆ឆ្នាំ១៩៧៥សម្រេចមហាជ័យជម្នះអស្ចារ្យនៃ..................៤

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆សក្ខីកម្ម ឌុច ប្រឆាំងនឹងអតីតមេដឹកនាំខ្មែរក្រហម............១៦

◆ស្តូបតម្កល់អដ្ឋិធាតុវត្តព្រៃតាធឹកសង់ថ្មី....................៣២

◆ការឈឺចាប់នៅក្នុងរបបខ្មែរក្រហម.............................៣៤

◆ខ្មែរឥស្លាមចង់ឲ្យមេដឹកនាំខ្មែរក្រហមនិយាយការពិត........៣៦

◆"វិធីសាស្ត្រដែលធ្វើឲ្យគ្រួសារខ្ញុំរស់" ...........................៣៨

◆គ្មានទេពាក្យថា "អត់ឱន".........................................៤០

**ផ្នែកច្បាប់**

◆ការពារការសម្ងាត់របស់ដំណើរការស៊ើបអង្កេត.................៤២

**វេទិកាពិភាក្សាសាធារណៈ**

◆កេរដំណែលសោហ្មងរបស់អង្គជំនុំជម្រះនិងអង្គការ ............៥១

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆មកស្រុកកំណើតដើម្បីស្វែងរកការពិត.........................៥៤

◆រឿងបដិវត្តន៍ : របស់យុទ្ធមិត្តយើង..........................៥៦



ការសម្តែងរឿងអំពីរបបខ្មែរក្រហមនៅថ្ងៃ២០ ខែឧសភា ឆ្នាំ២០១២

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម/៩៩
ចុះថ្ងៃទី២ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ :** រី លក្ខិណា, ម៉ម សុវណ្ណ, និត្យ ធរន្តាពណ, គ្រីស្តា ណេលសាន់, ភីធើ ម៉ាហ្គាយ **អ្នកនិពន្ធនិងស្រាវជ្រាវ :** ទាវ សារៈមុនិន្ទ, សោម ប៊ុនថន, ស៊ិន សុធីតា **អ្នកបកប្រែ :** ទែន សុខស្រីនិត **និពន្ធនាយកទូទៅ :** ឆាំង យុ **ជំនួយការនិពន្ធនាយក :** ញាណ សុជាតិ **ក្រាហ្វិកកុំព្យូទ័រ :** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយ :** ឆេង វ៉េង Email: dccam@online.com.kh, Homepage: www.dccam.org

# សិល្បៈដើម្បីចងចាំ និងអប់រំ

ទិវា២០ ឧសភា ត្រូវបានរៀបចំនិងប្រារព្ធឡើងជារៀងរាល់ឆ្នាំដោយរាជរដ្ឋាភិបាលកម្ពុជា ។ តាំងពីដើមទសវត្សរ៍៨០រហូតដល់ឆ្នាំ២០០១ រដ្ឋាភិបាលកម្ពុជាបានហៅពិធីនេះថា "ទិវាចងកំហឹង" ដែលត្រូវបានប្រារព្ធឡើងដើម្បីចងកំហឹង និងថ្កោលទោសរបបខ្មែរក្រហមដែលបានបណ្តាលឲ្យប្រជាជនកម្ពុជាស្លាប់បាត់បង់ជីវិតប្រមាណជាពីរលាននាក់ចាប់តាំងពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។ ចាប់ពីឆ្នាំ២០០១មក រាជរដ្ឋាភិបាលកម្ពុជាបានប្តូរឈ្មោះទិវានេះទៅជា "ទិវានៃការចងចាំ" ក្នុងន័យដើម្បីកាត់បន្ថយការចងគំនុំ និងលើកកម្ពស់ការផ្សះផ្សាជាតិ បើទោះបីជារូបភាព និងខ្លឹមសារនៃការសម្តែងនៅក្នុងពិធីនេះនៅតែមានលក្ខណៈហិង្សា រន្ធត់ និងចងគំនុំនឹងរបបខ្មែរក្រហមខ្លះក៏ដោយ ។ រៀងរាល់ឆ្នាំ ក្នុងការប្រារព្ធ "ទិវានៃការចងចាំ" នេះ សិល្បៈមានតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឲ្យមានការចងចាំ ការអប់រំ ការព្យាបាលរបួសពីអតីតកាល និងការធ្វើដំណើរទៅមុខ ។

សេក សាវុធ បានប្រើប្រាស់សិល្បៈដើម្បីរំឭកនិងបង្រៀនពីរបបខ្មែរក្រហមដល់អ្នកដែលធ្លាប់ឆ្លងកាត់របបនេះផ្ទាល់ និងក្មេងជំនាន់ក្រោយចាប់តាំងពីរបបនេះបានដួលរំលំក្នុងឆ្នាំ១៩៧៩ ។ ជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ សេក សាវុធ ដែលមានអាយុ៥៤ឆ្នាំ បានចូលរួមការសម្តែងអំពីប្រវត្តិទុក្ខសោកក្នុងរបបខ្មែរក្រហមនៅជើងឯក ក្នុងគោលបំណងឲ្យសាធារណជនចងចាំ និងរៀនពីប្រវត្តិសាស្ត្រដែលបានកើតឡើងក្នុងប្រទេសកម្ពុជាពីឆ្នាំ១៩៧៥ដល់១៩៧៩តាមរយៈការនិយាយរឿង សូត្រកំណាព្យ អានសំណេររឿងរ៉ាវទុក្ខសោក និងសម្តែងល្ខោនអំពីជីវិតក្នុងរបបខ្មែរក្រហម ។



ការសម្តែងរឿងអំពីរបបខ្មែរក្រហមនៅថ្ងៃ២០ ខែឧសភា ឆ្នាំ២០១២ នៅវាលពិឃាតជើងឯក

ការសម្តែងសិល្បៈអំពីជីវិតក្នុងរបបខ្មែរក្រហមនេះធ្វើឡើងជារៀងរាល់ឆ្នាំ នៅថ្ងៃទី២០ ខែឧសភា ឬហៅថា "ទិវានៃការចងចាំ" នៅវាលពិឃាតជើងឯក ។ លោកសាស្ត្រាចារ្យបានមានប្រសាសន៍ថា "ការប្រារព្ធទិវានេះ គឺដើម្បីឲ្យអ្នកដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមចងចាំរបបនេះជារៀងរហូត និងដើម្បីឲ្យក្មេងជំនាន់ក្រោយដែលមិនទាន់ឆ្លងកាត់ដឹងពីប្រវត្តិរបស់ប្រទេសខ្លួន" ។

ប៉ុន្តែរាល់ពេលសម្តែងអំពីរបបនេះម្តងៗ សាវុធ តែងនឹកឃើញរឿងរ៉ាវពីអតីតកាលឡើងវិញដែលធ្វើឲ្យគាត់មានអារម្មណ៍ក្តុកក្តួល ឈឺចាប់ និងស្រក់ទឹកភ្នែក ។ សាវុធ បានអះអាងថា គាត់មិនចង់បំភ្លេចរបបនេះទេ ហើយបានពោលថា "ខ្ញុំបានឆ្លងកាត់ការឈឺចាប់ក្នុងរបបខ្មែរក្រហម ដូច្នេះពេលដែលខ្ញុំអានវិយោគកថា ខ្ញុំមិនអាចទប់ទឹកភ្នែកបានទេ" ។ សាវុធ ដែលបានបាត់បង់ឪពុកម្តាយ និងបងប្អូនបង្កើតរបស់គាត់ក្នុងរបបខ្មែរក្រហមបានរៀបរាប់ថា របបខ្មែរក្រហមបានធ្វើឲ្យគាត់ជួបប្រទះការអត់ឃ្លានខ្លាំងជាទីបំផុត ហើយចាប់តាំងពីពេលនោះមក សាវុធ តែងតែចងចាំថាគ្មានអ្វី "ធ្ងន់ធ្ងរ" ជាងជំងឺស្រេកឃ្លានទេ ។

នៅពេលរំឭកអំពីរបបខ្មែរក្រហម អ្វីដែល សាវុធ នឹកឃើញដំបូងគេគឺថា ខ្មែរក្រហមបានបំផ្លាញជីវិតរបស់គាត់ជាសិស្ស ដែលកាលនោះ គាត់កំពុងតែរីករាយនឹងជីវិតជាយុវវ័យ ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ សាវុធ និងសិស្សដទៃទៀតបាននាំគ្នាឈរអបអរសាទរ និងស្រែកហ៊ោរកញ្ជ្រៀវដើម្បីស្វាគមន៍យោធាខ្មែរក្រហមដែលទទួលជ័យជម្នះលើរបប លន់ នល់ ។ នៅថ្ងៃនោះ គាត់បានឡើងជិះរថយន្តហ្ស៊ីបជាមួយយោធាខ្មែរក្រហមនិងធ្វើដំណើរជុំវិញទីក្រុងភ្នំពេញដោយក្តីអបអរទៅនឹងជ័យជម្នះនេះ ។ មិនយូរប៉ុន្មាន យោធាខ្មែរក្រហមបានឲ្យ សាវុធ និងសិស្សដទៃទៀតចុះពីលើរថយន្តនោះ រួចឲ្យគាត់ចាកចេញពីទីក្រុងភ្នំពេញជាបន្ទាន់ ។ សាវុធ បានដើរឆ្លងស្ពានព្រះមុន្នីវង្សធ្វើដំណើរតាមផ្លូវជាតិលេខ១ រួចបន្តដំណើរទៅដល់ស្រុកសណ្តាន់ ខេត្តកំពង់ធំ ដែលទីនោះគាត់បានរស់នៅជាមួយអតីតគ្រូរបស់គាត់ គឺព្រឹទ្ធាចារ្យ ឆេង ផុន ។

ក្នុងឆ្នាំ១៩៧៩ សាវុធ បានត្រឡប់មកភ្នំពេញវិញ ។ ដោយចិត្តស្រឡាញ់សិល្បៈ គាត់បានចូលរៀននៅសាលាវិចិត្រសិល្បៈ និងបានរួមចំណែកលើកកម្ពស់វប្បធម៌ជាតិឡើងវិញបន្ទាប់ពីត្រូវបានបំផ្លិចបំផ្លាញដោយរបបខ្មែរក្រហម ។ ជាសិស្សនៅសាលាវិចិត្រសិល្បៈក្នុងទសវត្សរ៍៨០ សាវុធ បានចូលរួមសម្តែងជាល្ខោននិយាយនិងសូត្រកំណាព្យពីទុក្ខសោកក្នុងរបបខ្មែរក្រហមជាប្រចាំ ។

នៅពេលសួរថាតើការសម្តែងពីព្រឹត្តិការណ៍នៃរបបខ្មែរក្រហមធ្វើឲ្យគាត់ខឹងនឹងរបបនោះដែរឬទេ? សាវុធ បាននិយាយថាគាត់ធ្លាប់ខឹងនឹងខ្មែរក្រហមរួចទៅហើយ ហើយគាត់ក៏មិនដែលរសាយកំហឹងពីរបបនេះដែរ "ពេលនេះការខឹងនឹងរបបខ្មែរក្រហម វារសាយខ្លះហើយ ព្រោះរឿងវាកន្លងទៅជាងសាមសិបឆ្នាំមកហើយ តែខ្ញុំនឹងមិនភ្លេចរបបនោះទេ ខ្ញុំនៅតែស្តាយស្រណោះនឹងអ្វីៗដែលបានបាត់បង់ជានិច្ច" ។

សព្វថ្ងៃ សាវុធ បានបង្រៀនក្មេងជំនាន់ក្រោយដែលមិនបានឆ្លងកាត់របបខ្មែរក្រហមឲ្យសម្តែងរឿងរ៉ាវពីរបបនោះ ហើយសិស្សទាំងនោះបានសម្តែងនៅ



មន្ត្រីរដ្ឋាភិបាលដង្ហែកម្រងផ្កាទៅកាន់វាលពិឃាតជើងឯកដើម្បីគោរពវិញ្ញាណក្ខន្ធដល់អ្នកដែលបានស្លាប់ក្នុងរបបខ្មែរក្រហម

វាលពិឃាតជើងឯកជារៀងរាល់ឆ្នាំនៅថ្ងៃទី២០ ខែឧសភា ។ សម្រាប់ សារ៉ុធ ការបង្ហាត់សិស្សឲ្យសម្តែងពីសម័យមួយដែលសិស្សទាំងនោះមិនដែលបានជួបប្រទះគឺជាកិច្ចការដ៏លំបាកមួយ ប៉ុន្តែគាត់បានបង្រៀនសិស្សទាំងអស់ឲ្យចេះស្រមើស្រមៃឃើញរូបភាពពីរបបខ្មែរក្រហមផ្ទាល់ ។ សារ៉ុធ បាននិយាយថា មុនពេលបង្ហាត់សិស្សជំនាន់ក្រោយឲ្យសម្តែងពីរបបខ្មែរក្រហម គាត់បានបង្រៀនពីហេតុការណ៍សោកនាដកម្មពិតប្រាកដពីរបបនោះដើម្បីឲ្យសិស្សដឹងពីភាពឈឺចាប់ដូចជាការបង្រៀនសិស្សឲ្យចេះយំ និងចេះស្រមើស្រមៃពីមូលហេតុនៃការយំនោះ «យើងត្រូវឲ្យសិស្សនោះស្រមើស្រមៃឃើញរូបភាពនៃការឈឺចាប់ ។ យើងត្រូវដឹងថាយើងឲ្យសិស្សយំដោយសារហេតុផលអ្វី ដោយសារអត់បាយ ដោយសារគេវាយដំ ដោយសារមានគេធ្វើបាប ដោយសារការព្រាត់ប្រាសពីឪពុកម្តាយ ឬដោយសារការវាយដំធ្វើបាបពីសំណាក់កម្មាភិបាលខ្មែរក្រហម» ។

ដូចជាប្រជាជនកម្ពុជាភាគច្រើនដែរ សារ៉ុធ គាំទ្រឲ្យមានការប្រារព្ធពិធីនេះជារៀងរាល់ឆ្នាំដើម្បីឲ្យធ្វើមានការចងចាំនិងរៀនសូត្រពីអតីតកាល ។ ការប្រារព្ធពិធីនេះ រួមជាមួយការនិមន្តចូលរួមពីសំណាក់ព្រះសង្ឃក៏ជំរុញឲ្យមានការផ្សះផ្សាអារម្មណ៍ផ្លូវចិត្តដែរ តាមរយៈការប្រគេនចង្ហាន់ទៅព្រះសង្ឃ ដោយមានជំនឿថា ម្ហូបអាហារទាំងនោះនឹងបានទៅដល់ដៃសាច់ញាត្តិដែលបានស្លាប់បាត់បង់ជីវិតក្នុងរបបខ្មែរក្រហមដោយការអត់ឃ្លាន ។

ការសម្តែងសិល្បៈព្រមទាំងការរួមបញ្ចូលពិធីបែបពុទ្ធសាសនានៅក្នុង «ទិវានៃការចងចាំ» នេះបានជំរុញឲ្យមានការចងចាំ ផ្សះផ្សា និងព្យាបាលរបួសផ្លូវចិត្ត ។ សារ៉ុធ បានបញ្ជាក់ថា គាត់នឹងយកសិល្បៈសម្តែងពីរបបខ្មែរក្រហមដើម្បីរំឭក អប់រំ និងជំរុញឲ្យមានការផ្សះផ្សានៅក្នុងប្រទេសកម្ពុជា ។ បើទោះបីជាមិនទាន់មានការយល់ស្របគ្នាថាតើថ្ងៃ២០ឧសភា នៅតែមានលក្ខណៈជាថ្ងៃចងកំហឹង ឬផ្សះផ្សាក៏ដោយ ក្នុងកម្រិតបុគ្គល ថ្ងៃនេះបាននាំមកនូវការផ្សះផ្សាអារម្មណ៍ផ្លូវចិត្ត និងនាំឲ្យមានការចងចាំជានិច្ច ជាពិសេស សម្រាប់អ្នកបង្ហាត់ និងអ្នកសម្តែងសិល្បៈអំពីទិវានេះ ។ **ញាណ សុជាតិ**



ការសម្តែងរឿងអំពីរបបខ្មែរក្រហមនៅថ្ងៃ២០ ខែឧសភា ឆ្នាំ២០១២ នៅវាលពិឃាតជើងឯក

# ឆ្នាំ១៩៧៥ សម្រេចមហាជ័យជម្នះ មហាអស្ចារ្យនៃបដិវត្តន៍ប្រជាជាតិ-ប្រជាធិបតេយ្យ

**ដកស្រង់ចេញពីទង់បដិវត្ត លេខពិសេស ធ្នូ-មករា ១៩៧៥-៧៦**

## *ឆ្នាំ១៩៧០ - ១៩៧៥*

### *១) សភាពការណ៍ក្រោយរដ្ឋប្រហារថ្ងៃ១៨ ខែមីនា ឆ្នាំ១៩៧០*

ខែមីនា ឆ្នាំ១៩៧០ ចក្រពត្តិអាមេរិក និងពួកអាក្បត់ លន់ លន់ បានធ្វើរដ្ឋប្រហារ ។ ពេលវាធ្វើរដ្ឋប្រហារភ្លាម សភាពការណ៍នយោបាយប្រែប្រួលភ្លាម ទាំងក្នុងប្រទេស ទាំងក្រៅប្រទេស ។ ក្នុងប្រទេស បក្សយើងដណ្តើមបានកម្លាំងប្រជាជនច្រើនថែមទៀត រហូតដល់ពួកវណ្ណៈកាន់អំណាច ជាសក្តិភូមិ នាយទុន ដែលប្រឆាំងយើងពីកាលមុន ក៏យើងដណ្តើមបានពីព្រោះមុនរដ្ឋប្រហារ បក្សយើងមាននយោបាយរណសិរ្សមួយស្រេចទៅហើយ ។ ក្រោយរដ្ឋប្រហារ យើងក៏ពង្រីកនយោបាយរណសិរ្សនេះភ្លាម ។ ប្រជាជនភាគច្រើន ឥស្សរជនភាគច្រើនក្នុងប្រទេសមកចូលរួមក្នុងរណសិរ្ស ។ ចក្រពត្តិអាមេរិក និងពួកអា លន់ នល់ ត្រូវឯកោពីមតិប្រជាជននិងប្រជាជនទាំងមូល ។ គេឃើញច្បាស់ថា ពួកអា លន់ នល់ វាធ្វើរដ្ឋប្រហារចូលដៃជាមួយចក្រពត្តិអាមេរិកដែលប្រជាជនប្រឆាំងយូរមកហើយ ។ ពេលនេះ បក្សឈរលើមាគ៌ារណសិរ្សប្រមូលកម្លាំងប្រជាជាតិធំទូលាយប្រឆាំងចក្រពត្តិអាមេរិកនិងបរិវារ ។ រណសិរ្សនេះគឺបក្សដឹកនាំកម្លាំងចក្រពត្តិអាមេរិកនិងបរិវារ ។ រណសិរ្សនេះគឺបក្សមេដឹកនាំកម្លាំងប្រឆាំងជាមូលដ្ឋានជាកម្លាំងបង្អែកគឺសម្ព័ន្ធភាពកម្មករ-កសិករ ។ សាកលលោកឧបត្ថម្ភយើងហើយឃើញកម្លាំងយើងច្បាស់ ។

ក្នុងសភាពការណ៍ហ្នឹង បក្សបានដឹកនាំវាយសម្រុកភ្លាម ។ កម្លាំងប្រជាជននិងកងទ័ពបដិវត្តន៍ដែលបានហ៊ឹកហ៊ឺនក្នុងចលនាបដិវត្តន៍ នយោបាយ និងអាវុធ បានធ្វើកុប្បកម្មយកអំណាចតាមភូមិ-ឃុំនិងទូទាំងប្រទេស ។ ប្រជាជន-មហាជនបានងើបឡើងមហាបាតុកម្ម មហាកុប្បកម្មទូទាំងប្រទេស ។ ដូច្នោះ បដិវត្តន៍វាយសម្រុកទាំងនយោបាយទាំងយោធាធ្វើឲ្យចក្រពត្តិអាមេរិកទាល់ច្រក ហើយ លន់ នល់ ក៏ទាល់ច្រកដែរ ។ ប្រជាជនរាប់លានពីគ្រប់ទិសទី វាយសម្រុកបុកចូលមកភ្នំពេញបម្រុងចាប់ លន់ នល់ កម្ទេចចោល ។ ក្នុងរយៈពេលមួយខែប៉ុណ្ណោះ យើងរំដោះភូមិ-ឃុំនិងទូទាំងប្រទេសចំនួន៧០-៧៥ ភាគរយ ។ ចក្រពត្តិអាមេរិកឃើញសភាពការណ៍យ៉ាងនេះ វាក៏លើកកងទ័ពចូលមកវាយយើងដោយផ្ទាល់ វាចូលច្រើនម៉ឺនតាមព្រំប្រទល់ខាងកើតពីវៀតណាមខាងត្បូងចូលមកវាយយើង ។ កងទ័ពចក្រពត្តិអាមេរិកសម្បូរបែបជាងគេលើសាកលលោក មានទាំងរថក្រោះនិងយន្តហោះគ្រប់បែបយ៉ាង ។ ពួកអាធីវគីក៏ចូលមករាប់សែននាក់ក្នុងទឹកដីកម្ពុជាដើម្បីស្រោចស្រង់ពួកក្បត់ លន់ នល់ ។ ដូច្នោះកម្លាំងក្បត់នៅពេលនោះមាន លន់ នល់ មានអាមេរិក មានអាធីវគី ។ ការដែលអាមេរិកនិងពួកក្បត់នៅវៀតណាមខាងត្បូងមកចូលវាយកម្ពុជានេះហើយ ដែលយើងហៅថា “អាមេរិកតួបនីយកម្មសង្គ្រាមនៅកម្ពុជា” និង “វៀតណាមនីយកម្មសង្គ្រាមនៅកម្ពុជា” សភាពនេះខ្លាំងក្លា និងឃោរឃៅណាស់ ។ អាមេរិកវាចូលមកជាមួយអាធីវគីដើម្បីយកកម្លាំងវាវាយយើង ហើយកសាងរៀបចំកម្លាំង លន់ នល់ ដើម្បីអនុវត្តនយោបាយខ្មែររូបនីយកម្មសង្គ្រាមនៅកម្ពុជាតាមនយោបាយនិចសុន យកខ្មែរវាយខ្មែរដោយវាជាអ្នកចេញលុយនិងអាវុធ ។ ក្នុងពេលហ្នឹង បើប្រៀបធៀបកម្លាំងខ្មាំង វាខ្លាំងណាស់ព្រោះមានកម្លាំងអាមេរិកផង ធីវគីផង តែបក្សយើងឃើញថាបើវាយអាមេរិកជាប់ អាមេរិកក៏ត្រូវស្លាប់នៅកម្ពុជាហើយបើវានៅយូរ កាន់តែស្លាប់ច្រើនទៀត ដូច្នេះយើងវាយបានដោយសារម្យ៉ាងកងទ័ពយើងធ្លាប់វាយវា ហើយម្យ៉ាងទៀត ប្រជាជនយើងស្អប់អាធីវគីសម្បើមណាស់ សូម្បីតែទាហានក្បត់ លន់ នល់ ក៏ឈ្លោះជាមួយទាហានក្បត់ធីវគីដែរ ។ បក្សយើងបានបំផុសស្មារតីស្នេហាជាតិឲ្យខ្ពង់ខ្ពស់ដើម្បីវាយចក្រពត្តិអាមេរិកឈ្លានពានធីវគីឈ្លានពាន

និង លន់ នល់ ក្បត់ជាតិ ហើយអំពាវនាវប្រជាជនសាកលលោកជួយគស្ស៊ូប្រឆាំងចក្រពត្តិអាមេរិក និងបរិវាររបស់វា ។ យើងទទួលបានការឧបត្ថម្ភពីប្រជាជនអាមេរិកផង ដូច្នោះរបស់ដែលហៅថា «អាមេរិកុរូបនីយកម្មសង្គ្រាមនៅកម្ពុជា» និង «វៀតណាមូបនីយកម្មសង្គ្រាមនៅកម្ពុជា» ត្រូវបានបរាជ័យយ៉ាងអាម៉ាស់មុខ ។

ព្រមជាមួយនិងចលនាវាយសម្រុកនៅសមរភូមិមុខក្នុងឆ្នាំ ១៩៧០ នេះ បក្សក៏បានបើកចលនាមហាជននៅក្នុងតំបន់រំដោះ បង្កបង្កើនផល ដើម្បីឧបត្ថម្ភខ្លួនផង និងឧបត្ថម្ភដល់សង្គ្រាមបដិវត្តន៍ផង ។

ឆ្នាំ១៩៧១ បក្សបានបើកមហាសន្និបាតបក្សលើកទី១ ។ ខ្លឹមសារសរុបនៃមហាសន្និបាតបក្សគឺបន្តធ្វើសង្គ្រាមប្រជាជនរបស់បក្សប្រឆាំងសង្គ្រាមឈ្លានពានចក្រពត្តិអាមេរិកនិងបរិវារ ដើម្បីរំដោះកម្ពុជាឲ្យបានឯករាជ្យ សន្តិភាព អព្យាក្រឹត្យ ។ ទន្ទឹមនឹងនេះ បន្តអនុវត្តនូវប្រជាធិបតេយ្យ វាយរំលំសក្តិភូមិម្ចាស់ដី នាយទុនប្រតិកិរិយាដើម្បីរំដោះប្រជាជនទាំងមូលពិសេសកសិករ ។ ភារកិច្ចនេះ នៅក្នុងក្របខណ្ឌបដិវត្តន៍ បដិវត្តន៍ប្រជាជាតិ-ប្រជាធិបតេយ្យដដែល ។ បញ្ហាសំខាន់ត្រូវរៀបចំកម្លាំងគ្រប់ផ្នែកដើម្បីដំណើរការឲ្យបានខ្លាំងក្លា ។ ព្រមជាមួយគ្នានេះ មហាសន្និបាតបក្សឯកភាពគ្នាអំពីជ័យជម្នះយ៉ាងធំនៃមហាសន្និបាតបក្សលើកទីមួយ និងលើកទីពីរដែលបានកំណត់និងបានអនុវត្តយ៉ាងត្រឹមត្រូវនូវមាគ៌ាជាយុទ្ធសាស្រ្តនៃបដិវត្តន៍ប្រជាជាតិ-ប្រជាធិបតេយ្យ ។ ពន្លឺនៃមហាសន្និបាតបក្សលើកទីមួយ បានធ្វើឲ្យបរាជ័យជាមូលដ្ឋាននៃនយោបាយខ្មែររូបនីយកម្មសង្គ្រាមរបស់ចក្រពត្តិអាមេរិកក្នុងកិច្ចប្រតិបត្តិការចេនឡា ។

ក្នុងឆ្នាំ១៩៧២ ព្រមគ្នាជាមួយនិងការវាយសម្រុកនៅសមរភូមិមុខនៅសមរភូមិក្រោយ បក្សបានចាប់ផ្តើមបំផុសចលនាតស៊ូកម្ចាត់ការទាក់ទងផលិតកម្មចាស់ ហើយកសាងការទាក់ទងផលិតកម្មថ្មីដើម្បីជំរុញចលនាបង្កបង្កើនផលឲ្យខ្លាំងក្លាថែមទៀតសម្រាប់ឧបត្ថម្ភខ្លួននិងឧបត្ថម្ភសង្គ្រាមប្រជាជនប្រយុទ្ធជាមួយវណ្ណៈនាយទុនដើម្បីបក្សក្តាប់ពាណិជ្ជកម្មនៅក្នុងដៃ ។ ក្នុងឆ្នាំ១៩៧២នេះ ចលនាវាយខ្លាំងនៅសមរភូមិមុខក៏ខ្លាំងក្លាចលនាតស៊ូវណ្ណៈនៅក្នុងតំបន់រំដោះទូទាំងប្រទេសក៏ឡើងខ្ពស់មួយកម្រិតថែមទៀត ។ ក្នុងចលនាក្តៅគគុកទាំងសមរភូមិមុខនិងសមរភូមិក្រោយនេះ កម្លាំងបដិបក្សគ្រប់ផ្នែកក៏បានពង្រីងនឹងពង្រីកថែមទៀត ជាពិសេសកម្លាំងសម្ព័ន្ធភាពកម្មករ-កសិករ ។

ឆ្នាំ១៩៧៣ បក្សពិនិត្យឃើញច្បាស់ថា ខ្មាំងវាខ្សោយក៏លើកគោលការណ៍វាយសម្រុកខ្មាំងជាយុទ្ធសាស្រ្តពិតមែនតែយើងទើបនិងមានកម្លាំងត្រឹមវរសេនាធំ យើងវាយរហូតទាំងប្រាំង ទាំងវស្សា ។ ទិសសំខាន់ គឺវាយខ្មែររូបនីយកម្មសង្គ្រាម ។ កាលណាកងទ័ពអាក្សត់ត្រូវខ្ទេចខ្ទីចក្រពត្តិអាមេរិកគ្មានកម្លាំងមូលដ្ឋានជាជំនួយនៅក្នុងប្រទេសទេព្រោះអាមេរិកឈ្លានពានប្រទេសមួយៗវាសង្ឃឹមលើកម្លាំងពួកអាក្សត់ ដូច្នេះយើងវាយកម្លាំងពួកអាក្សត់ឲ្យខ្ទេចខ្ទី វាយវាទាំងយោធា ទាំងនយោបាយ ទាំងសេដ្ឋកិច្ចឲ្យវាហត់ហេវមែនទែន ។ ពួកអាក្សត់អស់មនុស្សចាប់ធ្វើទាហានពីព្រោះប្រជាជននៅខាងយើងអស់ ។ កសិករនៅនឹងយើងទាំងអស់ ។ ប្រជាជនក្រីក្រភាគច្រើននៅខាងយើង ។ ឯពួកស្រទាប់កណ្តាលក៏នៅខាងយើង ។ ខ្មាំងអស់កម្លាំងមនុស្សពង្រីកទាហានវា ។ ដោយយើងមានមាគ៌ាពង្រីកប្រជាជនពីខ្មាំង ដូច្នោះមួយឆ្នាំកាន់តែអស់មួយឆ្នាំកាន់តែអស់ ។ អស់ប្រជាជនគឺអស់សេដ្ឋកិច្ចអស់កម្លាំងយោធា អស់កម្លាំងនយោបាយ ដូច្នោះ ពួកក្បត់ត្រូវឯកោដល់កម្រិតយ៉ាងខ្ពស់បំផុត ។ ព្រមជាមួយគ្នានេះ ក្នុងឆ្នាំ១៩៧៣ដដែលចលនាសហករណ៍រូបនីយកម្មនៅជនបទក៏បានពង្រីកយ៉ាងខ្លាំងក្លាធ្វើឲ្យកម្លាំងសមរភូមិក្រោយកាន់តែបានពង្រឹងនិងពង្រីកជាមូលដ្ឋានរឹងមាំសម្រាប់សមរភូមិមុខ ។ ចលនាដឹកប្រឡាយដាំដំណាំយុទ្ធសាស្រ្តផុសផុលកាន់តែខ្លាំងក្លាបម្រើសង្គ្រាមប្រជាជននិងជំរុញសង្គ្រាមប្រជាជនទៅកាន់ជ័យជម្នះជាបន្តបន្ទាប់ ។ ម្យ៉ាងទៀត ឆ្នាំ១៩៧៣ ក៏ជាឆ្នាំដែលចក្រពត្តិអាមេរិកកាំងត្រូវបរាជ័យយ៉ាងអាម៉ាស់នូវសង្គ្រាមអាកាសរបស់វាមកលើប្រទេសកម្ពុជាយើង ។ ដូច្នោះ ចក្រពត្តិត្រឡប់មកអនុវត្តនយោបាយខ្មែររូបនីយកម្មសង្គ្រាមវិញទៀត ដោយផ្គត់ផ្គង់សម្ភារសឹក សេដ្ឋកិច្ចហិរញ្ញវត្ថុគ្រប់បែបយ៉ាងឲ្យពួកអាក្សត់ លន់ នល់ នៅភ្នំពេញតែចក្រពត្តិអាមេរិកមិនអាចស្តារកម្លាំងពួកអាក្សត់ដែលកាន់តែខ្សោះអស់ឈាមបានឡើយ ។

នៅពាក់កណ្តាលឆ្នាំ១៩៧៤ បក្សបានកំណត់បើកការវាយ

សម្រុកជាយុទ្ធសាស្ត្រដើម្បីផ្តាច់ព្រ័ត្ររំដោះទូទាំងប្រទេស ។ បក្សបានកំណត់វាយដូចតទៅនេះ ៖

◆ វាយមេគង្គក្រោមជាគន្លឹះ ដើម្បីផ្តាច់ស្បៀង ផ្តាច់ផ្លូវគមនាគមន៍របស់ខ្មាំង ។

◆ វាយជុំវិញភ្នំពេញដើម្បីវាយផ្តាច់ភ្នំពេញ ។

◆ បើកវាយទីរួមខេត្តខ្លះដែលខ្មាំងកាន់កាប់បណ្តោះអាសន្នដើម្បីរួមផ្សំ ។

◆ វាយទាំងអស់ព្រមជាមួយគ្នាកុំឲ្យខ្មាំងដកកម្លាំងទៅជួយគ្នាបាន ។

នាចុងឆ្នាំ១៩៧៤ បក្សបានលម្អិតនិងលំអថែមនូវសេចក្តីសម្រេចចិត្តដែលកំណត់បើកការវាយសម្រុកជាយុទ្ធសាស្ត្រពីពាក់កណ្តាលឆ្នាំ១៩៧៤ដោយបញ្ជាក់ច្បាស់ថាត្រូវតែប្តេជ្ញាចិត្តបញ្ចប់សង្គ្រាមឈ្លានពានរបស់ចក្រពត្តិអាមេរិកនិងបញ្ចប់វាសនាពួកអាក្បត់នៅភ្នំពេញក្នុងរដូវប្រាំង១៩៧៥ ។ ទូទាំងប្រទេសត្រូវបើកឆាកវាយសម្រុកឲ្យព្រមៗគ្នាឲ្យខ្លាំងក្លាជាប់ជានិច្ច និងវាយឲ្យចំទិសតាំងពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៥ ។

វេលាម៉ោងសូន្យថ្ងៃទី១ មករា ឆ្នាំ១៩៧៥ ទូទាំងប្រទេសផ្ទុះអាវុធបើកឆាកវាយសម្រុកតាមផែនការកំណត់របស់បក្ស ។ ចូលខែកុម្ភៈ ឆ្នាំ១៩៧៥ ទិដ្ឋភាពរួមរបស់ខ្មាំងគឺខ្មាំងកាន់តែបាក់ខ្លាំងឡើងៗ ។ វាស្ថិតក្នុងសភាពស្ហឈាមទូទាំងប្រទេស ។ ខ្មាំងខ្សោយខ្លាំងមែនទែន ។ នៅមេគង្គ វាត្រូវខ្ទេចខ្ទីជាមូលដ្ឋានទាំងកម្លាំងរស់ទាំងទីតាំង ទាំងសម្ភារ ។ សមរភូមិជុំវិញភ្នំពេញខ្មាំងស្ហឈាមមួយកម្រិតធំថែមទៀតព្រោះអស់កម្លាំងរស់អស់ទីតាំងមួយកម្រិតធំទៀតដើម្បីការពារភ្នំពេញ ។ មធ្យោបាយសឹកក៏ត្រូវអន្តរាយច្រើនទាំងយន្តហោះ រថក្រោះ កាំភ្លើងធំ ។ ចំណែកកម្លាំងដែលវាយកមកពីខេត្តក៏ប៉ះប៉ូវមិនបាន គឺគ្រាន់តែទប់ទល់ៗជាបណ្តោះអាសន្ន តែកម្លាំងនេះក៏ត្រូវខ្ទេចខ្ទីជាបណ្តើរទៀត ។

នៅសមរភូមិទីរួមខេត្តនានា ខ្មាំងក៏ត្រូវបាក់ទាំងជួរៗ គ្មានកម្លាំងជំនួយ ហើយថែមទាំងអត់បាយទៀត ។

ឯខាងនយោបាយ បនក្បត់ និងបក្សពួកវាចោទតែពីរឿងស្លាប់ ។ ចក្រពត្តិអាមេរិកសារភាពថា វាអស់សង្ឃឹមពេញទីចលនាតស៊ូរបស់ប្រជាជននៅទីក្រុងភ្នំពេញនៅបាត់ដំបងកាន់តែខ្លាំងក្លា ។ ភ្នាក់ងារទូត និងអង្គការបរទេសផ្សេងៗនិងអណិកជនបរទេសនាំគ្នារត់ចេញពីភ្នំពេញអត់មានសង្ឃឹមលើពួកអាក្បត់ទេ ។

ឯខាងសេដ្ឋកិច្ចវិញក្នុងខែកុម្ភៈនេះលុយក៏អស់រលីងជំនួយអាមេរិកថែមមកទៀតក៏មិនគ្រប់ ។ រកតែលុយបើកប្រាក់ខែក៏គ្មានអង្ករក៏អស់រលីង ។ បញ្ហាដឹកពីក្រោមកក៏អត់ទៀត ។ ចូលខែមិនា ឆ្នាំ១៩៧៥ ខ្មាំងបាត់ម្ចាស់ការ ស្ទើរតែអស់រលីង ទាំងយោធា នយោបាយសេដ្ឋកិច្ច ។

ថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៥ យើងរំដោះអ្នកលឿង ។ អាក្បត់ លន់ នល់ រត់ចោលស្រុក ។ កងទ័ពបដិវត្តន៍ស្ថិតនៅក្នុងឋានៈម្ចាស់ការទាំងស្រុងបន្តការវាយសម្រុកយ៉ាងខ្លាំងក្លាចូលរំដោះភ្នំពេញ ។

ថ្ងៃទី១២ មេសា ឆ្នាំ១៩៧៥ ទូតចក្រពត្តិអាមេរិក និងបុគ្គលិកវារត់ផាស់ក្រញ៉ាំឡើងឧទ្ធម្ភាគចក្រយ៉ាងអាម៉ាស់មុខ ។

ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ យើងរំដោះភ្នំពេញ រំដោះ



យោធាខ្មែរក្រហមចូលទីក្រុងភ្នំពេញ នៅឆ្នាំ១៩៧៥

ទូទាំងប្រទេសបានទាំងស្រុង ។

បដិវត្តន៍ប្រជាជាតិ-ប្រជាធិបតេយ្យបានបញ្ចប់ដោយមហាជោគជ័យ មហាអស្ចារ្យ ក្រោមពន្លឺដ៏ត្រចេះត្រចង់នៃមាគ៌ាជាយុទ្ធសាស្ត្រនៃបដិវត្តន៍ប្រជាជាតិ-ប្រជាធិបតេយ្យនៃមហាសន្និបាតបក្សលើកទីមួយនិងមហាសន្និបាតបក្សលើកទីពីរលើកទីបីជាបន្តបន្ទាប់ ។

មេរៀនធំៗមួយចំនួនក្នុងរយៈកាលឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ មានដូចតទៅៈ

១) អំពីការកសាងកម្លាំងបក្សដឹកនាំសង្គ្រាមប្រជាជនរំដោះជាតិ រំដោះប្រជាជនបញ្ហានេះមានសារសំខាន់ជាងគេបំផុត ។ បើបក្សដឹកនាំត្រឹមត្រូវតាមមាគ៌ាគឺពិតជាបានជ័យជម្នះ ។ បើដឹកនាំខុស មាគ៌ាពិតជាបរាជ័យ ។

## ការរៀបចំកម្លាំងបក្សខាងនយោបាយ

តាមទិដ្ឋភាព ជាពិសោធន៍ផ្សេងៗមួយចំនួនក្នុងការកសាងដឹកនាំសង្គ្រាមបដិវត្តន៍ពីឆ្នាំ១៩៧០-១៩៧៥មានទិដ្ឋភាពប្រយុទ្ធខាងទស្សនៈនយោបាយ និងមាគ៌ាជាបន្តបន្ទាប់រវាងបក្សយើងនិងពលានុភាពសត្រូវានុម័តនៅលើសាកលលោកប្រទង់ប្រទាញគ្នាតឹងតែងស៊ុតស្វាញជ្រាលជ្រៅណាស់ ។ ទិដ្ឋភាពមួយចំនួនគឺមាគ៌ានយោបាយបក្សយើងដោយឈរលើពិសោធន៍ជាបន្តបន្ទាប់មកយើងឈរលើគោលជំហរឯករាជ្យ ម្ចាស់ការខ្លួនឧបត្ថម្ភខ្លួនជាសំខាន់ ។ ព្រមជាមួយគ្នានេះ ក៏ប្រមូលកម្លាំងសកលលោកដើម្បីឧបត្ថម្ភខ្លួនលើគ្រប់ផ្នែកទាំងអស់ ។ ឈរលើគោលជំហរនេះយើងរៀបចំបក្ស កងទ័ព រដ្ឋអំណាច ប្រជាជន សេដ្ឋកិច្ច មូលដ្ឋានបង្អែក វប្បធម៌ សង្គមកិច្ច ការងារបរទេស ។ល ។ តែគោលជំហរនេះត្រូវកម្លាំងខាងក្រៅតស៊ូសង្កត់ជាច្រើនដោយមិនសូវយល់គោលជំហរនេះ ខ្លះប្រឆាំងទៀត ព្រោះទស្សនៈខុសគ្នា ។ គេយល់ថា យើងតូច ពុំអាចឯករាជ្យម្ចាស់ការ ខ្លួនឧបត្ថម្ភខ្លួនបានទេត្រូវពឹងផ្អែកលើសកលលោក ។ បញ្ហានេះ មានការប្រយុទ្ធជាទស្សនៈគោលជំហររហូតដល់ចាត់តាំង ។ យើងសុខចិត្តសាមគ្គីជាមួយសាកលលោកតែដាច់ខាតយើងត្រូវឯករាជ្យ ម្ចាស់ការខ្លួនឧបត្ថម្ភខ្លួន ខ្លួនក្តាប់វាសនាប្រទេសជាតិខ្លួន ដោយខ្លួនឯងទើបសាមគ្គីជាមួយសាកលលោកបានល្អ ។ ពិសោធន៍របស់យើងគឺទោះបីជាយើងតូច ប្រជាជនយើងតិច តែបើមានមាគ៌ាត្រឹមត្រូវហើយឯកភាពជាធ្លុងមួយនៅក្នុងបក្ស ក្នុងប្រជាជន និងក្នុងកងទ័ពនោះគឺពិតជាឈ្នះដាច់ខាត ។ នៅក្នុងបក្ស ក៏មានកម្លាំងប្រឆាំងមួយចំនួនតិចដែលទទួលឥទ្ធិពលពីបរទេស ។ តែមជ្ឈិមបក្សក្តាប់បញ្ហានេះបាន ហើយផ្សព្វផ្សាយទូទាំងប្រទេសឯកោពួកប្រឆាំងនេះដល់កម្រិតខ្ពស់រហូតដល់ពួកវាចេញមុខប្រឆាំងចំហបកអាក្រាតមុខមាត់ក្បត់របស់វា ។ ក្រៅពីនេះ មានសភាពភាពខ្លះទៀតដែរតែមួយចំនួន តិចច្រើនអ្នកមិនទាន់ជាប់ចលនា មិនយល់ចលនាមិនមានពិសោធន៍ដោយខ្លួនឯង ហើយបុគ្គលនិយមស្លូនតួនិយមខ្ពស់ក៏មានអាប្បកិរិយាមិនសមរម្យចំពោះមាគ៌ារបស់បក្សនេះ ។

តើពិសោធន៍អ្វីដែលនាំឲ្យយើងឯករាជ្យ ម្ចាស់ការខ្លួនឧបត្ថម្ភខ្លួន? គឺពិសោធន៍ជាក់ស្តែង នៃចលនាមហាជនយើងនិងពិសោធន៍ជាក់ស្តែងក្នុងសកលលោក ដូចជាពិសោធន៍កាលវាយបារាំងពិសោធន៍កិច្ចព្រមព្រៀងហ្សឺណែវឆ្នាំ១៩៥៤ ពិសោធន៍កិច្ចព្រមព្រៀងប៉ារីសស្តីអំពីបញ្ហាវៀតណាមឆ្នាំ១៩៧៣ ។ល ។ ទាល់តែខ្លួនឯងធ្វើបដិវត្តន៍ខ្លួនឯង ទើបឯករាជ្យ-ម្ចាស់ការខ្លួនឧបត្ថម្ភខ្លួនរឹងមាំ ។

មានចលនាហើយដកពិសោធន៍ពីចលនារៀនពីចលនាសុភាពរាបសាដាក់ខ្លួនក្រោមចលនានេះជាបញ្ហាគន្លឹះមួយដើម្បីពង្រឹងទស្សនៈគោលជំហរមាគ៌ារបស់បក្សយើង ។ ដូច្នោះត្រូវសុភាពរាបសារៀនសូត្រពីចលនាមហាជន ។ ត្រូវរៀនសូត្រចលនាដើម្បីយល់មាគ៌ានិងតំរែតម្រង់មាគ៌ា ។ ដូច្នោះ កុំដាច់ពីមូលដ្ឋានកុំដាច់ពីចលនាកុំដាច់ពីប្រជាជននៅមូលដ្ឋានភូមិ-ឃុំកុំដាច់ពីសហករណ៍ ។

## ការរៀបចំកម្លាំងបក្ស ខាងសតិអារម្មណ៍

មានមាគ៌ាហើយ ត្រូវមានសតិអារម្មណ៍ប្រយុទ្ធដាច់ខាតមិនស៊ីស្នាស មិនរួមរស់ មិនសម្រុះសម្រួលជាមួយសតិអារម្មណ៍ខុសឆ្គង ។

ពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ បក្សយើងប្រយុទ្ធកសាងសតិអារម្មណ៍យ៉ាងម៉េច? ការប្រយុទ្ធរវាងសតិអារម្មណ៍បដិវត្តន៍និងមិនបដិវត្តន៍ រវាងសតិអារម្មណ៍តស៊ូដាច់ខាតនិងសតិអារម្មណ៍សម្រុះសម្រួលបានប្រយុទ្ធជាប់រហូតហើយមិនមែនជាការងាយ

ស្រួលទេ ។ វាមានសភាពតឹងតែងស្មុគស្មាញលំបាកជាងនយោបាយទៅទៀត ។ យើងបានដកពិសោធន៍ពីឆ្នាំ១៩៧០មក ដូចជាសតិអារម្មណ៍ភ្លើតភ្លើន កម្មសិទ្ធិបុគ្គល សួនតួ ខាងសម្ភារ និងអំណាចសតិអារម្មណ៍មិនអធននៅប្រឡូកប្រឡំច្រើននៅឡើយ ។ ទន្ទឹមនឹងនេះ គោលជំហរវណ្ណៈអធន នៅមិនទាន់បានពង្រឹងពង្រីកនៅឡើយទេ ។ សតិអារម្មណ៍នេះ ពាក់ព័ន្ធដល់ភារកិច្ចធ្វើសង្គ្រាមរំដោះជាតិ រំដោះប្រជាជន ។ ដូច្នោះ បក្សប្រយុទ្ធកម្ចាត់នូវសតិអារម្មណ៍ខុសឆ្គងនិងកសាងសតិអារម្មណ៍នៃវណ្ណៈអធនជាប់ជានិច្ច ។

សន្និបាតមជ្ឈិមបក្ស ខែឧសភា ឆ្នាំ១៩៧២ បក្សយើងបើកឆាកប្រកាសអាសន្ននៃគោលជំហរមិនអធនដែលមាននៅក្នុងបក្ស ។ ខ្លឹមសារជាស្នូលធ្វើជាឯកសារអប់រំ គឺបញ្ហាវណ្ណៈនិងតស៊ូវណ្ណៈ បញ្ហាផ្តាច់ការវណ្ណៈអធនរបស់បក្ស សម្ភារនិយមបដិច្ចសមុប្បាទ និងសម្ភារនិយមប្រវត្តិសាស្ត្រ ។ ព្រមជាមួយគ្នានេះ បក្សបានបើកឆាករៀបចំសហករណ៍ជាជំហានដំបូង ដូច្នេះមានចលនាផុសផុលទូទាំងប្រទេស ។ ដល់កណ្តាលឆ្នាំ១៩៧៣ មជ្ឈិមបក្សបើកសន្និបាតទៀត ពិនិត្យអំពីការតស៊ូវណ្ណៈនៅក្នុងបក្សនិងក្នុងមហាជន ។ ជ័យជម្នះមួយជំហាននេះធំដែរ តែក៏នៅមានសតិអារម្មណ៍ អនុធន សក្តិភូមិ នាយទុននិងសតិអារម្មណ៍នៃវណ្ណៈមិនបដិវត្តន៍ឯទៀត តាមធាតុភាពផ្សេងៗនៅក្នុងបក្ស រដ្ឋអំណាច កងទ័ពឈ្លប ។ល ។ យើងបន្តការប្រយុទ្ធតទៅទៀត ដោយរៀនសូត្រចលនា ។ ការខ្វះខាតក៏នៅមានឆ្អេងជាស្តាំ ។ ការកសាងសតិអារម្មណ៍នៃវណ្ណៈអធនមិនទាន់ត្រឹមត្រូវ ។

ដោយការតស៊ូកសាងយ៉ាងនេះ ទើបបំពេញភារកិច្ចប្រជាជាតិ-ប្រជាធិបតេយ្យពេលនោះបាន ។ ដើមឆ្នាំ១៩៧៤ មានបញ្ហាកើតជាច្រើនដោយខ្មាំងវាធ្វើសន្តិសម្ព័ន្ធធ្វើឲ្យខូចខាតខ្លះដល់កងទ័ព រដ្ឋអំណាច កម្មាភិបាលមួយចំនួន ប៉ះពាល់ដល់ចលនាមួយកម្រិតដែរធ្វើឲ្យខូចខាតសមរភូមិមុខមួយចំនួន ។ មូលហេតុមកពីគោលជំហរអធននៅស្រពិចស្រពិលយ្លេងយ្លោង ។ នៅពាក់កណ្តាលឆ្នាំ១៩៧៤ បក្សបានប្រើវិធានការចាត់តាំងគឺផ្អាកពង្រីកបក្សនិងអង្គការសម្ងាត់សិន ។ ពិសោធន៍នោះយើងបានខិតខំកសាងនៅឆ្នាំ១៩៧២-១៩៧៣ខ្មាំងដែរតែដល់ខ្មាំងវាយមកវិញខាងគោលជំហរសីលធម៌បដិវត្តន៍នាំឲ្យយើងខូចខាតខ្លះដែរ ។ យើងរៀបចំសតិអារម្មណ៍ដើម្បីធានាអះអាងដល់ការដឹកនាំនៅសមរភូមិមុខនិងសមរភូមិក្រោយត្រៀមវាយផ្តាច់ព្រ័ត្រនៅរដូវប្រាំងឆ្នាំ១៩៧៥ ។

ពិសោធន៍អំពីការងារសតិអារម្មណ៍ឃើញថាៈ

១) សតិអារម្មណ៍វាប្រែប្រួលយើងត្រូវធ្វើការងារសតិអារម្មណ៍ជាប់ ។ កន្លងមក យើងធ្វើបានមួយកម្រិតតែវាថយចេញទៅវិញដូច្នេះត្រូវជាប់ជានិច្ចកុំអន្តោម័ត ។

២) ខ្លឹមសារសតិអារម្មណ៍ ដែលបក្សសម្រុកកសាងមានច្រើនតែទាំងអស់នេះសរុបទៅគឺសតិអារម្មណ៍នៃវណ្ណៈអធនគោលជំហរនៃវណ្ណៈអធន ។

◆ អធនគ្មានអ្វីទាំងអស់ ទាំងសម្ភារ អំណាចកម្មសិទ្ធិខាងបុគ្គលកម្មសិទ្ធិទស្សនៈ ។

◆ មានការចាត់តាំងខ្ពស់បំផុត គឺគោរពវិន័យអង្គការខ្ពស់ ។

◆ ផលិតកម្មចម្រើនជឿនលឿនច្នៃប្រឌិត ។

ព្រមជាមួយគ្នានេះ ឯកសារសម្ភារនិយមបដិច្ចសមុប្បាទនិងសម្ភារនិយម ប្រវត្តិសាស្ត្រ ក៏ជួយពង្រឹងនូវគោលជំហរវណ្ណៈអធនច្រើនដែរ ។

៣) ផ្អែកលើចលនាតស៊ូបដិវត្តន៍របស់មហាជនទាំងក្នុងបក្ស ។

កងទ័ពប្រជាជនដែលគេធ្វើចលនាបដិវត្តន៍គ្រប់ទីកន្លែងមានសតិអារម្មណ៍ខុស-ត្រូវយ៉ាងម៉េចយើងយកចលនាទាំងនោះមករៀនសូត្របំពាក់បំប៉ននៅក្នុងបក្សទាំងមូលការកសាងកម្លាំងបក្សខាងចាត់តាំងមានមាគ៌ាត្រឹមត្រូវមានសតិអារម្មណ៍នៃវណ្ណៈអធនល្អ ហើយត្រូវរៀបចំការចាត់តាំងឲ្យត្រឹមត្រូវរៀបរយទាំងអស់ទាំងបក្ស កងទ័ព ប្រជាជន រដ្ឋអំណាច មន្ទីរផ្សេងៗ ។ល ។

មាគ៌ាចាត់តាំងរបស់បក្សផ្អែកលើមាគ៌ាវណ្ណៈជាមូលដ្ឋានទាល់តែផ្អែកលើមាគ៌ារបស់បក្សទើបអនុវត្តន៍មាគ៌ានយោបាយរបស់បក្សបាន ។

**ក្នុងន័យអនុវត្តមានពីរយ៉ាង ៈ**

ម្យ៉ាងគឺអ្នកដែលចូលមកក្នុងជួរហើយ ត្រូវបំពាក់បំប៉នគោលជំហរវណ្ណៈអធនឲ្យគេ ដើម្បីគេបម្រើបក្សឲ្យបានត្រឹមត្រូវ ។ ម្យ៉ាងទៀតក្នុងការជ្រើសរើសថ្មីត្រូវផ្អែកលើវណ្ណៈ មូលដ្ឋានដោយ



កងចល័តកំពុងធ្វើការរបបខ្មែរក្រហម



កងចល័តកំពុងធ្វើការរបបខ្មែរក្រហម

មាគ៌ាចាត់តាំងរបស់បក្សយ៉ាងនេះយើងទប់ទល់សមាសភាពទិកាសនិយមបានទប់ទល់សកម្មភាពខ្មាំងស៊ីរូងផ្ទៃក្នុងបានជាអតិបរមា ។

មាគ៌ាចាត់តាំងតាមលាក់ការណ៍ផ្សេងៗរបស់បក្សគឺ៖

◆ ចេញពីចលនាបដិវត្តន៍សាកល្បងច្រើនលើកច្រើនសាក្នុងចលនាបដិវត្តន៍ៈ

◆ វណ្ណៈភាពល្អ

◆ សីលធម៌បដិវត្តន៍ល្អ ទាំងការរស់នៅ ទាំងនយោបាយ

◆ សភាពការណ៍ចាត់តាំងរបស់យើងដល់ថ្ងៃនេះមានទិដ្ឋភាពពីរ ។

ម្យ៉ាងមានការរីកចម្រើននាំឲ្យធំធាត់ តែម្យ៉ាងទៀត ក៏នៅមិនទាន់បរិសុទ្ធទាំងក្នុងបក្ស កងទ័ព អង្គការមហាជន តាមក្រសួងមន្ទីរផ្សេងៗ ។ល ។ នេះជាទិដ្ឋភាពខ្វះខាតដើម្បីបន្តការរៀបចំចាត់តាំងតទៅទៀតដើម្បីទប់ទល់សកម្មភាពខ្មាំងជាចក្រពត្តិជាសំណល់នៃវណ្ណៈសក្តិភូមិ នាយទុន ពួកបំផ្លាញបដិវត្តន៍ផ្សេងទៀត ។

ពិសោធន៍មួយចំនួនបានបង្ហាញឲ្យយើងឃើញថា៖

១) ដើម្បីពង្រឹងការចាត់តាំងឲ្យល្អស្អាតស្អំ

ត្រូវផ្អែកលើចលនាមហាជន ។ កុំជ្រើសរើសសម្រិតសម្រាំងពង្រឹងពង្រីកដោយក្រុប ខណ្ឌចង្អៀតឬថ្នាក់ណាមួយ ។ ត្រូវយកចលនាមហាជនជាបន្តបន្ទាប់វិនិច្ឆ័យ ។

២) ការពង្រឹងនិងពង្រីកអង្គការចាត់តាំងរបស់បក្សឬក្នុងជួរបដិវត្តន៍ទាំងអស់ត្រូវធ្វើឡើងដោយអនុវត្តមាគ៌ាចាត់តាំងរបស់បក្សជាបន្តបន្ទាប់តាមមាគ៌ាចាត់តាំងវណ្ណៈនិងលាក់ការណ៍ចាត់តាំងរបស់បក្សកុំធ្វើតែមួយដងមួយកាល ហើយឈប់ទៅវិញ ។

៣) សមាសភាពទីទៃ ជាទិកាសនិយមជាពួកចៃដន្យ

ពួកមិនជាប់នឹងចលនាប្រវត្តិរូបមិនច្បាស់លាស់ជាខ្សែសន្ទាក់ត្រូវប្រុងប្រយ័ត្នជាអតិបរមាហើយឈរលើការប្រុងប្រយ័ត្ននេះ យើងសាកល្បងជាបណ្តើរៗកុំប្រគល់ការងារអ្វីធំៗឲ្យពិនិត្យតាមដានជាបន្តបន្ទាប់ ហើយក្នុងរយៈពេលយូរ ។ តាមពិសោធន៍សមាសភាពនេះ បម្រើចលនាមិនបាន ហើយគ្រោះថ្នាក់ដល់ចលនាបដិវត្តន៍ទៀត ។

៤- លើកម្ពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ឲ្យខ្ពស់បំផុត

ខាងចាត់តាំងព្រោះខ្មាំងគ្រប់ប្រភេទទាំងក្នុងទាំងក្រៅវាមានផែនការបំផ្លិចបំផ្លាញ យុទ្ធសាស្ត្រាប់ជំនាន់ៗ

ភារកិច្ចការពារប្រទេស និងកសាងប្រទេសនៅធ្ងន់ធ្ងរណាស់ត្រូវបន្តការកសាងបក្សខាងគោលនយោបាយសតិអារម្មណ៍ឲ្យខ្លាំងក្លាជានិច្ចក្នុងរយៈកាលថ្មីនេះ ។

## ២) ការកសាងកម្លាំងប្រជាជននិងកសាងកម្លាំងវណ្ណសិរ្សប្រជាជាតិប្រជាធិបតេយ្យដើម្បីធ្វើជាកម្លាំងអនុវត្តន៍កិច្ចបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យតាមសង្គ្រាមរំដោះជាតិរំដោះប្រជាជន

ប្រជាជនបានចូលប្រឡូកក្នុងសង្គ្រាមរំដោះជាតិ តែជាដំបូងនៅមិនទាន់ខ្លាំងក្លានៅឡើយដែរ ។

◆ ខាងនយោបាយ នៅយល់ត្រឹមថារួមគ្នាវាយចក្រពត្តិអាមេរិក និងពួកក្បត់ លន់ ណល់ ទស្សនៈគោលជំហរគេ នៅមិនទាន់បដិវត្តន៍ឲ្យជ្រៅជ្រះ ។

◆ ការផលិតកម្មនៅឯកជន ។

◆ ពេលខ្វះខាត គេនៅនាយទុនលើម្ចាស់ដី អ្នកមានស្រែពឹងលើនាយទុន ឈ្មួញនៅឡើយ ។

◆ ដូច្នោះបានជាបក្សមានផែនការរៀបចំ ។ ពេលនោះយកវិធានចាត់តាំងជាកន្ទឹះគឺក្តាប់ពាណិជ្ជកម្មដោយក្តាប់បញ្ហាធំៗមុន ហើយឈានមកក្តាប់បញ្ហាផ្សេងៗឯទៀត ។

◆ រំលាយផ្សារដើម្បីកុំឲ្យនាយទុន វាក្តាប់ផ្សារបម្រើវាបាន ។

◆ រៀបចំការទាក់ទងផលិតកម្មថ្មី ដោយវាយកម្ទាត់ការទាក់ទងផលិតកម្មចាស់ កសាងការទាក់ទងផលិតកម្មថ្មី នៅតំបន់រំដោះប្រភេទទី១ និងទី២ តាមកម្រិតខ្ពស់ទាប ជាក់ស្តែងតាមសភាពការណ៍ ។

◆ យកដីធ្លីពីពួកក្បត់ និងដីធ្លីដែលនៅសល់ឲ្យកសិករក្រនិងកសិករថ្នាក់ក្រោម បង្កបង្កើនផល ។

◆ ចាត់តាំងសហករណ៍ ។

◆ បំផុសបំផុលចលនាបង្កបង្កើនផលពិសេសស្រូវនិងស្បៀង ។

ដោយវិធានការខាងចាត់តាំងនេះ ប្រជាជនត្រូវពឹងផ្អែកបដិវត្តន៍ ហើយបដិវត្តន៍ក៏គ្រប់គ្រងគេបាន ។

ដូច្នេះឆ្នាំ១៩៧២ ជាដូវបត់មួយនៃការរៀបចំកម្លាំង

ប្រជាជននៅក្នុងមូលដ្ឋានរបស់យើង ។ ធ្វើយ៉ាងនេះគឺយើងប្រមូលកម្លាំងបាន ។ តែបើយើងគ្រាន់តែឃោសនាអប់រំ ហើយមិនដណ្តើមយកសេដ្ឋកិច្ចពីសក្តិភូមិ នាយទុនគឺយើងមិនមានកម្លាំង ។ ដល់យើងមានកម្លាំងមូលដ្ឋានហើយ យើងប្រមូលកម្លាំងស្រទាប់ឯទៀតបាន ។ ដល់យើងមានកម្លាំងប្រជាជនហើយគឺជំរុញចលនាវាយសក្តិភូមិ ម្ចាស់ដី នាយទុន ធ្វើឲ្យពួកវាបាត់ម្ចាស់ការ ។ ឋានៈប្រជាជនឡើងចលនាបដិវត្តន៍ឡើង អនុភាពបដិវត្តន៍ក៏ឡើង ។ សម្ព័ន្ធភាពកម្មករ-កសិករ រឹងប៉ឹង ធំទូលាយ ក្រោមការដឹកនាំរបស់បក្ស ហើយពិសោធន៍នេះបានបង្ហាញឲ្យឃើញថា៖

១. ត្រូវផ្អែកលើចលនាជាក់ស្តែងដើម្បីពិនិត្យកម្លាំង

យកចលនាជាក់ស្តែងរបស់មហាជនពិនិត្យមើល តើយើងមានកម្លាំងប៉ុនណា ហើយត្រូវរៀបចំបង្កើនកម្លាំងយ៉ាងណា និងរៀបចំយ៉ាងម៉េច? ត្រូវមានវិធានការណ៍ចំពោះវណ្ណៈ សក្តិភូមិ នាយទុន កុំទៅប្រកួតប្រណាំងជាមួយវាដោយសន្តិវិធីដាច់ខាត ។

២.ដើម្បីប្រមូលកម្លាំងប្រជាជនឲ្យខ្លាំងក្លានិងជាប់លាប់

ត្រូវមានចលនាត្រូវបំផុសចលនាឲ្យជាប់ តាំងពីចលនាធ្វើភ្លឺ លើកទំនប់ បង្កបង្កើនផល ត្បាញរវៃ ។ល ។ តាមពាក្យស្លោក បំផុសជាប់ ដុតជាប់ ក្តៅជាប់ ។ ក្រោយរំដោះប្រទេសបានទាំងស្រុង យើងបំផុសចលនាបង្កបង្កើនផលទូទាំងប្រទេស ។ ក្នុងចលនានេះ យើងកសាងទស្សនៈថ្មីគោលជំហរថ្មី បច្ចេសទេសថ្មីឲ្យប្រជាជនយើង ។

### ៣) ការកសាង ពង្រឹង និងពង្រីករដ្ឋអំណាចបដិវត្តន៍របស់បក្ស

◆ ចំពោះបញ្ហានេះ ក៏មានការប្រយុទ្ធ រវាងមាគ៌ាឯករាជ្យម្ចាស់ការ ខ្លួនខបត្តម្ភខ្លួន និងមាគ៌ាឈ្លានពានមកលើកម្ពុជាយើង ។

◆ ការប្រយុទ្ធជាមួយពួកសក្តិភូមិ-ម្ចាស់ដី អ្នកស្រែ មាន និងនាយទុន ដោយពួកនេះ ក៏ចង់ក្តាប់រដ្ឋអំណាច ។

◆ ការប្រយុទ្ធរវាងមាគ៌ាចាត់តាំងរដ្ឋអំណាចបដិវត្តន៍របស់បក្ស និងពួក ។ ឱកាសនិយមផ្សេងៗដែលចូលមកកាន់កាប់រដ្ឋអំណាចតាមកាលៈទេសៈពេលនោះ ។

◆ ការតស៊ូរវាងបក្សបដិវត្តន៍យើង ហើយនឹងការចង់បានរដ្ឋអំណាចឡើងវិញរបស់សមាសភាពមិនល្អក្នុងស្រទាប់លើដែលនៅក្នុងជួរវណសិរ្ស ។

ទិសដៅបដិវត្តន៍យើងគឺកម្ទេចអំណាចចាស់ កសាងរដ្ឋអំណាចបដិវត្តន៍ថ្មី ។ យើងបានដណ្តើមជាបន្តបន្ទាប់មក ។ យើងខំពង្រឹងពង្រីករដ្ឋអំណាចនេះ តែទន្ទឹមនឹងនេះ ពួកខ្មាំងសត្រូវក៏ខំដណ្តើមដោយម្យ៉ាងវាចាត់តាំងផ្ទាល់ ។ ឯវិធីប្រយោលគឺបញ្ចូលមនុស្សវាដែលទាក់ទងបានចូលរដ្ឋអំណាចភូមិ-ឃុំតាមវិធីផ្សេងៗ ។ វិធីប្រយោលមួយទៀតគឺតាមរយៈកម្មាភិបាលយើងដែលទាក់ទងបានជា កម្មាភិបាលមូលដ្ឋាន យោធា សេដ្ឋកិច្ច រហូតដល់ដណ្តើមរដ្ឋអំណាចនៅក្នុងបក្សដោយរៀបចំកម្លាំង ដឹកនាំវាជាបន្តបន្ទាប់តាមរយៈដៃជើងវា និងពួកសមាសភាពឱកាសនិយម ។ ការប្រយុទ្ធនេះមានជាបន្តបន្ទាប់ហើយមានការបង្ហូរឈាម ។ តែផែនការនេះត្រូវវាយឲ្យខ្ចាត់ខ្ចាយជាបន្តបន្ទាប់ ដោយមកពីយើងមានទស្សនៈត្រឹមត្រូវចំពោះធាតុពិតនិងគោលបំណងឈ្លានពានរបស់ខ្មាំងសត្រូវ ។ ដូច្នេះ យើងបំពាក់គោលជំហរ ទស្សនៈឲ្យបក្ស ប្រជាជន និងកងទ័ពបាត់ម្ចាស់ការ ។

ការដណ្តើមរដ្ឋអំណាច រវាងយើង និងវណ្ណៈជិះជាន់ផ្សេងៗក្នុងតំបន់រំដោះយើង គឺតាមមូលដ្ឋានមួយៗ ពួកវារៀបចំកម្លាំងវាឲ្យចូលក្នុងអង្គការយើងមាននៅក្នុងឆ្នាំ១៩៧២-១៩៧៣ ។ វណ្ណៈនេះចង់មានសិទ្ធិអំណាចក្នុងរបបថ្មី ។ តែពួកនេះដណ្តើមមិនបានដោយបក្សបំពាក់បំប៉ន និងពង្រឹងគោលជំហរវណ្ណៈអធនជាប់ជានិច្ច ។

ពួកឱកាសនិយមតាំងពីឆ្នាំ១៩៧២មក ក៏ចូលច្រើនជាថ្នាលឲ្យខ្មាំងធ្វើសកម្មភាពចូលជ្រៀតជ្រែកប្រឆាំងបដិវត្តន៍បាន ។ ពួកនេះយើងសម្រិតសម្រាំងជាបន្តបន្ទាប់ ។ ពួកសមាសភាពមិនល្អក្នុងវណសិរ្សខាងលើមានបំណងរក្សាសិទ្ធិអំណាចចាស់របស់គេតាមរយៈនេះ គេសង្ឃឹមពង្រឹងនិងពង្រីករដ្ឋអំណាចគេ តាមរយៈរបបថ្មីបានមួយកម្រិតទៀត ។ ចក្រពត្តិអាមេរិក បារាំងក៏វាសង្ឃឹមដើម្បីបានទាក់ទងវិញជាមួយពួកនេះ ។

យើងដណ្តើមជ័យជម្នះនេះបានមកពីយើងកំណត់ធាតុពិតនៃរដ្ឋអំណាចបដិវត្តន៍បានត្រឹមត្រូវរហូតដល់ប្រកាសប្រើរដ្ឋធម្មនុញ្ញថ្មីបដិវត្តន៍ ។ យើងអនុវត្តន៍ផ្តាច់ការបដិវត្តន៍ជាបន្តបន្ទាប់ រដ្ឋអំណាចខាងនយោបាយ យោធា សេដ្ឋកិច្ច ។ បក្សយើងក្តាប់ទាំងអស់ ។ តទៅទៀត យើងត្រូវយកចិត្តទុកដាក់ក្តាប់ពង្រឹង និងពង្រីករដ្ឋ

អំណាចបដិវត្តន៍របស់បដិវត្តន៍របស់បក្សតទៅទៀតឲ្យរដ្ឋអំណាចនេះបរិសុទ្ធតទៅទៀត ។ ពិតមែនតែសក្តិភូមិ នាយទុន រលំរលាយ ចក្រពត្តិអាមេរិក និងបរិវាររវា ត្រូវបរាជ័យ ខ្មាំងសត្រូវឯទៀតបែកខ្ចាត់ខ្ចាយ តែពួកវានៅតែធ្វើសកម្មភាព និងរកវិធីដណ្តើមរដ្ឋអំណាចពីយើងតទៅទៀត ។ វិធីរបស់គេ ដោយបំបែកបំបាក់ លើកដាក់ បង្វែរមាគ៌ារហូតដល់ត្រៀមយូរអង្វែងទៅទៀតពិសេសខាងសីលធម៌ ។

ការទប់ទល់សំខាន់របស់យើង គឺឯកភាពផ្ទៃក្នុងបក្សផ្ទៃក្នុងប្រជាជន ផ្ទៃក្នុងកងទ័ពបដិវត្តន៍ ទាំងខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំង ។

## ៤) អំពីការកសាង ពង្រឹង និងពង្រីកកងទ័ពបដិវត្តន៍របស់បក្ស និងការអនុវត្ត មាគ៌ាយោធា មាគ៌ាប្រយុទ្ធរបស់បក្ស

ចំពោះបញ្ហាកសាងកម្លាំងកងទ័ពបដិវត្តន៍របស់បក្សរបស់យើងក៏យើងឈរលើគោលជំហរឯករាជ្យ-ម្ចាស់ការ ខ្លួនឧបត្ថម្ភខ្លួនជាមូលដ្ឋាន ទាំងការរៀបចំកងទ័ព ការកសាងកម្មាភិបាល មាគ៌ាប្រើប្រាស់អាវុធ មាគ៌ាប្រយុទ្ធ ។ល ។ តែគោលជំហរប្រឆាំង និងមាគ៌ានេះ ក៏មានចេញមកពីខ្មាំងសត្រូវទៀត ។ មានការប្រយុទ្ធតឹងតែងមានសភាពស្លាប់-រស់ ឈ្នះចាញ់សង្គ្រាមតែម្តង ។

### មាគ៌ាសង្គ្រាមប្រជាជនរបស់បក្ស

ដំបូងខ្មាំងនៅខ្លាំងជាងយើង ខាងយោធា ។ យើងខ្លាំងជាងវាខាងនយោបាយ តែខ្សោយ ជាងវាបណ្តោះអាសន្នខាងយោធា ។ យើងលើកមាគ៌ាគឺប្រជាជនទាំងមូលចូលរួមប្រាស្រ័យធ្វើសង្គ្រាមប្រជាជន ទាំងសមរភូមិមុខ ទាំងសមរភូមិក្រោយ ។ វាយខ្មាំងទាំងយោធា នយោបាយ សេដ្ឋកិច្ច គ្រប់ផ្នែក ។

យើងបំផុសប្រជាជនបានប្រជាជនធ្វើទាំងអស់តាំងពីដឹកជញ្ជូន បង្កបង្កើនផលចូលទ័ព ។ល ។

វាយខាងនយោបាយមានទិដ្ឋភាពច្រើន ។ យើងវាយវាបានដាប់ព្រោះវាក្បត់ជាតិ ពុករលួយ ហ្វាស៊ីស ។ យើងសង្កត់កវាដាប់ ។

ចំណុចនយោបាយមួយទៀតនៃសង្គ្រាមប្រជាជនគឺពង្រឹងប្រជាជនពីខ្មាំង មិនឲ្យខ្មាំងយកប្រជាជនបាន ។ វាយសមរភូមិមួយៗ យើងដកយកប្រជាជនអស់ ។ បញ្ហានេះ ជាកម្លាំងមួយខ្លាំងដោយវាយចំទ្រឹស្តីអានិចសុនដែលយកខ្មែរសម្លាប់ខ្មែរ ។ យើងវាយខាងសេដ្ឋកិច្ចខ្មាំងព្រោះសេដ្ឋកិច្ច ភាគច្រើនដាច់ខាតនៅតំបន់រំដោះយើង ។

យើងបំផុសប្រជាជននៅក្រុងតស៊ូ ច្រើនរូបភាពវាយចំក្បាលម៉ាស៊ីនគ្រប់គ្រងកណ្តាលរបស់ ខ្មាំង ។

### បញ្ហាកសាងកងទ័ព បំពាក់អាវុធ និងមាគ៌ាប្រយុទ្ធ

ធាតុវណ្ណៈរបស់កងទ័ពគឺវណ្ណៈអធន ក្រោមការដឹកនាំរបស់បក្សដាច់ខាត ។ សមាសភាពភាគច្រើនដាច់ខាតគឺកសិករ និងកសិករកណ្តាលថ្នាក់ក្រោមដែលបានលត់ដំក្នុងចលនាសង្គ្រាមផ្ទាល់ ទាំងនយោបាយ សតិអារម្មណ៍ ចាត់តាំង និងបច្ចេកទេស ។

យើងបំពាក់អាវុធតាមគោលជំហរឯករាជ្យ-ម្ចាស់ការតាមលទ្ធភាព និងវាយយកបានពីខ្មាំង ។

មាគ៌ាប្រយុទ្ធរបស់យើង គឺវាយឈ្លប និងសម្បូរបែប ។ ពេលខ្លះ យកឈ្លបជាមូលដ្ឋាន ពេលខ្លះយកសម្បូរបែបជាសំខាន់ ។ យើងវាយផ្លូវគមនាគមន៍ វាយខាងក្នុងបរិវេណខ្មាំង វាយខាងក្រៅបរិវេណខ្មាំង វាយពុះ វាយកាត់ ។ល ។ ពេលយើងវាយផ្តាច់ព្រ័ត្រ គឺយើងវាយជុំវិញភ្នំពេញ វាយតាមខេត្ត វាយទន្លេមេគង្គដោយមេគង្គជាគន្លឹះ ។

## ៥) ការកសាងសេដ្ឋកិច្ច ហិរញ្ញវត្ថុរបស់បក្ស

ក្នុងរយៈកាលអនុវត្តន៍សង្គ្រាម ប្រជាជនយើងរៀបចំកសាងពង្រឹង និងពង្រីកសេដ្ឋកិច្ច ហិរញ្ញវត្ថុ ព្រោះវាមានតួនាទីសំខាន់ណាស់ក្នុងសង្គ្រាមរំដោះជាតិរំដោះប្រជាជន ។ បើសេដ្ឋកិច្ចហិរញ្ញវត្ថុដើរមិនស្រួលគឺបរាជ័យ ។

មាគ៌ាសេដ្ឋកិច្ច ហិញ្ញវត្ថុរបស់យើងគឺ៖

ចំណុចពិសេសទី១គឺមាគ៌ាបង្កបង្កើនផល ផលិតកម្មស្រូវ និងស្បៀងផ្សេងៗ ។ផលិតកម្មនេះជាស្នូលនៅសមរភូមិក្រោយ ។ កម្លាំងសមរភូមិខាងក្រោយទាំងអស់បម្រើផលិតកម្ម ។ មាគ៌ានេះបានបំផុសចលនាល្អ ពិសេស តាំងពីឆ្នាំ១៩៧២ ។ មាគ៌ានេះបម្រើបានគោលជំហរឯករាជ្យ ម្ចាស់ការ ខ្លួនឧបត្ថម្ភខ្លួនកម្រិតខ្ពស់បំផុត ។

ចំណុចពិសេសទី២គឺរដ្ឋក្តាប់ផ្នែកពាណិជ្ជកម្មសំខាន់ទាំងអស់ធ្វើឲ្យសភាពការណ៍ក្រឡាប់ចាក់ មានផលប្រយោជន៍ដល់

សង្គ្រាមបដិវត្តន៍ កាត់ដៃជើងឈ្មួញក្នុងស្រុក ឈ្មួញបម្រើបរទេស បម្រើចក្រពត្តិ ហើយធ្វើឲ្យពួកវាវណបយើងវិញ ។ វិធានការខ្លាំងក្លានេះ បម្រើសំណូមពរសង្គ្រាមបដិវត្តន៍បានបម្រើផលិតកម្ម បានបម្រើភាពប្រចាំថ្ងៃរបស់ប្រជាជនបាន ។

ចំណុចពិសេសទី៣ គឺការរៀបចំចាត់តាំងសហករណ៍នៅតំបន់រំដោះទី១ ទី២ កម្រិតទាប-កម្រិតខ្ពស់ ដែលជាវិធានការវាយការទាក់ទងផលិតកម្មចាស់ កសាងការទាក់ទងផលិតកម្មថ្មី ។ សហករណ៍ជាបង្អែកឲ្យកសិករក្រ និងកសិករកណ្ដាលថ្នាក់ក្រោម ។ សហករណ៍នេះ វាយទាំងចក្រពត្តិ វាយទាំងចក្រពត្តិ សក្ដិភូមិ ម្ចាស់ដី និងនាយទុន ។

ចំណុចពិសេសទី៤ គឺការមិនចាយលុយ ។ វិធានការណ៍នេះយើងចាប់ផ្ដើមពីឆ្នាំ១៩៧៣ ។ មិនចាយលុយ មានន័យទាំងបដិវត្តន៍ប្រជាជាតិ និងប្រជាធិបតេយ្យ ហើយទប់ទល់ខ្លាំង បន្ថយកម្លាំងខ្មាំងខាងហិរញ្ញវត្ថុបាន ។ ន័យខាងប្រជាធិបតេយ្យគឺជាមធ្យោបាយមួយ កម្ចាត់កម្មសិទ្ធិឯកជន ជាសម្ភារ ជាគោលជំហរសតិអារម្មណ៍ ។ ជាកម្លាំងធំណាស់ក្នុងការធ្វើបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ ។ បើគ្មានវិធានការទាំងនេះ យើងគ្មានកម្លាំងខាងសេដ្ឋកិច្ច ហិរញ្ញវត្ថុ ។

យើងធ្វើបានមកពីយើងមានកម្លាំងគ្រប់គ្រាន់គឺមានកងទ័ពខ្លាំងក្លា មានរដ្ឋអំណាចជិតទូទាំងប្រទេស យើងប្រមូលកម្លាំងប្រជាជនបានកាន់ច្រើនហើយក្រោមការដឹកនាំរបស់បក្សដាច់ខាត ។

យើងដំណើរការទៅបានយ៉ាងនេះ ដោយបក្សតាមដានចលនាជាប់ ហើយចលនានេះ វាបង្ហាញយើងថា តើត្រូវធ្វើអ្វីមិនត្រូវធ្វើអ្វី ។

## ៦) អំពីការកសាងវប្បធម៌-សង្គមកិច្ច របស់បក្សដើម្បីបម្រើសង្គ្រាមប្រជាជន

វប្បធម៌ សង្គមកិច្ច ក៏ជាកម្លាំងមួយនៃរដ្ឋអំណាចចាស់, កម្លាំងនេះបានពង្រឹង និងពង្រីកដុះស្លែ រាប់ពាន់ឆ្នាំមានលក្ខណៈសក្ដិភូមិ នាយទុនប្រតិកិរិយា ចក្រពត្តិ ដូច្នេះភារកិច្ចបដិវត្តន៍ប្រជាធិបតេយ្យ ក៏វាយរំលំវប្បធម៌សង្គមកិច្ចចាស់នេះដែរ ។ ពិសេសក្រោយមហាសន្និបាតបក្សលើទីមួយឆ្នាំ១៩៧១ យើងបន្តវាយបោសសម្អាតភ្លាមអស់ជាមូលដ្ឋានហើយបោសសម្អាតវាជាបន្តបន្ទាប់ ។

ការតស៊ូនេះក៏ជ្រាលជ្រៅណាស់ដែរ ។

មូលហេតុដែលធ្វើឲ្យរលំរលាយវប្បធម៌-សង្គមកិច្ចចាស់ មានកត្តាពីរ ៖

- កត្តាបក្សដឹកនាំដែលបែងចែកវប្បធម៌បដិវត្តន៍ និងបដិវត្តន៍ច្បាស់លាស់ ហើយមានគោលជំហរប្រយុទ្ធច្បាស់លាស់ដាច់ខាត ។
- កត្តាទីពីរគឺយើងមានកម្លាំង ដូច្នេះ អនុវត្តបានរហ័ស ។ បើមានតែកម្លាំងសម្ភារ តែបើគ្មានកម្លាំងគោលជំហរក៏អនុវត្តន៍មិនបាន ។

ដូច្នេះយើងវាយរំលំទាំងរបបយោធា នយោបាយ សេដ្ឋកិច្ច វប្បធម៌របស់របបសក្ដិភូមិ នាយទុន អស់ដល់ឫសគល់ ។ តែអានុភាពចាស់នៃវប្បធម៌សង្គមកិច្ចចាស់វានៅសេសសល់ដែរ ដែលយើងបន្តការតស៊ូកម្ចាត់ទៅទៀត ។

អំពីការសាកល្បងវប្បធម៌ សង្គមកិច្ចថ្មី យើងមិនផ្អែកលើបច្ចេកទេសទេ ។ យើងឈរលើគោលជំហរបដិវត្តន៍ ដើម្បីកសាងបច្ចេកទេស ។ អ្វីៗមិនបដិវត្តន៍យើងមិនធ្វើ ។ បើយើងមិនឃ្លាតពីគោលជំហរបដិវត្តន៍នៃវណ្ណៈអធនទេ យើងមុខជាលឿនព្រោះយើងដើរផ្លូវកាត់ត្រង់ មិនក្រងិកក្រងក់ ។

## ៧) ការកសាងពង្រឹងពង្រីកមូលដ្ឋានបង្អែកបម្រើសង្គ្រាមរំដោះជាតិ រំដោះប្រជាជន

ក្រោយរដ្ឋប្រហារយើងរំដោះបានទឹកដី ៧០-៧៥ ភាគរយភ្លាម ។ មូលដ្ឋានរំដោះ ធំទូលាយ ចែកជាមូលដ្ឋានបង្អែកចាស់ និងរំដោះថ្មី ។

ហៅថាមូលដ្ឋានបង្អែកគឺជាប្រជាជនខ្លាំង សេដ្ឋកិច្ចខ្លាំង បន្ទាប់មកគឺភូមិសាស្ត្រ ។ ពេលយើងរំដោះធំទូលាយ បើនៅតែរក្សាមូលដ្ឋានបង្អែកចាស់ យើងបម្រើភារកិច្ចបដិវត្តន៍មិនបាន ។ ដូច្នេះបក្សសម្រេចយកតំបន់រំដោះទាំងមូលទូទាំងប្រទេសធ្វើជាមូលដ្ឋានបង្អែកគ្រាន់តែមានចំណុច ខ្ពស់-ទាប រឹង-ខ្សោយ តាមលក្ខណៈសម្បត្តិរបស់វា ។ ឈរលើទស្សនៈនេះ គ្រប់ទីកន្លែងត្រូវមានកងទ័ពរឹងប៉ឹងទាំងបីប្រភេទ ។ រដ្ឋអំណាចរឹងប៉ឹងត្រូវក្ដាប់ប្រជាជនដាច់ខាត ។ ទន្ទឹមនេះកសាងសេដ្ឋកិច្ចឲ្យខ្លាំង ។ បក្សដឹកនាំ

ត្រូវខ្លាំង ។ បើកន្លែងណា១មានលក្ខណៈសម្បត្តិយ៉ាងនេះ វាជាមូលដ្ឋានបផ្អែក ។ ធ្វើយ៉ាងនេះសូម្បីតែនៅជុំវិញភ្នំពេញ ក៏ជាមូលដ្ឋានបផ្អែកបានដែរ ។ យើងត្រូវកសាងមូលដ្ឋានបផ្អែកទូទាំងប្រទេសកន្លែងណាក៏ជាមូលដ្ឋានបផ្អែក ។

**៨) កិច្ចការបរទេសរបស់បក្ស**

ជាផ្នែកមួយនៃការងាររបដិវត្តន៍របស់យើងក្នុងការរំដោះជាតិរំដោះប្រជាជន ។ វាមិនមានតួនាទីជាកត្តាកំណត់ទេ តែវាទាក់ទងដល់យុទ្ធសាស្ត្រយុទ្ធវិធីសង្គ្រាមប្រជាជនរបស់យើង ។

តើយើងដំណើរការយ៉ាងម៉េច?

◆ ការងារបរទេសរបស់បក្សផ្អែកសំខាន់បំផុតលើកត្តាអន្តោម័តលើចលនាលើកម្លាំងបដិវត្តន៍របស់ខ្លួនលើជ័យជម្នះក្នុងប្រទេស ។ តទៅថ្ងៃមុខទៀត យើងនៅតែត្រូវឈរលើកត្តាអន្តោម័តតទៅទៀត លើជំហរឯករាជ្យ ម្ចាស់ការ ខ្លួនទីបត្តមួខ្លួន ។

◆លើកកម្ពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ឲ្យខ្ពស់ ប្រុងប្រយ័ត្នបដិវត្តន៍លើគ្រប់ផ្នែក ទាំងនយោបាយសតិអារម្មណ៍ និងចាត់តាំង ។ បញ្ហានេះក៏មានតួនាទីជាយុទ្ធសាស្ត្រសំខាន់ណាស់ដែរ ។

**៩) បញ្ហាទប់ទល់ និងកម្ទាត់សកម្មភាពចារកម្មដែលប៉ុនប៉ងបំផ្លិចបំផ្លាញបដិវត្តន៍យើង**

សង្គ្រាមចារកម្មពីខាងចក្រពត្តិអាមេរិក-បរិវារ និងពីប្រកពផ្សេង១គឺសំដៅស៊ីរូងយ៉ាងជ្រាលជ្រៅដោយមានបំណងវាយកម្ទេចកងទ័ព និងបដិវត្តន៍យើងបំណងគ្រប់គ្រងយើង ។ សកម្មភាពវា គឺវាយទាំងយុទ្ធសាស្ត្រ ។ ចំពោះមុខគឺកុំឲ្យយើងឈ្នះសង្គ្រាម ។ តែពេលបដិវត្តន៍ឈ្នះវាបន្តសកម្មភាពទៅទៀតធ្វើឲ្យបដិវត្តន៍ប្រែពណ៌សម្បុរតែយើងបានកម្ទាត់វាឲ្យខ្ទាត់ខ្ទាយជាបន្តបន្ទាប់ ។

ពិសោធន៍បានបង្ហាញឲ្យឃើញថាៈ

◆ ត្រូវមានគោលជំហរ វិភាគខ្មាំង សត្រូវ យុទ្ធសាស្ត្រយុទ្ធវិធី ឲ្យច្បាស់លាស់ ហើយ មានវិធានការណ៍ច្បាស់លាស់ ប្រុងប្រយ័ត្នបដិវត្តន៍ឲ្យខ្ពស់ ។

◆ មានប្រជាជន មហាជន ដែលបំពាក់ដោយគោលជំហរប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ កម្ទាត់ចារកម្មសំខាន់ គឺផ្អែកលើកម្លាំងមហាជនដើរតួជាងគេ គឺកម្លាំងសហករណ៍ ។

យើងទប់ទល់ ហើយឈ្នះរាល់តែបញ្ហាចារកម្មនេះនៅមានតទៅទៀត ។ យើងបន្តវាយឲ្យខ្ទាត់ខ្ទាយទៀតដោយពង្រឹងគោលជំហររបស់បក្សឲ្យរឹងប៉ឹងគោលការណ៍សហករណ៍ប្រជាជនឯកភាពជាមួយបក្ស ។

**១០) មាគ៌ាការពារបក្សបដិវត្តន៍ និងអង្គការដឹកនាំគ្រប់ថ្នាក់របស់បក្សបញ្ហានេះជាអាយុជីវិតព្រោះជាកិច្ចការពារក្បាលម៉ាស៊ីនរបស់បក្ស**

បើរក្សាការពារក្បាលម៉ាស៊ីនដឹកនាំបានគឺដំណើរការដឹកនាំ ។ ការពិសោធន៍ក្នុងចលនាបានបង្ហាញឲ្យឃើញថា ៖

◆ ប្រុងប្រយ័ត្នបដិវត្តន៍ឲ្យខ្ពស់តែព្រមជាមួយនេះត្រូវបំពេញភារកិច្ចដឹកនាំឲ្យបានល្អ ។

◆ ត្រូវក្តាប់ឲ្យជាប់នូវមាគ៌ាសកម្មភាពសម្ងាត់របស់បក្សតាំងពីការធ្វើការងាររការរស់នៅស៊ីចុក ។ល ។

◆ ត្រូវក្តាប់ឲ្យជាប់នូវលាក់ការណ៍ចាត់តាំងរបស់បក្សក្នុងការជ្រើសរើសយុទ្ធជន យុទ្ធកម្មាភិបាល ។ល ។

បញ្ហានេះ ត្រូវមានទស្សនៈឲ្យច្បាស់ថាជាបញ្ហាស្មុគស្មាញប្រចាំថ្ងៃ ហើយ ចោទជាប្រចាំថ្ងៃតទៅទៀត ។

សរុបខ្លី គឺតាំងពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ បក្សយើងបានដឹកនាំកសាងកម្លាំងបដិវត្តន៍គ្រប់ផ្នែកបានត្រឹមត្រូវតាមមាគ៌ារបស់បក្សជាមូលដ្ឋានដូច្នោះទើបទទួលបាននូវមហាជ័យជម្នះមហាអស្ចារ្យនាថ្ងៃ១៧មេសា ឆ្នាំ១៩៧៥ បញ្ចប់នូវមាគ៌ាជាយុទ្ធសាស្ត្រនៃបដិវត្តន៍ប្រជាជាតិ-ប្រជាធិបតេយ្យបានទាំងស្រុងនិងស្ថាពរ ។ ឆ្នាំ១៩៧៦ លទ្ធផលជាមហាជោគជ័យនៃការបំពេញភារកិច្ចនិងសម្រេចភារកិច្ចយុទ្ធសាស្ត្របដិវត្តន៍ ប្រជាជាតិ-ប្រជាធិបតេយ្យមានទំហំសម្បើមអស្ចារ្យណាស់ ។

**ខាងប្រជាជាតិ**

◆ វាយចក្រពត្តិអាមេរិកនិងបរិវារឲ្យខ្ទាត់ខ្ទាយរលំពីកម្ពុជា

◆ ចក្រពត្តិដទៃទៀតទាំងអស់ក៏ត្រូវបោសសំអាតចេញពីប្រទេសកម្ពុជាទាំងមូលដ្ឋាននយោបាយ សេដ្ឋកិច្ច វប្បធម៌ សង្គមកិច្ច ។ល ។

◆ បញ្ហាប្រជាជាតិ អធិបតេយ្យភាពបូរណភាពដែនដីស្អាតជ្រះស្រឡះ គ្មានជំពាក់ជំពិនអ្វីទាំងអស់ ។

**ខាងប្រជាធិបតេយ្យ**

◆ សម្រេចបានទាំងស្រុងដោយវាយរលំវណ្ណៈសក្តិភូមិបានទាំងអស់ទាំងស្រុង ស្ថាពររបបនយោបាយ សេដ្ឋកិច្ច វប្បធម៌ត្រូវរលំរលាយជាមូលដ្ឋាន នៅសល់បន្តិចបន្តួចដែលយើងត្រូវបន្តផ្តាច់ផ្តិលតទៅទៀត ។

◆ ព្រមជាមួយគ្នានេះ បានសម្រេចភារកិច្ចមួយទៀត គឺវាយរំលំនាយទុន ទាំងរបប ទាំងវណ្ណៈទាំងស្រុង ។ យើងវាយតាំងពីឆ្នាំ១៩៧២-៧៣-៧៤ នៅក្នុងតំបន់រំដោះរបស់យើង ក្រោយពីយើងបានរំដោះភ្នំពេញហើយ យើងបានបំផុសបំផុលចលនាប្រជាជន ព្រមទាំងវណ្ណៈនាយទុនផង ទៅធ្វើពលកម្មកសាងប្រទេសនៅជនបទ ។ ជាមូលដ្ឋាន យើងវាយរលំរលាយតែឥទ្ធិពលរបស់វានៅមាននៅឡើយ យើងបន្តបដិវត្តន៍សង្គមនិយមតទៅទៀត ។

◆ យើងសម្រេចបដិវត្តន៍សង្គមនិយមមួយភាគធំហើយ យើងបោះទីតាំងសមូហភាពូបនីយកម្មសេដ្ឋកិច្ចនៅក្នុងសង្គម យើងមានសហករណ៍ រោងចក្ររដ្ឋ ឯមូលដ្ឋាន សេដ្ឋកិច្ចឯកជនស្ទើរតែគ្មានទៀតទេ ។ តែបញ្ហានេះនៅថ្មីថ្មោងនៅឡើយ ។

ដូច្នោះ ឆ្នាំ១៩៧៦នេះ ទង់ប្រយុទ្ធរបស់បក្សគឺវាយសម្រុកខ្លាំងក្លាបំផុត ដោយមហាចលនាមហាជន មហាលោតផ្លោះ មហាអស្ចារ្យ ។ ជាក់ស្តែងគឺ៖

## ភារកិច្ចបដិវត្តន៍សង្គមនិយម

ខិតខំបន្តធ្វើបដិវត្តន៍សង្គមនិយមដោយបន្តវាយរំលំនិងគាស់ឫសកែវជាសំណល់ផ្សេងៗ គ្រប់ប្រភេទរបស់របបវណ្ណៈនាយទុន របបឯកជនរបស់វណ្ណៈទាំងអស់ដែលអធន និងកម្មសិទ្ធិឯកជនទាំងអស់ឲ្យខ្លាំងក្លាកាន់តែជ្រាលជ្រៅជាប់ជានិច្ច ក្នុងមួយឆ្នាំ១៩៧៦នេះ ដើម្បីកុំឲ្យសំណល់របបវណ្ណៈនាយទុនរបបឯកជន និងកម្មសិទ្ធិឯកជនទាំងអស់ វាពង្រីងនិងពង្រីកខ្លួនបាន ។ ផ្ទុយទៅវិញ ឲ្យវាកាន់តែរំលំរលើងខ្ទេចខ្ទីអស់រលីងទៅទៅជានិច្ច ។ ការបន្តធ្វើបដិវត្តន៍សង្គមនិយមនេះ ត្រូវធ្វើឡើងខាងសតិអារម្មណ៍ ខាងចាត់តាំងសេដ្ឋកិច្ច វប្បធម៌សង្គមកិច្ច បច្ចេកទេស វិទ្យាសាស្ត្រ ហើយធ្វើឡើងក្នុងបក្សទាំងមូល អង្គការស្ហួលទាំងមូលកងទ័ពបដិវត្តន៍ទាំងមូលក្នុងជួរបដិវត្តន៍ យើងទាំងមូលក្នុងសហជីពកម្មករទាំងមូលក្នុងសភាពការណ៍កសិករទាំងមូល ក្នុងមន្ទីរក្រសួងទាំងមូលក្នុងសង្គមជាតិទាំងមូល ។

## ភារកិច្ចកសាងសង្គមនិយម

### ក) ផ្នែកកសាងពង្រឹង និងពង្រីករបបសមូហភាព

ខិតខំកសាងពង្រឹងនិងពង្រីករបបនៃវណ្ណៈអធនឲ្យកាន់តែរឹងប៉ឹង និងជ្រាលជ្រៅលើគ្រប់ផ្នែកទាំងអស់ សតិអារម្មណ៍ ចាត់តាំង សេដ្ឋកិច្ច វប្បធម៌សង្គមកិច្ច បច្ចេកទេស វិទ្យាសាស្ត្រ ។ល ។

ក្នុងឆ្នាំ១៩៧៦ ត្រូវរៀបចំពង្រឹង និងពង្រីកទីតាំងសមូហភាពនេះឲ្យបានជាទូទៅក្នុងសង្គមជាតិ យើងទាំងមូល ។

### ខ) ផ្នែកកសាង

ឈរលើទីតាំងសមូហភាពនៃវណ្ណៈអធនដែលត្រូវបានពង្រឹង និងពង្រីកជាលំដាប់ត្រូវខិតខំជំរុញ និងបំផុសបំផុលការកសាងសង្គមនិយម ខាងសេដ្ឋកិច្ច វប្បធម៌សង្គមកិច្ច បច្ចេកទេស វិទ្យាសាស្ត្រ ។ល ។ ឲ្យខ្លាំងក្លាឆាប់រហ័សមានគុណភាពខ្ពស់ដោយជំហរឯករាជ្យ ម្ចាស់ការ ខ្លួនទុកខ្លួន ជាសំខាន់បំផុត ។

ភារកិច្ចកសាងសង្គមនិយមខាងលើនេះត្រូវធ្វើឡើងនៅក្នុងបក្សទាំងមូល អង្គការស្ហួលទាំងមូល កងទ័ពបដិវត្តន៍ទាំងមូលក្នុងជួរបដិវត្តន៍ទាំងមូល សហជីពទាំងមូល សហករណ៍កសិករទាំងមូល មន្ទីរក្រសួងទាំងមូល និងក្នុងសង្គមជាតិទាំងមូល ។

## ភារកិច្ចការពារប្រទេស

ត្រូវខិតខំជំរុញភារកិច្ចការពារប្រទេសជាប្រជាធិបតេយ្យការពារលទ្ធផលបដិវត្តន៍ឲ្យបានខ្លាំងក្លាបំផុតឆាប់រហ័សបំផុតលើគ្រប់ផ្នែកទាំងអស់ ។ បំពាក់បំប៉នគោលជំហរនយោបាយ សតិអារម្មណ៍បដិវត្តន៍នៅក្នុងមហាជនទាំងអស់ឲ្យជ្រួតជ្រាបអំពីភារកិច្ចការពារប្រទេសដើម្បីទៅជាកំពែងដែកយ៉ាងរឹងមាំក្នុងកិច្ចការពារប្រទេស ។

ត្រូវក្តាប់ឲ្យជាប់និងជ្រួតជ្រាបនៅភារកិច្ចនយោបាយក្នុងឆ្នាំ១៩៧៦នេះ ក្នុងន័យអនុវត្តន៍ជាក់ស្តែង ដើម្បីជំរុញចលនាឲ្យខ្លាំងក្លា មហាលោតផ្លោះ មហាអស្ចារ្យបាន ។ ដូច្នេះ ត្រូវសិក្សាពិនិត្យពិគ្រោះ និងដកពិសោធន៍ជាបុគ្គលក្តីដោយសមូហភាពក្តីឲ្យជាប់ជានិច្ចក្នុងចលនាប្រយុទ្ធជាក់ស្តែង ។

**ឯកសារ D២១៤១២**

# សក្ខីកម្ម ឌុច ប្រឆាំងនឹងអតីតមេដឹកនាំខ្មែរក្រហម

**(តចប់)**

## *សក្ខីកម្មថ្ងៃទីប្រាំបី (ថ្ងៃទី២ ខែមេសា ឆ្នាំ២០១២)*

### *សក្ខីកម្មពេលព្រឹក*

នៅព្រឹកថ្ងៃច័ន្ទ ទី២ ខែមេសា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបន្តចោទសួរសាក្សី ឌុច បន្តទៀត ។ នាព្រឹកនេះ ព្រះរាជអាជ្ញាត្រូវបានផ្តល់ពេលមួយម៉ោងនិងសាមសិបនាទីដើម្បីចោទសួរសាក្សី ។ ជាកិច្ចចាប់ផ្តើម លោក វីលៀម ស្មឺត សហព្រះរាជអាជ្ញារងអន្តរជាតិបានចោទសួរ ឌុច ថាតើគាត់បានចូលរួមប្រជុំបក្សចំនួនប៉ុន្មានដងក្នុងអំឡុងរបបខ្មែរក្រហម ។ ឌុច បានជម្រាបអង្គជំនុំជម្រះទាំងមូលថា គាត់បានចូលរួមអង្គប្រជុំគម្រប់ខួបជ័យជម្នះរបស់បក្សកុម្មុយនីស្តកម្ពុជាចំនួនបីលើកនៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៦, ១៩៧៧, និង១៩៧៨ និងអង្គប្រជុំគម្រប់ខួបកំណើតកងទ័ពបដិវត្តន៍កម្ពុជាលើកទីដប់នៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៨ ។ គាត់បានបញ្ជាក់ថា ប៉ុល ពត និង នួន ជា តែងតែមានវត្តមានជាគណៈប្រតិភូក្នុងអង្គប្រជុំធំៗទាំងអស់នេះ ។ ខណៈដែលសហព្រះរាជអាជ្ញារងអន្តរជាតិដកស្រង់អត្ថបទមួយចេញពីទស្សនាវដ្តីទង់បដិវត្តនិងចោទសំណួរឲ្យ ឌុច បកស្រាយពាក្យថា "ជម្លោះវណ្ណៈ" នោះ ឌុច បានរៀបរាប់ថាក្នុងប្រទេសកម្ពុជាមានវណ្ណៈចំនួនប្រាំហើយក្នុងចំណោមវណ្ណៈទាំងអស់នោះមានវណ្ណៈមួយចំនួនដែលប្រកួតប្រជែងគ្នាដណ្តើមយក "តួនាទីដឹកនាំក្នុងសង្គម" ។ ឌុច បានបន្ថែមថា ក្នុងចំណោមប្រជាជនទាំងអស់ ប្រជាកសិករមានចំនួនប្រមាណ៨៥ភាគរយ ប៉ុន្តែប្រជាជនទាំងអស់នេះត្រូវបានគាបសង្កត់ដោយពួកមូលធននិយម ។ ដូច្នេះ ប្រជាកសិករគឺជម្លោះវណ្ណៈជាមួយនឹងពួកមូលធននិយម ។ បន្ទាប់មកទៀត សហព្រះរាជអាជ្ញារងអន្តរជាតិបានសួរស្នើឲ្យ ឌុច បកស្រាយឃ្លាដែលមានសរសេរក្នុងអត្ថបទនោះគឺ"ជម្លោះស្លាប់រស់" ។ ឌុច បានពន្យល់ឃ្លានេះថា "បើមានអ្នករស់ នោះម្នាក់ត្រូវតែស្លាប់" ។ ខណៈពេលនេះ សហព្រះរាជអាជ្ញារងអន្តរជាតិងាកមកសួរសំណួរ ឌុច ទាក់ទងនឹងគោលការណ៍សមាជិកបក្សកុម្មុយនីស្តកម្ពុជាចំពោះសមាជិក "រណសិរ្ស" ដែលសំដៅលើរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ។ ឌុច បានអះអាងថា ថ្នាក់ដឹកនាំបានចាត់ទុកក្រុមរណសិរ្សជាខ្មាំងគំរាមកំហែងខ្មែរក្រហមដូច្នេះអ្នកទាំងអស់នេះត្រូវបានចាប់ខ្លួនបញ្ជូនទៅមជ្ឈមណ្ឌលអប់រំកែប្រែហើយក្រោយមកត្រូវបានបញ្ជូនទៅមន្ទីរស-២១ដើម្បីសួរចម្លើយ ។ សហព្រះរាជអាជ្ញារងអន្តរជាតិបានសួរ ឌុច ថាតើបានបំផ្លាញចោលឯកសារទាំងអស់នៅមន្ទីរស-២១ដែរឬទេ នៅពេលយោធាវៀតណាមវាយចូលទីក្រុងភ្នំពេញនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។ ឌុច បានអះអាងថា កាលណោះមានរថក្រោះមកឈប់មុខផ្ទះគាត់



ឌុច កំពុងធ្វើសក្ខីកម្ម (រូបថត : អ.វ.ត.ក)

ដូច្នេះគាត់បានរត់គៀសខ្លួនដោយគ្មានយកអ្វីទៅជាមួយទេ ។ នួន ជា មិនបានបង្គាប់ឲ្យគាត់ចាត់វិធានការអ្វីចំពោះឯកសារទាំងអស់នោះទេ បើទោះបីជា នួន ជា បានដឹងថារបបគ្រប់គ្រងរបស់ខ្លួននឹងឈានដល់ទីបញ្ចប់ដោយបានបញ្ជាឲ្យគាត់សម្លាប់អ្នកទោសទាំងអស់ដែលនៅសេសសល់ពីមន្ទីរស-២១យ៉ាងណាក៏ដោយ ។ នៅឆ្នាំ១៩៨៣ នួន ជា បានកោះហៅគាត់ឲ្យចូលរួមអង្គប្រជុំមួយ ហើយបានសួរគាត់ពីរឿងឯកសារនៅមន្ទីរស-២១ ។ នៅពេលនោះ ឌុច បានបញ្ជាក់ប្រាប់ នួន ជា ថា គាត់មិនដែលបានបំផ្លាញឯកសារទាំងអស់នៅមន្ទីរស-២១ ។ នួន ជា បានខឹងសម្បានឹងគាត់ជាខ្លាំងហើយថា "ឌុច ជាមនុស្សភ្លីភ្លើ មិនចេះថែរក្សាឯកសារ" ។



នួន ជា ក្នុងបន្ទប់សវនាការ (រូបថត៖ អ.វ.ត.ក)

ក្រោយពេលឈប់សម្រាកពេលព្រឹក ភាគីព្រះរាជអាជ្ញាបានបញ្ចប់ការចោទសួរសាក្សី ឌុច ក្រោយពីបានចំណាយពេលអស់មួយសប្តាហ៍ ។ ជាកិច្ចបន្ទាប់ លោក ហុង គីមសួន មេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានចាប់ផ្តើមសាកសួរសាក្សី ឌុច ។ លោកមេធាវីបានសួរ ឌុច ពីទំនាក់ទំនងរវាងគាត់ និង អៀង សារី ។ ឌុច បានបកស្រាយថា អៀង សារី គឺជារដ្ឋមន្ត្រីក្រសួងការបរទេស ហើយថា មានអ្នកទោសមួយចំនួនធំដែលមកពីក្រសួងការបរទេសត្រូវបានចាប់ខ្លួនបញ្ជូនមកមន្ទីរស-២១ ។ ឌុច បានបញ្ជាក់ទៀតថា គាត់មិនដែលបានចូលរួមប្រជុំជាមួយនឹងក្រសួងការបរទេសឬគណៈអចិន្ត្រៃយ៍ទេ ប៉ុន្តែ ដឹងថាមានអ្នកទោសមួយចំនួនគឺមកពីក្រសួងការបរទេស ។ បន្ទាប់មកទៀត លោកមេធាវី ជាតិ សំ សុគង់ បានឡើងសាកសួរសាក្សីវិញម្តង ។ លោកមេធាវីបានសួរ ឌុច ពីចរន្តអំណាចរបស់គណៈមជ្ឈិម ។ ជាការឆ្លើយតប ឌុច បានអះអាងថា អៀង សារី គឺជាអ្នកចេញសេចក្តីសម្រេចទាំងអស់សម្រាប់ការចាប់ខ្លួនមនុស្សពីក្រសួងការបរទេស ។ ឌុច បានបន្ថែមអ្នកការទូតនិងអ្នកប្រាជ្ញជាច្រើននាក់ត្រូវបានក្រសួងការបរទេសកោះហៅឲ្យវិលត្រឡប់ចូលស្រុកវិញ ហើយក្រោយមកបញ្ជូនមកមន្ទីរស-២១ដើម្បីសួរចម្លើយ និងសម្លាប់ចោល ។

### សវនាការពេលរសៀល

ក្រោយពីសម្រាកអាហារថ្ងៃត្រង់មក កញ្ញា លីម៉ា ង្វៀន មេធាវីដើមបណ្តឹងរដ្ឋប្បវេណីចាប់ផ្តើមសួរសាក្សី ឌុច វិញម្តង ។ ទាក់ទងនឹងសំបុត្រដែល ឌុច ទទួលបានពី សុន សេន កាលពីថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៧ ឌុច បានរៀបរាប់ថាសំបុត្រនោះបានបង្គាប់ឲ្យគាត់ទាញយកចម្លើយសារភាពឲ្យកាន់តែច្រើនដើម្បីជួយឲ្យលេខាបក្ស ប៉ុល ពត វែកមុខរកខ្មាំងបន្ថែមទៀត ។ ប៉ុន្តែ សុន សេន មិនបានចុះហត្ថលេខាលើសំបុត្រនោះទេ ពីព្រោះតាមពិតសំបុត្រនោះគឺ ស៊ូម៉េត ជាអ្នកសរសេរដោយសារតែ ឌុច ស្គាល់អក្សររបស់ ស៊ូម៉េត ។ កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៧៧ ឌុច បានទទួលសំបុត្រមួយទៀតពី សុន សេន ដែលសំបុត្រនោះបានបង្គាប់ឲ្យគាត់ទាញយកចម្លើយសារភាពពីអ្នកទោសម្នាក់ភ្លាមៗ ដើម្បីឲ្យអង្គការចាត់វិធានការទាន់ពេលវេលា ហើយគាត់ត្រូវតែរាយការណ៍ផ្ទាល់ទៅអង្គការ ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានសួរ ឌុច ថាតើពាក្យ "អង្គការ" នេះសំដៅទៅលើ សុន សេន ឬ ប៉ុល ពត ។ ឌុច បានបញ្ជាក់ថា សុន សេន មិនដែលចាត់ទុកខ្លួនឯងជាអង្គការឡើយ ដូច្នេះ អង្គការនេះគឺសំដៅទៅលើ ប៉ុល ពត ។ ទាក់ទងនឹងការផ្ញើសារទៅឌុច និងថ្នាក់លើគាត់ ឌុច បាននិយាយថា គាត់មិនអាចផ្ញើសារអ្វីទៅអង្គការថ្នាក់លើបានទេ ប៉ុន្តែ ប្រសិនបើអង្គការចង់ផ្ញើសារទៅគាត់ អង្គការផ្ញើសារតាមនិរសាររបស់អង្គការចាត់តាំង ។ បន្ទាប់មកទៀត មេធាវី លីម៉ា ង្វៀន បានសួរ ឌុច ពីការចាប់ខ្លួនជនបរទេសបញ្ជូនទៅមន្ទីរ ស-២១ ។ ឌុច បានរៀបរាប់ថា មានការចាប់ខ្លួនជនបរទេសជាច្រើននាក់ដូចជាមុនការចាប់ខ្លួនអ្នកនេសាទជនជាតិថៃមួយចំនួនបញ្ជូនទៅមន្ទីរស-២១ ក្រោយពីបានទទួលបញ្ជាពី សុន សេន ។ បើទោះបីជាអ្នកនេសាទទាំងនេះមិនត្រូវបានចាត់ទុកជាអ្នកទោសពិសេសយ៉ាងណាក្តី ក៏អ្នកទាំងអស់

*នោះក៏ត្រូវតែសម្លាប់ដែរ ។ បន្ថែមលើនេះ ឌុច បានបញ្ជាក់ពីការចាប់ខ្លួនជនជាតិបរទេសចំនួនបួននាក់ដែលត្រូវបានធ្វើទារុណកម្ម សួរចម្លើយ ហើយដុតសម្លាប់ក្នុងសំបកកង់ឡានទាំងរស់ ។ ឌុច បានអះអាងថា ជនបរទេសទាំងបួននាក់នេះបានចូលក្នុងទឹកដីកម្ពុជាដោយខុសច្បាប់ដូច្នេះខ្មែរក្រហមបានចាត់ទុកជនបរទេសទាំងអស់នេះជាខ្មាំងយកការណ៍ ។ ប៉ុន្តែ ការចាប់ខ្លួន ធ្វើទារុណកម្ម សួរចម្លើយ និងសម្លាប់ជនបរទេសទាំងអស់នេះមិនមានជាប់ពាក់ព័ន្ធនឹងក្រសួងការបរទេសទេ ។ ការទទួលខុសត្រូវចំពោះការស្លាប់របស់ជន*



*អៀង សារី ក្នុងបន្ទប់សវនាការ (រូបថត៖ អ.វ.ត.ក)*

*បរទេសទាំងនេះគឺឋិតលើ ប៉ុល ពត និង នួន ជា ។ យ៉ាងណាមិញមិនមានឯកសារបញ្ជាក់ពីការចេញបញ្ជារបស់ ប៉ុល ពត និង នួន ជា ឲ្យសម្លាប់ជនបរទេសទាំងបួននាក់នេះទេ ។ មេធាវី លីម៉ា ង្វៀន បានសួរ ឌុច ពីគោលនយោបាយ "ប្រឆាំងសេ.អ៊ី.អា, កា.ហ្សេ.បេ និងយួន ។ ឌុច បានបញ្ជាក់ថា "សេ.អ៊ី.អា" នេះគឺសំដៅលើជនទាំងឡាយណាដែលទទួលបានការចាត់តាំងពីសហរដ្ឋអាមេរិកហើយថា យួនគឺជាខ្មាំងរបស់អង្គការ ។ ឌុច បានអះអាងទៀតថា ជនដែលកំណត់សមាសភាពខ្មាំងស្លាប់រស់របស់អង្គការគឺមានតែលេខាបក្ស ប៉ុល ពត តែម្នាក់គត់ ។*

*ក្រោយពីឈប់សម្រាកពេលរសៀល ភាគីមេធាវីការពារក្តីទាំងអស់បានលើកឡើងពីបញ្ហាថេរវេលាសម្រាប់ចោទសួរសាក្សីបន្ទាប់ពីភាគីមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ចប់ការសាកសួរសាក្សី ។ ដោយសារតែមានការខាតបង់ពេលវេលាដោយសារតែការស្ទះចរាចរណ៍កាលពីពេលព្រឹក ចៅក្រមបានអនុញ្ញាតឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីចោទសួរសាក្សីរយៈពេលពីរម៉ោងបន្ថែមទៀត ។ ជាកិច្ចបន្ទាប់ មេធាវី លីម៉ា ង្វៀន បានសួរ ឌុច ថាតើ សុន សេន បានបង្ខំឲ្យគាត់ទាញយកចម្លើយសារភាពពី សេ.អ៊ី.អា នៅឆ្នាំណា ។ ឌុច បានគូសបញ្ជាក់ថា សុន សេន បានចេញបញ្ជាដូច្នេះនៅខែធ្នូឆ្នាំ១៩៧៥ មុនពេលដែលគាត់រៀបការ ។ ខណៈពេលដែលមេធាវីបានសួរថាតើការបង្គាប់ដូច្នេះគឺជាការគាបសង្កត់ដែរឬយ៉ាងណានោះ ឌុច បាននិយាយថា "គ្មាននរណាម្នាក់អាចបដិសេធបញ្ជារបស់អង្គការបានឡើយ ។ ម្នាក់ៗត្រូវតែគោរពតាមបញ្ជារបស់ថ្នាក់លើ" ។ ទាក់ទងនឹងបញ្ជីឈ្មោះអ្នកទោសដែលត្រូវបានធ្វើទារុណកម្ម និងសម្លាប់ ឌុច បានគូសបញ្ជាក់ថា ក្នុងបញ្ជីនេះមានជនបរទេសអាយុប្រមាណ២៩ឆ្នាំចំនួនពីរនាក់ដែលត្រូវបានធ្វើទារុណកម្មនិងសម្លាប់ ។ គាត់មិនប្រាកដថាបានជួបជនបរទេសទាំងពីរនាក់នេះឡើយ ។ ដើម្បីទាញយកចម្លើយសារភាពពីជនបរទេសទាំងពីរនាក់នេះទាមទារឲ្យមានអ្នកបកប្រែជំនាញ ។ ដូច្នេះអ្នកទោសជនជាតិខ្មែរដែលចេះភាសាអង់គ្លេសយ៉ាងស្ទាត់ជំនាញត្រូវបានចាត់តាំងជាអ្នកបកប្រែសម្រាប់ការសួរចម្លើយជនបរទេសទាំងពីរនាក់នេះ ។*

### សក្ខីកម្មថ្ងៃទីប្រាំបួន (ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១២)

#### សវនាការពេលព្រឹក

*នាព្រឹកនេះ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី លីម៉ា ង្វៀន បានបន្តសួរសំណួរ ឌុច ពាក់ព័ន្ធពីអ្នកទោសជនបរទេសដែលត្រូវបានបញ្ជូនមកមន្ទីរស-២១ ។ ឌុច បានបញ្ជាក់ថា គាត់ចាំបានតែជនបរទេសបួននាក់ដែលត្រូវបានចាប់ខ្លួនមកមន្ទីរស-២១តែប៉ុណ្ណោះ ។ ជនបរទេសទាំងនេះត្រូវបានអ្នកសួរចម្លើយបង្ខំឲ្យហូបផ្លែឈើពុល ។ បន្ទាប់មកទៀត មេធាវី បានសួរគាត់ថាតើអ្នកបកប្រែគឺជាអ្នកសរសេរចម្លើយសារភាពរបស់ជនបរទេសទាំងនេះជាភាសាខ្មែរឬ ។ ឌុច បានឆ្លើយតបថា អ្នកបកប្រែមានវត្តមានរហូតក្នុងអំឡុងពេលសួរចម្លើយជនបរទេសទាំងនេះ ។ សម្រាប់ចម្លើយសារភាពជាភាសាអង់គ្លេសជនបរទេសទាំងនេះត្រូវតែសរសេរដោយខ្លួនឯង ។ សម្រាប់ចម្លើយសារភាពជាភាសាខ្មែរអ្នកសួរចម្លើយគឺជាអ្នកសរសេរដោយទទួលបានការបកប្រែជាភាសាខ្មែរពីអ្នកបកប្រែ ។ ទាក់ទងនឹងចម្លើយសារភាព ឌុច បានអះអាងថា គាត់មិនដែល*

បានកំណត់ថាចម្លើយសារភាពរបស់អ្នកទោសណាមួយខុសឬត្រូវទេ ។ ជាទូទៅថ្នាក់លើរបស់គាត់គឺជាអ្នកសម្រេចថាតើចម្លើយសារភាពមួយណាត្រូវមួយណាខុស ។ រាល់ចម្លើយសារភាពទាំងអស់ត្រូវបានបញ្ជូនទៅឲ្យ សុន សេន ឬ នួន ជា ហើយបន្ទាប់មកគណៈមជ្ឈិមនឹងសម្រេចថាតើគួរធ្វើយ៉ាងណាចំពោះអ្នកទោស ។ មេធាវី លីម៉ា ង្វៀន បានសួរ ឌុច ថាតើចម្លើយសារភាពរបស់អ្នកទោសពិសេសត្រូវបានយកមកប្រើប្រាស់ក្នុងយុទ្ធនាការឃោសនាដែរឬទេ ។ ឌុច បានអះអាងថា ប៉ុល ពត បានប្រើប្រាស់ចម្លើយសារភាពរបស់អ្នកទោសធ្វើជាការឃោសនា ។ ពាក់ព័ន្ធនឹងឯកសារដែលមានចំណងជើងថា «គម្រោងរួមចុងក្រោយ» ចុះកាលពីថ្ងៃទី១១ កក្កដា ឆ្នាំ១៩៧៧ ឯកសារនេះត្រូវបានរៀបរៀងឡើងក្រោយពេលដែល សុន សេន បានបង្គាប់ឲ្យ ឌុច សរុបចំនួនអ្នកទោសនិងរៀបរាប់ពីខ្សែបណ្តាញរបស់ខ្មាំងនៅមន្ទីរស-២១ ។ ឌុច បានបង្គាប់ឲ្យសមមិត្ត ប៉ុន សរសេរអត្ថបទនេះ ។ ប៉ុន្តែក្រោយពី សុន សេន ធ្វើដំណើរទៅអ្នកលឿងគ្មាននរណាម្នាក់ពិភាក្សាពីឯកសារនេះទៀតឡើយ ។ ដោយសារពេលវេលាកាន់តែខិត មេធាវី លីម៉ា ង្វៀន បានងាកមកសួរ ឌុច ពាក់ព័ន្ធនឹង នួន ជា ។ ឆ្លើយតបនឹងសំណួរថាតើ នួន ជា ពិតជាបានបង្គាប់ឲ្យគាត់ថតចម្លើយសារភាពរបស់ឈ្លើយសឹកចំនួនពីរនាក់ជាសំឡេងក្នុងមួយសប្តាហ៍មុនដើម្បីផ្សាយតាមវិទ្យុ ឌុច បាននិយាយថាកាលពីថ្ងៃទី ៨ ខែមករា ឆ្នាំ១៩៧៨ នួន ជា បានបង្គាប់ឲ្យគាត់ថតចម្លើយសារភាពរបស់ឈ្លើយសឹកវៀតណាមម្នាក់ជាសំឡេងដើម្បីចាក់



នួន ជា និង មេធាវីជាតិ សុន អរុណ (រូបថត៖ អ.វ.ត.ក)

ផ្សាយតាមវិទ្យុ ។ ទាក់ទងនឹងការប្រព្រឹត្តអំពើផ្សេងៗលើជនជាតិវៀតណាម ឌុច បានអះអាងថា បក្សកុម្មុយនីស្តកម្ពុជាមិនដែលចាត់ទុកជនជាតិវៀតណាមរស់នៅក្នុងប្រទេសកម្ពុជាជាជនជាតិភាគតិចទេ ប៉ុន្តែបានចាត់ទុកជនជាតិចាមជាជនជាតិភាគតិច ហើយបានជម្លៀសប្រជាជនទាំងអស់នេះដើម្បីធានាថា ជនជាតិចាមបោះបង់ចោលអត្តសញ្ញាណនិងសាសនារបស់ខ្លួន ។ មេធាវី លីម៉ា ង្វៀន បានលើកឡើងពីគោលនយោបាយ សាសនារបស់បក្សកុម្មុយនីស្តកម្ពុជាដោយដកស្រង់រដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យទាក់ទងនឹង«សាសនាប្រតិកិរិយា» ។ ឌុច បានរៀបរាប់ថា «សាសនាព្រះពុទ្ធ និងសាសនាអ៊ីស្លាម» មិនមែនជាសាសនាប្រតិកិរិយាទេ លើកលែងតែសាសនាគ្រឹស្តដែលខ្មែរក្រហមចាត់ទុកជាសាសនាប្រតិកិរិយា ។

ខណៈពេលដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីអស់ពេលសួរសាក្សី ភាគីសហព្រះរាជអាជ្ញាបានលើកឡើងពីបញ្ហានីតិវិធីដាក់ឯកសារធ្វើជាភស្តុតាង ។ ក្រោយពីមានការតស៊ូមតិគ្នារវាងគ្រប់ភាគីទាំងអស់ ចៅក្រមត្រូវការពេលវេលាសមរម្យមួយដើម្បីចេញសេចក្តីសម្រេច ។

ជាកិច្ចបន្ទាប់ ចៅក្រម ហ្សង់ម៉ាក ឡាវេញ៉ូ ចាប់ផ្តើមចោទសួរសាក្សី ឌុច ។ ចៅក្រមបានសួរ ឌុច ពីខ្មាំងទាំងបីប្រភេទរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយថាតើបក្សកុម្មុយនីស្តកម្ពុជាមានគោលការណ៍ទាក់ទាញខ្មាំងឲ្យចូលបម្រើបដិវត្តន៍ដែរឬទេ ។ ឌុច បានអះអាងថា មិនមានការរើសអើងក្នុងចំណោមខ្មាំងទាំងបីប្រភេទនេះឡើយ ។ មានន័យថាខ្មាំងទាំងអស់ត្រូវតែសម្លាប់ ។ ឧទាហរណ៍ រាជវង្សានុវង្សត្រូវបានបញ្ជូនទៅតំបន់រំដោះជាមុនសិនមុននិងសម្លាប់ ។ ឌុច ក៏បានបញ្ជាក់ថា បក្សកុម្មុយនីស្តកម្ពុជាគ្មានគោលការណ៍យកខ្មាំងមកឲ្យបម្រើបដិវត្តន៍ទេ ។ ឆ្លើយតបនឹងសំណួរថាតើមានរឿងអ្វីកើតឡើងចំពោះប្រជាជនសាមញ្ញដែលភៀសខ្លួនមកតំបន់រំដោះខ្មែរក្រហម ឌុច បានអះអាងថា ប្រជាជនដែលភៀសខ្លួនចេញពីតំបន់ខ្មាំងមកតំបន់រំដោះរបស់ខ្មែរក្រហមត្រូវបានចាត់ទុកថាជាខ្មាំង ។ ចៅក្រមបានសួរ ឌុច បន្ថែមទាក់ទងនឹងគោលនយោបាយរបស់ខ្មែរក្រហមក្នុងការទាក់ទាញអ្នកបដិវត្តន៍ថាតើមានការអះអាងថា អ្នកដែលចូលបម្រើបដិវត្តន៍នឹងទទួលបាន

របបអាហារគ្រប់គ្រាន់ដែរឬទេ ។ ឌុច បានអះអាងថា ការសន្យាបែបនេះធ្វើឡើងដើម្បីទាក់ទាញមនុស្សឲ្យចូលបម្រើបដិវត្តន៍តែប៉ុណ្ណោះ ប៉ុន្តែជាក់ស្តែងប្រជាជនថ្មីដែលចូលបម្រើបដិវត្តន៍ទាំងអស់មិនទទួលបានរបបអាហារគ្រប់គ្រាន់ឡើយ ។ បន្ទាប់មកទៀត ចៅក្រមបានសួរពីបញ្ហាជម្លៀសប្រជាជននៅអមលាំងកាលពីឆ្នាំ ១៩៧៤ ។ ឌុច បានសង្កត់ធ្ងន់ថា ប្រជាជនភាគច្រើនត្រូវបានបញ្ជូនទៅខេត្តពោធិ៍សាត់ ប៉ុន្តែគាត់មិនបានដឹងពីដំណើរការជម្លៀសប្រជាជននេះទេ ប៉ុន្តែប្អូនថ្លៃប្រុសរបស់គាត់គឺជាអ្នកចាត់ចែង ។ ទាក់ទងនឹងការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញវិញ ឌុច បាននិយាយថា មានអ្នកទីក្រុងជាច្រើននាក់បានមកដល់អមលាំង ។ ពេលមកដល់ អ្នកទីក្រុងត្រូវតែប្រាប់ពីប្រវត្តិរូបនិងមុខរបររបស់ខ្លួន ។

## សវនាការពេលរសៀល

ក្រោយពីឈប់សម្រាកអាហារថ្ងៃត្រង់ ចៅក្រម ហ្សង់ម៉ាក ឡាវេរ៉ាញ់ បានបន្តសួរសំណួរឲ្យ ឌុច បកស្រាយ ។ ចៅក្រមបានដាក់បង្ហាញឯកសារសរសេរដោយដៃរបស់ ម៉ម ណៃ ដែលជាបុគ្គលិកមន្ទីរស-២១ ។ ឌុច បានអះអាងថា ម៉ម ណៃ បានសរសេរចំណារនេះក្នុងអំឡុងពេលទទួលវគ្គបណ្តុះបណ្តាល ។ ចំណារនោះបានរៀបរាប់ពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាពីការហាមឃាត់សេចក្តីស្រឡាញ់រវាងឪពុកម្តាយនិងកូន និងរវាងប្តីប្រពន្ធដែលប៉ះពាល់ដល់ការបំពេញកាតព្វកិច្ចបម្រើជាតិ ។ បន្ថែមលើនោះ បក្សកុម្មុយនីស្តកម្ពុជាមានគោលនយោបាយលុបបំបាត់ស្នេហាប្រុសស្រី ។ ឌុច បានបញ្ជាក់ថា នួន ជា បានចាប់ខ្លួនក្មួយរបស់ខ្លួនដោយសារបញ្ហាខាងលើនេះ ។ ឌុច បានអះអាងថា ឪពុកម្តាយមិនសមនឹងទទួលបានការគោរពពីកូនទេ ក្រៅពីអង្គការ ។ ដោយឡែកគាត់បានជម្រាបអង្គជំនុំជម្រះថា សមាជិកគ្រួសាររបស់ នួន ជា ចំនួនបួននាក់ត្រូវបានចាប់ខ្លួនដែលក្នុងនោះរួមមានក្មួយស្រីចំនួនពីរនាក់និងក្មួយប្រុសថ្លៃចំនួនពីរនាក់ ។ ក្មួយស្រីរបស់ នួន ជា គឺជាគ្រូពេទ្យដែលបានបញ្ចប់ការសិក្សាពីប្រទេសចិន ហើយក្មួយស្រីម្នាក់បានចូលបម្រើការនៅក្រសួងការបរទេស ។ ឌុច បានបញ្ជាក់ថា តាមគោលការណ៍មានតែ ប៉ុល ពត និង នួន ជា តែប៉ុណ្ណោះជាអ្នកមានសិទ្ធិអំណាចចេញបញ្ជាឲ្យចាប់ខ្លួនសមាជិកគ្រួសាររបស់សមាជិកគណៈមជ្ឈិម ។ ក្រោយមកទៀត ចៅក្រមបានសួរថាតើ ឌុច បានលុបឈ្មោះមនុស្សជាប់ពាក់ព័ន្ធនឹងអ្នកទោសចេញពីចម្លើយសារភាពចំនួនប៉ុន្មានលើក ។ ឌុច បានរៀបរាប់ថា ការលុបឈ្មោះមនុស្សចេញពីចម្លើយសារភាពគឺកម្រកើតមានណាស់ ។ ខណៈពេលនេះ លោកប្រធានចៅក្រម និល ណុន បានសួរ ឌុច បន្ថែមពីរចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ឌុច បានឆ្លើយតបថាក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានក្រសួងចំនួនបួនមន្ទីរនិងគណៈកម្មាធិការផ្សេងៗទៀត ។ ក្រសួងមានតួនាទីដឹកនាំក្នុងថ្នាក់ជាតិ ។ ចំណែកឯមន្ទីរ និងគណៈកម្មាធិការមានតួនាទីដឹកនាំក្នុងថ្នាក់តំបន់ ។

ក្រោយពីឈប់សម្រាកពេលរសៀល វេទិកាសួរសាក្សី ឌុច ត្រូវបានប្រគល់ឲ្យមេធាវីអន្តរជាតិការពារក្តី នួន ជា គឺ ម៉ៃឃើល ផេស្តមេន ដើម្បីផ្ទៀងផ្ទាត់សក្ខីកម្មរបស់ ឌុច ប្រឆាំងនឹងកូនក្តីរបស់ខ្លួន ។ មេធាវីការពារក្តីអន្តរជាតិបានចោទសួរថាតើ ឌុច បាននិយាយពីការពិតដែរឬទេ ។ ឌុច បានឆ្លើយតបវិញថា “អ្វីៗគឺអាស្រ័យលើការវិនិច្ឆ័យរបស់លោកមេធាវីទេ ។ ខ្ញុំមិនអាចកំណត់បានដោយឯកឯងឡើយ” ។ បន្ថែមលើនេះ មេធាវីបានសួរថាតើ ឌុច មានបានធ្វើទារុណកម្មអ្នកទោសនៅមន្ទីរម-១៣ដែរឬទេ ។ ឌុច បានបដិសេធមិនឆ្លើយតប ។ ប៉ុន្តែឆ្លើយតប នឹងសំណួរទាក់ទងនឹងការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកនៅមន្ទីរម-១៣ ឌុច បានរៀបរាប់ថា បុគ្គលិក និងអ្នកទោសនៅមន្ទីរម-១៣ត្រូវតែពួនក្នុងរណ្តៅដើម្បីរត់គេចពីគ្រាប់ ហើយថាគាត់មិនបានដឹងពីផលប៉ះពាល់នៃការទម្លាក់គ្រាប់បែកនេះទេ ។ ប៉ុន្តែគាត់បានបញ្ជាក់ថា ការទម្លាក់គ្រាប់បែកនេះបានបង្កើនចំនួនអ្នកទោសនៅមន្ទីរម-១៣ ។

មេធាវីបានសួរថាតើ ឌុច ធ្លាប់បានធ្វើទារុណកម្មអ្នកទោសនៅមន្ទីរស-២១ដែរឬយ៉ាងណា ។ ឌុច បាននិយាយថាធ្លាប់បានទះកំភ្លៀងអ្នកទោសពីរបីដងដែរ ខណៈពេលដែលអ្នកទោសមិនព្រមផ្តល់ចម្លើយសារភាព ។ បន្ទាប់មកទៀត មេធាវីបានសួរថាតើ ឌុច ធ្លាប់បានឃើញការធ្វើទារុណកម្មអ្នកទោសនៅមន្ទីរស-២១ដែរឬទេ ។ ឌុច បាននិយាយថា គាត់មិនធ្លាប់ឃើញការធ្វើទារុណកម្មទេ ប៉ុន្តែបានចូលត្រួតពិនិត្យមើលការបកប្រែរបស់អ្នកទោសជនបរទេស ។

## សក្ខីកម្មថ្ងៃទីដប់ (ថ្ងៃទី៤ ខែមេសា ឆ្នាំ២០១២)

### សវនាការពេលព្រឹក

នាព្រឹកថ្ងៃពុធ ទី៤ ខែមេសា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបន្តដំណើរការនីតិវិធីសាកសួរសាក្សី ឌុច ។ មុននឹងមេធាវីការពារក្តីអន្តរជាតិ ម៉ៃឃើល ផេស្តមេន សួរ ឌុច ចៅក្រមបានចេញសេចក្តីសម្រេចលើបញ្ហាសិទ្ធិរបស់សាក្សីនិងជនជាប់ចោទក្នុងការមិនឆ្លើយតប ។ បន្ទាប់មកទៀត ខណៈពេលដែលមេធាវីការពារក្តីអន្តរជាតិសួរថាតើ ឌុច មានចាំអ្នកទោសម្នាក់ឈ្មោះ ណាប ស៊ុនប៊ុន នោះ ឌុច បានឆ្លើយថាចាំ ។ មេធាវីក៏បានដកស្រង់ចំណាររបស់ ឌុច នៅលើចម្លើយសារភាពរបស់អ្នកទោសនេះដែលមានខ្លឹមសារដូចតទៅ “ខ្ញុំបានចំណាយពេលជាងមួយខែដើម្បីសម្រេចក្នុងការធ្វើទារុណកម្មវាយដំ និងសួរចម្លើយអ្នកទោសរូបនេះ ។ ខ្ញុំបានខិតខំប្រឹងប្រែងអស់ពីសមត្ថភាពហើយ” ។ ក្រោយមកទៀត មេធាវីការពារក្តីក៏បានសួរ ឌុច ពីអ្នកទោសឈ្មោះ ហ្វ្រង់ស្វ័រ ប៊ីហ្សូត ដែលបានសរសេររៀបរាប់ពីបទពិសោធន៍ផ្ទាល់ខ្លួននៅមន្ទីរម-១៣ ។ នៅក្នុងសៀវភៅនោះមានសរសេរថា ឌុច បានវាយអ្នកទោសម្នាក់រហូតដល់សន្លប់ ។ ឌុច បានបញ្ជាក់ថា សៀវភៅនេះបានរៀបរៀងឡើងជាលក្ខណៈសៀវភៅប្រលោមលោកហើយព័ត៌មានភាគច្រើនគឺជាការប្រឌិត ។ ក្រោយពីមានការតស៊ូមតិគ្នាពីបញ្ហានីតិវិធីបន្តិចបន្តួចមក មេធាវីការពារក្តីអន្តរជាតិបានសួរពីមូលហេតុដែល ឌុច បានឆ្លើយប្រាប់សហចៅក្រមស៊ើបអង្កេតថា គាត់មិនបានដឹងពីពាក្យ “ក្រុមក្តៅ ក្រុមត្រជាក់ និងក្រុមអង្គាម” ទេ រហូតដល់ពេលគាត់បានមើលខ្សែភាពយន្តឯកសារនៅមន្ទីរស-២១ ។ មុននឹងឆ្លើយតប ឌុច បានស្នើសុំឲ្យមេធាវីដាក់បង្ហាញឯកសារនោះ ។ ប៉ុន្តែ មេធាវីការពារក្តីអន្តរជាតិបានអះអាងថា ឯកសារនេះត្រូវបានដាក់បង្ហាញលើអេក្រង់កុំព្យូទ័ររួចម្តងហើយហើយថាមានឯកសារជាច្រើនដែលនឹងត្រូវដាក់បង្ហាញក្នុងថ្ងៃនេះ ។ ឌុច បាននិយាយថា “មេធាវីការពារក្តីគួរតែធ្វើការឲ្យបានហ្មត់ចត់ជាងនេះពីព្រោះថា មេធាវីកំពុងតែសួរខ្ញុំពីព្រឹត្តិការណ៍ដែលបានកើតឡើងកាលពីសាមសិបឆ្នាំមុន ។ ដូច្នេះ វាមិនទំនងទាល់តែសោះដែលលោកមេធាវីដកស្រង់តែពាក្យពីរបីឃ្លាមកចោទសួរខ្ញុំ” ។ ទោះជាយ៉ាងណាក្តី មេធាវី ម៉ៃឃើល ផេស្តមេន នៅតែទទូចឲ្យ ឌុច ឆ្លើយនឹងសំណួររបស់ខ្លួន ។ ប៉ុន្តែ ឌុច បាននិយាយថា “ខ្ញុំមិនបាននិយាយកុហកទេ ។ ខ្ញុំ ជាមនុស្សស្មោះត្រង់ម្នាក់ ។ ប៉ុន្តែការសួរសំណួររបស់លោកមេធាវីវិញទេដែលមិនស្មោះត្រង់” ។ ក្រោយពីមានការសម្របសម្រួលពីសំណាក់ចៅក្រម ឌុច បានឆ្លើយតបថា សហចៅក្រមស៊ើបអង្កេតបានចោទសួរ ឌុច ពីពាក្យទាំងបីឃ្លាខាងលើនេះ ។ ឌុច បាននិយាយថា “ខ្ញុំបានព្យាយាមបំភ្លេចអតីតកាលជូរចត់កាលពីមុនទេ” ។ ប៉ុន្តែ ក្រោយមក ឌុច ក៏បានឮពាក្យបីឃ្លានេះសារជាថ្មីម្តងទៀតនៅពេលដែលគាត់បានតាមដានខ្សែភាពយន្តឯកសារមួយ ។

ក្រោយពីឈប់សម្រាកពេលព្រឹក មេធាវី ម៉ៃឃើល ផេស្តមេន បានសួរ ឌុច ថាតើធ្លាប់បានធ្វើទារុណកម្មអ្នកទោសនៅមន្ទីរស-២១ ដែរឬទេ ។ ឌុច បានអះអាងថា គាត់មិនដែលបានធ្វើទារុណកម្មអ្នកទោសណាម្នាក់ក្រៅពីបានទះកំភ្លៀងអ្នកទោសម្នាក់តែប៉ុណ្ណោះ ។ បន្ទាប់មកទៀត មេធាវីបានដកស្រង់សម្តីរបស់ ឌុច ឆ្លើយតបនឹងសំណួររបស់តុលាការយោធាកម្ពុជាកាលពីឆ្នាំ១៩៩៩ពីការសួរចម្លើយ កុយធួន ។ កាលណោះ ឌុច បាននិយាយថា គាត់បានសួរចម្លើយ កុយ ធួន ។ ផ្អែកលើអំណះអំណាងនេះ មេធាវីបានសួរថាតើ ឌុច ពិតជាបានសួរចម្លើយ កុយ ធួន មែនដែរឬទេ ។ ឌុច បានបញ្ជាក់ថា គាត់បានគ្រាន់តែបានបញ្ជូនសំបុត្រពី សុន សេន ទៅឲ្យ កុយ ធួន ដើម្បីជំរុញឲ្យ កុយ ធួន ឆ្លើយសារភាពតែប៉ុណ្ណោះ ។ ខណៈពេលដែលមេធាវីបានដាក់បង្ហាញបទសម្ភាសន៍ដ៏វែងមួយរបស់ ឌុច ជាមួយនឹងអ្នកសារព័ត៌មាន គ្រីស្ទហ្វឺ ពេហ្សូត ក្នុងគោលបំណងទាញយកការគូសបញ្ជាក់មួយចំនួនពី ឌុច នោះ ឌុច បានបដិសេធមិនឆ្លើយនឹងសំណួររបស់មេធាវី ដោយអះអាងថា ឯកសារនេះគឺជាឯកសារថតចម្លង ។ ទោះជាយ៉ាងណាក្តី មេធាវីបានបង្ខំឲ្យ ឌុច អានខ្លឹមសារអត្ថបទឯកសារនេះ ។ ប៉ុន្តែ ឌុច បានបដិសេធមិនអានខ្លឹមសារនេះ ។

### សវនាការពេលរសៀល

ក្រោយពីឈប់សម្រាកអាហារថ្ងៃត្រង់ មេធាវីការពារក្តីអន្តរជាតិរបស់ នួន ជា បានសួរ ឌុច ពីវិធីសាស្ត្រសួរចម្លើយបីប្រភេទរបស់មន្ទីរស-២១ ហើយសួរថាតើក្នុងករណីណាដែលវិធីសាស្ត្រសួរចម្លើយអង្គាមត្រូវតែអនុវត្ត ។ ឌុច បានឆ្លើយថា “នៅ

ពេលដែលអ្នកទោសមិនព្រមឆ្លើយ» ។ កុយធួន ត្រូវបានធ្វើទារុណកម្មដោយសារតែគាត់ប្រកែកមិនព្រមឆ្លើយ ។ កុយ ធួន ត្រូវបានឃុំខ្លួននៅក្នុងអគារដាន់ទីបួនដោយមានអ្នកយាមតាមដាន ។ ទាក់ទងនឹងវិធីសាស្ត្រ សួរចម្លើយក្តៅ ឌុច បានបញ្ជាក់ថា វិធីសាស្ត្រនេះត្រូវបានប្រើប្រាស់ដើម្បីដឹងពីអ្នកទោសនិយាយកុហកឬនិយាយការពិត ។ ខណៈពេលដែលមេធាវីការពារក្តីបានចោទសួរថាហេតុអ្វីបានជាគាត់ប្រាប់សហចៅក្រមស៊ើបអង្កេតថាខ្លួនមិនធ្លាប់ពាក្យ "ក្រុមក្តៅ ក្រុមត្រជាក់ និងក្រុមអង្គាម" នោះ ឌុច បាននិយាយថារយៈពេលសាមសិបឆ្នាំបានកន្លងផុតទៅហើយ ដូច្នេះ គាត់ក៏មានការភ្លេចភ្លាំងចំពោះរឿងរ៉ាវដែលបានកើតឡើងនៅមន្ទីរស-២១ ។ បន្ទាប់មកទៀត មេធាវីបានដាក់បង្ហាញចម្លើយសារភាពមួយច្បាប់ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ។ ឌុច បានរៀបរាប់ថា នៅក្នុងចម្លើយសារភាពនេះមានកំណត់ត្រារបស់គាត់ផ្ញើជូនចំពោះសមមិត្តបងដែលសំដៅទៅលើ នួន ជា ។ មេធាវីក៏បានដាក់បង្ហាញចម្លើយសារភាពមួយទៀតដោយឲ្យ ឌុច គូសបញ្ជាក់ពីចំណារនៅលើចម្លើយសារភាពនោះ ។ ក្រោយពីបានអានចំណារនោះ ឌុច បានជម្រាបអង្គជំនុំជម្រះថា ចំណារនោះគឺជាចំណាររបស់ នួន ជា ។ មេធាវីបានអះអាងថា ឌុច មិនបានជម្រាបសហចៅក្រមស៊ើបអង្កេតដូច្នេះទេ នៅពេលដែលសហចៅក្រមស៊ើបអង្កេតបានសាកសួរ ឌុច ។ ឌុច បានសង្កត់ធ្ងន់ប្រាប់មេធាវីថាដោយសារតែគាត់មិនសូវយល់នឹងសំណួរនោះ ។ បន្ទាប់មកទៀត មេធាវីក៏បានដាក់បង្ហាញឯកសារមួយទៀតដើម្បីសួរ ឌុច ។ មេធាវីបានសួរថាតើ ឌុច បានស្គាល់ឯកសារនេះដែរឬទេហើយបានបង្គាប់ឲ្យគាត់អានឃ្លាមួយដែលសរសេរថា "ជូនបងជាទីគោរព" ដោយចុះកាលបរិច្ឆេទខាងលើពីថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៧៧ ។ ដោយសារតែកាលបរិច្ឆេទ ឌុច បានឆ្លើយតបថា សំបុត្រនេះត្រូវបានផ្ញើជូនបង នួន ។ មេធាវីបានបង្គាប់ឲ្យ ឌុច អានចំណារមួយទៀតដែលមាននៅលើចម្លើយសារភាពរបស់ អ្នកទោសម្នាក់ទៀត ចុះកាលពីថ្ងៃទី១៧ខែ តុលា ឆ្នាំ១៩៧៧ ។ ឌុច បានអះអាងថា ចំណារនោះត្រូវបានសរសេរដោយ សុន សេន ហើយបញ្ជូនទៅ នួន ជា ។ រាល់ចម្លើយសារភាពត្រូវបានបញ្ជូនទៅឲ្យថ្នាក់លើ ហើយចម្លើយសារភាពទាំងនោះមិនត្រូវបានបញ្ជូនមកវិញឡើយ ។ ក្រោយពីលប់សម្រាកពេលរសៀល មេធាវី ម៉ៃឃើល ផេស្តមេន បានដាក់បង្ហាញចម្លើយសារភាពមួយចំនួនបន្ថែមទៀតដែលមានចំណាររបស់ ឌុច នៅលើនោះ ។ មេធាវីបានសួរគាត់ថា តើចម្លើយសារភាពមួយចុះកាលពីថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៧៧ដែលមានសរសេរថា "ជូនចំពោះបងជាទីគោរព" នោះត្រូវបានផ្ញើឲ្យនរណា ។ ឌុច បាននិយាយថា ចម្លើយសារភាពនោះគឺផ្ញើទៅឲ្យ នួន ជា ។ ឌុច ក៏ត្រូវបានមេធាវីបង្គាប់ឲ្យអានចំណារលើចម្លើយសារភាពមួយទៀតដែលសរសេរដោយ សុន សេន ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ។ មេធាវីបានសួរ ឌុច ថាហេតុអ្វីបានជាចម្លើយសារភាពនេះមានឈ្មោះ សុន សេន ទៅវិញ បើកាលនោះ សុន សេន ត្រូវផ្លាស់ទៅកាន់ខាងតំបន់ហើយនោះ ឌុច បាននិយាយថា ក្រោយពេលដែល សុន សេន ចាកចេញទៅគាត់នៅតែទាក់ទងជាមួយនឹង សុន សេន មួយខែម្តង ។ ក្រោយមកទៀត មេធាវីបានដាក់បង្ហាញឯកសារមួយទៀតចុះកាលពីថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ហើយបានបង្គាប់ឲ្យ ឌុច ធ្វើការបកស្រាយ ។ ឌុច បានអះអាងថា នេះគឺជាសំបុត្ររបស់ សុន សេន ផ្ញើមកកាន់គាត់កាលពីចុងឆ្នាំ១៩៧៧ណែនាំឲ្យគាត់ទាញយកចម្លើយសារភាពពីអ្នកទោសដោយប្រុងប្រយ័ត្នជាងមុន ។ មេធាវីបានសួរ ឌុច ថាតើហេតុអ្វីបានជា សុន សេន ជាអ្នកសរសេរសំបុត្រនេះ


ម៉ៃឃើល ផេស្តមេន មេធាវីអន្តរជាតិរបស់ នួន ជា

ទៅវិញ ។ ឌុច បានបញ្ជាក់ថា មូលហេតុគឺមុនពេល សុន សេន ផ្លាស់ទៅកាន់ខាងតំបន់គាត់បានសរសេរសំបុត្រនោះទៅឲ្យ សុន សេន ។ អាស្រ័យហេតុនេះ សុន សេន បានសរសេរឆ្លើយតបនឹងសំបុត្ររបស់ ឌុច វិញ ។ មេធាវីបានដាក់បង្ហាញឯកសារមួយទៀតចុះកាលពីថ្ងៃ ទី១៤ ខែតុលា ឆ្នាំ១៩៧៧ដែល ឌុច បានអះអាងថា ចំណារលើឯកសារនោះគឺជាចំណាររបស់ នួន ជា ។ ប៉ុន្តែឆ្លើយតបនឹងសំណួររបស់សហចៅក្រមស៊ើបអង្កេតកាលពីប៉ុន្មានឆ្នាំមុន ឌុច បាននិយាយថា ចំណារនោះ គឺជាចំណាររបស់ សុន សេន ។ ជាការឆ្លើយតបបញ្ជាក់សារជាថ្មី ឌុច បានអះអាងថា ចំណារនោះគឺពិតជាចំណាររបស់សុន សេន មែន ។ មេធាវីការពារក្តីបានចោទសួរថា តើ ឌុច មានការភ័ន្តច្រឡំលើចំណារនោះមែនដែរឬទេ ។ ឌុច បានឆ្លើយថា "មែន" ។ ពេលឆ្លើយតបនឹងសំណួររបស់សហចៅក្រមស៊ើបអង្កេត ឌុច បានធ្វើការប៉ាន់ស្មានតែប៉ុណ្ណោះ ហើយក្នុងខណៈពេលនេះ ឌុច ក៏កំពុងតែធ្វើការប៉ាន់ស្មានលើចំណារនេះសារជាថ្មីម្តងទៀតដដែល ។ នៅក្នុងទំព័រមួយនៃឯកសារនេះមានសរសេរថា "សម្ងាត់" ។ ទាក់ទងនឹងបញ្ហានេះ ឌុច បានរៀបរាប់ចំពោះមុខអង្គជំនុំជម្រះថា ឯកសារសម្ងាត់នេះគឺត្រូវបានបញ្ជូនទៅឲ្យ ប៉ុល ពត ដោយមានចំណាររបស់ សុន សេន ។ មេធាវី ម៉ៃឃើល ផេស្តមេន បានសង្កត់ធ្ងន់ថា ចម្លើយសារភាពមួយនេះត្រូវបានបញ្ជូនពី ឌុច ទៅកាន់ សុន សេន ហើយពី សុន សេន ទៅកាន់ ប៉ុល ពត ។ បន្ទាប់មកទៀត មេធាវីបានដាក់បង្ហាញចម្លើយសារភាពមួយទៀតដែលសរសេរដោយ ឌុច ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ។ ឌុច បានបញ្ជាក់ថា ពាក្យ "ជូនចំពោះបងជាទីស្រឡាញ់" នេះគឺសំដៅលើបង នួន ឬ នួន ជា ។

### សក្ខីកម្មថ្ងៃទីដប់មួយ (ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១២)

#### សវនាការពេលព្រឹក

នាព្រឹកថ្ងៃព្រហស្បតិ៍ទី៥ ខែមេសា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបន្តដំណើរការនីតិវិធីរបស់ខ្លួនដោយសាកសួរសាក្សី ឌុច ទាក់ទងនឹងរចនាសម្ព័ន្ធកិច្ចការរដ្ឋបាលនៃរបបកម្ពុជាប្រជាធិបតេយ្យនិងទំនាក់ទំនង តួនាទី និងការទទួលខុសត្រូវរបស់ជនជាប់ចោទទាំងបីនាក់គឺ នួន ជា, ខៀវ សំផន និង អៀង សារី ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ នាព្រឹកនេះ មេធាវី ម៉ៃឃើល ផេស្តមេន បានបន្តចោទសួរសាក្សី ឌុច ដើម្បីបញ្ជាក់ពីភាពដែលអាចគួរឲ្យជឿជាក់បានលើសក្ខីកម្មដែលគាត់បានធ្វើកន្លងមក ។ មេធាវីបានឲ្យ ឌុច បកស្រាយខ្លឹមសារសំបុត្រដែលភ្ជាប់នឹងចម្លើយសារភាពមួយចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៨ ។ សំបុត្រនោះសរសេរថា "ផ្ញើជូនមន្ទីរ៨៧០" ។ ឌុច បានបញ្ជាក់ថា ឃ្លា "ផ្ញើជូនមន្ទីរ៨៧០" នេះមានន័យថា "ផ្ញើជូន ប៉ុល ពត" ពីព្រោះ ប៉ុល ពត គ្រប់គ្រងមន្ទីរ៨៧០នេះ ។ ឌុច បានអះអាងបន្ថែមទៀតថា ឃ្លា "ពិនិត្យរួចហើយ" នេះគឺសរសេរដោយ នួន ជា បើយោងតាមកាលបរិច្ឆេទអក្សររបស់ នួន ជា និងឃ្លា "ពិនិត្យរួចហើយ" ពីព្រោះ នួន ជា តែងតែសរសេរឃ្លានេះលើរាល់ឯកសារដែល នួន ជា បានអាន ។ យ៉ាងណាមិញ មេធាវីការពារក្តីបានលើកឡើងអំណះអំណាងរបស់ ឌុច ចំពោះមុខសហចៅក្រមស៊ើបអង្កេតដែលកាលណោះគាត់បាននិយាយថា "អក្សរនេះប្រហែលជាអក្សររបស់ នួន ជា បើតាមការស្មានរបស់ខ្ញុំ ពីព្រោះខ្ញុំមិនសូវបានឃើញអក្សររបស់ នួន ជា ប៉ុន្មានទេ ។ ឌុច បានឆ្លើយតបវិញថា គាត់បាននិយាយដូច្នោះដោយសារតែកាលណោះគាត់ មិនមានឯកសារផ្ទៀងផ្ទាត់គ្រប់គ្រាន់ ។ ប៉ុន្តែមេធាវីបានចោទប្រកាន់ថា ឌុច មិនស្គាល់អក្សររបស់ នួន ជា ច្បាស់លាស់ទេ ហើយផ្ទុយទៅវិញបែរជាសន្និដ្ឋានដោយផ្អែកលើកាលបរិច្ឆេទរបស់ឯកសារតែប៉ុណ្ណោះ ។ ខណៈពេលនេះមានការជំទាស់ពីភាគីមេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញាទាក់ទងនឹងការចោទប្រកាន់របស់មេធាវីការពារក្តី នួន ជា ចុងក្រោយបង្អស់ ចៅក្រមបានសម្រេចឲ្យ ឌុច លើកឡើងអំណះអំណាងរបស់ខ្លួនម្តងទៀតដើម្បីគូសបញ្ជាក់ថាតើចំណារលើចម្លើយសារភាពនោះគឺជាចំណាររបស់ នួន ជា មែនដែរឬយ៉ាងណា ។ ឌុច បានអះអាងថាអក្សរលើចម្លើយសារភាពនេះគឺពិតជាអក្សររបស់ នួន ជា ដោយផ្អែកលើមូលហេតុបីគឺ ៖ ១) មានតែថ្នាក់ដឹកនាំបីនាក់តែប៉ុណ្ណោះដែលអាចកត់ត្រាលើឯកសាររបស់មន្ទីរស-២១បាន ។ ២) សុន សេន ធ្វើការកត់ត្រាលើតែឯកសារដែលត្រូវតែបញ្ជូនឲ្យ នួន ជា ។ ៣) គាត់ធ្លាប់បានឃើញអក្សររបស់ នួន ជា ជាច្រើនលើកដែរ ។ ឌុច បានព្រលយពាក្យនិយាយថា "ខ្ញុំមិនទាន់ភ្លេចភ្លាំងវង្វេងស្មារតីទេ" ។ បន្ទាប់មក ទៀតមេធាវីបានអានឃ្លាមួយចេញពីឯកសារ

មួយដែលសរសេរថា "នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៧៧ នួន ជា បានមកគ្រប់គ្រងមន្ទីរស-២១" ហើយបានសួរបញ្ជាក់ពីកាលបរិច្ឆេទនេះ ។ ឌុច បានអះអាងថា តាមពិតទៅ នួន ជា មិនបានមកមន្ទីរស-២១ទេ ហើយថា នួន ជា បានគ្រប់គ្រងមន្ទីរស-២១ នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ ។ មេធាវីបានដកស្រង់អត្ថបទរបស់អ្នកសារព័ត៌មាន គ្រីស្ទូហ្វឺ ពេហ្សូត ដែលនិយាយថា នួន ជា បានមកគ្រប់គ្រងមន្ទីរស-២១នៅខែកក្កដា ឆ្នាំ១៩៧៧ ។ មេធាវីបានចោទសួរថាហេតុអ្វីបានជាកាលបរិច្ឆេទនេះខុសពីការអះអាងរបស់ ឌុច ដែលថា នួន ជា បានគ្រប់គ្រងមន្ទីរស-២១ នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ ។ ឌុច បានបញ្ជាក់ថា គាត់បានស្នើសុំបទសម្ភាសន៍ដែលគាត់បានធ្វើជាមួយនឹងលោក គ្រីស្ទូហ្វឺ យូរមកហើយ ប៉ុន្តែមិនដែលទទួលបានឡើយ ។ សារជាថ្មីម្តងទៀត មេធាវីបានចោទប្រកាន់ ឌុច ថា បានលើកឡើងនូវកាលបរិច្ឆេទមិនពិតចំពោះមុខអង្គជំនុំជម្រះ ។ ឌុច បានប្រកែកថា "ខ្ញុំមិនបាននិយាយអ្វីផ្សេងក្រៅពីនិយាយថា ខ្ញុំបានជួបបង នួន នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧តែប៉ុណ្ណោះ" ។ ទោះជាយ៉ាងណាក្តី មេធាវីបានអះអាងថា សុន សេន នៅតែដើរតួនាទីជាថ្នាក់លើរបស់ ឌុច ហើយថា គាត់មិនដែលទទួលបញ្ជាអ្វីពី នួន ជា ឡើយ ។ បន្ទាប់មកទៀត មេធាវីការពារក្តីអន្តរជាតិបានសួរ ឌុច ទាក់ទងនឹងការរំដោះទីក្រុងភ្នំពេញ ហើយសួរថាតើនរណាជាអ្នកគ្រប់គ្រងកងទ័ពបដិវត្តន៍កម្ពុជាទាំងអស់នៅឆ្នាំ១៩៧៥ ។ ឌុច បានគូសបញ្ជាក់ថា មានតែលេខាបក្សនិងអនុលេខាបក្សតែប៉ុណ្ណោះដែលមានអំណាចពេញទី ដោយឡែកកម្លាំងតាមតំបន់គឺគ្រប់គ្រងដោយលេខាតំបន់ ។ ឆ្លើយតបនឹងសំណួររបស់មេធាវីថាតើ ឌុច បានស្គាល់សម្តេច ហេង សំរិន មុនពេលរំដោះទីក្រុងភ្នំពេញដែរឬយ៉ាងណា គាត់បាននិយាយថា ហេង សំរិន ជាប្រធានកងពលធំ៣ភូមិភាគបូព៌ា ។

ក្រោយពីឈប់សម្រាកពេលព្រឹក មេធាវីការពារក្តីអន្តរជាតិ នួន ជា បានរំឭក ឌុច ពីអំណះអំណាងមួយចំនួនដូចជា ១) ក្នុងអំឡុងពេលសួរសាក្សី មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញឯកសារមួយចំនួនដែលបញ្ជាក់ថា សុន សេន បានបង្គាប់ ស៊ូ មេ៉ត ឲ្យសរសេរសំបុត្រមកឲ្យ ឌុច នៅឆ្នាំ១៩៧៧ ។ ២) ឌុច បាននិយាយថាសំបុត្រទាំងនោះមិនបានប្រគល់ឲ្យគាត់ផ្ទាល់ទេ ប៉ុន្តែ សុន សេន ជាអ្នកប្រគល់សំបុត្រទាំងនោះ ។ ៣) នៅក្នុងដីកាកាត់ទោស ឌុច ក្នុងសំណុំរឿង០០១ទេ អង្គជំនុំជម្រះសាលាដំបូងបានអះអាងថា ការបកស្រាយរបស់ ឌុច ពីសំបុត្រទាំងនេះ "មិនគួរឲ្យជឿជាក់បានទេ" ។ សហព្រះរាជអាជ្ញាបានជំទាស់នឹងការបញ្ចេញមតិបែបនេះ ហើយស្នើសុំឲ្យចៅក្រមធ្វើអន្តរាគមន៍ ។ ក្រោយពីចៅក្រមបង្គាប់មិនឲ្យ ឌុច បកស្រាយសេចក្តីអត្ថាធិប្បាយរបស់មេធាវីការពារក្តីមក មេធាវីបានចោទប្រកាន់ ឌុច បន្ថែមទៀតថា គាត់បានទម្លាក់កំហុសលើ នួន ជា សម្រាប់ឧក្រិដ្ឋកម្មដែលគាត់បានប្រព្រឹត្តនៅមន្ទីរស-២១ក្រោយពេលដែល សុន សេន បានផ្លាស់ទៅកាន់តំណែងខាងតំបន់វិញ ។ មេធាវី បាននិយាយទៅកាន់ ឌុច ថា "អ្នកឯងគឺជាមនុស្សនិយាយកុហក ហើយថែមទាំងប្រឌិតចម្លើយសារភាពទៀត" ។

## សវនាការពេលរសៀល

ក្រោយពីឈប់សម្រាកអាហារថ្ងៃត្រង់ មេធាវីការពារក្តីអន្តរជាតិ ចាស្តឺ ប៉ាវ៉ បានបន្តចោទសួរ ឌុច ។ ឆ្លើយតបនឹងសំណួររបស់មេធាវី ឌុច បាននិយាយថា ឌុច មិនបានចូលរួមក្នុងអង្គប្រជុំជាមួយគណៈមជ្ឈិម នៅចន្លោះឆ្នាំ១៩៧៧និងឆ្នាំ១៩៧៩ ឡើយ ។ គណៈមជ្ឈិមគឺជាអ្នកសម្រេចលើចម្លើយសារភាពនីមួយៗរបស់មន្ទីរស-២១ ។ មេធាវីបានដកស្រង់សម្តីរបស់ ឌុច ឆ្លើយតបទៅកាន់សហចៅក្រមស៊ើបអង្កេតដែលបាននិយាយថា "ខ្ញុំគិតថារបបកម្ពុជាប្រជាធិបតេយ្យនេះជារបបឧក្រិដ្ឋចាប់ពីឆ្នាំ១៩៨៣ទៅ" ។ យោងតាមអំណះអំណាងនេះ មេធាវីបានសួរ ឌុច ថា ហេតុអ្វីបានជារហូតមកដល់ឆ្នាំ១៩៨៣ទើបគាត់យល់ថារបបកម្ពុជាប្រជាធិបតេយ្យជារបបឧក្រិដ្ឋកម្ម ។ ឌុច បានឆ្លើយតបថា "ដើម្បីសម្រេចថារបបនេះគឺជារបបឧក្រិដ្ឋកម្មបានលុះត្រាតែយើងមានការយល់ដឹងយ៉ាងទូលំទូលាយពីរបបកម្ពុជាប្រជាធិបតេយ្យនេះ ។ មិនមែនចេះតែនិយាយដោយគ្មានមូលដ្ឋានច្បាស់លាស់ឡើយ" ។ មេធាវីបានរៀបរាប់ថា ឌុច បានអានឯកសារជាច្រើនដែលត្រូវបានដាក់ចូលក្នុងសំណុំរឿងដូចជាសៀវភៅរបស់លោក ដេវីដ ឆេដល័រ និង ភាពយន្តឯកសាររបស់លោក រិទ្ធី ប៉ាន់ ជាដើម ។ អាស្រ័យហេតុនេះ មេធាវីបានចោទសួរថា តើ ឌុច បានយល់ពីរចនាសម្ព័ន្ធនៃរបបកម្ពុជាប្រជាធិបតេយ្យកាន់តែច្បាស់

តាមរយៈឯកសារទាំងអស់នេះមែនដែរឬទេ ។ ឌុច បានយល់ស្របថាការអានឯកសារទាំងអស់នេះជួយឲ្យគាត់យល់កាន់តែច្បាស់ពីទំនាក់ទំនងរវាងមន្ទីរស-២១ជាមួយនឹងគណៈមជ្ឈិម ។

បន្ថែមលើនេះ មេធាវីបានលើកឡើងសក្ខីកម្ម ឌុច ដែលបានផ្តល់ឲ្យសហចៅក្រមស៊ើបអង្កេត ។ ឌុច តែងតែនិយាយឃ្លាមួយថា «បើតាមការប៉ាន់ស្មានរបស់ខ្ញុំ ឬតាមការសន្មត» ។ ដូច្នេះ មេធាវីបានចោទប្រកាន់ថា ឌុច បានធ្វើសក្ខីកម្មដោយផ្អែកលើការប៉ាន់ស្មានតែប៉ុណ្ណោះ ប៉ុន្តែហ៊ានអះអាងថា ខ្លួនបានដឹងពីរចនាសម្ព័ន្ធថ្នាក់លើរបស់កម្ពុជាប្រជាធិបតេយ្យ បើទោះបីជាគាត់បាននិយាយនៅក្នុងបទសម្ភាសន៍ជាមួយនឹងសហចៅក្រមស៊ើបអង្កេត «ទោះបីជាអ្នកសួរខ្ញុំពីរឿងរ៉ាវដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យយ៉ាងណាក្តី ក៏ខ្ញុំមិនមានអ្វីនឹងនិយាយប្រាប់អ្នកដែរ ពីព្រោះខ្ញុំហាក់បីដូចជាបានជាប់ឃុំនៅមន្ទីរស-២១រហូតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ» ។

ក្រោយពីឈប់សម្រាកពេលរសៀល មេធាវីការពារក្តីជាតិរបស់ នួន ជា គឺលោក សុន អរុណ បានបន្តចោទសួរសាក្សី ឌុច ដោយម្តងនេះលោកសួរពីរចនាសម្ព័ន្ធរបស់មន្ទីរសន្តិសុខ ។ ជាដំបូង មេធាវីបានសួរឲ្យបកស្រាយពីរចនាសម្ព័ន្ធរបស់មន្ទីរសន្តិសុខក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ឌុច បានបញ្ជាក់ថា យោងតាមឯកសារចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ គ្មានការកំណត់តំណែងជាមន្ត្រីមន្ទីរសន្តិសុខឡើយ ។ បន្ថែមលើនេះ មេធាវីការពារក្តីបានដាក់បង្ហាញឯកសារស្តីពីការប្រជុំរបស់គណៈមជ្ឈិមកាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៩ ។ ឯកសារនោះបានសរសេរថា នួន ជា ទទួលបន្ទុកផ្នែកកិច្ចការសង្គម ឃោសនាការនិងកិច្ចការបក្ស ។ យោងតាមមុខតំណែងដែលមានចែងក្នុងឯកសារនេះ មេធាវីបានសួរ ឌុច ថាតើ នួន ជា អាចមកជាប់ពាក់ព័ន្ធនឹងកិច្ចការសន្តិសុខបានដោយរបៀបណា ។ ឌុច បានអះអាងថា «កិច្ចការបក្ស» នេះមិនមែនមានន័យត្រឹមតែបង្រៀនគោលនយោបាយបក្សដល់សមាជិកបក្សប៉ុណ្ណោះទេ ប៉ុន្តែវាមានន័យថា នួន ជា ថែមទាំងមានសិទ្ធិជ្រើសតាំងសមាជិកបក្សនិងដាក់ទណ្ឌកម្មលើសមាជិកបក្សណាដែលប្រព្រឹត្តខុសពីគោលការណ៍បក្ស ។ ឌុច បានបន្ថែមទៀតថា ដើម្បីក្តាប់កិច្ចការបក្សបានលុះត្រាតែអ្នកនោះដឹងពីគ្រប់សកម្មភាពទាំងអស់របស់សមាជិកបក្សនីមួយៗ ។ ឌុច បានបញ្ជាក់ចុងក្រោយថា ប្រសិនបើលេខាបក្សមិននៅទេ នោះអនុលេខាបក្សនឹងចេញមុខបំពេញកិច្ចការជំនួស ។ ដោយឡែក មេធាវីការពារក្តីបានផាកមកសួរ ឌុច ពីរចនាសម្ព័ន្ធរបស់ក្រសួងការពារជាតិ ។ ឌុច បានបកស្រាយថា សុន សេន គឺជាអ្នកទទួលបន្ទុកគ្រប់គ្រងកិច្ចការនៅក្រសួងការពារជាតិ ចំណែកឯលេខាបក្ស និងអនុលេខាបក្សជាអ្នកមើលការខុសត្រូវពីខាងលើ ។ ឆ្លើយតបនឹងសំណួររបស់មេធាវីការពារក្តីទាក់ទងនឹងទំនាក់ទំនងក្នុងជួរថ្នាក់ដឹកនាំនិងរចនាសម្ព័ន្ធនៃរបបកម្ពុជាប្រជាធិបតេយ្យ ឌុច បានបញ្ជាក់ថា បក្សកុម្មុយនីស្តកម្ពុជាបានយកគំរូតាមបដិវត្តលក្ខណៈវប្បធម៌តាមប្រទេសចិន ។ មានន័យថាថ្នាក់ដឹកនាំខ្លះមានវ័យចាស់ ដូច្នេះគាត់ត្រូវបានសមាជិកបក្សផ្សេងទៀតគោរព ប៉ុន្តែ ជាក់ស្តែងគាត់គ្មានអំណាចអ្វីទេ ។ ខណៈពេលដែលមេធាវីការពារក្តីបានឲ្យ ឌុច ពន្យល់ឃ្លា «ដៃជើងរបស់បក្ស» និង «ដៃជើងរបស់ ប៉ុល ពត» ឌុច បានលើកយកអង្គប្រជុំកាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៦ មកបកស្រាយ ។ ឌុច បាននិយាយថា ក្នុងអង្គប្រជុំនេះលេខាបក្ស ប៉ុល ពត ក្តាប់កិច្ចការទូទៅទាំងអស់ ហើយចំណែកអនុលេខាបក្ស នួន ជា ក្តាប់កិច្ចការបក្ស ។ បើកាលណាលេខាបក្សមិននៅនោះអនុលេខាបក្សអាចមើលការខុសត្រូវចំពោះកិច្ចការទាំងអស់ជំនួសបាន ។ យ៉ាងណាមិញ មេធាវីការពារក្តីបានសួរ ឌុច ថាតើនៅមន្ទីរស-២១មានការផ្ទេរការទទួលខុសត្រូវដូចគ្នានឹងអំណះអំណាងខាងលើរបស់ ឌុច ដែរឬទេ ។ ឌុច បានអះអាងថា គាត់មានអំណាចមើលការខុសត្រូវកិច្ចការទាំងអស់នៅមន្ទីរស-២១ ហើយប្រសិនបើគាត់មិននៅមន្ទីរស-២១ នោះអនុប្រធានរបស់គាត់អាចមើលការខុសត្រូវជំនួស ឌុច បាន ។ ប៉ុន្តែ ឌុច បានបញ្ជាក់អង្គជំនុំជម្រះថា បើទោះបីជាយ៉ាងណាក្តី សេចក្តីសម្រេចទាំងអស់ត្រូវតែបញ្ជូនមកឲ្យគាត់ពិនិត្យដដែល ។ បន្ថែមលើនេះ មេធាវីការពារក្តីបានចោទសួរថាតើគាត់មានភស្តុតាងមកបញ្ជាក់ថា គាត់បានទាក់ទងជាមួយនឹង នួន ជា ផ្ទាល់បន្ទាប់ពី សុន សេន ផ្លាស់ទៅកាន់ខាងតំបន់ដែរឬទេ ។ ឌុច បាននិយាយថាគ្មានការប្រកាសជាសំបុត្រជូនការសម្រាប់ការផ្ទេរតំណែងរបស់ សុន សេន ទៅឲ្យ នួន ជា ទេក្នុងអំឡុងពេលនោះ ពីព្រោះតាមគោលការណ៍របស់បក្សបើទោះបីជាមានការផ្លាស់ប្តូរ

ថ្នាក់ដឹកនាំ ក៏មិនចាំបាច់មានសេចក្តីប្រកាសជាផ្លូវការអ្វីឡើយ ។ ឆ្លើយតបនឹងសំណួររបស់មេធាវីការពារក្តីទាក់ទងនឹងការជម្លៀសប្រជាជនពីទីក្រុង ឌុច បានអះអាងថា ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានណែនាំពីផែនការជម្លៀសប្រជាជនតាមរយៈទស្សនាវដ្តីទង់បដិវត្តន៍របស់បក្ស ។ ឌុច ក៏បាននិយាយបន្ថែមទៀតថាកាលពីឆ្នាំ១៩៧៤ សុន សេន បានបង្គាប់ឲ្យ ឌុច ជម្លៀសមនុស្សមួយចំនួនទៅខេត្តពោធិ៍សាត់ ។

### សក្ខីកម្មថ្ងៃទីដប់ពីរ (ថ្ងៃទី៩ ខែមេសា ឆ្នាំ២០១២)

#### សវនាការពេលព្រឹក

វេទិកាចោទសួរសាក្សី ឌុច ត្រូវបានផ្ទេរទៅឲ្យមេធាវីការពារក្តី អៀង សារី ។ ជាកិច្ចចាប់ផ្តើម មេធាវីការពារក្តីអន្តរជាតិ ម៉ៃឃើល ខារណាវ៉ាស់ បានធ្វើការសន្និដ្ឋានលើសក្ខីកម្មរបស់ ឌុច កន្លងមកនេះថា តួនាទី ការដើរហើរ និងការទទួលខុសត្រូវរបស់ ឌុច នៅមន្ទីរស-២១ នៅមានកម្រិតនៅឡើយ ។ បន្ថែមលើនេះ ឌុច គ្រាន់តែជាកម្មាភិបាលថ្នាក់កណ្តាលតែប៉ុណ្ណោះ ។ ដូច្នេះនៅមន្ទីរស-២១ ឌុច បានព្យាយាមប្រឹងប្រែងគោរពតាមគោលការណ៍និងវិន័យបក្សយ៉ាងខ្ជាប់ខ្ជួនតាមបញ្ជារបស់ថ្នាក់លើរបស់ខ្លួនគឺ សុន សេន និង នួន ជា ។ បន្ទាប់មកទៀត មេធាវីការពារក្តីបានសួរ ឌុច ពីភាពភ័យខ្លាចរបស់គាត់ក្នុងអំឡុងគ្រប់គ្រងមន្ទីរស-២១ ។ ឌុច បានឆ្លើយតបថា គាត់រន្ធត់ និងភ័យខ្លាចនៅពេលដែល នួន ជា ចេញបញ្ជាឲ្យគាត់សម្លាប់អ្នកទោសទាំងអស់នៅឆ្នាំ១៩៧៩ ។ មេធាវីការពារក្តីបានសួរ ឌុច ថាតើគាត់បានដឹងពីព័ត៌មានដែលត្រូវទាញយកពីចម្លើយសារភាពរបស់អ្នកទោស ហើយថាតើឲ្យតែអ្នកទោសដែលត្រូវបានចាប់ខ្លួនដោយបក្សកុម្មុយនីស្តកម្ពុជាត្រូវតែចាត់ទុកជាខ្មាំងមែនដែរឬទេ ។ ឌុច បានបញ្ជាក់ថាទាំងអស់នេះគឺជាការអនុវត្តទូទៅនៅមន្ទីរស-២១ ។ ឆ្លើយតបនឹងសំណួររបស់មេធាវីថា តើ ឌុច និងបុគ្គលិករបសគាត់បានព្យាយាមបង្ខំឲ្យអ្នកទោសទាំងអស់ឆ្លើយថាខ្លួនជាភ្នាក់ងារ សេ.អ៊ី.អា, កា.ហ្សេ.បេ ឬយួនតាមរយៈការធ្វើទារុណកម្មមែនដែរឬយ៉ាងណានោះ ឌុច បានបញ្ជាក់ថាតាមរយៈការសួរចម្លើយនិងការធ្វើទារុណកម្ម អ្វីដែលមន្ទីរស-២១ចង់បានពីអ្នកទោសគឺចម្លើយសារភាព ។ មេធាវីការពារក្តីបានសួរ ឌុច ទាំងបង្ខំថាតើគាត់បានបង្ខំឲ្យអ្នកទោសដែលទទួលទារុណកម្មឆ្លើយថាខ្លួនជាខ្មាំងមែនដែរឬទេ ។ បន្ថែមលើនេះ មេធាវីការពារក្តីបានសួរ ឌុច ថាតើអ្នកទោសត្រូវតែសរសេរចម្លើយសារភាពរបស់ខ្លួនម្តងហើយម្តងទៀតដើម្បីទាញយកចម្លើយមួយដែលមន្ទីរស-២១ចង់បានឬយ៉ាងណា ។ ឌុច បានបញ្ជាក់ថា អ្នកទោសខ្លះត្រូវតែសរសេរចម្លើយសារភាពរបស់ខ្លួនម្តងហើយម្តងទៀត ។ ការធ្វើដូច្នេះគឺដើម្បីធានាថា ចម្លើយសារភាពដែលទទួលបានមានលក្ខណៈប្រត្យក្សមិនមែនដើម្បីជំរុញឲ្យអ្នកទោសនិយាយកុហកទេ ។ ខណៈពេលដែលមេធាវីការពារក្តីបានសួរថាតើ ឌុច ត្រូវតែពិនិត្យមើលចម្លើយសារភាពមុននឹងផ្ញើទៅឲ្យ សុន សេន ឬ ឌុច បានអះអាងថា ក្រោយពីបានផ្ញើចម្លើយសារភាពទៅថ្នាក់លើជួនកាល សុន សេន បានបង្គាប់ឲ្យគាត់សួរចម្លើយអ្នកទោសម្តងទៀត ហើយជួនកាល នួន ជា បានសួរបញ្ជាក់ឃ្លោងឃ្លាមួយចំនួននៅក្នុងចម្លើយសារភាព ។ ឆ្លើយតបនឹងសំណួររបស់មេធាវីការពារក្តី អៀង សារី ឌុច បាននិយាយថា គាត់មិនមានទំនាក់ទំនងអ្វីជាមួយនឹង អៀង សារី ទេ ។ គាត់គ្រាន់តែធ្លាប់បានឃើញ អៀង សារី ពីចម្ងាយបានពីរដងតែប៉ុណ្ណោះ ។ ហើយគាត់មិនដែលបានទៅក្រសួងការបរទេសឬមានទំនាក់ទំនងជាមួយនឹងបុគ្គលិករបស់ក្រសួងនេះដែរ ។ ដោយឡែក មេធាវី ម៉ៃឃើល ខារណាវ៉ាស់ បានសួរ ឌុច ពីទំនាក់ទំនងរវាងថ្នាក់ដឹកនាំកំពូលរបស់បក្សកុម្មុយនីស្តកម្ពុជាថាតើគាត់បានដឹងពីទំនាក់ទំនងរវាង ប៉ុល ពត និង សុន សេន ឬ ប៉ុល ពត និង នួន ជា ឬ ប៉ុល ពត និង អៀង សារី ដែរឬទេ ។ ឌុច បានឆ្លើយតបយ៉ាងខ្លីថា គាត់មិនបានដឹងពីទំនាក់ទំនងរបស់ថ្នាក់ដឹកនាំបក្សច្បាស់លាស់ទេ ។ មេធាវីការពារក្តីបានសួរ ឌុច ថា តើធ្លាប់បានអានរបាយការណ៍ប្រជុំរបស់គណៈមជ្ឈិមឬគណៈអចិន្ត្រៃយ៍ដែរឬទេ ។ ឌុច បានបញ្ជាក់ថារាល់ការប្រជុំរបស់គណៈមជ្ឈិមតែងតែមានការកត់ត្រាជារបាយការណ៍ជានិច្ច ប៉ុន្តែ គាត់មិនដែលបានចូលរួមប្រជុំរបស់គណៈមជ្ឈិម ហើយក៏មិនបានអានរបាយការណ៍ទាំងនោះដែរ ។ យ៉ាងណាមិញ គាត់បានបញ្ជាក់ថា គាត់បានដឹងពីខ្លឹមសារនៃប្រជុំទាំងនោះតាមរយៈការសន្ទនាជាមួយ សុន សេន ។ ជួនកាល ឌុច បានសួរនាំនិរសា ប៉ាង ពីការប្រជុំនោះ ។ មេធាវីការពារក្តីបានសួរទៀតថា តើការសួរនាំពីការប្រជុំនេះអាចនាំទោសដល់ខ្លួនដែរឬទេ ។ ឌុច បានឆ្លើយថា ប្រសិនបើ ប៉ាង

និយាយពីរឿងនេះដល់ថ្នាក់លើនោះ ឌុច ប្រាកដជាត្រូវបាន ប៉ុល ពត ដាក់ទណ្ឌកម្មជាមិនខាន ។ ខណៈពេលនេះ មេធាវីការពារក្តី បាននាំកមកផ្តោតលើឯកសារដែលត្រូវបានដាក់ក្នុងសំណុំរឿង ០០២វិញម្តង ។ មេធាវីការពារក្តីបានសួរថាតើ ឌុច មានបានអាន ឯកសារដែលសហព្រះរាជអាជ្ញាបានឲ្យមុនពេលឡើងធ្វើសក្ខីកម្ម ដែរឬទេ ។ ឌុច បានបញ្ជាក់ថា គាត់ បានអានឯកសារទាំងនោះ ។

ក្រោយពីឈប់សម្រាកពេលព្រឹក មេធាវី ម៉ៃយើល ខាណាវ៉ាស់ បានដកស្រង់បទសម្ភាសន៍របស់ ឌុច ជាមួយនឹង សហចៅក្រមស៊ើបអង្កេតដែលក្នុងនោះ ឌុច បាននិយាយថា "បើ អ្នកចង់ឲ្យខ្ញុំនិយាយតែរឿងដែលខ្ញុំបានដឹងនោះខ្ញុំគិតថាខ្ញុំគ្មានអ្វី នឹងនិយាយប្រាប់អ្នកទេ ពីព្រោះខ្ញុំហាក់បីដូចជាជាប់ឃុំនៅមន្ទីរ ស-២១" ។ យោងតាមអំណះអំណាងនេះ មេធាវីការពារក្តីបាន សន្និដ្ឋានថា ក្នុងអំឡុងពេលគ្រប់គ្រងមន្ទីរស-២១ ឌុច បានត្រឹមតែ ធ្វើដំណើរទៅមន្ទីរស-២១រៀងរាល់ថ្ងៃ ប៉ុន្តែមិនបានធ្វើដំណើរ ជុំវិញទីក្រុងភ្នំពេញទេ ។ បន្ទាប់មកទៀត មេធាវីការពារក្តីបាន ដាក់បង្ហាញឯកសារបទសម្ភាសន៍ជាលាយលក្ខអក្សររបស់ ឌុច ជាមួយនឹងសហចៅក្រមស៊ើបអង្កេតដោយដកស្រង់ពាក្យសម្តី ឌុច ដែលនិយាយថា "ខ្លួនខ្ញុំផ្ទាល់មិនដឹងពីកិច្ចការរបស់អ្នកដទៃទេ ។ នេះ មានន័យថា យើងមិនអាចនិយាយបានថារបបកម្ពុជាប្រជាធិបតេយ្យ នេះគឺជារបបឧក្រិដ្ឋកម្មនោះទេ ប៉ុន្តែ យើងអាចត្រឹមតែដឹងថា ឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើងនៅមន្ទីរស-២១" ។ ជាការ ឆ្លើយតប ឌុច បាននិយាយថា កាលណោះគាត់បានឆ្លើយដូច្នេះផ្អែក តាមចំណេះដឹងផ្ទាល់ខ្លួនរបស់គាត់នាពេលនោះមុនពេលគាត់បាន អានឯកសារបន្ថែមផ្សេងៗទៀត ។ ក្រោយពីបានតស៊ូមតិជា មួយនឹងភាគីសហព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី មេធាវីការពារក្តីបានដាក់បង្ហាញបទសម្ភាសន៍របស់ ឌុច ជាមួយ នឹងសហចៅក្រមស៊ើបអង្កេតដែលធ្វើឡើងកាលពីឆ្នាំ២០០៧ដោយ ដកស្រង់សម្តី ឌុច ដូចតទៅ ៖

"ខ្ញុំចង់និយាយពីរឿងរ៉ាវរបស់សំបុត្រមួយដែលខ្ញុំបាន បដិសេធមិនទទួលស្គាល់ ។ ខ្ញុំបានបង្ខំខ្លួនខ្ញុំមិនឲ្យទទួលស្គាល់សំបុត្រ ទាំងនោះទាំងភាពភ័យខ្លាច និងខ្មាសអៀន ។ មូលហេតុគឺថា ខ្ញុំត្រូវ រង់ចាំទទួលបានឯកសារភ័ស្តុតាងយកមកអានដើម្បីពង្រឹងការចង ចាំរបស់ខ្ញុំ ។ ជារួមខ្ញុំត្រូវការភ័ស្តុតាងគ្រប់ប្រភេទទាំងអស់ដើម្បី បង្ហាញតុលាការពីទិដ្ឋភាពឧក្រិដ្ឋកម្មដែលកើតមានឡើងនៅមន្ទីរ ស-២១" ។

អាស្រ័យលើពាក្យសម្តីរបស់ ឌុច ទាំងអស់នេះ មេធាវីការ ពារក្តីបានអះអាងថា ឌុច បានផ្តល់ព័ត៌មានមិនពិត ពីព្រោះគាត់ចង់ អានឯកសារភ័ស្តុតាងសិនមុននឹងផ្តល់ចម្លើយ ។

### សវនាការពេលរសៀល

ក្រោយពីឈប់សម្រាកអាហារថ្ងៃត្រង់ ភាគីទាំងអស់បាន មានវត្តមាននៅក្នុងបន្ទប់សវនាការលើកលែងតែជនជាប់ចោទ អៀង សារី និង នួន ជា ។ ជាកិច្ចបន្ត ភាគីមេធាវីការពារក្តី អៀង សារី បាន ចោទសួរ ឌុច បន្ថែមទៀតដើម្បីផ្ទៀងផ្ទាត់សក្ខីកម្មរបស់ គាត់ ។ មេធាវីការពាក្តីបានលើកឡើងឃ្លាមួយដែល ឌុច បាន និយាយថា "នៅមន្ទីរស-២១ ខ្ញុំបានព្យាយាមគេចវេសពីការ ងារ ។ ខ្ញុំយល់ព្រមបំពេញកិច្ចការណាដែលខ្ញុំមិនអាចគេចវេស បានតែប៉ុណ្ណោះ ។ ខ្ញុំមិនយកចិត្តទុកដាក់នឹងកិច្ចការទាំងអស់នោះ ទេ" ។ ឌុច បានឆ្លើយតបនឹងការលើកឡើងនេះថា "ការគេចវេសពី ការងារនេះ" មានន័យថា គាត់ "មិនចង់បំពេញការងារជាមន្ត្រី សន្តិសុខទេ" ប៉ុន្តែ គាត់មិនអាចគេចវេសបាន ។ បន្ថែមលើនេះ មេធាវីការពារក្តីបានលើកឡើងនូវបទសម្ភាសន៍របស់ ឌុច ជាមួយ នឹងសហចៅក្រមស៊ើបអង្កេតដែលធ្វើឡើងនៅខែតុលាឆ្នាំ២០០៩ ដោយដកស្រង់ពាក្យសម្តីគាត់ពីរឃ្លា ៖ ១) "យើងត្រូវតែបែងចែង ខ្លឹមសារដែលមានចែងក្នុងទ្រឹស្តីនិងការអនុវត្តឲ្យដាច់ពីគ្នា ។ បើតាមទ្រឹស្តី ការបែងចែកអំណាចគឺអនុវត្តតាមសេចក្តីសម្រេច របស់គណៈមជ្ឈិមចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ។ ប៉ុន្តែបើតាម ការអនុវត្តអំណាចទាំងអស់គឺឋិតនៅក្នុងកណ្តាប់ដៃរបស់ ប៉ុល ពត" ។ ឌុច បានបញ្ជាក់ចំពោះខ្លឹមសារដកស្រង់នេះថា "ទ្រឹស្តី និយាយដូច្នេះ ប៉ុន្តែការអនុវត្តអាចខុសពីទ្រឹស្តី" ។ មេធាវីការពារក្តី បានឲ្យ ឌុច បកស្រាយពីខ្លឹមសារទ្រឹស្តី និងការអនុវត្តនេះបន្ថែម ទៀត ។ ជាការឆ្លើយតប ឌុច បានបញ្ជាក់ដោយលើកស្ថានភាព ជាក់ស្តែងមួយមកបង្ហាញថា "តាមទ្រឹស្តី លេខាបក្សមានសិទ្ធិ អំណាចក្នុងការកម្ទេចខ្មាំង ។ ប៉ុន្តែការអនុវត្តជាក់ស្តែង ក្នុងការ កម្ទេចខ្មាំងអាចខុសពីនេះ" ។ មេធាវីការពារក្តីបានដកស្រង់បទ

សម្ភាសន៍របស់ ឌុច ជាមួយនឹងសហចៅក្រមស៊ើបអង្កេតកាលពីខែមីនា ឆ្នាំ២០០៩ ហើយបានអះអាងថា រាល់សេចក្តីសម្រេចទាំងអស់របស់លេខាបក្សនិងអនុលេខាបក្សត្រូវតែអនុវត្តតាមដាច់ខាត ។ បើនរណាមិនគោរពតាមសេចក្តីសម្រេច ជននោះត្រូវតែកម្ចាត់ចោល ។ ឆ្លើយតបនឹងខ្លឹមសារដែល ឌុច បាននិយាយក្នុងបទសម្ភាសន៍ដែលថា«ក្នុងចំណោមសមាជិកគណៈមជ្ឈិមទាំងប្រាំពីរនាក់ មានតែសមាជិកបីនាក់តែប៉ុណ្ណោះដែលមានសិទ្ធិអំណាចមើលការខុសត្រូវលើមន្ទីរសន្តិសុខដែលសមាជិកទាំងបីនាក់នោះគឺ ប៉ុល ពត, នួន ជា និង សុន សេន» ឌុច បានបញ្ជាក់ពីគោលជំហរយល់ស្របតាមការអះអាងរបស់ខ្លួនកាលពីឆ្នាំ២០០៩ដដែល និងបានបន្ថែមទៀតថា ប៉ុល ពត មានអំណាចធំជាងគេបង្អស់ ។ ភ្លាមនោះមេធាវីការពារក្តីបានសួរ ឌុច បញ្ជាក់ថា តើឃ្លានេះមានន័យថា ប៉ុល ពត អាចចាប់ខ្លួន អៀង សារី, នួន ជា, ឬ ខៀវ សំផន មែនដែរឬទេ ។ ឌុច បានឆ្លើយថា នេះគឺជាការពិតដោយបញ្ជាក់បន្ថែមថាវាក៏ អាស្រ័យលើមូលហេតុរបស់ ប៉ុល ពត ក្នុងការចាប់ខ្លួនអ្នកទាំងអស់នេះដែរ ។ ដោយឡែក មេធាវីការពារក្តីបានងាកមកសួរ ឌុច ពីការធ្វើ ទារុណកម្មលើ វន វ៉េត ។ ឌុច បាននិយាយថា វន វ៉េត ត្រូវបានធ្វើទារុណកម្ម ។ នេះគឺជាគោលការណ៍បក្សក្នុងការធ្វើទារុណកម្មអ្នកទោស បើសិនជាអ្នកទោសមិនព្រមឆ្លើយ ។ ឌុច បានឆ្លើយបន្ថែមទៀតថា វន វ៉េត បានសរសេរចម្លើយសារភាពដោយខ្លួនឯង ហើយថាគាត់បានពិនិត្យចម្លើយសារភាពនោះ មុនពេលបញ្ជូនទៅឲ្យ នួនជា ពិនិត្យ ។ មេធាវីបាន សួរ ឌុច ថា តើ វន វ៉េត បានសារភាពពីកំហុសរបស់ខ្លួនដែរឬទេ ។ ឌុច បានបញ្ជាក់ថា វន វ៉េត បានសារភាពថាជា សេ.អ៊ី.អា ។ ឆ្លើយតបនឹងសំណួរថា តើ ឌុច ជឿថា វន វ៉េត គឺជាសេ.អ៊ី.អា.មែនដែរឬយ៉ាងណានោះ គាត់បាននិយាយថា គាត់មិនដឹងច្បាស់ទេ ។

ក្រោយពីឈប់សម្រាកពេលរសៀល មេធាវីការពារក្តីអន្តរជាតិបានងាកមកសួរសំណួរទូទៅវិញម្តង ។ ជាកិច្ចបន្តមេធាវីបានសួរ ឌុច ថា តើបានដឹងពីវិធីសាស្ត្រក្នុងការចាប់ខ្លួនបុគ្គលិករបស់ក្រសួងការបរទេសដែរឬទេ ។ ឌុច គ្រាន់តែឆ្លើយតបថា បុគ្គលិកក្រសួងការបរទេសជាច្រើននាក់ត្រូវបានចាប់ខ្លួន ។ ហើយថា បើតាមគោលការណ៍មានតែ សុន សេន និង នួន ជា តែប៉ុណ្ណោះដែលអាចសម្រេចថានរណាត្រូវចាប់ខ្លួន ។ ឌុច បានបញ្ជាក់ទៀតថា នេះគឺជាខ្លឹមសារដែលមានចែងក្នុងទ្រឹស្តី ប៉ុន្តែការអនុវត្តជាក់ស្តែងអាចខុសពីនេះ ។ បន្ថែមលើនេះ ឌុច បានអះអាងថា គាត់មិនចាំថានរណាជាអ្នកចាប់ខ្លួនមនុស្សពីក្រសួងការបរទេសបញ្ជូនមកមន្ទីរស-២១ទេ ។ មេធាវីការពារក្តីបានចោទប្រកាន់ថា ឌុច កំពុងតែធ្វើការសន្និដ្ឋាននៅពេលនិយាយពីគោលការណ៍ចាប់ខ្លួន ។ ឌុច បានឆ្លើយតបថា ជាទូទៅគាត់បានឃើញការចាប់ខ្លួនមនុស្សពីក្រសួងការបរទេសមែន ប៉ុន្តែគាត់គ្មានភស្តុតាងមកបញ្ជាក់ថា អៀង សារី ជាអ្នកចាត់តាំងឲ្យមានការចាប់ខ្លួននេះទេ ។ ឌុច បានបន្ថែមទៀតថា ប្រសិនបើ អៀង សារី មិនបានចូលរួមប្រជុំជាមួយសមាជិកគណៈមជ្ឈិមទេ នោះ ប៉ុល ពត នឹងសម្រេចថានរណាត្រូវចាប់ខ្លួន ហើយបន្ទាប់មកនឹងរាយការណ៍ឲ្យ អៀង សារី អនុវត្ត ។ បន្ទាប់មកទៀត មេធាវីការពារក្តីបានសួរ ឌុច ថាតើពាក្យ «អង្គការ» នេះសំដៅ ប៉ុល ពត ហើយថា សុន សេន ដើរតួនាទីតំណាងឲ្យ ប៉ុល ពត មែនដែរឬទេ ។ ឌុច បានអះអាងថា«មែន» ។ ឆ្លើយតបនឹងសំណួររបស់មេធាវីការពារក្តីថាតើ«គោលបំណងរបស់មន្ទីរស-២១ គឺដើម្បីស្វែងរកការពិតមែនដែរឬទេ?» ឌុច បានឆ្លើយតបការសន្និដ្ឋានបែបនេះគឺអាស្រ័យលើចៅក្រមនិងអស់លោកអ្នកវិនិច្ឆ័យ ហើយថាមន្ទីរស-២១មានកាតព្វកិច្ចប្រឆាំងនឹងខ្មាំង ។ បន្ថែមលើនេះ មេធាវីការពារក្តីបានលើក យកពាក្យសម្តីដែល ឌុច បាននិយាយក្នុងបទសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេតទាក់ទងនឹងការចាប់ខ្លួនបុគ្គលិកក្រសួងការបរទេសថា «ខ្ញុំយល់ថាសេចក្តីសម្រេចចាប់ខ្លួនបុគ្គលិកក្រសួងការបរទេសប្រហែលជាយកទៅពិភាក្សាយោបល់ជាមួយនឹង អៀង សារី» ។ ឌុច បានអះអាងលើការដកស្រង់ពាក្យសម្តីនេះថា គាត់នៅតែប្រកាន់ជំហរលើការសន្និដ្ឋានបែបនេះដដែល ។ ជាការតទល់មតិ មេធាវីការពារក្តីបានចោទសួរថាតើ ឌុច មិនគិតថាការសន្និដ្ឋានរបស់គាត់នេះវាខុសទេឬ ។ ឌុច បានបញ្ជាក់ថា «វាមានខុសម្តងម្កាល ប៉ុន្តែជាទូទៅការសន្និដ្ឋានរបស់គាត់គឺត្រឹមត្រូវ» ។ ក្រោយមកទៀត មេធាវីការពារក្តីបានសួរ ឌុច ពីកុមារដែល អៀង សារី បានទុកក្រោយពេលដែលឪពុកម្តាយរបស់កុមារទាំងអស់នេះត្រូវបានសម្លាប់ ។ ឌុច បានរៀបរាប់ថា គាត់បានដឹងថា អៀង សារី បាន

ទុកកុមារទាំងអស់នេះនៅទសវត្សរ៍៩០ ។ ប៉ុន្តែ គាត់មិនបានដឹងពីព័ត៌មានអ្វីបន្ថែមទេគ្រាន់តែដឹងថាកុមារនេះបាននៅរស់រានមានជីវិតក្រោយពេលដែលឪពុកម្តាយរបស់អ្នកទាំងអស់នេះត្រូវបានសម្លាប់ ។ ផ្អែកលើអំណះអំណាងដ៏ខ្ចីនេះ មេធាវីការពារក្តីបានចោទប្រកាន់ថា ឌុច គ្មានព័ត៌មានជាក់លាក់ដើម្បីបញ្ជាក់ថា អៀង សារី មានជាប់ពាក់ព័ន្ធនឹងការចាប់ខ្លួននិងសម្លាប់ឪពុកម្តាយរបស់កុមារទាំងអស់នេះទេ ។

## ***សក្ខីកម្មថ្ងៃទីដប់បី (ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១២)***

### ***សវនាការពេលព្រឹក***

ថ្ងៃនេះគឺជាថ្ងៃបញ្ចប់សក្ខីកម្មរបស់ ឌុច ។ ជាកិច្ចចាប់ផ្តើម មេធាវីការពារក្តីអន្តរជាតិ អាធ័រ វើកខេន បានជម្រាបអង្គជំនុំជម្រះថាភាគីរបស់ខ្លួននឹងប្រុងប្រយ័ត្នជាមួយនឹងការសួរសំណួរពាក់ព័ន្ធនឹងព័ត៌មានដែល ឌុច បានអះអាងថា ខ្លួនបានដឹងបានឃើញនិងបានឮ ។ មេធាវីការពារក្តីបានបន្តទៀតថា ឌុច មិនមែនជាអ្នកជំនាញ ហើយក៏មិនមែនជាប្រវត្តិវិទូដែរ ។ ដូច្នេះ ឌុច មិនគួរទាមទារអានឯកសារដែលគាត់មិនបានឃើញឬអានក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យដើម្បីឆ្លើយតបនឹងសំណួររបស់មេធាវីឡើយ ។ ឆ្លើយតបនឹងសំណួររបស់មេធាវីការពារក្តី ឌុច បាននិយាយថា មុនពេលចូលរួមប្រជុំនៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ឌុច មិនដែលមានទំនាក់ទំនងអ្វីជាមួយនឹង ខៀវ សំផន ទេ ។ ឌុច បានបន្ថែមទៀតថា តាមគោលការណ៍បក្ស អ្នកនៅក្រោមបង្គាប់អាចជួបពិភាក្សាតែជាមួយនឹងថ្នាក់លើផ្ទាល់របស់ខ្លួនឯងតែប៉ុណ្ណោះ ដូច្នេះ ឌុច មិនដែលបានជួបជា មួយ ខៀវ សំផន ទេ ហើយថា សុន សេន ក៏មិនដែលនិយាយពី ខៀវ សំផន ដែរ ។ បន្ទាប់មកទៀត មេធាវីការពារក្តីបានដាក់ឯកសារសក្ខីកម្មដែល ឌុច ផ្តល់ឲ្យសហចៅក្រមស៊ើបអង្កេតដើម្បីចោទសួរសំណួរ ។ ឌុច បានបញ្ជាក់ថា គាត់មិនបានដឹងថាតើថ្នាក់លើរបស់គាត់ចេញសេចក្តីសម្រេចយ៉ាងដូចម្តេចទេ ហើយថា ខៀវ សំផន មិនបានពិនិត្យចម្លើយសារភាពមុន សុន សេន ទេ ។ ខណៈពេលនេះ មេធាវីការពារក្តីបានងាកមកសួរ ឌុច ពីអំណះអំណាងមួយដែល ប៉ង់ បាននិយាយថា ខៀវ សំផន នឹងឡើងធ្វើជាគណៈប្រតិភូជំនួស វន វ៉េត ក្នុងអង្គប្រជុំរបស់គណៈមជ្ឈិម ។ មេធាវីការ ពារក្តីបានសួរ ឌុច ថាតើ ប៉ង់ បានចូលរួមក្នុងអង្គប្រជុំគណៈមជ្ឈិមនេះដែរឬទេ ។ ឌុច បានរៀបរាប់ថា បើតាមគោលការណ៍ ប៉ង់ គឺជាអ្នករៀបចំអង្គប្រជុំនេះ ប៉ុន្តែ ប៉ង់ ប្រហែលជាមិនមានសិទ្ធិចូលរួមក្នុងអង្គប្រជុំនេះទេ ។ មេធាវីការពារក្តីបានចោទសួរថា «ដូច្នេះមានន័យថា ប៉ង់ មិនអាចប្រាប់ ឌុច បានថា ខៀវ សំផន បានធ្វើជាគណៈប្រតិភូក្នុងអង្គប្រជុំនេះទេ» ។ ឌុច បានអះអាងថា ក្នុងនាមជាអ្នករៀបចំអង្គប្រជុំ ប៉ង់ បានទទួលបញ្ជាពី ប៉ុល ពត ឲ្យកោះអញ្ជើញ ខៀវ សំផន ចូលរួមក្នុងអង្គប្រជុំ ។ ឌុច បាន រៀបរាប់បន្ថែមទៀតថា គាត់មិនដែលបាននិយាយជាមួយនឹង ប៉ង់ ទេនៅពេលដែល ប៉ង់ ត្រូវបានជាប់ឃុំនៅមន្ទីរស-២១ ។ ប៉ុន្តែ មេធាវីការពារក្តីបានដកស្រង់សក្ខីកម្មដែល ឌុច បាននិយាយកាលពីឆ្នាំ១៩៩៩ថា គាត់បាននិយាយជាមួយ ប៉ង់ ក្រោយពេលដែល ប៉ង់ ត្រូវបានធ្វើទារុណកម្ម ។ ឌុច បានអះអាងថា អ្វីដែលគាត់និយាយក្នុងតុលាការថ្ងៃនេះគឺជាការពិត ។ ឌុច បានបន្ថែមទៀតថា ឌុច មិនចាំថា ប៉ង់ ត្រូវបានចាប់ខ្លួននៅពេលណាទេ ប៉ុន្តែគ្រាន់តែដឹងថា ប៉ង់ ត្រូវបានចាប់ខ្លួនបញ្ជូនមកមន្ទីរស-២១ ពីរខែក្រោយពេល ដួ ដេត ត្រូវបានបញ្ជូនមកមន្ទីរស-២១នៅខែមេសា ឆ្នាំ១៩៧៨ ។ ឆ្លើយតបនឹងសំណួររបស់មេធាវីការពារក្តីថាតើ ប៉ង់ ត្រូវបានកម្មាភិបាលខ្មែរក្រហមផ្សេងទៀតតាមដានដែរឬទេ ឌុច បានបញ្ជាក់ថា សុន សេន បានបង្គាប់ឲ្យអ្នកទោសឆ្លើយដាក់ ប៉ង់ ហើយ ឌុច បានដឹងថា ប៉ង់ មានជាប់ពាក់ព័ន្ធនឹងខ្សែខ្មាំងមុនពេល ដួ ដេត ត្រូវបានចាប់ខ្លួន ។ សុន សេន បានចាកចេញពីមន្ទីរស-២១មុន ពេល ដួ ដេត មកដល់មន្ទីរស-២១ ។ ឌុច បានបញ្ជាក់ថា រឿងរ៉ាវដែល ប៉ង់ មានជាប់ពាក់ព័ន្ធនឹងអ្នកទោសត្រូវបានរក្សាទុកជាការសម្ងាត់រហូតដល់មានបញ្ជាពីថ្នាក់លើឲ្យចាប់ខ្លួន ប៉ង់ ។ យោងតាមអំណះអំណាងខាងដើមមេធាវីការពារក្តីបានជឿជាក់ថា ឌុច បានជួបនិយាយជាមួយនឹង ប៉ង់ ពាក់ព័ន្ធនឹងការប្រជុំរបស់គណៈមជ្ឈិម ។ ដូច្នេះ មេធាវីការពារក្តីបានសួរថាតើ ឌុច មិនខ្លាចថា ប៉ង់ នឹងឆ្លើយដាក់ខ្លួនទេឬ ។ ឌុច បានអះអាងថា «រឿងនេះវាមិនអាចកើតឡើងទេ» ។ ឌុច បានចោទជាសំណួរវិញថា «តើអ្នកសួរចម្លើយគេឲ្យ ប៉ង់ មកឆ្លើយដាក់ខ្ញុំងាយៗបានឬ? តើគណៈមជ្ឈិមគេជឿការចោទប្រកាន់របស់ ប៉ង់ មកលើរូបខ្ញុំដែរទេ?» ឌុច បានគូសបញ្ជាក់សារជាថ្មីម្តងទៀតថា

ការជាប់ពាក់ព័ន្ធរបស់ ប៉ាន់ ជា មួយនឹងខ្មាំងមិនត្រូវបានលេចឮនៅក្នុងមន្ទីរស-២១ ទេ ប៉ុន្តែត្រូវបានបញ្ជូនទៅ ប៉ុល ពត ផ្ទាល់ ។

ក្រោយពីឈប់សម្រាកពេលព្រឹក មេធាវីការពារក្ដីអន្តរជាតិរបស់ ខៀវ សំផន បានបន្តសួរ ឌុច ជាហូរហែ ។ មេធាវីការពារក្ដីបានសួរថាតើ តាម៉ុក បានអះអាងថា ជូ ជេត មានជាប់ពាក់ព័ន្ធនឹងខ្សែខ្មាំងដែរឬទេ ។ ឌុច បានបញ្ជាក់ថាតាមទស្សនៈរបសគាត់ តាម៉ុក មិនចូលចិត្ត ជូ ជេត ទេ ។ យោងតាមបទសម្ភាសន៍របស់ ឌុច ជាមួយនឹងសហចៅក្រមស៊ើបអង្កេត "មុនពេល ជូ ជេត ត្រូវបានចាប់ខ្លួនអ្នកនៅក្រោមបង្គាប់របស់ ជូ ជេត ទាំងអស់ត្រូវបានចាប់ខ្លួន ។ បន្ថែមលើនេះ មេធាវីការពារក្ដីបានសួរថាតើ ឌុច មានបានឆ្លើយប្រាប់សហចៅក្រមស៊ើបអង្កេតថា ខៀវ សំផន បានចូលរួមក្នុងសេចក្ដីសម្រេចចាប់ខ្លួន ជូ ជេត ដែរឬទេ ។ ឌុច បានអះអាងថា នេះគឺហេតុការណ៍ដែលគាត់បានដឹងតាម ប៉ាន់ ទាំងអស់ ។ កាលនោះ ខៀវ សំផន ត្រូវបាន ប៉ុល ពត អញ្ជើញឲ្យចូលរួមក្នុងអង្គប្រជុំរបស់គណៈមជ្ឈិមពាក់ព័ន្ធនឹងការចាប់ខ្លួនរបស់ ជូ ជេត ។ ឌុច បានបន្ថែមថា "ខ្ញុំបានចាំថាកាលនោះ ខៀវ សំផន ត្រូវបានអញ្ជើញឲ្យចូលរួមក្នុងអង្គប្រជុំនេះជំនួស វន វេត ដើម្បីឲ្យ ខៀវ សំផន បានជ្រាបពី "វិធានការបន្សុទ្ធកម្មក្នុងជួរបក្ស" ។ មេធាវីការពារក្ដីបាន សួរ ឌុច បន្ថែមទៀតថាតើ ប៉ាន់ មានប្រាប់ពីមូលហេតុដែល វន វេត មិនត្រូវបានអញ្ជើញឲ្យចូលរួមក្នុងអង្គប្រជុំរបស់គណៈមជ្ឈិមនេះដែរឬទេ ។ ឌុច បានបញ្ជាក់ថា "វន វេត ជាមនុស្សពិបាកធ្វើការជាមួយ ។ មានម្ដងនោះ វន វេត មិនយល់ស្របឲ្យបក្សធ្វើការវេចមុខខ្មាំងក្នុងជួរបក្ស" ។ ឆ្លើយតបនឹងសំណួររបស់មេធាវីការពារក្ដី ឌុច បាននិយាយថា ឌុច បានជួប វន វេត ជាលើកចុងក្រោយនៅថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ១៩៧៨ ។ កាលណោះ វន វេត បានទៅមន្ទីរស-២១ ខណៈពេលដែល ប៉ាន់ ត្រូវបានឃុំខ្លួន ។ ឌុច បានបន្ថែមទៀត នៅពេលដែល ប៉ាន់ ត្រូវបានចាប់ខ្លួន នួន ជា បានបញ្ជូនសំបុត្រមួយបង្គាប់ឲ្យ វន វេត ធ្វើការជាមួយ ឌុច នៅមន្ទីរស-២១ ។

## សវនាការពេលរសៀល

ក្រោយពីឈប់សម្រាកអាហារថ្ងៃត្រង់ មេធាវី អាធ័រ វើកខេន បានបន្តចោទសំណួរទៅកាន់ ឌុច បន្ថែមទៀត ។ មេធាវីការពារក្ដីបានសួរ ឌុច ពីការអះអាងរបស់ ឌុច ដែលថា ខៀវ សំផន បានកាន់កាប់ឃ្លាំងគ្រាប់ពូជមួយកន្លែង ។ ឌុច បាននិយាយថា គាត់បានដឹងព័ត៌មានតាមរយៈអតីតប្រធានឃ្លាំងនេះដែលត្រូវបានចាប់ខ្លួនបញ្ជូនមកមន្ទីរស-២១ ។ ឌុច បានបន្ថែមថា អតីតប្រធានឃ្លាំងនោះបាននិយាយថា ខៀវ សំផន បានបង្គាប់ឲ្យធ្វើជាភ្នាក់ងារ សេ.អ៊ី.អា ។ ដោយឡែក មេធាវីការពារក្ដីបានលើកឡើងពីសក្ខីកម្មដែល ឌុច បានផ្ដល់កាលពីថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងការប្រជុំជាមួយ ខៀវ សំផន នៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩មុន ពេលកងទ័ពវៀតណាមវាយចូលទីក្រុងភ្នំពេញ ។ ឌុច បានរៀបរាប់ថា កាលនោះ ខៀវ សំផន ជាអ្នកដឹកនាំអង្គប្រជុំនោះហើយបានបង្គាប់ឲ្យសមាជិកបក្សទាំងអស់កុំព្រួយបារម្ភ ហើយបន្តបំពេញការងាររបស់ខ្លួនដូចធម្មតា ។ ឆ្លើយតបនឹងសំណួររបស់មេធាវីការពារក្ដីថាតើ ឌុច មានអំណះអំណាងអ្វីដែលបញ្ជាក់ថាតើ ខៀវ សំផន គឺជាប្រធានឃ្លាំងរដ្ឋនោះ ឌុច បានអះអាងថា គាត់បានដឹងពីរឿងនេះតាមរយៈអ្នកចូលរួមក្នុងអង្គប្រជុំខាងលើនិងតាមរយៈអ្នកនៅក្រោមបង្គាប់របស់ ខៀវ សំផន ផ្ទាល់ដែលត្រូវបានចាប់ខ្លួនបញ្ជូនទៅមន្ទីរស-២១ ។ ឌុច បានបន្ថែមថា ខៀវ សំផន គឺជាភ្នាក់ងារសេ.អ៊ី.អា ។ ជាងនេះទៅទៀត តាមរយៈភ័ស្តុតាងមួយចំនួនឌុច បានអះអាងថា ខៀវ សំផន គឺជាអ្នកចេញសំបុត្រអនុញ្ញាតឲ្យធ្វើដំណើរពីតំបន់មួយទៅតំបន់មួយឲ្យកម្មាភិបាលទាំងអស់ ។ មេធាវីការពារក្ដីបានសួរ ឌុច ថានរណាជាអ្នកចុះហត្ថលេខាលើសំបុត្រអនុញ្ញាតឲ្យធ្វើដំណើរនោះ ។ ឌុច បាននិយាយថា ខៀវ សំផន ជាអ្នកចុះហត្ថលេខាហើយគាត់បានស្គាល់អក្សររបស់ ខៀវ សំផន ច្បាស់ ។ បន្ទាប់មកទៀត មេធាវីការពារក្ដីបានងាកមក សួរ ឌុច ថា តើនរណាទទួលខុសត្រូវខាងចាប់អ្នកទោសពីក្រសួងការបរទេសបញ្ជូនមកមន្ទីរស-២១ ។ ឌុច បានអះអាងថា គឺជា "លឹន" ។

ក្រោយពីឈប់សម្រាកពេលរសៀលមក មេធាវី អាធ័រ វើកខេន បានសួរបញ្ជាក់ ឌុច ម្ដងទៀតថា តើមាននរណាក្រៅពីសមមិត្ត លឹន ដែលបានចាប់ខ្លួនអ្នកទោសពីក្រសួងការបរទេសបញ្ជូនមកមន្ទីរស-២១ដែរឬទេ ។ ឌុច បាននិយាយថាមានម្ដងនោះ សមមិត្ត ចៀម ក៏បានចាប់ខ្លួនអ្នកទោសពីក្រសួងការបរទេសមក

មន្ទីរស-២១ដែរ ។ ដោយឡែក មេធាវីការពារក្តីក៏បានសាកមកសួរ ឌុច ជាលើកចុងក្រោយថាតើបានដឹងថាអ្នកនៅក្រោមបង្គាប់របស់ ខៀវ សំផន ដែលត្រូវបានចាប់ខ្លួនមកមន្ទីរស-២១នោះបានធ្វើការនៅមន្ទីរឃុំឃាំងរដ្ឋដោយរបៀបណា ។ ឌុច បានបញ្ជាក់ថាគាត់បានជួបអ្នកនៅក្រោមបង្គាប់របស់ ខៀវ សំផន នៅក្នុងអង្គពិធីគម្រប់ខួបជ័យជម្នះរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយបានដឹងថាអ្នកនៅក្រោមបង្គាប់នោះធ្វើការនៅភូមិភាគនិរតី ។

បន្ទាប់ពីភាគីមេធាវីការពារក្តីរបស់ ខៀវ សំផន បានបញ្ចប់ការសាកសួរសាក្សីមក ចៅក្រមក៏បានប្រគល់វេទិកាសួរសាក្សីឲ្យដល់ភាគីមេធាវីការពារក្តីរបស់ នួន ជា វិញម្តង ។ មេធាវីការពារក្តីជាតិ សុន អរុណ បានចាប់ផ្តើមដោយសួរសំណួរពីរថាតើ ឌុច មានរក្សាទុកសំបុត្រដែល នួន ជា បានចុះហត្ថលេខាដែរឬទេ និងថាតើ នួន ជា ពិតជាបានបង្គាប់ឲ្យ វន វេត ទៅបំពេញការងារនៅមន្ទីរស-២១មែនដែរឬយ៉ាងណា ។ ឌុច បានបញ្ជាក់ថា សំបុត្រដែលចាត់តាំង វន វេត ឲ្យមកបំពេញការងារនៅមន្ទីរស-២១មានចុះឈ្មោះ "សម្ងាត់" របស់ នួន ជា ហើយថា ឌុច មិនបានរក្សាទុកសំបុត្រនោះទេ ។ ឌុច ក៏បានបញ្ជាក់បន្ថែមទៀតថា តាមគោលការណ៍ ប៉ុល ពត ជាអ្នកសម្រេចចាត់តាំង វន វេត ប៉ុន្តែស្របពេលជាមួយគ្នានោះ នួន ជា ក៏បានចូលរួមពិនិត្យដែរ ។ មេធាវីការពារក្តីបានសួរថាតើ ឌុច បានដឹងពីរឿងរ៉ាវរបស់បក្សកុម្មុយនីស្តកម្ពុជានេះច្រើនបែបនេះដោយរបៀបណា បើគាត់មានវត្តមាននៅតែក្នុងមន្ទីរស-២១ ។ ឌុច បានអះអាងថា ក្នុងនាមជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាចាប់តាំងពីឆ្នាំ១៩៧១និងជាអ្នករស់នៅឆ្លងកាត់របបកម្ពុជាប្រជាធិបតេយ្យគាត់បានដឹងព្រឹត្តិការណ៍ជាច្រើនដែលបានកើតឡើងក្នុងរបបនេះ ។ យ៉ាងណាមិញ មេធាវីការពារក្តីបានចោទប្រកាន់ថា ឌុច បានដឹងពីរឿងរ៉ាវទាំងអស់នេះតាមរយៈការអានឯកសារជាជាងតាមបទពិសោធន៍របស់ខ្លួនផ្ទាល់ ។ ឆ្លើយតបនឹងសំណួរបន្ថែមទៀតរបស់មេធាវីការពារក្តី ឌុច បានរៀបរាប់ថានៅដើមឆ្នាំ១៩៧៩ នួន ជា បានបង្គាប់ឲ្យគាត់សម្លាប់អ្នកទោសដែលនៅសេសសល់ចោលទាំងអស់ ។ ឌុច បានបន្ថែមទៀតថាគាត់បានសួរពីហេតុផលក្នុងការសម្លាប់អ្នកទោសចោលទាំងអស់ដែរ ប៉ុន្តែ នួន ជា មិនបានឆ្លើយតបអ្វីឡើយ ។ មេធាវីការពារក្តីបានសួរ ឌុច បន្តទៀតថា តើនៅពេលដែល សុន សេន ត្រូវបានចាត់តាំងទៅគ្រប់គ្រងកិច្ចការខាងតំបន់ថ្នាក់លើមានបានចេញសំបុត្រជាផ្លូវការបង្គាប់ថា នួន ជា នឹងឡើងកាន់កាប់តំណែងមើលខុសត្រូវមន្ទីរស-២១ ជំនួស សុន សេន ដែរឬទេ ។ ឌុច បាននិយាយថា រាល់ការផ្លាស់ប្តូរតួនាទី ឬមុខតំណែងគ្មានការចេញសំបុត្រជាផ្លូវការពីសំណាក់ថ្នាក់ដឹកនាំឡើយ ។

ជាចុងបញ្ចប់ ក្រោយពេលដែលភាគីមេធាវីការពារក្តីទាំងអស់បានបញ្ចប់ការ សាកសួរសាក្សី ឌុច លោកប្រធានចៅក្រមនៃអង្គជំនុំជម្រះបានដំបូងបានបិទអង្គសវនាការត្រឹមថ្ងៃនេះសម្រាប់នីតិវិធីសួរនាំសាក្សី ឌុច ។ **វ៉ែន សុខស្រីនិត**



*សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង*

# ស្តូបតម្កល់អដ្ឋិធាតុវត្តព្រៃតាធឹកសង់ថ្មី

ដោយសារភាពចាស់ទ្រុឌទ្រោមនៃកន្លែងតម្កល់អដ្ឋិធាតុចាស់ស្ថិតក្នុងបរិវេណអតីតមន្ទីរសន្តិសុខវត្តព្រៃតាធឹកប្រ គគីសោម មន្ត្រី អាជ្ញាធរស្រុក ព្រះសង្ឃ និងអ្នកភូមិបានផ្តួចផ្តើមឲ្យមានការកសាងសង់ស្តូបថ្មីមួយទៀត ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏សាងសង់នេះនៅតែទាមទារឲ្យមានការជួយជ្រោមជ្រែងពីប្រជាពលរដ្ឋ និងសប្បុរសជនបន្ថែមទៀតដែរ ។ នៅក្នុងរបបខ្មែរក្រហម មន្ទីរសន្តិសុខវត្តព្រៃតាធឹកជាអតីតមន្ទីរសុខស្រុកប្រសូតិ បច្ចុប្បន្ន (ស្រុកស្វាយទាប) តំបន់២៣ ។ មន្ទីរសន្តិសុខវត្តព្រៃតាធឹកនេះស្ថិតនៅភូមិព្រៃតាធឹក ឃុំគគីសោម ស្រុកស្វាយទាប ខេត្តស្វាយរៀង មានចម្ងាយប្រមាណប្រាំគីឡូម៉ែត្រពីព្រំប្រទល់ប្រទេសវៀតណាម ។ មន្ទីរសន្តិសុខនេះបង្កើតឡើងនៅឆ្នាំ១៩៧៥ ដោយមានឈ្មោះ តាខសា ជាអ្នកគ្រប់គ្រង ។ ក្រោយមកអង្គការបានផ្លាស់ តាខសា ឲ្យទៅធ្វើការនៅមន្ទីរសន្តិសុខស្រុកស្វាយរៀងវិញ រួចដាក់អ្នកថ្មីមកគ្រប់គ្រងមកជំនួសវិញ ។ ប៉ុន្តែអ្នកគ្រប់គ្រងក្រោយៗនោះត្រូវអង្គការចាប់ខ្លួនទាំងអស់ ។ ចំពោះអ្នកទោសដែលត្រូវបានចាប់ខ្លួនមកឃុំឃាំងក្នុងមន្ទីរសន្តិសុខនេះមានដូចជាប្រជាជនរស់នៅក្នុងសហករណ៍ដែលធ្វើខុសសីលធម៌, សិល្បៈករ, ព្រះសង្ឃ, ទាហាន និងមន្ត្រីរាជការនៅក្នុងសង្គមចាស់ ។ អ្នកទោសទាំងអស់នោះត្រូវទទួលរងនូវទារុណកម្មនិងបង្អត់អាហារមុននឹងឆ្មាំគុកយកទៅសម្លាប់ចោល ។ ចំណែក អ្នកទោសដែលមានឋានៈនិងតួនាទីធំៗក្នុងសង្គម-ចាស់ត្រូវប្រធានគុកបញ្ជូនបន្តទៅមន្ទីរសន្តិសុខតំបន់ ។ មន្ទីរសន្តិសុខវត្តព្រៃតាធឹកនេះមានកងឈ្លបនិងឆ្មាំគុកយាមការពារយ៉ាងតឹងរឹង ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយក៏មានជនរងគ្រោះបានរួចរស់ជីវិតក្រោយឆ្នាំ១៩៧៩មកដែរ ដូចជា ឈ្មោះ ស ដៃ, ភាគ សម្បត្តិ, សោម តាក, នាង សំអាត, មឹង សំផន និង ឈ្មោះ ហ៊ុល សារ៉ែន ។ បើតាមអ្នកទោសឈ្មោះ ស ដៃ អតីតទាហាន លន់ នល់ ដែលធ្លាប់ជាប់ឃុំឃាំងនៅក្នុងមន្ទីរសុខវត្តព្រៃតាធឹករយៈ១៨ខែបានឲ្យដឹងថា មានអ្នកទោសប្រមាណមួយម៉ឺនប្រាំពាន់នាក់ជាប់ឃុំនៅក្នុងមន្ទីរសុខនេះ ។ ដៃ បន្តថា គាត់ឃើញកងសន្តិសុខយកអ្នកទោសរាប់រយនាក់ទៅឃុំឃាំងនៅក្នុងព្រះវិហារកុដិនៅខាងលើនិងក្រោមសាលាឆាននិងក្នុងបរិវេណវត្តព្រៃតាធឹកទាំងមូល ។ ក្រោយមក អ្នកទោសទាំងអស់នោះបាត់ខ្លួនទាំងអស់ ។ ចំណែក លោក ប៉ាល់ សុន បច្ចុប្បន្នមេឃុំគគីសោម បាននិយាយថា បើតាមការប្រជុំសួរនាំមន្ត្រីនៅក្នុងឃុំទាំងមូល គឺមានអ្នកទោសសរុបទាំងអស់ប្រមាណជិតប្រាំមួយពាន់នាក់ត្រូវបានសម្លាប់នៅក្នុងមន្ទីរសន្តិសុខនេះ ។ ចំណែក អ្នកទោសមួយចំនួនទៀតត្រូវប្រធានគុកផ្ទេរយកទៅដាក់នៅមន្ទីរសុខក្នុងស្រុកស្វាយជ្រំវិញនៅដែលពេលកងទ័ពវៀតណាមវាយចូលមកដល់ផ្សារ



ស្តូបតម្កល់នៅវត្តព្រៃតាធឹកកំពុងសាងសង់

កំពង់ចក បច្ចុប្បន្ន (ស្ថិតក្នុងស្រុករំដួល) ដែលមានចម្ងាយប្រមាណជាង៨០គីឡូម៉ែត្រពីព្រំប្រទល់ប្រទេសវៀតណាមនៅឆ្នាំ១៩៧៧ ។

បន្ថែមលើនេះ អ្នកភូមិដែលរស់នៅជិតមន្ទីរសន្តិសុខនេះក្នុងអំឡុងរបបខ្មែរក្រហមបានប៉ាន់ស្មានថា មានអ្នកទោសប្រមាណជាងប្រាំពីរពាន់ប្រាំរយនាក់បានស្លាប់នៅក្នុងមន្ទីរសន្តិសុខនេះ ។ ទោះបីជាប្រភពទាំងបីខាងលើនេះ បង្ហាញពីតួរលេខខុសគ្នាអំពីចំនួនអ្នកទោសដែលបានស្លាប់ទោយ៉ាងក៏ដោយ ក៏ក្រោយរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩មានសាកសពរាប់រាយនាក់ត្រូវបានគាស់ចេញពីរណ្តៅក្នុងបរិវេណមន្ទីរសន្តិសុខវត្តព្រៃតាធីកហៅវត្តគគីសោមនេះ ដោយមិនគិតពីរណ្តៅខ្លះទៀតដែលមិនបានធ្វើការគាស់កកាយរហូតមកដល់សព្វថ្ងៃនេះទេ ។ ឆ្អឹងសាកសពទាំងនោះត្រូវបានព្រះសង្ឃ ប្រជាជន និងមន្ត្រី នៅក្នុងមូលដ្ឋានយកទៅតម្កល់ក្នុងរោងមួយដែលសាងសង់ឡើងពីឈើប្រក់ក្បឿងស្ថិតក្នុងបរិវេណមន្ទីរសន្តិសុខវត្តព្រៃតាធីកនេះតែម្តងប៉ុន្តែកន្លែងតម្កល់នេះពុំមានទ្វារឬរបងព័ទ្ធការពារឲ្យបានមាំទាំនោះទេ ។

ក្រោយមក អាជ្ញាធរមូលដ្ឋានបានយកឆ្អឹងមួយចំនួនពីកន្លែងតម្កល់អដ្ឋិធាតុវត្តព្រៃតាធីកទៅតម្កល់ទុកនៅមណ្ឌលឧក្រិដ្ឋប្រល័យពូជសាសន៍ ប៉ុល ពត ស្ថិតនៅភូមិតាណៅ ឃុំស្វាយតឿ បច្ចុប្បន្ន (សង្កាត់ស្វាយតឿ) ស្រុកកំពង់រោទ៍ បច្ចុប្បន្ន (ក្រុងស្វាយរៀង) ខេត្តស្វាយរៀង ដែលជាកន្លែងប្រារព្ធទិវាចងកំហឹងនៅរៀងរាល់ថ្ងៃទី២០ ខែឧសភា ជាផ្លូវការរបស់ខេត្តវិញ ។ ចំណែកឆ្អឹងមួយចំនួនទៀតដែលនៅសេសសល់ត្រូវគោស៊ីហើយមួយចំនួនទៀតត្រូវគ្រូផ្សំថ្នាំខ្មែរទោយកមកដុសផ្សំថ្នាំសម្រាប់ព្យាបាលអ្នកជំងឺ ។ ជាក់ស្តែង ឆ្អឹងលលាដ៍ក្បាលរបស់អ្នកទោសនៅសល់ចំនួន៣៣៧នាក់ប៉ុណ្ណោះ ។

រហូតមកដល់ឆ្នាំ២០០៩ ដោយសារមើលឃើញកន្លែងតម្កល់អដ្ឋិធាតុវត្តព្រៃតាធីកឬវត្តគគីសោមនេះមានសភាពទ្រុឌទ្រោមខ្លាំង និងគ្មានការថែទាំឲ្យបានជិតដល់ ទើបលោក សោម ថា អភិបាលស្រុកស្វាយទាបបានចាត់តាំងលោក ពេញ ជា ធ្វើជាប្រធានគណៈកម្មាធិការរៃអង្គាសថវិកាពីប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងមន្ត្រីរាជការក្នុងស្រុកទាំងមូលដើម្បីសាងសង់ស្តូបតម្កល់អដ្ឋិធាតុថ្មីដែលមានទំហំបីម៉ែត្រគុណនឹងបីម៉ែត្រ ។

ការសាងសង់ស្តូបថ្មីនេះ បានចំណាយថវិកាប្រមាណជិតបីពាន់នាក់ដុល្លារអាមេរិកប៉ុន្តែថវិកាដែលបានមកពីរៃអង្គាសនេះពុំគ្រប់ចំនួនទៅធ្វើឲ្យការសាងសង់នេះបានអូសបន្លាយរហូតមកដល់ពេលនេះ ។ បច្ចុប្បន្ន ការសាងសង់ នៅខ្វះខាតទ្វារកញ្ចក់, ធ្នើរសម្រាប់តម្កល់អដ្ឋិធាតុនិងសម្ភារមួយចំនួនទៀត ។ ហេតុដូច្នេះហើយ ទើបលោកអភិបាលស្រុក គណៈកម្មាធិការ សាងសង់ព្រះសង្ឃនិងប្រជាពលរដ្ឋក្នុងស្រុកស្វាយទាបសំណូមពរឲ្យសប្បុរសជនជួយសាងសង់ស្តូបតម្កល់អដ្ឋិធាតុនេះបន្តទៀតដើម្បីទុកជាកន្លែងគោរពសក្ការបូជានិងកន្លែងប្រារព្ធពិធីបុណ្យរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះក្នុងមូលដ្ឋានរបស់គាត់ ។

សព្វថ្ងៃ ទោះបីជាការសាងសង់ស្តូបតម្កល់អដ្ឋិធាតុវត្តព្រៃតាធីកនេះពុំទាន់ចប់រួចរាល់ហើយក៏ដោយ ក៏ការផ្តួចផ្តើមគំនិតឲ្យមានសំណង់នេះមានតម្លៃនិងមានសារសំខាន់ណាស់ក្នុងការបង្កើតឲ្យមានការចងចាំសម្រាប់អ្នកដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហមនិងជនរងគ្រោះដែលបានស្លាប់និងជាពិសេសដើម្បីថែរក្សាប្រវត្តិសាស្ត្ររបស់ជាតិទាំងមូល ។ **សោម ប៊ុនថន**


ស្តូបតម្កល់ដែលបានសង់រួចរាល់

# ការឈឺចាប់នៅក្នុងរបបខ្មែរក្រហម

លោកយាយ ខេង ជិត អាយុ៥៣ឆ្នាំ រស់នៅខណ្ឌឬស្សីកែវ រាជធានីភ្នំពេញបានរៀបរាប់ពីការរស់នៅក្នុងរបបខ្មែរក្រហមថា៖

១៧ ខែមេសា ឆ្នាំ១៩៧៥ ជាថ្ងៃដែលយោធាខ្មែរក្រហមចូលក្រុងភ្នំពេញ ។ យោធាខ្មែរក្រហមចាប់ផ្តើមជម្លៀសប្រជាជនដែលរស់នៅក្នុងទីក្រុងភ្នំពេញរួមទាំងក្រុមគ្រួសាររបស់ ជិត ផង ។ ពេលនោះ យោធាខ្មែរក្រហមបានបង្ខំឲ្យគ្រួសាររបស់គាត់ចេញពីផ្ទះដោយប្រាប់ថា ចេញតែរយៈពេលបីម៉ោងប៉ុណ្ណោះ ហើយភ្លាមនោះដែរ យោធាខ្មែរក្រហមផ្សេងទៀតប្រកប ដោយទឹកមុខកាចសាហាវបានមកប្រាប់ទៀតថាឲ្យចេញតែបីថ្ងៃទេ ។ ពេលនោះក្រុមគ្រួសាររបស់ ជិត មិនបានយកសម្ភារមកតាមខ្លួនច្រើនទេដោយគិតថាចេញតែបីថ្ងៃ ។ ក្រុមគ្រួសារ ជិត សម្រេចចិត្តមកស្រុកកំណើតខាងម្តាយ នៅកោះដាច់ខេត្តកណ្តាល តែមិនបានធ្វើដំណើរតាមផ្លូវជាតិលេខ៦ទេ ព្រោះយោធាខ្មែរក្រហមមិនឲ្យទៅ ។ គ្រួសាររបស់គាត់ក៏សម្រេចចិត្តធ្វើដំណើរតាមផ្លូវច្បារអំពៅ រួចឆ្លងទូកនៅមុខវត្តនិរោធន៍រង្សីមកកាន់អរិយក្សត្រ ហើយបន្តដំណើរនិងឆ្លងទូកមួយទៀតទៅកាន់កោះដាច់ ។ ពេលមកដល់ស្រុកខាងម្តាយដំបូង ក្រុមគ្រួសារ ជិត រស់នៅជាលក្ខណៈឯកជនមិនទាន់ហូបរួមនៅឡើយទេ ។ ដោយសារតែខ្វះអាហារហូបចុកគ្រួសាររបស់ ជិត បានយកខោអាវខ្លះទៅដូរយកមាន់ ឬអង្ករពីអ្នកមូលដ្ឋានដើម្បីមកហូប ។ រស់នៅទីនោះបានពីរខែ ជិត ក៏ធ្លាក់ខ្លួនឈឺដោយជ្រុះសក់និងចូលទៅសម្រាកនៅពេទ្យដែលមានទីតាំងសព្វថ្ងៃជាសាលាជាតិកសិកម្មព្រែកលៀប ។ ជិត បានរៀបរាប់ថា កាលនោះអគារពេទ្យមានបីឬបួនអគារ ។ ពេលដែលកំពុងសម្រាកព្យាបាលនៅពេទ្យ កម្មាភិបាលពេទ្យបានឲ្យគាត់លេបថ្នាំអាចម៍ទន្សាយនិងចាក់ទឹកដូងតែគាត់នៅតែមិនមានភាពធូរស្រាលសោះឡើយ ។ ជិត បាននិយាយថា គាត់គ្មានជម្រើសអ្វីទេគឺត្រូវតែស្នាក់នៅមន្ទីរពេទ្យអស់រយៈពេលពីរខែ ។ ជិត បន្ថែមទៀតថា នៅក្នុងបរិវេណមន្ទីរពេទ្យមានរោងបាយឋិតនៅផ្នែកខាងក្រោយ (បច្ចុប្បន្នរុះរើចោលហើយ) និងមានកន្លែងឃុំឃាំងនៅជិតរោងបាយ (បច្ចុប្បន្នជាអគារសិក្សាផ្នែកសេដ្ឋកិច្ច) ។ ជិត មិនបានដឹងថា ទីនោះគឺជាគុកទេ តែក្រោយមក ទើបគាត់ដឹងព្រោះមានពេលអ្នកទោសម្នាក់បានឈឺហើយមកគេងក្បែរគ្រែរបស់ ជិត ដែរ ។ ក្រោយពីសួរនាំរួចទើប ជិត ដឹងថា គុកមានទីតាំងនៅក្នុងបរិវេណមន្ទីរពេទ្យនេះដែរ ។

នៅឆ្នាំ១៩៧៦ មានអគ្គីភ័យមួយនៅវត្តខ្នុរ ព្រែកលាប ដោយពេលនោះកម្មាភិបាលបានប្រកាសថា អ្នកដែលមកពីទីក្រុងភ្នំពេញទាំងអស់ត្រូវឲ្យចេញទៅខេត្តពោធិ៍សាត់ និងបាត់ដំបងនាពេលឆាប់ៗនេះ ។ ថ្ងៃធ្វើដំណើរបានមកដល់ពេលនោះសភាពជំងឺរបស់ ជិត មិនទាន់ជាដាច់នៅឡើយទេ តែគាត់គិតថាបើទៅពោធិ៍សាត់ និងបាត់ដំបងប្រហែលស្ថានភាពស្រួលជាងនៅទីនេះ ព្រោះពីមុនខេត្តបាត់ដំបងជាខេត្តដែលសម្បូរសប្បាយ ។ គាត់ក៏ស្ម័គ្រចិត្តឡើងលើកាណូតជាមួយនឹងអ្នកផ្សេងទៀតឆ្ពោះទៅតំបន់នោះ ។ ជិត បានរៀបរាប់ថា កាលនោះកាណូតទាំងអស់មានបួនគ្រឿងហើយកាណូតនីមួយៗផ្ទុកមនុស្សណែនសឹងតែលិច ។ កាណូតបានទៅឈប់នៅកំពង់ហ្លួងខេត្តកណ្តាល ។ ក្រោយមកទើបពេលទៅដល់ពោធិ៍សាត់ ជិត អះអាងថា ស្ថានភាពមិនដូចអ្វីដែលគាត់គិតទុកទេ ព្រោះពេលទៅដល់កម្មាភិបាលនៅភូមិភាគពាយព្យបានបំបែកតាមក្រុមគ្រួសារគាត់កងរៀងៗខ្លួនមិនឲ្យនៅជួបជុំគ្នាទេ ។ ជិត បានរៀបរាប់ដោយទុក្ខសោកថា “បើសិនជា កម្មាភិបាល ឲ្យខ្ញុំទៅការដ្ឋានយប់ឡើងខ្ញុំបាននៅជាមួយម្តាយតែបើឲ្យខ្ញុំទៅធ្វើការទៅតាមកងវិញ ខ្ញុំមិនបានជួបម្តាយទេ បើចង់មកជួបគាត់ទាល់តែសុំមេក្រុម តែភាគច្រើនគេមិនឲ្យយើងទៅជួបម្តាយទេ” ។ ជិត រៀបរាប់ទៀតថា កាលនោះគាត់មានអាយុ១៥-១៦ឆ្នាំ ហើយកម្មាភិបាលដាក់គាត់ក្នុងកងយុវជនដែលមាន តាឡូញ ជាប្រធានកង ហើយការងារដែលធ្វើមានរែកដី ស្ទូង ច្រូត ហើយ តាឡូញ បានបង្រៀនគាត់ឲ្យចេះកាន់នង្គ័លភ្ជួរ ។ ជិត និយាយទៀតគាត់មិនភ្ជួរបានល្អដូចយុវជនទេ តែគាត់អាចភ្ជួរបាន ។ ជិត រៀបរាប់ថា “តាឡូញ ជាមនុស្សស្លូតគួរសម ហើយពេលដែលខ្ញុំធ្វើឲ្យបាក់នង្គ័លគាត់មិនប្រកាន់ទោសព្រៃអ្វីទេ” ។ ក្រោយមក តាឡូញ

ត្រូវបានផ្លាស់ចេញ តែ ដិត មិនដឹងថា ឲ្យគាត់ទៅណាទេ ហើយស្ត្រីម្នាក់ឈ្មោះ ក្រែម ចូលមកជំនួស ។ ដិត បាននិយាយថា «យាយក្រែម ក៏មិនកាចដែរ តែគាត់រិតត្បិតការហូបចុកខ្លាំងណាស់ដោយអង្ករបីកំប៉ុងហូបគ្នាដប់នាក់លាយជាមួយព្រលិត ។ រៀងរាល់ដប់ថ្ងៃទើបមានការប្រជុំម្តង ។

ឆ្នាំ១៩៧៨ ដិត ត្រូវអង្គការបង្ខំឲ្យរៀបការដែលកាលនោះមាន៨០គូរ ។ ដិតរៀបរាប់ថា អំឡុងពេលពិធីនោះមានធ្វើនំបញ្ចុកដើម្បីអបអរសាទរផង ។ ពេលកងទ័ពវៀតណាមវាយចូលប្រទេសកម្ពុជា ដិត ត្រូវបានកៀរឲ្យចូលព្រៃជាមួយកម្មាភិបាលខ្មែរក្រហម តែក្រោយមក អ្នកភូមិនានាបានប្រាប់ ដិត ថាឲ្យធ្វើដំណើរឆ្ពោះទៅបឹងទន្លេសាប នោះនឹងបានជួបកងទ័ពវៀតណាម ។ ដិត បានប្រឹងប្រែងគេចខ្លួនពីកម្មាភិបាលខ្មែរក្រហមជាមួយប្តី ក្របីមួយនឹមនិងអង្ករមួយបាវ ។ ដិត និយាយថា «កាលនោះយើងធ្វើដំណើរដោយដើងទទេ ។ យោធាខ្មែរក្រហមតាមយើងជាប់ពីក្រោយព្រោះគេដឹងថាយើងព្យាយាមរត់គេច» ។ ដិត ខិតខំរកស៊ីជាមួយប្តីដើម្បីចិញ្ចឹមជីវិតដោយធ្វើការនៅសាលាជាតិកសិកម្មព្រែកលៀបដែលជាមន្ទីរពេទ្យដែលគាត់ធ្លាប់សម្រាកព្យាបាលកាលពីរបបខ្មែរក្រហម ។ ដិត បាននិយាយថា ពេលដែលគាត់ឃើញទីតាំងសាលាព្រែកលាបដំបូងគាត់ស្រណោះខ្លួនណាស់ ។

ដិត បាននិយាយថា គាត់តែងតែនិយាយប្រាប់កូនរបស់គាត់អំពីរបបខ្មែរក្រហម ហើយពេលដែលមានការបញ្ចាំងខ្សែភាពយន្តដែលនិយាយពីរបបខ្មែរក្រហមម្តងៗ គាត់តែងតែនិយាយប្រាប់កូនឲ្យទៅមើលដើម្បីឲ្យដឹងពីជីវិតរបស់គាត់កាលពីរបបនោះ ។ ដិត និយាយទៀតថា កូនរបស់គាត់ជឿថាមានរបបខ្មែរក្រហមកើតឡើងដោយកូនរបស់គាត់ធ្លាប់ប្រាប់គាត់ថា «បើខ្ញុំកើតទាន់សម័យនោះប្រហែលមិនរស់ទេ ព្រោះលំបាក ហើយហូបមិនគ្រប់» ។ ដិត បន្ថែមទៀតថា អតីតមេកងរបស់គាត់សព្វថ្ងៃនៅរស់នៅឡើយ ។ ទោះបីជាអតីតមេកងនោះជាមនុស្សចិត្តល្អក៏ដោយ ក៏គាត់មិនចង់ទៅសួរសុខទុក្ខដែរ ដោយសារ ដិត ស្អប់និងរបបខ្មែរក្រហមព្រោះរបបនេះធ្វើឲ្យគាត់ព្រាត់ប្រាសម្តាយស្លាប់ប្អូនស្រីពីរនាក់បងប្រុសម្នាក់និងក្មួយពីរនាក់ ។ ដិត បន្ថែមថា «ទោះកើតជាតិណាៗក៏ខ្ញុំនៅ តែស្អប់ខ្មែរក្រហមដែរ» ។

ចំពោះតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ដិត យល់ឃើញថានេះជាគំនិតល្អទោះបីជារឿងរ៉ាវកន្លងផុតទៅជាយូរឆ្នាំហើយក៏ដោយ ក៏មេដឹកនាំនោះត្រូវទទួលបានការកាត់ទោសដែរគឺមិនត្រូវឲ្យអ្នកដែលប្រព្រឹត្តិខុសរួចខ្លួនទេ ទោះចាស់ក៏ដោយ ។ដិត បាននិយាយថា «ដើម្បីកុំឲ្យក្មេងជំនាន់ក្រោយយកតម្រាប់តាមមេដឹកនាំខ្មែរក្រហមគឺក្មេងៗត្រូវតែខំរៀននិងដឹកនាំប្រទេសឲ្យរីកចម្រើនមានសន្តិភាព» ។ តែចម្ងល់នៅតែមានសម្រាប់ ដិត នៅឡើយ «ខ្ញុំចង់ដឹងថាហេតុអ្វីបានជាមេដឹកនាំទាំងនោះសម្លាប់ខ្មែរគ្នាឯង ។ បើធ្វើស្រែបានផលស្រូវច្រើន ហេតុអ្វីឲ្យហូបបបរ? ហើយរបស់ដែលខ្ញុំដាំបានហេតុអ្វីបានជាខ្ញុំហូបមិនបាន? ។ បើយើងជជែកគ្នាប្រុសនិងស្រីតែពីរនាក់គេចោទថា យើងខុសសីលធម៌ ឬយើងជជែកស្រីៗតែពីរនាក់គេថាយើងបំផុសបំផុល ។ ហេតុអ្វីបានជាយ៉ាងនេះ?»

ចុងបញ្ចប់ ដិត មិនចង់ឲ្យមានរបបនេះកើតឡើងម្តងទៀតព្រោះរបបនេះធ្វើឲ្យគាត់ឈឺចាប់ ហើយមិនចង់ឲ្យកូនចៅគាត់ជួបប្រទះដែរ ។

**រី លក្ខិណា**

# ដំណឹងស្វែករកញាតិ

នាងខ្ញុំឈ្មោះ លឹម ភានុវណ្ណវង្សសីហៈ រស់នៅសង្កាត់សន្សំកុសល្យ ខណ្ឌមានជ័យ ក្រុងភ្នំពេញ សូមប្រកាសរកពូឈ្មោះ ហាក់ អុល មកដល់បច្ចុប្បន្នមានអាយុ៧២ឆ្នាំ ។ កាលពីសម័យ លន់ នល់ ពូរបស់នាងខ្ញុំមានផ្ទះនៅទួលគោក ហើយគាត់ធ្វើជាប៉េអឹម ។ គាត់បានបែកពីគ្រួសារនៅមុំវត្តលង្កា ពេលដែលខ្មែរក្រហមជម្លៀសប្រជាជនចេញពីក្រុងឆ្នាំ១៩៧៥ ។ ចាប់តាំងពីពេលនោះមក គ្រួសារនាងខ្ញុំបាត់ដំណឹងគាត់រហូត ។

ប្រសិនបើ បងប្អូនណាបានដឹង ឬស្គាល់ឈ្មោះពូរបស់នាងខ្ញុំ សូមមេត្តាទាក់ទងមកនាងខ្ញុំតាមរយៈទូរស័ព្ទលេខ : ០១៥ ៥៥៥ ០០៧ ឬមជ្ឈមណ្ឌលឯកសារកម្ពុជា អាសយដ្ឋានលេខ៦៦ មហាវិថីព្រះសីហនុ ក្រុងភ្នំពេញ ឬទូរស័ព្ទលេខ : ០១២ ៩៩៦ ៧៥០ ។ សូមអរគុណ ។

# ខ្មែរឥស្លាមចង់ឱ្យមេដឹកនាំខ្មែរក្រហមនិយាយការពិត

កាលពីចុងខែមិនា ឆ្នាំ២០១២ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលដឹកនាំដោយ អេង កុកថាយ បានធ្វើការចាក់បញ្ចាំងការផ្សាយបន្តផ្ទាល់ពីការផ្តល់សក្ខីកម្មរបស់ ឌុច នៅភូមិឃ្លាំងស្បែក ស្រុកពញាឮ ខេត្តកណ្តាល ។ ឃ្លាំងស្បែកជាភូមិមួយដែលមានប្រជាជនរស់នៅចំនួន១៣៤០នាក់ឬ៣៣៧គ្រួសារដែលភាគច្រើនគឺជាខ្មែរឥស្លាម ។ ពេលសួរអ្នកភូមិអំពីប្រវត្តិឈ្មោះភូមិឃ្លាំងស្បែកនេះ អ្នកភូមិភាគច្រើននិយាយថាគាត់មិនដឹងពីប្រវត្តិឈ្មោះនេះទេ គឺគ្រាន់តែឮតគ្នាពីមាត់មួយទៅមាត់មួយតាមឪពុកម្តាយតែប៉ុណ្ណោះ ។ លោកអ៊ុំ ហិម ភាស់ ដែលមានអាយុ៨០ឆ្នាំបាននិយាយថា កាលពីរបបសង្គមរាស្ត្រនិយម មិនទាន់មានឈ្មោះភូមិឃ្លាំងស្បែកនៅឡើយទេគឺមានតែឃុំឃ្លាំងស្បែក ហើយក្នុងអំឡុងរបប លន់ នល់ ភូមិឃ្លាំងស្បែកជាតំបន់ប្រទាញប្រទង់រវាងកងទ័ព លន់ នល់ និងយោធាខ្មែរក្រហមដែលនៅម្ខាងម្នាក់ខណ្ឌដោយដងទន្លេសាប ។ ប្រជាជនក្នុងភូមិស្ថិតនៅក្រោមការគ្រប់គ្រងរបស់របប លន់ នល់ ជាប់តាមផ្លូវជាតិលេខ៥ រីឯយោធាខ្មែរក្រហមគ្រប់គ្រងនៅត្រើយទន្លេម្ខាងទៀត ។ ភាស់ និយាយថា ជាប្រចាំនៅពេលយប់ យោធាខ្មែរក្រហមតែងតែធ្វើការវាយឆ្មក់ដោយបាញ់រះមកលើអ្នកភូមិនៅពេលឃើញនរណាម្នាក់ធ្វើដំណើរឬធ្វើសកម្មភាពផ្សេងៗ ។ ពេលខ្មែរក្រហមឡើងកាន់អំណាច ប្រជាជនក្នុងភូមិឃ្លាំងស្បែកភាគច្រើនត្រូវបានខ្មែរក្រហមជម្លៀសទៅកាន់ខេត្តបន្ទាយមានជ័យ ។

ពេលនេះ អ្នកភូមិជាច្រើននាក់ដែលធ្លាប់ឈឺចាប់កាលពីជំនាន់ខ្មែរក្រហមបានមកចូលរួមមើលការចាក់ផ្សាយបន្តផ្ទាល់ពីសក្ខីកម្មរបស់ ឌុច រៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ក្រោយពីការសាកសួរក្នុងចំណោមអ្នកចូលរួមចំនួនសាមសិបនាក់ទាំងអស់គ្នាបានឆ្លើយថា គាត់ដឹងអំពីការកាត់ទោស ឌុច នៅសាលាក្តីខ្មែរក្រហម ។ ហ្សះ រ៉ស់ ភេទស្រី អាយុ៣៩ឆ្នាំជាខ្មែរឥស្លាមបានបញ្ចេញគំនិតយោបល់ថា «ខ្ញុំមានអារម្មណ៍ស្អប់ខ្ពើមនិងខឹងសម្បាយ៉ាងខ្លាំងទៅនឹងរបបខ្មែរក្រហមនៅពេលដែលខ្ញុំបានដឹងឮរឿងរ៉ាវទុក្ខលំបាកវេទនា និងឈឺចាប់របស់ម្តាយខ្ញុំដែលជារងគ្រោះម្នាក់



ខ្មែរឥស្លាមកំពុងអានទស្សនាវដ្តីស្វែងការពិតនិងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

ក្នុងចំណោមជនរងគ្រោះជាច្រើនទូទាំងប្រទេស» ។ ហ្សុះ រ៉ស់ បានបន្ថែមទៀតថា «ការកាត់ទោសមេដឹកនាំជាន់ខ្ពស់ក្រហមនាពេលបច្ចុប្បន្ននេះមិនផ្តល់អ្វីជាយុត្តិធម៌សម្រាប់ជនរងគ្រោះទេ ព្រោះមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមទាំងនោះមិនគ្រាន់តែមានមេធាវីការពារក្តីនូវអំពើឃោរឃៅរបស់ខ្លួនដែលបានប្រព្រឹត្តមកលើប្រជាជនទេ តែថែមទាំងមានជីវភាពរស់នៅស្រួលផង ពេលឈឺមានពេទ្យចាំជួយព្យាបាល ។ ក្នុងរបបដ៏ខ្មៅងងឹតនេះ ប្រជាជនមិនមានអាហារហូបគ្រប់គ្រាន់ គ្មានសិទ្ធិសេរីភាព គ្មានពេទ្យ ជួយព្យាបាលប្រកបដោយប្រសិទ្ធិភាពទេ» ។ ហ្សុះ រ៉ស់ បានបន្ថែមថា «ម្តាយខ្ញុំបានស្លាប់ភ្លាមក្រោយពីពេលកម្មាភិបាលខ្មែរក្រហមដែលគ្មានជំនាញបានចាក់ថ្នាំឲ្យគាត់» ។ អ្វីដែលមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមកំពុងតែមានសព្វថ្ងៃនេះ ហ្សុះ រ៉ស់ យល់ថាតុលាការខ្មែរក្រហមមិនបានផ្តល់យុត្តិធម៌ជូនគាត់ទេ ។ ជនជាតិខ្មែរឥស្លាមភាគច្រើនចង់ឲ្យមេដឹកជាន់ខ្ពស់ខ្មែរក្រហមទទួលខុសត្រូវនូវអំពើដែលបានប្រព្រឹត្តនិងផ្តល់ការពិតដល់ប្រជាជនព្រោះមេដឹកនាំទាំងនោះមានវ័យចាស់ជរាហើយ ។

ជារៀងរាល់ឆ្នាំ ខ្មែរឥស្លាមតែងតែធ្វើពិធីបុណ្យ «លើកលែងទោសគ្នាទៅវិញទៅមក» ដែលជាពិធីបុណ្យប្រពៃណីទំនៀមទម្លាប់តាំងពីដូនតាមកម្ល៉េះ ។

ប៉ុន្តែ ហ្សុះ រ៉ស់ នៅតែមិនអាចអត់ឱនទោសឲ្យមេដឹកនាំខ្មែរក្រហមបានដដែល «ខ្ញុំមិនលើកលែងឲ្យមេដឹកនាំខ្មែរក្រហមទាំងនោះបានទេ ទោះជាគាត់មកសុំការលើកទោសពីខ្ញុំក្តី» ។ ទាក់ទងទៅនិងករណី ឌុច ដែលត្រូវបានសាលាក្តីខ្មែរក្រហមកាត់ទោសឲ្យជាប់គុកអស់មួយជីវិត ហ្សុះ រ៉ស់ នៅតែគិតថាមិនមានយុត្តិធម៌នៅឡើយព្រោះ ឌុច រស់នៅស្រួលដេកស្រួលក្នុងគុក ។ អ្វីដែល ហ្សុះ រ៉ស់ ចង់បានគឺចង់ឲ្យ ឌុច ស្គាល់រស់ជាតិដូចអ្នកទោសគុកទួលស្លែងដែរ ដោយត្រូវបង្អត់អាហារនិងធ្វើទារុណកម្ម ។ ស្រដៀងគ្នានេះដែរ បុរសខ្មែរឥស្លាមឈ្មោះ ម៉ាក់ សាលិ អាយុ៤៣ឆ្នាំ បានលើកឡើងថា ឌុច ត្រូវតែបញ្ជូនទៅកាន់ពន្ធនាគារណាដែលមានលក្ខណៈដូចគុកខ្មែរក្រហម ហើយជាប្រភេទគុកងងឹតដើម្បីឲ្យស្គាល់រស់ជាតិទុក្ខលំបាកវេទនាដូចអ្នកទោសរបស់ខ្មែរក្រហមដែរ ។ តែ ម៉ាក់ សាលិ អាចលើកលែងទោសឲ្យខ្មែរក្រហមបាន «ខ្ញុំអាចទទួលយកការលើកទោសឲ្យមេដឹកនាំក្រហមបានពីព្រោះខ្ញុំទុកឲ្យព្រះជាអ្នកសម្រេចទោសកំហុសមេដឹកខ្មែរក្រហមទាំងនោះ ។ មយ៉ាងវិញទៀត មេដឹកខ្មែរក្រហមទាំងនោះសព្វថ្ងៃមានអាយុច្រើនណាស់ទៅហើយដូចនេះខ្ញុំមិនចងកម្មចងពៀរអ្វីនោះទេ» ។ សេចក្តីប្រាថ្នារបស់អ្នកចូលរួមក្នុងកម្មវិធីផ្សាយបន្តផ្ទាល់នេះគឺចង់ឲ្យមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមទាំងនោះមានការទទួលខុសត្រូវដោយនិយាយការពិតនូវទង្វើរបស់ខ្លួនដែលបានប្រព្រឹត្តមកលើជនរងគ្រោះគ្រប់រូបក្នុងពេលដែលខ្លួនបានកាន់អំណាច ។ ទាំងអស់គ្នាចង់ឲ្យមេដឹកនាំខ្មែរក្រហមបង្ហាញការពិតដល់ប្រជាជនកម្ពុជារួមទាំងមនុស្សជំនាន់ក្រោយឲ្យបានដឹងឲ្យយល់នូវទំព័រប្រវត្តិសាស្ត្ររបបនេះ ។

នាពេលបច្ចុប្បន្ននេះ មេដឹកដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលរួមមាន ៖ នួន ជា, ខៀវ សំផន និង អៀង សារី ហាក់បីដូចចង់គេចវេះមិនព្រមនិយាយពីអ្វីដែលខ្លួនធ្លាប់ធ្វើទេ ។ ក្រោមការដឹកនាំរបស់របបខ្មែរក្រហម ប្រជាជនជិតពីរលាននាក់បានបាត់បង់ជីវិតតាមរយៈការធ្វើទារុណកម្ម ការបង្អត់អាហារ និងការបង្ខិតបង្ខំឲ្យធ្វើការងារធ្ងន់ធ្ងរ ។ ប្រជាជនកម្ពុជាដែលរួចរានមានជីវិតមួយចំនួនធំគឺស្ត្រីមេម៉ាយ កុមារកំព្រា ហើយអ្នកទាំងអស់នេះត្រូវប្រឈមមុខនឹងការតស៊ូរស់រានមានជីវិតឡើងវិញបន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។ ប្រជាជនកម្ពុជាខ្លះមានជំងឺផ្លូវចិត្ត ក្រោយពីបានជួបប្រទះនូវបទពិសោធន៍យ៉ាងធ្ងន់ធ្ងរដែលបានប៉ះទង្គិចសតិបញ្ញាស្មារតីតាមរយៈការឃើញហេតុការណ៍ឈឺចាប់ដោយផ្ទាល់ភ្នែកដូចជាការស្លាប់ឪពុកម្តាយ បងប្អូនញាតិសន្តានឬមិត្តភក្តិ ។ ជំងឺនេះនៅតែដក់ជាប់នៅក្នុងខ្លួនរបស់អ្នកធ្លាប់ឆ្លងកាត់របបខ្មែរក្រហមនេះនៅឡើយ ។ ការបាត់បង់ធនធានទាំងនេះនាំឲ្យប៉ះពាល់ដល់ការអភិវឌ្ឍន៍ប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ ដែលរដ្ឋាភិបាលបានខិតខំស្តារធនធានមនុស្សឡើងវិញ ។ ប្រជាជនកម្ពុជានៅជនបទមិនច្រើនទេដែលមានឱកាសទទួលបានព័ត៌មានពីដំណើរការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ។ ប៉ុន្តែតាមការជួបផ្ទាល់ជាមួយប្រជាជនកម្ពុជាទាំងអស់គ្នាបាននិយាយថានិងត្រូវទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅកម្ពុជាឲ្យខានតែបាន ។

**ម៉ម សុវណ្ណ**

# «វិធីសាស្ត្រដែលធ្វើឱ្យគ្រួសារខ្ញុំរស់»

អ៊ំស្រី សុខ សារឿន អាយុ៦៣ឆ្នាំ មានប្តីធ្លាប់បម្រើការឲ្យរបប លន់ នល់ ។ សារឿន បានលាក់អត្តសញ្ញាណពីកម្មាភិបាលខ្មែរក្រហមក្នុងរបបនេះទាំងមូល ហើយ សារឿន បាននិយាយថា គាត់អាចរស់រានមានជីវិតរហូតដល់សព្វថ្ងៃនេះ ដោយសារគាត់កុហកបោកប្រាស់កម្មាភិបាលខ្មែរក្រហម ។ សារឿន បានហៅរបបខ្មែរក្រហមនេះថា "ជារបបដ៏ខ្មៅងងឹត" ។

ជាកូនទីពីរនៃគ្រួសារកសិករមួយនៅស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល សារឿន ធ្លាប់បានសិក្សារៀនសូត្ររហូតដល់ថ្នាក់ទី៧ ទើបឈប់ដើម្បីមកជួយធ្វើស្រែចម្ការឪពុកម្តាយ ។ នៅឆ្នាំ ១៩៧០ សារឿន បានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងទាហាន លន់ នល់ ម្នាក់ឈ្មោះ ប៉ែន រឹម ដែលមានស្រុកកំណើតនៅខេត្តស្វាយរៀង ដែលទើបតែផ្លាស់មកនៅទីក្រុងភ្នំពេញ ។ ខណៈពេលនោះ រឹម ជាប់រវល់ការងារយ៉ាងមមាញឹកដែលត្រូវបានបញ្ជូនទៅច្បាំងជាមួយនឹងយោធាខ្មែរក្រហមដើម្បីទប់ស្កាត់ក្រុមកុម្មុយនីស្ត ។ សារឿន បានអះអាងថា ប្តីរបស់គាត់ជាប់ភារកិច្ចច្បាំងរហូតដល់ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ពេលដែលរដ្ឋាភិបាល លន់ លន់ បរាជ័យ ។



សុខ សារឿន

សារឿន បានរៀបរាប់ពីប្រវត្តិរបស់គាត់ថា នៅថ្ងៃជម្លៀស គាត់និងប្តីរបស់គាត់ត្រូវបានជម្លៀសទៅដល់វត្តអង្គតាភោគ ស្រុកត្រាំកក់ ខេត្តតាកែវ ។ នៅទីនោះ កម្មាភិបាលខ្មែរក្រហមបានសួរពីប្រវត្តិរូបរបស់គាត់និងប្តីរបស់គាត់ ។ ដោយភាពស្មោះត្រង់ ប្តីរបស់គាត់បាននិយាយប្រាប់កម្មាភិបាលថា គាត់ធ្លាប់ធ្វើជាទាហាន លន់ នល់ ប៉ុន្តែគ្រាន់តែជាទាហានថ្នាក់តូចប៉ុណ្ណោះ គ្មានសក្តិបំពាក់នឹងគេទេ ។ នៅយប់ថ្ងៃដដែល កម្មាភិបាលខ្មែរក្រហមចាប់ផ្តើមចាប់ខ្លួនអ្នកដែលមានសក្តិមួយទាំងអស់ដាក់បញ្ជូនទៅតាមឡានរួចដឹកទៅបាត់ ។ សារឿន និយាយថា ចាប់ពីថ្ងៃដែលគាត់និងប្តីរបស់គាត់ឃើញទិដ្ឋភាពដូច្នេះ គាត់ក៏បានសម្រេចចិត្តលាក់អត្តសញ្ញាណរបស់គាត់រហូត ។ បីបួនខែក្រោយមក ខ្មែរក្រហមបានបញ្ជូនគ្រួសាររបស់គាត់ដែលមានកូនស្រីតូចម្នាក់ ព្រមទាំងគ្រួសារជាច្រើននាក់ទៀតមកនៅភ្នំធិបតី ខេត្តបាត់ដំបង ។ ពេលទៅដល់ខេត្តបាត់ដំបង សារឿន បាននិយាយថា ប្រជាជនថ្មី និងអ្នកមូលដ្ឋានត្រូវបានដាក់ឲ្យនៅដោយឡែកពីគ្នា ។ គ្រួសាររបស់ សារឿន ដែលជាប្រជាជនថ្មីត្រូវបានដាក់ឲ្យនៅឆ្ងាយពីប្រជាជនមូលដ្ឋាន ។ សារឿន ធ្វើការនៅកងនារីដែលមាននាទីធ្វើស្រែចម្ការ ដកស្ទូង និងលើកទំនប់ជាដើម ។ សារឿន បាននិយាយថា គាត់បានរួចរស់ដល់សព្វថ្ងៃដោយសារគាត់រណបនិងអែបអបកម្មាភិបាលដោយខិតខំធ្វើការមិនហ៊ានសម្រាក ។ សំណាងល្អ

កម្មាភិបាលខ្មែរក្រហមនៅខេត្តបាត់ដំបងមិនដឹងថា ប្ដីរបស់គាត់ធ្លាប់ធ្វើជាទាហានលន់ នល់ ទេ ដែលជាហេតុធ្វើឲ្យគាត់អាចរស់រានមានជីវិតបាន ។ សារឿន និងប្ដីរបស់គាត់ធ្លាប់ឃើញខ្មែរក្រហមនាំមនុស្សទៅសម្លាប់ទាំងក្រុមៗ ។ គ្រាមួយនៅពេល សារឿន និងប្ដីរបស់គាត់ទៅកាប់ឧសនៅក្បែរព្រៃ មានកម្មាភិបាលម្នាក់បានហាមគាត់មិនឲ្យចូលទៅក្នុងព្រៃជ្រៅទៀត ។ សារឿន គោរពតាមការហាមប្រាមនោះតែក្នុងចិត្តនៅតែចង់ដឹងពីមូលហេតុនេះ ។ រំពេចនោះ ពេលដែល សារឿន កំពុងកាប់ឧសស្រាប់តែគាត់ឮសំឡេងមនុស្សស្រែក ។ ពេលនោះគាត់នឹកស្មានថាប្រហែលជាមានមនុស្សត្រូវរងរបួសពេលកំពុងកាប់ឧស ។ គាត់ក៏ដើរចូលព្រៃជ្រៅបន្តិចគាត់ក៏បានឃើញឈ្លបកំពុងវាយមនុស្សនឹងដងចបនៅក្បែររណ្ដៅ ។ បន្ទាប់ពីបានឃើញហេតុការណ៍នោះមក គាត់មានអារម្មណ៍ភ័យតក់ស្លុតជាខ្លាំង ហើយរត់ទៅប្រាប់ប្ដីគាត់អំពីហេតុការណ៍នេះ ហើយប្ដីរបស់គាត់បានប្រាប់គាត់ឲ្យឈប់ទៅម្ដងនោះទៀត ។ កូនស្រីរបស់គាត់ដែលមានអាយុបីឆ្នាំត្រូវបានដាក់ឲ្យនៅជាមួយចាស់ៗនៅក្នុងភូមិ ។ រឹម ដែលជាប្ដីរបស់ សារឿន បានរៀបរាប់ថា ប្រពន្ធរបស់គាត់បានលៃទុកម្ហូបអាហារបន្តិចបន្តួចឲ្យគាត់ជានិច្ច ។ រឹម និយាយថា «ប្រពន្ធខ្ញុំស្រលាញ់និងចេះគិតគូរណាស់ទោះមានអ្វីក៏ទុកឲ្យខ្ញុំ និងកូនមិនដែលខានទេ សុខចិត្តអត់ខ្លួនឯង» ។

ពេលដែលវៀតណាមលើកទ័ពចូលមកដល់ខេត្តបាត់ដំបង សារឿន ស្ទើរតែមិនជឿទាល់តែសោះព្រោះគាត់អរជាខ្លាំង ។ គាត់មិនអាចបំភ្លេចគុណវៀតណាមបានទេដែលបានចូលរំដោះគាត់និងគ្រួសាររបស់គាត់ចេញពីរបបខ្មែរក្រហមដែលកំពុងតែយាយីជីវិតគាត់ ។ សារឿន និងក្រុមគ្រួសារបានត្រលប់មកស្រុកកំណើតវិញ ហើយបន្តរស់នៅទីនោះរហូតមកដល់សព្វថ្ងៃ ។

**និត្យ ធរន្ដារាណា**



សុខ សារឿន និងអ្នកភូមិផ្សេងទៀតកំពុងមើលការផ្សាយបន្តផ្ទាល់សវនាការ ឌុច

# គ្មានពាក្យថា “អត់ឱន”

អង្គុយជជែកលេងនៅលើផ្ទះកន្តាំងពីរខ្នង ខ្ញុំកត់សម្គាល់ឃើញថា ផ្ទះធំទូលាយនេះមានតែលោកយាយ និងលោកតាពីរនាក់ប៉ុណ្ណោះរស់នៅ ។ លោកយាយ អិត ណាន់ អាយុ៦៩ឆ្នាំ និងលោកតា សោម ឌុល អាយុ៧០ឆ្នាំ ។ យាយតា មានកូនបួននាក់ គឺស្រីបីនាក់ និងប្រុសម្នាក់ ។ កូនស្រីទាំងបីមានគ្រួសារ និងបែកទៅរស់នៅផ្ទះផ្សេង ចំណែកកូនប្រុសពៅបានទៅធ្វើការនៅខេត្តឆ្ងាយ ហើយរយៈពេលពីរអាទិត្យ ឬមួយខែទើបមកលេងផ្ទះម្តង ។

សព្វថ្ងៃយាយតារស់នៅស្រុកព្រះស្តេច ខេត្តព្រៃវែង ។ អំឡុងពេលខ្ញុំជជែកលេងជាមួយគាត់ពីរឿងរ៉ាវផ្សេងៗ ស្រាប់តែទឹកមុខរបស់ អិត ណាន់ ប្រែស្រងូតស្រងាត់មួយរំពេច បន្ទាប់ពីខ្ញុំបានសួរគាត់ទាក់ទងទៅនឹងរបបខ្មែរក្រហម ឬដែលប្រជាជនខ្មែរទូទៅហៅថារបប ប៉ុល ពត នោះ ។ គាត់បានសម្លឹងមើលមកខ្ញុំបន្តិចទៅដោយទុក្ខព្រួយ រួចនិយាយថា គាត់មិនដែលភ្លេចទេរបបបីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃ ភាពឈឺផ្សាវេទនាទាំងឡាយដែលបានជួបប្រទះវានៅតែដិតដាមនៅក្នុងចិត្តជានិច្ច ទោះបីជារឿងរ៉ាវទាំងនេះកន្លងផុតទៅជាងសាមសិបឆ្នាំហើយក៏ដោយ ។ អិត ណាន់ បន្តថា គាត់មិនអាចអត់ឱនឲ្យអ្នកទាំងនោះបានទេ ចំពោះទង្វើដែលគេបានធ្វើមកលើរូបគាត់ ។

ឈោងដៃយកក្រមាមកជូតមុខ ហើយងាកសម្លឹងទៅរកវាលស្រែខៀវស្រងាត់នៅមុខផ្ទះ អិត ណាន់ បានរៀបរាប់ពីជីវិតដ៏លំបាកនៅក្នុងរបបកាប់សម្លាប់នោះថា នៅឆ្នាំ១៩៧៥ ខ្មែរក្រហមកាន់កាប់កម្ពុជាទាំងស្រុង គាត់និងកូនតូចៗពីរនាក់ (ស្រីម្នាក់ ប្រុសម្នាក់) ព្រមទាំងប្តី មិនត្រូវបានខ្មែរក្រហមជម្លៀសចេញពីភូមិទេ ដោយហេតុថា គាត់ជាប្រជាជនមូលដ្ឋាន ប៉ុន្តែគ្រួសារគាត់ត្រូវធ្វើការដូចអ្នកថ្មីដែរ ។ នៅសហករណ៍ភូមិពោធិ៍ ណាន់ ត្រូវបានអង្គការចាត់តាំងឲ្យដកស្ទូង ចំណែកប្តីទៅអារឈើតាមភូមិស្រុកនានា ក្នុងតំបន់២៤ ខេត្តព្រៃវែង ។

នៅឆ្នាំ១៩៧៦ និងនៅដើមឆ្នាំ១៩៧៧ ការហូបចុកនៅភូមិពោធិ៍នេះមិនសូវជាពិបាកប៉ុន្មានទេ ព្រោះមនុស្សម្នាក់ទទួលបានស្រូវប្រាំមួយខាំក្នុងមួយថ្ងៃ ប៉ុន្តែក្រោយមកក៏មានការផ្លាស់ប្តូរមកហូបរួមនៅក្នុងសហករណ៍ ដោយថ្ងៃខ្លះមានតែរបប បបររាវពោតស្ងោរ ឬដំឡូងម្នាក់មួយដុំតែប៉ុណ្ណោះ ។ គាត់ឆ្ងល់ថា ស្រូវធ្វើបានច្រើនសន្ធឹកសន្ធាប់ ហេតុអ្វីបានជាអង្គការឲ្យប្រជាជនហូបបបរ ឬដំឡូង ដូច្នេះតើអង្គការដឹកស្រូវដែលគាត់ខំធ្វើទាំងយប់ទាំងថ្ងៃនេះទៅណា? គាត់បានដកដង្ហើមធំ ហើយងាកមករកខ្ញុំដោយពោលថា គាត់ចាំមិនភ្លេចទេ ខ្មែរក្រហមធ្វើឲ្យកូនប្រុសជាទីស្រឡាញ់របស់គាត់ស្លាប់ វាហាក់ដូចជាយកកាំបិតមកចាក់កាត់ផ្តាច់បេះដូងគាត់អីចឹងដែរ ។

ណាន់ រំឭកថា ប្រហែលក្នុងអំឡុងពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៧ កូនប្រុសពៅដែលមានអាយុទើបប្រាំមួយឆ្នាំប៉ុណ្ណោះឈឺគ្រុនក្តៅ គាត់បានទៅសុំថ្នាំពីពេទ្យភូមិដែលមានចម្ងាយមិនដល់១០០ម៉ែត្រផង ពីផ្ទះរបស់គាត់ ប៉ុន្តែពេលទៅដល់ទីនោះ អ្នកកាន់ថ្នាំឆ្លើយថា មិនមានសិទ្ធិបើកថ្នាំឲ្យទេដូច្នេះពេលព្រឹកចាំមកសុំពេទ្យទៅ ។ ណាន់ ត្រឡប់មកវិញទាំងក្តីអស់សង្ឃឹម ហើយដោយសារកូនគាត់មានជំងឺកាន់តែធ្ងន់ធ្ងរ ទើបស្លាប់នៅពេលនោះទៅ ចំណែក ណាន់ និងប្តី បានត្រឹមតែយំ និងឈឺចាប់ប៉ុណ្ណោះ ។ ក្រោយពីមរណភាពកូន ណាន់ និងប្តី ខិតខំធ្វើការងារមិនហ៊ានឈប់ ឬឈិលប្រអូសទេ ព្រោះពេលមានអ្នកឈឺម្តងៗ អង្គការតែងតែចោទថា នោះមានជំងឺសតិអារម្មណ៍ ឬជាគ្រុនទន្សាយទៅវិញ ។ ណាន់ បញ្ជាក់ថា អង្គការឲ្យគាត់ហូបតិច ប៉ុន្តែឲ្យធ្វើការច្រើន បើមិនធ្វើទេ អង្គការមិនចែកបាយ ឬបបរឲ្យហូបទេ ។ រាល់ថ្ងៃ ណាន់ ត្រូវធ្វើជាមនុស្សខ្វាក់ គរ ថ្លង់ និងប្រឹងប្រែងធ្វើការដើម្បីផ្គាប់ចិត្តអង្គការ ដើម្បីរក្សាជីវិតគាត់ កូន និងប្តី រហូតដល់វៀតណាមរំដោះនៅឆ្នាំ១៩៧៩ ។

អិត ណាន់ និយាយមួយៗថា ខ្មែរក្រហមមិនដែលធ្វើទុក្ខបុកម្នេញមកលើរាងកាយអ្វី ក្រៅពីដាក់ផែនការឲ្យធ្វើការងារ

នោះទេ ប៉ុន្តែអ្វីដែលធ្វើឲ្យខ្លួនឈឺចាប់នោះ គឺការបាត់បង់កូនជាទីស្រឡាញ់របស់គាត់ កាត់ផ្តាច់មនោសញ្ចេតនាបងប្អូន ប្តីប្រពន្ធ ហើយការធ្វើបាបផ្លូវចិត្តរបស់គាត់ហាក់ដូចជាស្រមោលដែលអន្ទោលតាមប្រាណគាត់ជាងសាមសិបឆ្នាំមកហើយ ។ ភាពឈឺចាប់ទាំងអស់នេះ វានៅតែជាស្នាមខ្មៅជិតនៅក្នុងចិត្តរបស់គាត់ ដែលមិនអាចលុបបាន ហើយក៏គ្មានពាក្យថា អត់ឱនចំពោះខ្មែរក្រហមទាំងនោះដែរ សម្រាប់រូបគាត់ ទោះបីរឿងរ៉ាវនេះកន្លងផុតទៅជាច្រើនឆ្នាំហើយក៏ដោយ ។

សព្វថ្ងៃនេះ ថ្វីបើ អិត ណាន់ និងប្តីមានវ័យជរាបន្តិចទៅហើយក៏ពិតមែន ប៉ុន្តែគាត់មានការចាប់អារម្មណ៍ពីដំណើរការនៃការកាត់ក្តីមេដឹកនាំខ្មែរក្រហម ។ គាត់សំណូមពរឲ្យតុលាការពន្លឿនការកាត់ទោសនេះឲ្យបានឆាប់ ហើយស្នើតុលាការដាក់ទោសឲ្យធ្ងន់ធ្ងរទៅលើមេដឹកនាំខ្មែរក្រហម ព្រោះប្រជាជនខ្មែរច្រើនណាស់បានស្លាប់នៅក្នុងអំឡុងពេលគ្រប់គ្រងរបស់គេ ។

អិត ណាន់ បានបញ្ជាក់ទៀតថា ការរៀនប្រវត្តិសាស្ត្រខ្មែរក្រហម មានសារសំខាន់ណាស់សម្រាប់កូនចៅជំនាន់ក្រោយឲ្យយល់ដឹង និងចងចាំដើម្បីទប់ស្កាត់កុំឲ្យរបបនេះកើតមានឡើងម្តងទៀត ។

**ផាន សារៈមុនិន្ទ**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរស័ព្ទលេខៈ (៨៥៥) (១៦) ៨៧៦ ៦៩២
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
*Email: truthsocheat@dccam.org*
*Home page: www.dccam.org*



អិត ណាន់ កំពុងស្តាប់ការរៀបរាប់ពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

# ការពារការសម្ងាត់របស់ដំណើរការស៊ើបអង្កេត ឬបិទមាត់អ្នកសារព័ត៌មាន? សេរីភាពនៃការបញ្ចេញមតិ

## ១) សេចក្តីផ្តើម

បើយើងសម្លឹងមើលមួយភ្លែត គុកទួលស្លែង គឺដូចជាសាលារៀនដទៃផ្សេងទៀតនៅទីក្រុងភ្នំពេញដែរ ។ សាលារៀននេះមានទីធ្លាផ្លូវដើរទូលាយ នៅតាមមុខបន្ទប់រៀននីមួយៗ ហើយមានកៅអីបង់តម្រៀបជាជួរដែលសិស្សសាលាធ្លាប់រត់លេងនៅលើទីធ្លានេះ ។ ប៉ុន្តែក្នុងខ្សែភ្នែកភ្ញៀវទេសចរណ៍វិញ គុកទួលស្លែងដែលក្លាយជាសារមន្ទីរប្រល័យពូជសាសន៍នេះឆ្លុះបញ្ចាំងឲ្យឃើញនូវកេរដំណែលដ៏ជូរចត់របស់ខ្មែរក្រហម ។ បន្ទាលួសរុំព័ទ្ធជុំវិញរបងទ្វារចូល ហើយឧបករណ៍ធ្វើទារុណកម្មអ្នកទោសគរដេរដាសនៅក្នុងទីធ្លាតូចមួយនៅក្នុងអតីតបន្ទប់រៀននៃគុកទួលស្លែងនេះវិញ ឈាមរបស់អ្នកទោសប្រឡាក់ពាសពេញនោះ ហើយរនុកដែកនិងច្រវាក់ទុកគរចោលនៅនឹងមួយកន្លែងដែលស្ថានភាពនេះមើលទៅហាក់បីដូចជាខ្មែរក្រហមទើបតែរត់ចោលគុកទួលស្លែងកាលពីប៉ុន្មានថ្ងៃមុននេះដោយសារតែការវាយលុករបស់កងទ័ពវៀតណាម ។

គុកទួលស្លែងដែលស្គាល់ថាជាមន្ទីរស-២១ដែលត្រូវបានកែប្រែមកជាមន្ទីរឃុំឃាំងរបស់ខ្មែរក្រហមគឺជាមន្ទីរសន្តិសុខរបស់ខ្មែរក្រហមដែលឡើងកាន់កាប់អំណាចប្រទេសកម្ពុជានៅថ្ងៃទី១៧



ក្រុមអ្នកសារព័ត៌មានកំពុងសម្ភាស លី ហឹរ

ខែមេសា ឆ្នាំ១៩៧៥ ។ នៅក្នុងរយៈពេលបួនឆ្នាំ ប្រជាជនកម្ពុជាប្រមាណជិតពីរលាននាក់ត្រូវបានសម្លាប់ក្រោមរបបគ្រប់គ្រងកុម្មុយនីស្តផ្តាច់ការកម្ពុជាប្រជាធិបតេយ្យ ។ ដោយខំប្រឹងប្រែងប្រែក្លាយប្រទេសកម្ពុជាឲ្យទៅជាប្រទេសដែលគ្មានការបែងចែកវណ្ណៈ ដោយលុបបំបាត់ចោលលុយនិងទ្រព្យសម្បត្តិឯកជន ខ្មែរក្រហមបានជម្លៀសប្រជាជន “ថ្មី” ចេញពីទីក្រុងនិងទីប្រជុំជនទៅកាន់តំបន់ជនបទដែលប្រជាជនទាំងអស់នេះត្រូវបានបង្ខំឲ្យស្លៀកខោអាវឈុតខ្មៅ ហើយធ្វើការងារពលកម្មស្រែចម្ការ ។ អង្គការបដិវត្តន៍ដែលជាឈ្មោះរដ្ឋាភិបាលកំបាំងមុខរបស់ខ្មែរក្រហមបានទាមទារនូវភាពស្មោះស្ម័គ្រខ្ពស់ ។ ដូច្នេះហើយ ខ្មែរក្រហមបានកាប់សម្លាប់អ្នកចេះដឹង មន្ត្រីរដ្ឋាភិបាលចាស់និងជនសង្ស័យដែលខ្លួនគិតថាជាជនក្បត់ជាច្រើនផ្សេងទៀតដោយគ្មានក្រេងញញើតអ្វីឡើយ ។



ប្ញូជនីយដ្ឋានតម្កល់អដ្ឋិធាតុបឹងជើងឯក

នៅក្នុងមន្ទីរស-២១ អ្នកទោសប្រមាណមួយម៉ឺនបួនពាន់នាក់ត្រូវបានធ្វើទារុណកម្ម និងសម្លាប់ក្រោមបញ្ជារបស់ ឌុច ដែលជាមេដឹកនាំដ៏សាហាវព្រៃផ្សៃ ។ រយៈពេលសាមសិបឆ្នាំកន្លងផុតទៅនៅខែកក្កដា ឆ្នាំ២០១០ ឌុច ត្រូវបានរកឃើញថាមានពិរុទ្ធភាពនៅក្នុងសំណុំរឿង០០១ នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលជាតុលាការកូនកាត់របស់អង្គការសហប្រជាជាតិនិងតុលាការកម្ពុជាដែលត្រូវបានបង្កើតឡើងដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់និងជនដែលមានការទទួលខុសត្រូវខ្ពស់បំផុតសម្រាប់ឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តមកលើប្រជាជនកម្ពុជា ។

បើទោះបីជាប្រជាជនកម្ពុជាបានរង់ចាំយុត្តិធម៌អស់រយៈពេលជាងសាមសិបឆ្នាំក៏ដោយ ក៏នៅក្នុងអំឡុងពេលស៊ើបអង្កេតរបស់តុលាការ សាធារណជនត្រូវបានដកហូតនូវសិទ្ធិទទួលបានព័ត៌មានដែលទាក់ទងនឹងសំណុំរឿងរបស់តុលាការខ្មែរក្រហម ។ ជាផ្នែកមួយនៃដំណើរការស៊ើបអង្កេតនៅឆ្នាំ២០០៨ ការវិលទៅពិនិត្យមើលគុកទួលស្លែងនិងវាលពិឃាតជើងឯកដែលជាទីតាំងរណ្តៅកប់សាកសពដ៏ធំមួយនៅជាយក្រុងភ្នំពេញបានធ្វើឲ្យមានការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់សាធារណជន ។ ទាំងសាធារណជននិងអ្នកសារព័ត៌មានបាននាំគ្នាទៅទីតាំងទាំងពីរនោះដើម្បីតាមដានព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយនេះ ។ ផ្ទុយទៅវិញ អ្នកសារព័ត៌មានត្រូវបានហាមឃាត់មិនឲ្យចូលរួមដោយក្រុមប៉ូលីសប្រដាប់ដោយអាវុធអាកា៤៧ ហើយក្រុមប៉ូលីសនេះបានធ្វើការបិទផ្លូវមិនឲ្យមានការធ្វើដំណើរចេញចូលទៀតផង ។ សហចៅក្រមស៊ើបអង្កេតបានហាមប្រាមមិនឲ្យអ្នកសារព័ត៌មាននិងសាធារណជនដទៃផ្សេងទៀតតាមដានព្រឹត្តិការណ៍នេះទេ ហើយបានបង្គាប់ឲ្យបិទសារមន្ទីរទួលស្លែងនេះមិនឲ្យសាធារណជនឬភ្ញៀវទេសចរណ៍ណាចូលទស្សនាដែរ ។ អ្នកសារព័ត៌មានខ្លះដែលបានព្យាយាមចូលទៅជិតដើម្បីតាមដានព្រឹត្តិការណ៍នេះត្រូវបានព្រមានដោយមន្ត្រីតុលាការថា ប្រសិនបើព័ត៌មាននេះចុះនៅក្នុងកាសែត នោះអ្នកសារព័ត៌មានត្រូវតែទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន ហើយអាចនឹងត្រូវបានចុះក្នុងបញ្ជីខ្មៅរបស់តុលាការ ។ ក្រុមប៉ូលីសបានសួរចម្លើយអ្នកសារព័ត៌មានអស់រយៈពេលជាច្រើនម៉ោង ព្រមទាំងបំផ្លាញរូបថត

របស់អ្នកសារព័ត៌មានចោល ហើយបានព្រមានដល់អ្នកសារព័ត៌មានពីបទរំលោភលើដំណើរការស៊ើបអង្កេតសម្ងាត់របស់តុលាការ ។

ប៉ុន្តែបច្ចុប្បន្ននេះតុកកុទូលស្លែងគឺជាសារមន្ទីរមួយដែលទទួលស្វាគមន៍សាធារណជននិងភ្ញៀវទេសចរណ៍ឲ្យចូលរួមទស្សនាដោយឥតគិតថ្លៃ ហើយជំរុញសាធារណជនឲ្យស្វែងយល់ពីប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតរបស់កម្ពុជានិងពី ឌុច ដែលជាមនុស្សសាហាវព្រៃផ្សៃនិងជាជនត្រូវបានតុលាការបិទបាំងអត្តសញ្ញាណនៅក្នុងអំឡុងពេលស៊ើបអង្កេត ។ មូលហេតុដែលអ្នកសារព័ត៌មានមិនត្រូវបានអនុញ្ញាតឲ្យដឹងពីព័ត៌មានទាក់ទងនឹងការស៊ើបអង្កេតមានលក្ខណៈមិនច្បាស់លាស់ឡើយ ដោយសារតែចៅក្រមមិនបានផ្តល់មូលហេតុនៃការបញ្ចប់ដំណើរការស៊ើបអង្កេតនីមួយៗរបស់ខ្លួនឲ្យបានច្បាស់លាស់ ។

ការរឹតត្បិតអ្នកសារព័ត៌មានមិនឲ្យតាមដានព្រឹត្តិការណ៍ស៊ើបអង្កេតនៅតុកកុទូលស្លែងមិនមែនជាព្រឹត្តិការណ៍ដែលកម្រកើតឡើងនោះទេ ផ្ទុយទៅវិញនេះគឺជាឧទាហរណ៍មួយនៃព្រឹត្តិការណ៍ច្រើនផ្សេងទៀតដែលតុលាការខ្មែរក្រហមបានរឹតត្បិតមិនឲ្យសាធារណជនទទួលបានព័ត៌មានទាក់ទងនឹងតុលាការ ហើយលាក់បាំងការសម្ងាត់របស់តុលាការ ។ យ៉ាងណាមិញ ក្រៅពីការនាំមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមកកាត់ទោស តុលាការខ្មែរក្រហមដែលដើរតួជាតុលាការកាត់ទោសកូនកាត់មួយនេះមានគោលដៅធំៗចំនួនពីរដែលទាក់ទងនឹងសារសំខាន់នៃការចូលរួមរបស់សាធារណជននិងការជឿទុកចិត្តលើតុលាការ ៖ ១) ដើម្បីការផ្សះផ្សាជាតិសម្រាប់ប្រជាជនកម្ពុជា និង ២) ដើម្បីផ្តល់គំរូដល់ប្រព័ន្ធច្បាប់កម្ពុជា ។ ការមិនទទួលបាននូវព័ត៌មានរបស់សាធារណជនទាក់ទងនឹងដំណើរការនិតិវិធីរបស់តុលាការបានគំរាមកំហែងដល់តុលាការខ្មែរក្រហមក្នុងការសម្រេចគោលដៅរបស់ខ្លួន ហើយតុលាការនេះអាចបានត្រឹមតែបន្សល់ទុកនូវកេរដំណែលដែលជាអំពើពុករលួយជាជាងកេរដំណែលដែលជាយុត្តិធម៌ ។

ការសន្ធតដ៏តឹងរ៉ឹងរបស់តុលាការខ្មែរក្រហមស្តីពីការលាក់ការសម្ងាត់នៅក្នុងដំណើរការស៊ើបអង្កេតមុនអង្គជំនុំជម្រះក្តីមិនត្រឹមតែក្លាយជាឧបសគ្គក្នុងការសម្រេចបានយុត្តិធម៌ប៉ុណ្ណោះទេ តែថែមទាំងធ្វើឲ្យការជឿទុកចិត្តរបស់សាធារណជនមកលើតុលាការមានការថយចុះ ។ មន្ត្រីតុលាការខ្មែរក្រហមបានគំរាមកំហែងដាក់ទណ្ឌកម្មលើអ្នកសារព័ត៌មានសម្រាប់ការចុះផ្សាយព័ត៌មានសម្ងាត់របស់តុលាការដែលអនុលោមទៅតាមវិធានផ្ទៃក្នុង៣៥របស់តុលាការដែលជាបញ្ញត្តិមួយដែលអនុញ្ញាតឲ្យមានការដាក់ទណ្ឌកម្មលើអ្នក «ដែលជ្រៀតជ្រែកលើការគ្រប់គ្រងលើវិស័យយុត្តិធម៌របស់តុលាការ» ។ ការគំរាមកំហែងមកលើអ្នកសារព័ត៌មានដែលចុះផ្សាយព័ត៌មានថ្មីៗរបស់តុលាការបានបណ្តាលឲ្យមានការរិះគន់យ៉ាងខ្លាំងមកលើតុលាការខ្មែរក្រហមពីសំណាក់អ្នកសារព័ត៌មានសហគមន៍អង្គការមិនយកប្រាក់កម្រៃ និងស្ថាប័នផ្សេងៗទៀត ។ ហើយការរារាំងមិនឲ្យអ្នកសារព័ត៌មានទទួលបានព័ត៌មាននេះអាចក្លាយជាគំរូមិនល្អមួយដល់ប្រទេសកម្ពុជាដែលជាប្រទេសពុករលួយមួយក្នុងចំណោមប្រទេសផ្សេងៗទៀតជុំវិញពិភពលោកដែលសេរីភាពរបស់អ្នកសារព័ត៌មានត្រូវបានរឹតត្បិតយ៉ាងខ្លាំង ហើយការលើកមូលហេតុថាប៉ះពាល់ដល់កេរ្តិ៍ឈ្មោះច្បាប់ក្នុងស្រុកនិងការរាយការណ៍ព័ត៌មានមិនពិតត្រូវបានប្រើប្រាស់ជាញឹកញាប់ដោយតុលាការកម្ពុជាដើម្បីគំរាមកំហែងអ្នកសារព័ត៌មាន ។

ការចោទប្រកាន់ពីការជ្រៀតជ្រែករបស់អ្នកសារព័ត៌មាននៅឯតុលាការអន្តរជាតិមិនមែនជាបញ្ហាចម្លែកនោះទេ សម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិបានធ្វើការកាត់ទោសអ្នកសារព័ត៌មានជាច្រើននាក់នៅក្នុងអង្គនីតិវិធីបទប្រមាថមើលងាយតុលាការ ។ យ៉ាងណាមិញ អ្វីដែលជារឿងចម្លែកនោះគឺទាក់ទងនឹងមូលដ្ឋានគោលការណ៍របស់តុលាការខ្មែរក្រហមស្តីពីច្បាប់ ស៊ីវិលឡ និងយុត្តាធិការរបស់តុលាការដើម្បីកាត់ទោសបទឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងអំឡុងទសវត្សរ៍៧០ ។ ខុសពីតុលាការដែលអនុវត្តច្បាប់ខំមិនឡ ដែលប្រើប្រាស់បទបញ្ញត្តិស្តីពីការសម្ងាត់តុលាការខ្មែរក្រហមសន្មតថា ជនសង្ស័យទាំងអស់ដែលត្រូវបានស៊ើបអង្កេតមុនអង្គជំនុំជម្រះក្តីចាប់ផ្តើមត្រូវតែលាក់ការណ៍សម្ងាត់សូម្បីតែព័ត៌មានសម្រាប់សាធារណជនក៏ដោយ ។ ហេតុដូច្នេះ អ្នកសារព័ត៌មានដែលមិនដឹងថាព័ត៌មានដែលខ្លួនបានផ្សព្វផ្សាយត្រូវបានការពារនោះត្រូវតែគោរពតាមគោលការណ៍របស់តុលាការស្តីពីកាតព្វកិច្ចរក្សាការសម្ងាត់ ។ ដោយសារតែគោលការណ៍សន្មតដ៏តឹងរឹងស្តីពីការសម្ងាត់ទាំងអស់នេះនិងដោយសារតែកាតព្វកិច្ចរក្សាការ

សម្ងាត់ដ៏ធំធេងនិងបទដ្ឋានមិនច្បាស់លាស់ទាក់ទងនឹងការដាក់ទណ្ឌកម្មដូចដែលអនុលោមតាមវិធានផ្ទៃក្នុង៣៥របស់តុលាការខ្មែរក្រហមបានចោទជាបញ្ហាដល់តុលាការខ្មែរក្រហមដែលជាតុលាការមួយដែលសាធារណជនបានជឿជាក់ ។ ដោយសារតែការដាក់ទណ្ឌកម្មលើអ្នកសារព័ត៌មាននៅក្នុងប្រទេសកម្ពុជាអាចនឹងកើតមានឡើង នោះសេចក្តីសន្និដ្ឋាននេះ សូមណែនាំថាតុលាការខ្មែរក្រហមដើរខុសពីយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីក្នុងការកាត់ទោសពីបទប្រមាថមើលងាយដែលមិនធ្វើការទាមទារឲ្យមានការរកឃើញនូវចេតនាជាក់លាក់ឬប្រភពឯកសារដែលជ្រៀតជ្រែកវិស័យយុត្តិធម៌ដើម្បីដាក់ទណ្ឌកម្មនោះទេ ហើយអាទិភាពនេះក៏ជំរុញឲ្យមានការវិវឌ្ឍន៍ទៅជាការវិនិច្ឆ័យមួយដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងការវិនិច្ឆ័យដែលតុលាការសិទ្ធិមនុស្សអឺរ៉ុបបានប្រើប្រាស់ ។

តុលាការនេះបានយល់ឃើញថាការជ្រៀតជ្រែកលើសេរីភាពក្នុងការបញ្ចេញមតិយោបល់គឺជារឿងមួយដែលត្រឹមត្រូវតាមផ្លូវច្បាប់ មានសារសំខាន់ និងមានកម្រិតសមរម្យ ។

ផ្នែកទីពីរនៃសេចក្តីសន្និដ្ឋាននេះ បកស្រាយពីការសន្មតទុកនូវការសម្ងាត់របស់តុលាការនិងការរឹតត្បិតមកលើការទទួលបានព័ត៌មានថ្មីៗខណៈពេលដែលផ្នែកទីបីពិនិត្យមើលឡើងវិញនូវយុត្តិសាស្ត្រសម្រាប់ការកាត់ទោសពីបទប្រមាថមើលងាយរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ។ ចំណែកឯផ្នែកទីបួនពន្យល់បកស្រាយពីបទដ្ឋានដែលបង្កើតឡើងដោយតុលាការសិទ្ធិមនុស្សអឺរ៉ុបដែលតុលាការនេះបានយល់ថាការរឹតត្បិតលើសេរីភាពក្នុងការបញ្ចេញមតិយោបល់ត្រូវតែមានសារសំខាន់និងមានកម្រិតសមរម្យដើម្បីបម្រើដល់គោលដៅត្រឹមត្រូវតាមផ្លូវច្បាប់ មុនពេលដែលសេរីភាពក្នុងការបញ្ចេញមតិយោបល់របស់អ្នកសារព័ត៌មានអាចនឹងជ្រៀតជ្រែកនៅក្នុងអំឡុងពេលស៊ើបអង្កេតសម្ងាត់របស់តុលាការ ។ ផ្នែកទីប្រាំស្នើសុំឲ្យមានសេចក្តីណែនាំមួយចំនួនសម្រាប់ការដាក់ទណ្ឌកម្មលើអ្នកសារព័ត៌មាននៅឯតុលាការខ្មែរក្រហម ។ ដើម្បីសម្រេចគោលដៅរបស់តុលាការក្នុងការសម្របសម្រួលដល់ការផ្សះផ្សាជាតិ និងធ្វើជាគំរូមួយសម្រាប់ប្រព័ន្ធច្បាប់កម្ពុជា ផ្នែកចុងក្រោយនៃសេចក្តីសន្និដ្ឋាននេះបានសន្និដ្ឋានបញ្ចប់ថា តុលាការខ្មែរក្រហមគួរតែបញ្ជាក់ឲ្យច្បាស់ពីព័ត៌មានដែលត្រូវបាន ការពារដោយបទបញ្ញត្តិស្តីពីការសម្ងាត់ ហើយតុលាការត្រូវចេញសេចក្តីព្រមាននៅពេលដែលបទបញ្ញត្តិទាំងនោះត្រូវបានរំលោភបំពាន ។ ហើយទីបី តុលាការខ្មែរក្រហមគួរតែវាយតម្លៃលើការដាក់ ទណ្ឌកម្មដោយឈរលើមូលដ្ឋានតាមសាច់រឿងដែលធ្វើការពិចារណាលើព័ត៌មានដែលចាត់ទុកជាការជ្រៀតជ្រែកលើសារសំខាន់នៃវិធានការស្តីពីការសម្ងាត់និងចេតនារបស់ជនជាប់ចោទ ។

## ២) ការសន្មតពីការលាក់ការសម្ងាត់ និងការទទួលបានព័ត៌មានរបស់អ្នកសារព័ត៌មាននៅឯតុលាការខ្មែរក្រហម

បើទោះបីជាប្រភពនៃច្បាប់គ្រប់គ្រងតុលាការខ្មែរក្រហមដូចជាកិច្ចព្រមព្រៀងជារចនាសម្ព័ន្ធរបស់អង្គការសហប្រជាជាតិ ច្បាប់តុលាការខ្មែរក្រហមនិងវិធានផ្ទៃក្នុងរបស់តុលាការខ្មែរក្រហមឆ្លុះបញ្ចាំងពីគោលបំណងការពារការទទួលបានព័ត៌មានរបស់សាធារណជនទាក់ទងនឹងអង្គនីតិវិធីរបស់តុលាការក៏ដោយ ក៏ប្រភពនៃច្បាប់គ្រប់គ្រងតុលាការខ្មែរក្រហមទាំងអស់នេះបានដាក់បញ្ចូលបទបញ្ញត្តិស្តីពីការរក្សាការសម្ងាត់នៅក្នុងអំឡុងពេលស៊ើបអង្កេតមុនអង្គជំនុំជម្រះក្តីចាប់ផ្តើម ។ ផ្នែក “ក” នៃបទបញ្ញត្តិនេះចែងពីសេចក្តីសន្និដ្ឋានសង្ខេបមួយស្តីពីតុលាការខ្មែរក្រហមនិងបទបញ្ញត្តិផ្សេងទៀតដែលការពារការទទួលបានព័ត៌មានរបស់សាធារណជន ហើយចំណែកឯផ្នែក “ខ” សង្ខេបពីបទបញ្ញត្តិស្តីពីការលាក់ការសម្ងាត់នៅក្នុងអំឡុងពេលមុនអង្គជំនុំជម្រះក្តី ។ ផ្នែក “គ” ឆ្លុះបញ្ចាំងពីភាពតានតឹងរវាងការទទួលបានព័ត៌មានរបស់សាធារណជននិងការស៊ើបអង្កេតសម្ងាត់តាមរយៈការពិនិត្យមើលឡើងវិញនូវការទទួលបានព័ត៌មានរបស់អ្នកសារព័ត៌មាននៅក្នុងប្រទេសកម្ពុជានិងអាកប្បកិរិយារបស់អ្នកសារព័ត៌មានប្រចាំការនៅតុលាការខ្មែរក្រហម ហើយផ្នែកនេះធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ដោយការវិភាគមួយស្តីពីយុត្តិសាស្ត្រថ្មីៗរបស់តុលាការខ្មែរក្រហមទាក់ទងនឹងការដាក់ទណ្ឌកម្ម ។

### ១) តុលាការកូនកាត់ដែលនឹងដើរតួជាយានមួយសម្រាប់ការផ្សះផ្សាជាតិ និងជាគំរូមួយសម្រាប់ព្រះរាជាណាចក្រកម្ពុជា

តុលាការខ្មែរក្រហមគឺជាសមិទ្ធផលមួយនៃការចរចាដ៏

សស្រាក់សស្រាំរវាងព្រះរាជាណាចក្រកម្ពុជានិងអង្គការសហប្រជាជាតិ ។ ក្រោយពីការជជែកដេញដោលជាច្រើនលើកច្រើនសាទាក់ទងនឹងរចនាសម្ព័ន្ធរបស់តុលាការខ្មែរក្រហមទីតាំងវិសាលភាពនៃយុត្តាធិការនិងសមាសធាតុនៃបុគ្គលិកតុលាការខ្មែរក្រហម តុលាការខ្មែរក្រហមត្រូវបានបង្កើតឡើងជាតុលាការកូនកាត់ ។ ជាជាងដើរតួជាតុលាការបម្រើឲ្យអង្គការសហប្រជាជាតិ តុលាការខ្មែរក្រហមត្រូវបានស្ថាបនាឡើងដោយអនុវត្តតាមប្រព័ន្ធច្បាប់ក្នុងស្រុករបស់កម្ពុជា ប៉ុន្តែតុលាការនេះក៏អនុញ្ញាតឲ្យមានការចូលរួមនិងការចែករំលែកជាសេចក្តីណែនាំពីសំណាក់សហគមន៍អន្តរជាតិតាមបទដ្ឋានអន្តរជាតិ ។ នីតិវិធីរបស់តុលាការខ្មែរក្រហមត្រូវតែដើរស្របទៅតាមច្បាប់នីតិវិធីកម្ពុជា ប៉ុន្តែកិច្ចព្រមព្រៀងស្តីពីរចនាសម្ព័ន្ធរបស់តុលាការចែងថានៅពេលដែលច្បាប់កម្ពុជាមិនអាចដោះស្រាយបញ្ហាណាមួយឬនៅពេលដែលច្បាប់កម្ពុជាមិនមានលក្ខណៈច្បាស់លាស់ឬនៅពេលដែលច្បាប់កម្ពុជាមិនមានភាពស៊ីសង្វាក់គ្នានឹង “បទដ្ឋានអន្តរជាតិ នោះតុលាការខ្មែរក្រហមគួរតែដើរតាមសេចក្តីណែនាំស្តីពីវិធាននីតិវិធីដែលមានបទដ្ឋានជាអន្តរជាតិ” ។ មុននឹងឈានដល់ការអនុម័តនីតិវិធីក្រមព្រហ្មទណ្ឌកម្ពុជានៅខែសីហា ឆ្នាំ២០០៧ តុលាការខ្មែរក្រហមបានចែង “វិធានផ្ទៃក្នុង” ដោយប្រើប្រាស់អំណាចចេញសេចក្តីសម្រេចរបស់ខ្លួន ។ ដូច្នេះវិធានផ្ទៃក្នុងគឺជា “វិធីសាស្ត្រសំខាន់ដែលគួរតែប្រើប្រាស់ធ្វើជាសេចក្តីយោងក្នុងការកំណត់អង្គនីតិវិធីនៅចំពោះតុលាការខ្មែរក្រហម នៅពេលដែលមានភាពខុសគ្នារវាងនីតិវិធីនៅក្នុងវិធានផ្ទៃក្នុងនិងនីតិវិធីក្រមព្រហ្មទណ្ឌកម្ពុជា ។ តុលាការកូនកាត់ដូចជាតុលាការខ្មែរក្រហមនេះមានគោលបំណង ចងភ្ជាប់ភាគីពីររួមគ្នាគឺអ្នកជំនាញរបស់សហគមន៍អន្តរជាតិនិងភាពត្រឹមត្រូវតាមផ្លូវច្បាប់របស់អ្នកជំនាញក្នុងប្រទេសកម្ពុជា” ។ អ្នកចរចាបានអនុម័តយករចនាសម្ព័ន្ធតុលាការកូនកាត់ឲ្យតុលាការខ្មែរក្រហមដើម្បីសម្របសម្រួលដល់ការសម្រេចគោលដៅរបស់តុលាការក្នុងការនាំយកអតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមកកាត់ទោសនិងបន្តកិច្ចការសំខាន់ពីររបស់តុលាការខ្មែរក្រហមក្នុងនោះគឺ ៖ ដើម្បីធ្វើជាយានមួយដើម្បីការផ្សះផ្សាជាតិ និង ដើម្បីធ្វើជាគំរូសម្រាប់ប្រព័ន្ធច្បាប់កម្ពុជា ។

## ក) តុលាការកូនកាត់ដើម្បីសម្របសម្រួលដល់ការផ្សះផ្សាជាតិ

គោលដៅចម្បងមួយនៃគោលដៅចម្បងផ្សេងទៀតរបស់តុលាការខ្មែរក្រហមគឺដើម្បីសម្របសម្រួលដល់ការផ្សះផ្សាជាតិសម្រាប់ប្រជាជនកម្ពុជាតាមរយៈការស្វែងរកការពិត ។ មានការសួរដេញដោលថាតុលាការកូនកាត់ជាច្រើនមានសក្តានុពលភាពខ្លាំងក្នុងការចងក្រងប្រវត្តិសាស្ត្រមួយដ៏ពេញលេញ ពីព្រោះតុលាការទាំងអស់នេះត្រូវបានដំណើរការនៅក្នុងប្រទេសដែលមានឧក្រិដ្ឋកម្មកើតមានឡើងហើយភស្តុតាងងាយនឹងរកឃើញ ហើយប្រជាជនក្នុងតំបន់មានភាពងាយស្រួលក្នុងការទទួលបានព័ត៌មានអំពីអង្គជំនុំជម្រះរបស់តុលាការ ។ ការចងក្រងប្រវត្តិសាស្ត្រដ៏ត្រឹមត្រូវបម្រើជាប្រយោជន៍ដ៏សំខាន់ដល់ប្រទេសកម្ពុជាពីព្រោះថា បើទោះបីជាមានជនរងគ្រោះពីរបបខ្មែរក្រហមនិងកេរដំណែលនៃអំពើហិង្សានៅមានសេសសល់ក្រោយពីការសម្លាប់រង្គាលរបស់ខ្មែរក្រហមក៏ដោយ ក៏សាធារណជនមិនសូវដឹងពីរចនាសម្ព័ន្ធនៃរដ្ឋាភិបាលខ្មែរក្រហមនិងកត្តាដែលជំរុញឲ្យខ្មែរក្រហមប្រព្រឹត្តអំពើហិង្សាជាទ្រង់ទ្រាយធំនេះណាស់ ។ បន្ថែមលើនេះ អ្នករស់រានមានជីវិតមិនសូវបានពិភាក្សាចែករំលែកបទពិសោធពីរបបខ្មែរក្រហមដែលត្រូវបានចាត់ទុកថាជាប្រវត្តិសាស្ត្រខ្មៅងងឹតរបស់កម្ពុជានេះប៉ុន្មានទេ ។ នេះគឺដោយសារតែបញ្ហាវប្បធម៌ ។ លុះរហូតដល់មានការបង្រៀនកូនសិស្សសាលាពីប្រវត្តិសាស្ត្រខ្មែរក្រហមទើបប្រជាជនកម្ពុជាចាប់ផ្តើមនាំគ្នានិយាយពីប្រវត្តិសាស្ត្រនេះ ។

តុលាការខ្មែរក្រហមទទួលស្គាល់សារសំខាន់នៃការផ្សះផ្សាជាតិជាទូទៅ ។ ប៉ុន្តែវិធានផ្ទៃក្នុងរបស់តុលាការខ្មែរក្រហម និងកិច្ចព្រមព្រៀងស្តីពីលក្ខខណ្ឌបង្កើតតុលាការខ្មែរក្រហម “បានទទួលស្គាល់ការព្រួយបារម្ភពីបញ្ហាផ្លូវច្បាប់របស់រដ្ឋាភិបាល និងប្រជាជនកម្ពុជាក្នុងការសម្រេចឲ្យបានការផ្សះផ្សាជាតិ” ។ បទបញ្ញត្តិជាក់លាក់សម្រាប់តម្លាភាព និងវត្តមានរបស់តុលាការខ្មែរក្រហមនៅទីក្រុងភ្នំពេញកាន់តែជំរុញឲ្យមានការទទួលស្គាល់ពីសារសំខាន់នៃការផ្សះផ្សាជាតិ ។ យ៉ាងណាមិញ គោលការណ៍ចម្បងរបស់តុលាការខ្មែរក្រហមដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង២១តម្រូវឲ្យធ្វើការបកស្រាយច្បាប់ដែលជាប់ពាក់ព័ន្ធ “ដើម្បីធានាឲ្យបាននូវភាពច្បាស់លាស់ខាងផ្លូវច្បាប់ និងតម្លាភាពនៅក្នុង

អង្គជំនុំជម្រះ» បើអាចធ្វើទៅបាន ។ លើសពីនេះទីតាំងរបស់តុលាការខ្មែរក្រហមនៅទីក្រុងភ្នំពេញ ក៏ជួយសម្របសម្រួលដល់ការផ្សះផ្សាជាតិតាមរយៈជំរុញឲ្យមានការតាមដានរបស់ប្រជាជនកម្ពុជាអំពីដំណើរការរបស់តុលាការ ។ ខុសពីតុលាការអន្តរជាតិផ្សេងទៀតដូចជាតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីដែលប្រជាជនក្នុងតំបន់មិនអាចចូលរួមតាមដានដំណើរការរបស់តុលាការដែលបង្កើតឡើងបម្រើជាប្រយោជន៍ដល់ប្រជាជន តុលាការកូនកាត់ខ្មែរក្រហមមិនឋិតនៅក្នុងទីតាំងឆ្ងាយដែលប្រជាជនមិនអាចមកចូលរួមតាមដាននោះទេ ។

បទបញ្ញត្តិរបស់តុលាការខ្មែរក្រហមដែលថា "អង្គជំនុំជម្រះវិសាមញ្ញដែលត្រូវបានបង្កើតឡើងនិងអង្គជំនុំជម្រះតុលាការកំពូលគួរតែមានទីតាំងនៅទីក្រុងភ្នំពេញ" បានជួយសម្របសម្រួលដល់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រជាជន និងសិស្សានុសិស្ស ។ តុលាការកូនកាត់ដែលធ្វើជាគំរូដល់ប្រព័ន្ធច្បាប់កម្ពុជាដែលជាគោលដៅទីពីររបស់តុលាការខ្មែរក្រហមគឺមានតួនាទីពង្រឹងប្រព័ន្ធច្បាប់កម្ពុជាហើយ "ផ្តល់ជាគំរូថ្មីមួយសម្រាប់ដំណើរការប្រតិបត្តិរបស់តុលាការកម្ពុជា" ។ រចនាសម្ព័ន្ធតុលាការកូនកាត់មួយនេះបានតម្រូវឲ្យតុលាការខ្មែរក្រហមប្រើប្រាស់ប្រព័ន្ធច្បាប់តុលាការកម្ពុជា ហើយទទួលយកការសហការពីអន្តរជាតិ សម្រាប់ដំណើរអង្គជំនុំជម្រះក្តីរបស់ខ្លួន ។ រចនាសម្ព័ន្ធនេះធ្វើការការពារឯករាជ្យភាពរបស់រដ្ឋាភិបាលកម្ពុជា ហើយធានាថាគោលដៅនិងអង្គជំនុំជម្រះក្តីដែលមិនលម្អៀងនឹងដើរតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ។ ការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមពិតជាមានសារសំខាន់ក្នុងការធានាដល់ប្រជាជនកម្ពុជាថាប្រព័ន្ធច្បាប់ និងប្រព័ន្ធតុលាការកម្ពុជាគឺ "មានស្តេរភាពគួរឲ្យជឿជាក់ មានសមត្ថភាពមានក្រមសីលធម៌ខ្ពង់ខ្ពស់ និងគួរឲ្យទុកចិត្ត" ។

ក្នុងការបង្កើតតុលាការនេះឡើងដើម្បីកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម "ប្រទេសកម្ពុជាបានកោះអញ្ជើញឲ្យមានការចូលរួមពីសំណាក់មជ្ឈដ្ឋានអន្តរជាតិដោយសារតែភាពទន់ខ្សោយនៃប្រព័ន្ធច្បាប់កម្ពុជានិងដោយសារតែលក្ខណៈនៃឧក្រិដ្ឋកម្មអន្តរជាតិដើម្បីជួយកម្ពុជាដើរតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ" ។ ឥទ្ធិពលនៃការអប់រំពីតុលាការខ្មែរក្រហមក៏មានសារសំខាន់សម្រាប់ប្រជាជនកម្ពុជានិងប្រព័ន្ធច្បាប់កម្ពុជាដែរ ។នៅក្នុងអំឡុងគ្រប់គ្រងអំណាចខ្មែរក្រហមរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យស្ទើរតែលុបបំបាត់ចោលនូវប្រព័ន្ធច្បាប់តុលាការដោយលុបបំបាត់ចោលច្បាប់ក្នុងស្រុកសម្លាប់មេធាវីបំផ្លាញចោលឯកសារច្បាប់ ។ ក្រោយពីរបបខ្មែរក្រហមមាននិស្សិតច្បាប់ប្រមាណតែប្រាំនាក់ដែលក្នុងនោះមានចៅក្រមប្រាំនាក់ទៀតតែប៉ុណ្ណោះបានរួចរស់រានមានជីវិត ។ អស់រយៈពេលជាច្រើនឆ្នាំក្រោយមកទៀតប្រព័ន្ធច្បាប់កម្ពុជានៅតែមានការខ្វះខាតផ្នែកធនធានអ្នកជំនាញនិងបទពិសោធ ។ សព្វថ្ងៃ តុលាការខ្មែរក្រហមកំពុងតែផ្តល់នូវឱកាសមួយដ៏សំខាន់ដើម្បីជំនះឧបសគ្គទាំងអស់ដែលមាននៅក្នុងប្រព័ន្ធច្បាប់កម្ពុជាដែលអង្គការសហប្រជាជាតិបានកត់សម្គាល់មុននឹងការបង្កើតឡើងនូវតុលាការខ្មែរក្រហមដោយមានទៅដោយ "ចៅក្រមមេធាវីអ្នកស៊ើបអង្កេតដែលមានវិជ្ជាជីវៈត្រឹមត្រូវនិងសម្ភារបច្ចេកទេសគ្រប់គ្រាន់រួមជាមួយនឹងការបង្កើតមានជាវប្បធម៌គោរពតាមដំណើរការត្រឹមត្រូវតាមផ្លូវច្បាប់" ។

តួនាទីរបស់តុលាការខ្មែរក្រហមក្នុងការធ្វើជាគំរូមួយអាចនឹងសម្រេចបានពីព្រោះសមាសធាតុរបស់មេធាវីគឺកើតចេញពីការសហការគ្នារវាងមេធាវីជាតិនិងមេធាវីអន្តរជាតិដោយបង្កើតជាក្រុមសហចៅក្រមស៊ើបអង្កេតសហព្រះរាជអាជ្ញានិងក្រុមមេធាវីការពារក្តីដែលមានទាំងមេធាវីជាតិនិងអន្តរជាតិ ។ បន្ថែមលើនេះអង្គបុរេជំនុំជម្រះអង្គជំនុំជម្រះសាលាដំបូងនិងអង្គជំនុំជម្រះតុលាការកំពូលសុទ្ធតែមានចៅក្រមជាតិនិងចៅក្រមអន្តរជាតិ ។ មូលហេតុនៃការរួមបញ្ចូលសមាសធាតុមេធាវីចៅក្រមព្រះរាជអាជ្ញាជាតិនិងអន្តរជាតិគឺថាអ្នកជំនាញអន្តរជាតិនឹងធ្វើការពិភាក្សាជាមួយនឹងអ្នកជំនាញជាតិ ហើយតាមរយៈអង្គជំនុំជម្រះដែលមានតម្លាភាពនោះអ្នកជំនាញជាតិនិងអន្តរជាតិនឹងធ្វើការស្វែងយល់ពីប្រព័ន្ធច្បាប់កម្ពុជាកាន់តែប្រសើរឡើង ។ រចនាសម្ព័ន្ធនៃការបំពេញកិច្ចការជាក្រុមបែបនេះ ត្រូវបានទទួលស្គាល់ថាជាប្រយោជន៍មួយដ៏សំខាន់ដល់តុលាការកូនកាត់ ។ ដូច្នេះគោលដៅធំៗទាំងពីរនេះរបស់តុលាការកម្ពុជាដែលដើរតួជាយានមួយសម្រាប់ការផ្សះផ្សាជាតិនិងជាគំរូមួយសម្រាប់ប្រព័ន្ធតុលាការកម្ពុជាត្រូវតែមានតុល្យភាពនៃភាពចាំបាច់ក្នុងការស៊ើបអង្កេតសម្ងាត់ ។

### ១) ការសន្មតពីការសម្ងាត់ក្នុងអំឡុងពេលស៊ើប

## អង្កេតមុនអង្គជំនុំជម្រះចាប់ផ្តើមនៅឯតុលាការខ្មែរក្រហម

អង្គនីតិវិធីមុនអង្គជំនុំជម្រះក្តីនៅឯតុលាការខ្មែរក្រហមអនុវត្តតាមគោលការណ៍សន្មតពីការសម្ងាត់ដែលត្រូវបានអនុម័តដោយវិធានផ្ទៃក្នុងដែលការពារពីការសម្ងាត់នៃដំណើរការស៊ើបអង្កេតហើយតម្រូវឲ្យអង្គសវនាការប្រព្រឹត្តទៅដោយសម្ងាត់ដោយគ្មានមូលហេតុសម្រាប់ការចូលរួមរបស់សាធារណជន ។ បទបញ្ញាបន្ថែមផ្សេងទៀតដែលធ្វើការគ្រប់គ្រងតុលាការខ្មែរក្រហមចែងថាកាតព្វកិច្ចនៃការសម្ងាត់ត្រូវបានអនុវត្តយ៉ាងទូលំទូលាយហើយមិនបានលាក់បាំងពីបុគ្គលិកតុលាការខ្មែរក្រហមណាមួយឡើយ ។ ទាំងអស់នេះបានបណ្តាលឲ្យអ្នកសារព័ត៌មានមិនស្វែងយល់ឲ្យបានច្បាស់លាស់ថាព័ត៌មានណាដែលជាព័ត៌មានសាធារណៈ ហើយព័ត៌មានណាដែលជាព័ត៌មានហាមឃាត់ ។

### ១) ការស៊ើបអង្កេតរបស់តុលាការ

ទាំងតុលាការខ្មែរក្រហមនិងប្រព័ន្ធច្បាប់កម្ពុជាគឺដើរតាមប្រព័ន្ធច្បាប់ស៊ីវិលរបស់បារាំងដែលចៅក្រមស៊ើបអង្កេតអនុវត្តតាមដើម្បីធ្វើការស៊ើបអង្កេតជាសម្ងាត់ ។ យោងតាមវិធានផ្ទៃក្នុងរបស់តុលាការខ្មែរក្រហមសហព្រះរាជអាជ្ញាបានដាក់សេចក្តីសន្និដ្ឋានបឋមមួយដែលគូសបញ្ជាក់ពីដែនកំណត់នៃការស៊ើបអង្កេតហើយសហចៅក្រមស៊ើបអង្កេតត្រូវបានហាមឃាត់មិនឲ្យធ្វើការស៊ើបអង្កេតលើបញ្ហាដែលមិនមានចែងនៅក្នុងសេចក្តីសន្និដ្ឋានបឋមរបស់សហព្រះរាជអាជ្ញានោះទេ ។ សហចៅក្រមស៊ើបអង្កេតត្រូវប្រមូលទាំងភស្តុតាងដាក់បន្ទុកនិងភស្តុតាងដោះបន្ទុកហើយមេធាវីការពារក្តីជនជាប់ចោទត្រូវបានហាមប្រាមមិនឲ្យធ្វើការស៊ើបអង្កេតដោយខ្លួនឯងនោះទេ ។ ប៉ុន្តែមេធាវីការពារក្តីត្រូវបានអនុញ្ញាតឲ្យធ្វើការស្នើសុំទៅកាន់សហចៅក្រមស៊ើបអង្កេតឲ្យធ្វើការស៊ើបអង្កេត ។ នៅពេលបញ្ចប់ដំណើរការស៊ើបអង្កេតសហចៅក្រមស៊ើបអង្កេតនឹងចេញដីកាដំណោះស្រាយដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងដីកាចោទប្រកាន់ក្នុងប្រព័ន្ធច្បាប់ខំមិនឡូ ។

នៅក្នុងអំឡុងដំណើរការស៊ើបអង្កេតអង្គបុរេជំនុំជម្រះរបស់តុលាការខ្មែរក្រហមមានយុត្តាធិការដោះស្រាយការមិនយល់ស្របគ្នារវាងសហព្រះរាជអាជ្ញានិងសហចៅក្រមស៊ើបអង្កេតហើយក៏មានយុត្តាធិការក្នុងការស្តាប់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ។ដូចគ្នានឹងអង្គជំនុំជម្រះសាលាដំបូងអង្គបុរេជំនុំជម្រះមានចៅក្រមប្រាំរូបដែលក្នុងនោះបីរូបជាចៅក្រមជាតិនិងពីររូបទៀតជាចៅក្រមអន្តរជាតិ ។

### ២) វិសាលភាពនៃការស៊ើបអង្កេតសម្ងាត់របស់តុលាការ

ការស៊ើបអង្កេតដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតត្រូវបានសន្មតឲ្យរក្សាការសម្ងាត់ដើម្បីធានាឲ្យបាននូវគុណភាពនៃដំណើរការតុលាការ ។ វិធានផ្ទៃក្នុង៥៦របស់តុលាការខ្មែរក្រហមចែងថា «ដើម្បីការពារសិទ្ធិនិងប្រយោជន៍របស់ភាគីទាំងអស់ការស៊ើបអង្កេតរបស់តុលាការមិនត្រូវប្រព្រឹត្តឡើងជាសាធារណៈនោះទេ ។ ជនទាំងអស់ដែលចូលរួមនៅក្នុងដំណើរការស៊ើបអង្កេតរបស់តុលាការត្រូវរក្សាការសម្ងាត់» ។ លើសពីនេះវិធានផ្ទៃក្នុងរបស់តុលាការខ្មែរក្រហមចែងនូវសេចក្តីសន្មតមួយថាអង្គសវនាការសាឡើងវិញត្រូវតែដំណើរការឡើងជាសម្ងាត់ ។ ស្របជាមួយគ្នានេះការិយាល័យសហចៅក្រមស៊ើបអង្កេតស្រង់មូលហេតុជាក់លាក់បីដើម្បីការពារការសម្ងាត់នៃការស៊ើបអង្កេតដែលក្នុងនោះមានដូចជា ៖ ការធានាឲ្យបាននូវការការពារព័ត៌មានសម្ងាត់ទាក់ទងនឹងជនដែលមានឈ្មោះនៅក្នុងសំណុំរឿងការសន្មតថាគ្មានទោស និងប្រសិទ្ធភាពនៃដំណើរការស៊ើបអង្កេត ។

បទបញ្ញាស្តីពីការអនុវត្តរបស់តុលាការខ្មែរក្រហមធ្វើការបែងចែកជាបីផ្នែកគឺ ៖ ជាសាធារណៈសម្ងាត់និងសម្ងាត់ខ្ពស់បំផុត ។ ក្នុងការកំណត់យកការបែងចែកដ៏សមរម្យនៃសំណុំរឿងនៅចំពោះតុលាការបទបញ្ញាសម្រាប់ការអនុវត្តណែនាំកត្តាមួយចំនួនដែលនាំមកនូវតុល្យភាពដូចជាៈ គោលការណ៍ដែលឋិតនៅក្នុងបទបញ្ញាស្តីពីការអនុវត្តគឺជាតម្រូវការចាំបាច់ដើម្បីធ្វើឲ្យមានតុល្យភាពនៃការសម្ងាត់របស់ដំណើរការស៊ើបអង្កេតរបស់តុលាការនិងការសម្ងាត់នៃផ្នែកផ្សេងៗទៀតនៃអង្គនីតិវិធីរបស់តុលាការដែលមិនផ្សព្វផ្សាយជាសាធារណក្នុងគោលបំណងធានាមកនូវតម្លាភាពនៃអង្គនីតិវិធីជាសាធារណៈនិងសម្រេចគោលបំណងសម្រាប់ការអប់រំ និងកេរដំណែល ។

ការសន្មតពីការសម្ងាត់មានជាប់ពាក់ព័ន្ធនឹងទិដ្ឋភាពទាំងអស់នៃដំណើរការស៊ើបអង្កេតរបស់តុលាការដូច្នេះភស្តុតាងត្រូវបានការពារមិនថាមាតិការបស់ភស្តុតាងឬព័ត៌មានដែលបានលេចធ្លាយ

សាធារណជនក៏ដោយ ។ បើទោះបីជាវិធានផ្ទៃក្នុងផ្តល់ឆន្ទានុសិទ្ធិដល់សហចៅក្រមស៊ើបអង្កេតឲ្យផ្សព្វផ្សាយព័ត៌មាននៅពេលដែលវាមានសារសំខាន់ក្នុងការធ្វើឲ្យសាធារណជនបានជ្រាបឬអនុញ្ញាតឲ្យអ្នកសារព័ត៌មានទទួលបានព័ត៌មានខ្លះៗក្នុងករណីលើកលែងណាមួយក៏ដោយក៏តុលាការខ្មែរក្រហមនៅតែមិនទាន់មានហេតុផលច្បាស់លាស់ក្នុងការផ្សព្វផ្សាយព័ត៌មានជាសាធារណៈដែរ ។ បទបញ្ជាស្តីពីការអនុវត្តបានបែងចែកឯកសារដែលសម្ងាត់ "ជាគោលការណ៍" និងសម្ងាត់បំផុត ។ ប៉ុន្តែសេចក្តីបង្គាប់ដែលចែងសម្រាប់ការបែងចែកឯកសារណាជាឯកសារសាធារណៈបានណែនាំថាឯកសារ "ដែលត្រូវបានចាត់ទុកថាជាឯកសារសាធារណៈ ដោយសហចៅក្រមស៊ើបអង្កេត" និងឯកសារ "ដែលចៅក្រមអង្គបុរេជំនុំជម្រះសម្រេចថាជាឯកសារសាធារណៈ" ត្រូវបានសន្មតថាជាឯកសារដែលអាចផ្សព្វផ្សាយជាសាធារណៈបាន ។ អ្នកដាក់ពាក្យស្នើសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីអាចនឹងធ្វើការស្នើសុំឲ្យមានការបែងចែកដ៏សមរម្យមួយបើយោងតាមបទបញ្ជាស្តីពីការអនុវត្ត ។ ប៉ុន្តែសហចៅក្រមស៊ើបអង្កេតតែងតែក្រើនរំឭកដល់អ្នកទាំងអស់នេះថាការបែងចែកដែលអ្នកដាក់ពាក្យស្នើសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលបានគឺត្រឹមតែពាក្យស្នើសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ ។ សហចៅក្រមស៊ើបអង្កេតនិងចៅក្រមនៃអង្គបុរេជំនុំជម្រះមានឆន្ទានុសិទ្ធិខ្ពស់ក្នុងការសម្រេចថាការបែងចែកក្នុងកម្រិតបែបណាដែលសមរម្យសម្រាប់ឯកសារទាំងអស់នោះដែលអាចស្នើសុំមកតុលាការខ្មែរក្រហម ។

ថ្មីៗនេះអង្គបុរេជំនុំជម្រះបានឆ្លើយតបទៅនឹងមតិរិះគន់របស់សាធារណជនសម្រាប់ការខ្វះខាតនូវបទដ្ឋានគ្រប់គ្រងការសន្មតពីការសម្ងាត់ហើយបានចែងជាកត្តាចំនួនប្រាំមួយសម្រាប់ឲ្យចៅក្រមធ្វើការពិចារណានៅពេលចេញសម្រេចលើការបែងចែកឯកសារ ។ កត្តាទាំងប្រាំមួយនោះរួមមាន ១) ប្រយោជន៍បំរើដល់យុត្តិធម៌ ២) ភាពត្រឹមត្រូវសុចរិតនៃការស៊ើបអង្កេតបឋមនិងការស៊ើបអង្កេតរបស់ចៅក្រម ៣) សិទ្ធិទទួលបានអង្គជំនុំជម្រះក្តីត្រឹមត្រូវយុត្តិធម៌ ៤) សណ្តាប់ធ្នាប់សាធារណៈ ៥) តម្លាភាព ៦) វិធានការពារដែលសម្រេចដោយតុលាការ ។ បើទោះបីជាកត្តាទាំងអស់នេះផ្តល់មកនូវសេចក្តីបង្គាប់បន្ថែមទាក់ទងនឹងព័ត៌មានដែលសហចៅក្រមស៊ើបអង្កេតឬចៅក្រមអង្គបុរេជំនុំជម្រះធ្វើការពិចារណាក៏ដោយ ក៏កត្តាទាំងអស់នេះមិនផ្តល់នូវបទដ្ឋានជាក់លាក់មួយដែលទាក់ទងនឹងប្រភេទព័ត៌មានដែលត្រូវបានការពារនោះទេ ។ ដោយសារតែកង្វះខាតសេចក្តីបង្គាប់បន្ថែមនេះហើយទើបយុត្តិសាស្ត្ររបស់តុលាការខ្មែរក្រហមណែនាំថាឯកសារណាដែលមិនមានចុះនៅលើគេហទំព័ររបស់តុលាការខ្មែរក្រហមឯកសារនោះត្រូវបានសន្មតថាជាឯកសារសម្ងាត់ ។

## ៣) កាតព្វកិច្ចនៃការសម្ងាត់

បើទោះបីជាខ្វះខាតនូវសេចក្តីណែនាំទាក់ទងនឹងខ្លឹមសារនៃការសន្មតពីការសម្ងាត់ក៏ដោយក៏បទបញ្ជាស្តីពីការអនុវត្តបានកំណត់លើវិសាលភាពរបស់ជនដែលមានកាតព្វកិច្ចទាក់ទងនឹងបញ្ហានេះថា ៖ ជនទាំងឡាយណាដែលទទួលបានព័ត៌មានសម្ងាត់ឬសម្ងាត់បំផុតមានកាតព្វកិច្ចរក្សាការសម្ងាត់ ។ អ្នកទាំងអស់នោះមិនត្រូវផ្សព្វផ្សាយព័ត៌មាននោះទៅជនណាម្នាក់ឡើយលើកលែងតែការធ្វើបែបនេះមានចែងនៅក្នុងបទបញ្ជាស្តីពីការអនុវត្ត ។ បន្ថែមលើនេះអ្នកទាំងអស់នោះមិនត្រូវប្រព្រឹត្តទង្វើណាមួយដែលអាចបណ្តាលឲ្យមានការផ្សព្វផ្សាយព័ត៌មានសម្ងាត់ឬសម្ងាត់បំផុតដាច់ខាត ។

និយមន័យនៃពាក្យ "បុគ្គលិកតុលាការផ្លូវការ" និង "ចៅក្រម" ដែលមានចែងនៅក្នុងបទបញ្ជាស្តីពីការអនុវត្តនិងការលុបចោលនូវនិយមន័យនេះដែលមានចែងនៅក្នុងបទបញ្ញត្តិដែលធ្វើការគូសបញ្ជាក់ពីកាតព្វកិច្ចរក្សាការសម្ងាត់បានណែនាំថា "ជនទាំងឡាយណាដែលទទួលបាន" ព័ត៌មានដែលត្រូវបានការពារមិនត្រូវបានលាក់បាំងពីបុគ្គលិករបស់តុលាការខ្មែរក្រហមនោះទេ ។ លើសពីនេះការខ្វះខាតនូវបែបបទក្នុងការ "ទទួលបាន" ព័ត៌មានណែនាំថាជនម្នាក់អាចទទួលព័ត៌មានសម្ងាត់បានលុះត្រាតែជននោះមានកាតព្វកិច្ចធ្វើដូច្នោះបើទោះបីជាជននោះដឹងឬមិនដឹងថាព័ត៌មាននោះគឺជាព័ត៌មានសំខាន់ក៏ដោយ ។

ការខ្វះខាតនូវបទដ្ឋានច្បាស់លាស់ក្នុងការចាត់ចែងការបែងចែកព័ត៌មាននៅក្នុងអំឡុងដំណើរការស៊ើបអង្កេតមុនអង្គជំនុំជម្រះក្តីអមនឹងវិសាលភាពធំធេងរបស់ជនដែលមានកាតព្វកិច្ចរក្សាការសម្ងាត់បានចោទជាបញ្ហាលើការពិចារណាពីគោលដៅរបស់តុលាការក្នុងការផ្តល់ព័ត៌មានដល់សាធារណជន ។ ដោយសារតែការខ្វះខាតនូវបទ

ដ្ឋានទាក់ទងនឹងព័ត៌មានសាធារណៈនោះជនដែលទទួលបានព័ត៌មានដែលពាក់ព័ន្ធនឹងការស៊ើបអង្កេតរបស់ចៅក្រមមិនសូវទទួលបានសេចក្តីណែនាំឲ្យបានច្បាស់ថាព័ត៌មានណាជាព័ត៌មានដែលត្រូវបានការពារនោះទេ ។

ការសន្មតថាព័ត៌មានទាំងអស់គឺជាព័ត៌មានសម្ងាត់សូម្បីតែព័ត៌មានដែលត្រូវបានដឹងឮជាសាធារណៈរារាំងមិនឲ្យតុលាការខ្មែរក្រហមសម្រេចនូវគោលដៅរបស់ខ្លួនដូចដែលបានពិភាក្សានៅក្នុងផ្នែក "ក" ថាដើម្បីជំរុញឲ្យមានការផ្សះផ្សាជាតិនិងធ្វើជាគំរូមួយដល់ប្រព័ន្ធច្បាប់កម្ពុជាពីព្រោះថាឥទ្ធិពលនៃការសន្មតនេះធ្វើឲ្យសាធារណជនមិនពិភាក្សាជាសាធារណៈពីដំណើរការនីតិវិធីរបស់តុលាការ ។ ជនដែលរងនូវផលប៉ះពាល់ដោយសារការផ្លាស់ប្តូរបទដ្ឋាននេះគឺជនដែលមានការទទួលខុសត្រូវក្នុងការផ្សព្វផ្សាយព័ត៌មានដល់សាធារណជនដូចជាអ្នកសារព័ត៌មានជាដើម ។

**(នៅមានត)** **គ្រីស្តា ណេលសាន់**

# ការិយាល័យព័ត៌មានសាធារណៈ

"ការិយាល័យព័ត៌មានសាធារណៈ" របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារទាំងនេះរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

"ការិយាល័យព័ត៌មានសាធារណៈ" មានផ្តល់ជូននូវសេវាបីយ៉ាង ៖

**១) បណ្ណាល័យ** ៖ នៅក្នុងបណ្ណាល័យរបស់យើង សាធារណជនអាចអានឯកសារ សៀវភៅ និងទស្សនាវដ្តី ស្តាប់កាសែតសំឡេង ទស្សនាខ្សែភាពយន្តឯកសារ និងមើលរូបថតដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បណ្ណសារដ្ឋានជាតិកម្ពុជា និងពីប្រភពផ្សេងៗទៀត ។

**២) មជ្ឈមណ្ឌលអប់រំ** ៖ មជ្ឈមណ្ឌលមានបញ្ចាំងជូននូវខ្សែភាពយន្តឯកសារ និងបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ប្រធានបទទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញ និងប្រធានបទដទៃៗទៀត ។ ភាពយន្តឯកសារអំពីខ្មែរក្រហមមានបញ្ចាំងជូនទស្សនារៀងរាល់ថ្ងៃ ។

**៣) ក្រុមការងារផ្នែកតុលាការ** ៖ ទីប្រឹក្សាផ្នែកឯកសារនិងផ្នែកច្បាប់របស់យើងនឹងផ្តល់ជំនួយផ្នែកស្រាវជ្រាវដល់អ្នកជំនាញផ្នែកច្បាប់កម្ពុជានិងអង្គការសហប្រជាជាតិដែលធ្វើការងារផ្នែកតុលាការ ក៏ដូចជាដល់សាធារណជនទូទៅដែរ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ិរ សាវីណា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# កេរដំណែលសៅហ្មងរបស់អង្គជំនុំជម្រះនិងអង្គការសហប្រជាជាតិ

បន្ទាប់ពីចំណាយរយៈពេលជាងបីឆ្នាំ និងថវិកាជាងពីររយលានដុល្លាសហរដ្ឋអាមេរិក តុលាការខុក្រិដ្ឋកម្មសង្គ្រាមខ្មែរក្រហមឬអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានការរីកចម្រើនទៅមុខគួរឲ្យកត់សម្គាល់ក្នុងការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមរួមមានៈ នួន ជា, អៀង សារី និង ខៀវ សំផន ។ ទោះបីជាមានការរីកចម្រើនយ៉ាងនេះក៏ដោយ ក៏កិច្ចការទាំងអស់នៅក្នុងទីក្រុងភ្នំពេញមិនមានភាពរលូនទេ ។ ចៅក្រមបម្រុងជនជាតិស្វីសរបស់អង្គជំនុំជម្រះឈ្មោះ ឡូរ៉ង់ កាស្តេ អានសើម៉េត ដែលបានលាលែងតំណែងកាលពីខែមីនាកន្លងទៅដោយហេតុផលថាមិនមានការគាំទ្រពីសំណាក់រដ្ឋាភិបាលក្នុងការស៊ើបអង្កេតករណី០០៣និង០០៤បានរិះគន់អំពី "ភាពមិនអាចដំណើរការបានដ៏ធ្ងន់ធ្ងរ" របស់តុលាការ ។ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិបាន គីមូន បានប្រកាសថា អង្គការសហប្រជាជាតិមិនបណ្តោយឲ្យ "មាននិទណ្ឌភាពចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ" ជាដាច់ខាត ។ ការគោរពនិងគាំពារសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានប្រកាន់ភ្ជាប់យ៉ាងរឹងមាំជាដាច់គ្រាន់តែបញ្ចប់សវនាការឧក្រិដ្ឋកម្មសង្គ្រាមដ៏មានសារសំខាន់មួយនេះចាប់តាំងពីតុលាការនូរឹមបើកមក ។ ប៉ុន្តែវាយឺតពេលទៅហើយសម្រាប់អង្គការសហប្រជាជាតិក្នុងការទាញយកមកវិញនូវភាពបរិសុទ្ធផ្នែកនយោបាយនៅប្រទេសកម្ពុជាខណៈពេលដែលស្ថាប័នមួយនេះប្រឡូកចូលទៅក្នុង "តុលាការចម្រុះ" នេះ ។ ជាដាច់ការប្រើពាក្យសម្តែងនូវ "ក្តីបារម្ភ" "ក្តីបារម្ភខ្លាំង" ឬ "ក្តីបារម្ភយ៉ាងខ្លាំង" អង្គការសហប្រជាជាតិគួរធ្វើឲ្យបានល្អជាដាច់គ្រាន់ការប្រើប្រាស់ពាក្យគម្រាមដែលគ្មានសារសំខាន់នេះហើយដកខ្លួនចេញភ្លាមពេលដែលករណី០០២ត្រូវបានបញ្ចប់និងទម្លាក់ចោលនូវ "តុលាការចម្រុះ" នេះឲ្យចូលទៅក្នុងធុងសម្រាមប្រវត្តិសាស្ត្រ ។ អង្គការសហប្រជាជាតិមិនបានប្រើសិទ្ធិទៅនិងទណ្ឌកម្មដែលធ្លាប់ដាក់ឲ្យប្រទេសកម្ពុជានៅក្នុងប្រវត្តិរបស់ខ្លួនទេ ហើយមេរៀនប្រវត្តិនេះមានតាមលំដាប់លំដោយដូចតទៅ ។



រថយន្តនិងឧទ្ធម្ភាចក្ររបស់អង្គការសហប្រជាជាតិ (រូបថត ៖ បេនី វីដ្យូណូ)

ក្រោយពីវៀតណាមផ្តួលរំលំរបបខ្មែរក្រហមក្នុងឆ្នាំ១៩៧៩ ស្របពេលដែលហេតុការណ៍ច្បាស់ណាស់ថារបបដែលគាំទ្រដោយរបបម៉ៅនិយមរបស់ចិនមួយនេះបានប្រព្រឹត្តអំពើឃោរឃៅបំផុតក្នុងប្រវត្តិសាស្ត្រចាប់តាំងពីសង្គ្រាមលោកលើកទីពីរមក ហើយពេលនោះអង្គការសហប្រជាជាតិបានអនុញ្ញាតឲ្យរបបប្រល័យពូជសាសន៍ខ្មែរក្រហមរក្សាអសនរបស់កម្ពុជានៅសភាអង្គការសហប្រជាជាតិដដែល ។ ក្នុងអំឡុងពេលនៃការគ្រប់គ្រងប្រទេសកម្ពុជានិងការចំណាយថវិការពីរពាន់លានដុល្លារបស់អង្គការសហប្រជាជាតិពីឆ្នាំ១៩៩១ដល់១៩៩២ដែលបានបញ្ជូនទាហានចំនួនពីរម៉ឺននាក់និងទីប្រឹក្សាស៊ីវិលចំនួនប្រាំពាន់នាក់ទៅ

ប្រទេសកម្ពុជាកាលនោះអង្គការសហប្រជាជាតិមិនបាននិយាយអំពីឧក្រិដ្ឋកម្មសង្គ្រាមឬឧទ្រម្ង់ណាមួយនៃការដាក់ឲ្យមានការទទួលខុសត្រូវឡើយ ។ សន្ធិសញ្ញាទីក្រុងប៉ារីសឆ្នាំ១៩៩១ក៏មិនបានប្រើពាក្យប្រល័យពូជសាសន៍នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរគឺមានតែឃ្លាមួយដែលបានបេ្តជ្ញាថា «មិនអនុញ្ញាត្តិឲ្យមានការវិលត្រឡប់មកវិញនៃគោលនយោបាយនិងការអនុវត្តិដូចអ្វីដែលធ្លាប់កើតឡើងពីអតីតកាល» ឡើយ ។ ទោះជាយ៉ាងនេះក៏ដោយផុយទៅនិងការស្តាបនាឡើងវិញប្រកបដោយភាពជោគជ័យរបស់ប្រទេសអាឡឺម៉ង់និងប្រទេសជប៉ុន មានគោលការណ៍ថា ប្រទេសកម្ពុជាគួរតែគ្រប់គ្រងដោយជនស៊ីវិល ហើយខ្មែរក្រហមគួរតែត្រូវបានចាត់ទុកថាជាគណបក្សនយោបាយស្របច្បាប់មួយក្នុងចំណោមគណបក្សទាំងបួនក្នុងកិច្ចខំប្រឹងប្រែងក្នុងការបង្កើត «បរិស្ថាននយោបាយអព្យាក្រឹតមួយ» ។ យោងតាមផែនការ «ពង្រឹកកិច្ចការរក្សាសន្តិភាព» របស់អង្គការសហប្រជាជាតិ អព្យាក្រឹតភាពគឺជាគុណសម្បត្តិនយោបាយដ៏សំខាន់បំផុតចំណែកឯកិច្ចការយោធាត្រូវបានមើលឃើញថាជាកិច្ចការរបស់ប៉ូលីស ។ អង្គការសហប្រជាជាតិមិនបានព្យាយាមដកអាវុធពីក្រុមចលនាខ្មែរក្រហមទេ ហើយបានប្រមូលភ័ស្តុតាងតិចតួចទាក់ទងទៅនិងឧក្រិដ្ឋកម្មសង្គ្រាមឬផ្តល់ទម្រង់ណាមួយនៃការដាក់ឲ្យមានការទទួលខុសត្រូវ ។ ជំនួសមកវិញ អង្គការសហប្រជាជាតិមិនជំទាស់ទៅនិងខ្មែរក្រហមទេ ហើយថែមទាំងចាត់ទុកខ្មែរក្រហមជាគណបក្សនយោបាយស្របច្បាប់មួយថែមទៀតផង ។

កិច្ចការប្រមូលភ័ស្តុតាងក្នុងអំឡុងពេលនៃជម្លោះប្រដាប់អាវុធគឺជាកិច្ចការរបស់អង្គការផ្សេងៗគ្នាជាច្រើនដូចជា «យុទ្ធនាការប្រឆាំងនិងការវិលត្រឡប់មកវិញនៃរបបខ្មែរក្រហម» «ក្រុមបណ្ណសាររូបថត» «គម្រោងអំពើប្រល័យពូជសាសន៍របស់សាកលវិទ្យាល័យយែល» និងចុងក្រោយគឺ«មជ្ឈមណ្ឌលឯកសារកម្ពុជា» ។ គោលបំណងរួមគ្នារបស់ស្ថាប័នខាងលើនេះគឺការថែរក្សាភ័ស្តុតាងជាប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍កម្ពុជា ។ ហេតុអ្វីបានជាកិច្ចការទាំងនេះមានសារសំខាន់ម្លេះក្នុងទសវត្សរ៍៩០ ? ព្រោះកាលនោះខ្មែរក្រហមនៅមានអំណាចផ្នែកយោធានិងនយោបាយនៅឡើយ ហើយខ្មែរក្រហមបានកែប្រែប្រវត្តិសាស្ត្ររបស់ខ្លួនដោយជោគជ័យដោយទម្លាក់កំហុសនោះថាជាការប្រព្រឹត្តិអំពើឃោរឃៅរបស់វៀតណាមទៅវិញ ។ ទីបញ្ចប់ ខ្មែរក្រហមមិនត្រូវបានបំផ្លិចបំផ្លាញដោយសារតែហេតុផល «យុត្តិធម៌សាកល» ទេ តែដោយសារតែស្នាដៃយោធាយ៉ាងស្ទាត់ជំនាញនិងការប្រើប្រាស់ការទូតរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ។ ទើបតែខ្មែរក្រហមអស់អាវុធហើយទេ ដែលអង្គការសហប្រជាជាតិប្រឡូកចូលក្នុងកិច្ចការនេះឡើងវិញ ហើយបន្ទាប់ពីការចរចារអស់រយៈពេលជាច្រើនឆ្នាំមក អង្គការសហប្រជាជាតិបានបង្កើតតុលាការចម្រុះដ៏ស្មុគស្មាញមួយនេះរវាងកម្ពុជានិងអង្គការសហប្រជាជាតិដែលតុលាការនេះត្រូវបានគ្របដណ្តប់ភាគច្រើនដោយភាគីកម្ពុជានៅគ្រប់កម្រិតទាំងអស់ ។ ហេតុដូច្នេះ មិនមានអ្វីគួរឲ្យភ្ញាក់ផ្អើលទេដែលរដ្ឋាភិបាលកម្ពុជាជំទាស់មិនគាំទ្រឲ្យមានការកាត់ទោសបន្ថែមនោះ ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏មិនដែលកែប្រែជំហររបស់ខ្លួនដែរ ។ តែដោយសារតែបញ្ហានយោបាយរវាងអង្គការសហប្រជាជាតិនិងអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការខាងច្បាប់មនុស្សធម៌អន្តរជាតិ មន្ត្រីថ្នាក់លើរបស់អង្គការសហប្រជាជាតិហាក់បីដូចជាមានបំណងមិនរិះគន់ «អ្នកជំនាញច្បាប់អន្តរជាតិ» និងប្រកាន់ជំហរដែលហៅថា «បទដ្ឋានអន្តរជាតិ» ជាជាងខិតខំដើម្បីបញ្ចប់រឿងក្តីនៅសាលាក្តីខ្មែរក្រហមនេះ ។

ក្នុងអំឡុងទសវត្សរ៍៩០ អង្គការសហប្រជាជាតិមិនបានបង្ហាញឆន្ទៈដើម្បីបញ្ចប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនិងអំពើ



ទាហានស៊ីវិលរបស់អង្គការសហប្រជាជាតិកំពុងផ្តល់សេវាព្យាបាលដល់ប្រជាជនកម្ពុជា (រូបថត ៖ ប៉េនី រីដ្យូណូ)

ប្រល័យពូជសាសន៍នៅក្នុងសង្គ្រាមស៊ីវិលទូទាំងសាកលលោកទេ តែនៅពេលនេះអង្គការសហប្រជាជាតិបានផ្លាស់ប្តូរកិច្ចខិតខំព្យាយាមរបស់ខ្លួនពីការទប់ស្កាត់ឧក្រិដ្ឋកម្មសង្គ្រាមទៅជាការដាក់ទណ្ឌកម្មចំពោះឧក្រិដ្ឋកម្មសង្គ្រាមវិញ ។ ឧក្រិដ្ឋកម្មសង្គ្រាម សិទ្ធិមនុស្សនិងយុត្តិធម៌ក្រោយអំពើឃោរឃៅក្លាយជាឧស្សាហកម្មមួយដែលត្រូវបានបំពេញដោយមនុស្សសំខាន់ៗជាច្រើនដូចជា ដេវីឌ សេហ្វហ្វើ, អារៀ នីអ៊ើ និង ចច សូរ៉ូស ។ អ្នកទាំងអស់នេះជម្រុញឲ្យមានគំនិតសំខាន់ថា ប្រព័ន្ធច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិដែលយកចេញពីតុលាការនូរ៉ឹមប៊ើកនិងចាក់ឫសភ្លាមៗ ។ ដំណើររឿងរវាងសម័យក្រោយសង្គ្រាមត្រជាក់និងក្រោយព្រឹត្តិការណ៍ថ្ងៃ១១ កញ្ញា មិនមានភាពសាកសមទាល់តែសោះចំពោះជនស៊ីវិលក្នុងការសរសេរច្បាប់សង្គ្រាមឡើងវិញ ។ អស់ជាច្រើនសតវត្សរ៍មកហើយ តុលាការឧក្រិដ្ឋកម្មសង្គ្រាមគឺជាកិច្ចការរបស់យោធា ។

បើសិនជាថ្នាក់ដឹកនាំរបស់អង្គការសហប្រជាជាតិទទួចចង់បានជ្រុលពេកជាងអ្វីដែលខ្លួនអាចធ្វើបាន អង្គការសហប្រជាជាតិនិងមិនអាចបញ្ចប់ករណី០០២បានទេ ។ “តុលាការចម្រុះ” របស់កម្ពុជាមិនគួរចាត់ទុកថាជាបទពិសោធន៍ដែលមានតម្លៃថ្លៃនិងស្មុគស្មាញដែលមិនគួរមិនសាកល្បងម្តងទៀតនោះទេ ។ ច្បាប់ព្រហ្មទណ្ឌអន្តរជាតិមានលក្ខណៈខុសគ្នាទៅតាមស្ថានភាពនយោបាយរៀងៗខ្លួន ។ ច្បាប់នោះមិនមានអ្វីមួយច្បាស់ទេ តែអ្វីដែលសាមញ្ញនោះគឺថា ច្បាប់ការពិត ពេលវេលា លុយកាក់ឬភាពត្រឹមត្រូវផ្នែកទម្រង់បែបបទនេះមិនអាចផ្លាស់ប្តូរការពិតនេះបានទេ ។ តុលាការនូរ៉ឹមប៊ើកត្រូវបានធ្វើឲ្យហ្មងសៅដោយមានវត្តមានរបស់សូវៀតនៅក្នុងបន្ទប់សវនាការ ការចោទប្រកាន់ពីបទកាប់សម្លាប់នៅព្រៃកាទីននិងការដោះលែងឧក្រិដ្ឋជនសង្គ្រាមដោយសម្ងាត់ ។ កេរដំណែលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានធ្វើឲ្យហ្មងសៅដោយចៅក្រមស៊ើបអង្កេតដែលប្រកួតប្រជែងគ្នាដោយសារ “អង្គភាពគាំពារជនរងគ្រោះ” ដែលច្របូកច្របល់និងដោយសារការប៉ាន់ប្រមាណក្លែងក្លែងដោយការបោកបញ្ឆោតថា ចៅក្រមអន្តរជាតិអាចធ្វើការដោយរលូនជាមួយគ្នាដើម្បីថែរក្សាបូរណភាពរបស់តុលាការ ។ កេរ្តិ៍ឈ្មោះរបស់តុលាការអាចយកមកវិញបានប្រសិនបើអង្គការសហប្រជាជាតិអាចបញ្ចប់កិច្ចដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមពេលដែលមេដឹកនាំទាំងនោះនៅមានជីវិត ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងបញ្ចប់ដោយកេរ្តិ៍ឈ្មោះ ហើយពេលនោះសូម្បីតែអ្នកដែលធ្លាប់តែរិះគន់តុលាការនេះដូចជាខ្លួនខ្ញុំផ្ទាល់និងទទួលស្គាល់ការពិត ។ **ភីតធើ ម៉ាហ្គាយ**



ចៅក្រមជាតិនិងអន្តរជាតិនៅសាលាក្តីខ្មែរក្រហម (រូបថត ៖ អ.វ.ត.ក)

# មកស្រុកកំណើតដើម្បីស្វែងរកការពិត

ចេន ឈុនអៀង បានមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ប្រកបដោយភាពស្វាហាប់ និងក្តីសង្ឃឹមដើម្បីស្វែងរកព័ត៌មានអំពីសមាជិកគ្រួសាររបស់គាត់ដែលបានស្លាប់នៅក្រោមរបបខ្មែរក្រហម ។ ការធ្វើដំណើររបស់គាត់មកទីនេះគឺបន្ទាប់ពីគាត់បានឮ ឌុច និយាយអំពីឈ្មោះ ឆួន អេង ដែលជាបងថ្លៃរបស់គាត់នៅក្នុងបន្ទប់សវនាការកាលពីពេលថ្មីៗនេះ នៅពេលដែលគាត់កំពុងតាមដានដំណើរការសវនាការផ្ទាល់ពីគេហដ្ឋានរបស់គាត់នៅប្រទេសបារាំង ។ ដំណឹងនេះបានជំរុញឲ្យគាត់ធ្វើដំណើរមកប្រទេសកម្ពុជាភ្លាមដើម្បីស្វែងរកការពិតអំពីបងស្រី បងថ្លៃ និងក្មួយៗរបស់គាត់និងដើម្បីរកយុត្តិធម៌ជូនសាច់ញាតិទាំងនោះ ។ ការធ្វើដំណើរមកកាន់ស្រុកកំណើតនេះគឺដើម្បីចង់ដឹងព័ត៌មានលម្អិតបន្ថែមទៀតពីសាច់ញាតិដែលបានបាត់ខ្លួន ព្រោះគាត់បានខិតខំស្វែងរកសាច់ញាតិទាំងនោះអស់រយៈពេលជាងបីទសវត្សរ៍មកហើយ ។

ឈុនអៀង បានភៀសខ្លួនទៅរស់នៅប្រទេសបារាំងក្នុងឆ្នាំ១៩៧៣ ។ ប៉ុន្តែសមាជិកគ្រួសាររបស់គាត់ផ្សេងទៀតមិនបានចាកចេញទៅជាមួយគាត់ឡើយ ។ អ្នកទាំងនោះបានរស់នៅប្រទេសកម្ពុជារហូតដល់ពេលដែលខ្មែរក្រហមគ្រប់គ្រងប្រទេស ។ ឈុនអៀង នៅប្រទេសបារាំងតែម្នាក់ឯង ហើយមានទុក្ខសោកសង្រេងយ៉ាងខ្លាំងក្រោយពីប្រទេសត្រូវបានកាន់កាប់ដោយក្រុមកុម្មុយនីស្តខ្មែរក្រហម ។


K026M
TSL0794

ប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំង

ទីផ្នែក : 100

មកពី :

១- ឈ្មោះដើម ... ឈ្មោះក្រៅ ...

២- អាយុ ... ឆ្នាំ ភេទ ប្រុស ជនជាតិ ខ្មែរ

៤- កើតនៅភូមិ ... ឃុំ ... ស្រុក ... ខេត្ត ...

៥- ឪពុកឈ្មោះ ... ម្តាយឈ្មោះ ...

៧- ប្តី ឬ ប្រពន្ធ ឈ្មោះដើម ... ឈ្មោះក្រៅ ...

៨- កើតនៅភូមិ ... ឃុំ ... ស្រុក ... ខេត្ត ...

១០- មានកូនប្រុសចំនួន ៣ នាក់ កូនស្រី ២ នាក់

១១- ទីកន្លែងចាប់ខ្លួន ...

១២- ចាប់ខ្លួន ថ្ងៃទី ... ខែ 12 ឆ្នាំ ១៩៧៨ 31. 1. 9

ឈុនអៀង បានរៀបរាប់អំពីក្រុមគ្រួសារនិងសាច់ញាតិដែលគាត់កំពុងតាមរកហើយស្នើឲ្យខ្ញុំជួយស្រាវជ្រាវរកព័ត៌មានអ្នកទាំងនោះ ។ ខ្ញុំបានសាកសួរគាត់អំពីដំណើររឿងខ្លះៗ ហើយ ឲ្យគាត់រៀបរាប់ឈ្មោះសាច់ញាតិរបស់គាត់យ៉ាងលម្អិតដើម្បីងាយស្រួលស្វែងរកនៅក្នុងប្រព័ន្ធទិន្នន័យរបស់យើងជូនដល់គាត់ ។ គាត់បានដឹងថា ឆួន អេង ដែលជាវិស្វករត្រូវបានសម្លាប់នៅមន្ទីរ ស-២១ ប៉ុន្តែគាត់មិនទាន់ទទួលបានព័ត៌មានច្បាស់លាស់អំពី ចេន ឈុនស្រេង ដែលជាបងស្រីរបស់គាត់និងជាអ្នកមើលថែទាំកុមារព្រមទាំងក្មួយៗទាំងប្រាំនាក់របស់គាត់នៅក្នុងរបបនោះនៅឡើយ ។

គាត់និយាយថា ទោះបីជាពេលនេះហួសពេលក្នុងការដាក់ពាក្យបណ្តឹងក្នុងសំណុំរឿង០០១

ប្រឆាំងនឹង ឌុច ប៉ុន្តែគាត់បានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ ហើយមេធាវីរបស់គាត់ចង់បានព័ត៌មានទាំងនេះសម្រាប់ដំណើរការរឿងក្តី ។

បន្ទាប់ពីការស្វែងរកអស់ជាងកន្លះម៉ោងរួចមក យើងក៏បានរកឃើញប្រវត្តិរូប និងអំពីព័ត៌មានការឃាត់ខ្លួនរបស់ ង៉ួន អេង, ចេន ឈុនស្រេង និងក្មួយម្នាក់ក្នុងចំណោមក្មួយទាំងប្រាំ ។ នៅក្នុងឯកសារនោះបង្ហាញថា ចេន ឈុនស្រេង ត្រូវបានឃាត់ខ្លួននៅមន្ទីរសាធារណការនៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៩៧៨ ហើយបន្ទាប់មកក៏បញ្ជូនមកមន្ទីរស-២១ ។


K07506
TSL0682

ប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំង

លេខរៀង :
ទីផ្នែក : 129
អគតី :

១- ឈ្មោះដើម [illegible] ឈ្មោះបដិវត្ត [illegible]
២- អាយុ ៣៧ ឆ្នាំ ភេទ ស្រី ជនជាតិ ខ្មែរ.
៣- [illegible]
- [illegible]
៤- កើតនៅភូមិ [illegible] ឃុំ [illegible] ស្រុក ខេត្ត
៥- ឪពុកឈ្មោះ [illegible] ម្តាយឈ្មោះ [illegible]
៦- [illegible]
៧- ប្តី ឬ ប្រពន្ធ ឈ្មោះដើម ឈ្មោះបដិវត្ត
៨- កើតនៅភូមិ ឃុំ ស្រុក ខេត្ត
៩- ក្រសួង-មន្ទីរ [illegible]
១០- មានកូនប្រុសចំនួន នាក់ កូនស្រី នាក់
១១- ទីកន្លែងឃាត់ខ្លួន សាធារណការ.
១២- ឃាត់ខ្លួន ថ្ងៃទី 7 ខែ 12 ឆ្នាំ ១៩៧៨ 32.2.6
[illegible]
កំណត់ : ១៤៥៩
ត្រូវនឹងលេខខ្លួន: ០៣៧

នៅពេលឃើញឈ្មោះបងស្រីរបស់ខ្លួននៅក្នុងបញ្ជីឈ្មោះអ្នកជាប់ឃុំឃាំងនៅមន្ទីរស-២១ដូច្នេះ ឈុនអៀង មានអារម្មណ៍រំជើបរំជួលមួយរំពេច ។ ខ្ញុំបានទុកឲ្យគាត់ស្ងប់ស្ងាត់បន្តិចដើម្បីឲ្យគាត់មានអារម្មណ៍ធូរស្បើយឡើងវិញ ។ គាត់ក៏បន្ថែមថា "ការពិតដែលមាននៅក្នុងឯកសារនេះនឹងជួយឲ្យខ្ញុំរកយុត្តិធម៌ជូនសាច់ញាតិរបស់ខ្ញុំ ។ ខ្ញុំនឹងយកឯកសារនេះទៅឲ្យមេធាវីរបស់ខ្ញុំ" ។

ឈុនអៀង ជាមនុស្សម្នាក់ក្នុងចំណោមមនុស្សជាច្រើនដែលបានធ្វើដំណើរដ៏វែងឆ្ងាយមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីស្វែងរកសាច់ញាតិរបស់គាត់ ។ គាត់មិនបានឆ្លងកាត់របបខ្មែរក្រហមដោយផ្ទាល់ទេ ប៉ុន្តែសាច់ញាតិរបស់គាត់ជាច្រើនទទួលរងនិងបានបាត់បង់ជីវិតនៅក្រោមរបបនោះ ។

បើទោះបីជាគាត់បានដឹងព័ត៌មានខ្លះអំពីជោគវាសនារបស់បងថ្លៃគាត់តាមរយៈសក្ខីកម្មរបស់ ឌុច និងហាក់ដូចជាដឹងអំពីជោគវាសនារបស់បងស្រី និងក្មួយរបស់ខ្លួនមុនរួចទៅហើយ ប៉ុន្តែគាត់នៅតែមិនអាចទប់អារម្មណ៍បាននៅពេលទទួលឯកសារទាំងនោះ ។

ឯកសារទាំងនេះមានសារសំខាន់សម្រាប់គាត់ដើម្បីជួយគាត់ដឹងការពិតកាន់តែស៊ីជម្រៅ និងច្បាស់លាស់អំពីសាច់ញាតិរបស់គាត់និងជាពិសេសដើម្បីបម្រើជាភ័ស្តុតាងដល់បណ្តឹងរដ្ឋប្បវេណីរបស់គាត់នៅក្នុងសំណុំរឿង០០២ ។

មុននឹងត្រឡប់ទៅប្រទេសបារាំងវិញ ឈុនអៀង បានធ្វើបុណ្យឧទ្ទិសកុសលជូនដល់សាច់ញាតិដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហមក្នុងអំឡុងពេលចូលឆ្នាំប្រពៃណីខ្មែរដើម្បីសុំឲ្យព្រលឹងទាំងនោះទៅកាន់សុគតិភព ។

**ស៊ិន សុធីតា**

# រឿងបដិវត្តន៍ : ពលិកម្មរបស់យុទ្ធមិត្តយើង

**ដកស្រង់ចេញពី : យុវជន និងយុវនារីបដិវត្តន៍ លេខ២ កុម្ភៈ ១៩៧៦**

នៅថ្ងៃ១៦ មីនា ឆ្នាំ១៩៧០ នៅវេលារសៀលម៉ោង២ ស្រាប់តែមានទាហានខ្មាំងជិត១០០នាក់ចូលមកព័ទ្ធបាញ់ជំរំយើង ។ ពេលនោះ យុទ្ធមិត្តយើងភាគច្រើនចេញទៅរកក្តួច និងទៅកាប់ចម្ការអស់ ។ នៅចាំជំរំមានតែសមមិត្ត៤-៥នាក់ប៉ុណ្ណោះ ដែលគ្រុនទៅធ្វើការធ្ងន់ពុំបាន ។ ពេលនោះ មិត្ត រ៉េត វែកក្តួចមកដល់ជំរំមុនគេ ។ គ្រាន់តែមិត្តដាក់អំរែកក្តួចពីស្មាភ្លាម ខ្មាំងបាញ់ប្រាវចូលមកជំរំយើង ។ មិត្ត រ៉េត ត្រូវរបួសដៃម្ខាងដោយប្រឹងប្រយុទ្ធនឹងការឈឺចុកចាប់របស់ខ្លួន មិត្តយើងក៏ក្រាបនៅក្បែរគំនរក្តួចនោះហើយប្រើដៃម្ខាងទៀតដែលនៅសល់បាញ់តទល់នឹងខ្មាំងវិញយ៉ាងអង់អាចក្លាហានរហូតដល់អស់គ្រាប់ ។ ក្នុងពេលព្រមជាមួយនោះ យុទ្ធមិត្តឯទៀត ដែលដេកឈឺនៅចាំជំរំ ក៏ស្ទុះចូលប្រយុទ្ធបាញ់តទល់នឹងខ្មាំងវិញយ៉ាងខ្លាំងក្លាសម្រុកទៅលើខ្មាំងជាប់មិនឲ្យខ្មាំងចូលមកចាប់ មិត្ត រ៉េត ទាំងរស់បានឡើយ ។ ខ្មាំងត្រូវស្លាប់និងរបួសអស់ជាច្រើនដោយត្រូវគ្រាប់កាំភ្លើងរបស់យុទ្ធមិត្តយើងផងនិងដោយត្រូវចម្រូងខ្លារដែលយើងបានដោតនិងបានដាក់បង្កប់ក្នុងព្រៃជុំវិញជំរំយើងផង ។ ឈាមខ្មាំងហូរធ្លាក់ជាប់ដេរដាសលើថ្មដា ។ តែដោយខ្មាំងមានចំនួនច្រើនលើសលប់ផង ហើយដោយយើងមិនសូវមានគ្រាប់ប្រយុទ្ធតទល់ជាមួយខ្មាំងយូរផង យើងក៏សម្រេចដកថយចេញពីជំរំនេះគេចទៅកន្លែងផ្សេងដើម្បីការពារកម្លាំងបដិវត្តន៍យើង ។ ក្រោយមក ខ្មាំងក៏បានលូនចូលដល់ជំរំយើង ។ វាប្រមូលក្តួចស្ងួតរបស់យើងដែលធ្វើបាន ១៥ដាល ហើយចាក់ចោលរាយប៉ាយនៅលើដីនិងទៅក្នុងទឹកអស់រលីង ។ រួចហើយពួកវាបានដុតបំផ្លាញជំរំយើងខ្ទេចខ្ទីអស់ នៅពេលដកថយ យើងឆក់បានក្តួចកំពុងត្រាំក្នុងអន្លង់មួយចំនួន ។ រួចហើយ យើងនាំគ្នាសែងមិត្ត រ៉េត គេចចេញពីទីនោះភ្លាម ។ នៅក្នុងព្រៃយើងអស់ចានអស់ឆ្នាំងហើយ យើងនាំគ្នាយកបំពង់ឫស្សីដ្ឋ ដាក់ទឹក ជំនួសប៊ីដុង យកបំពង់ឫស្សីដ្ឋ ប្រកក្តួចដុតដាំបាយហូបជំនួសឆ្នាំង ។ យើងសម្រេចចិត្តថា នឹងរកកន្លែងថ្មីកាប់ចម្ការបង្កបង្កើនផលទៀត រង់ចាំមិត្តយើងឡើងមកពីកោះកុង ។ ជ្រោះ ស៊ីង អូរ ដែលមានទឹកទាំងប៉ុន្មាននៅម្តុំនោះ ត្រូវខ្មាំងយាមឃ្លាំមើលប្រចាំការទាំងយប់ទាំងថ្ងៃ ។ ពីរថ្ងៃក្រោយមក ទឹកយើងក្នុងបំពង់ឫស្សីនៅសល់តិចតួចណាស់ទៅហើយ ។ ទោះបីមិត្តយើងស្រេកទឹកខះក ក៏យើងមិនហ៊ានហូបទឹកក្នុងបំពង់ឫស្សីនេះដែរ ទុកសម្រាប់តែអ្នកឈឺនិងអ្នករបួស ។ យើងនាំគ្នាហូបទឹកដែលដក់ជាប់លើថ្មបន្តិចបន្តួច ដែលយើងដើរជួបប្រទះ ។ នៅរដូវប្រាំងទឹកថ្លុក អន្លង់តូចតាចផ្សេងៗត្រូវរីងហួតហែងស្ងួតអស់ហើយ ។ ថ្លុកអន្លង់ខ្លះដែលនៅមានទឹកដក់សល់បន្តិចបន្តួចឃើញតែអាចម៍ដំរីនិងអាចម៍សត្វព្រៃផងនានាអណ្តែតត្រាខាប់អស់ទាំងទឹក ។ តែដោយស្រេកពេកយើងនាំគ្នាវែកអាចម៍ដំរីចេញហើយយកក្រមាក្រាលពីលើផ្ទៃទឹកយើងនាំគ្នាឱនក្រេបជីកទឹកនោះដើម្បីផ្សើមបំពង់ក ។ ទឹកកន្លែងខ្លះ គ្មានរសជាតិជាទឹកអ៊ីទេ វាឡើងខាប់ប្រែផ្អេះ បីដូចជាហូបទឹកនោមដូច្នោះដែរ ។

មានមួយព្រឹកយើងនាំគ្នាធ្វើដំណើររហូតដល់ថ្ងៃត្រង់ស្រាប់តែផុតដីរកផ្លូវចុះពីលើខ្នងភ្នំពុំឃើញ ។ សមមិត្តខ្លះទៅឈរឱបដើមឈើនៅមាត់ជ្រោះចោលភ្នែកសម្លឹងមើលទៅក្រោម ឃើញជ្រៅគ្រលួង ខ្មៅស្លុងៗ ដូចជាភ្នំបាក់ស្រុតអីចឹង ។ សមមិត្តយើងម្នាក់ទៀតដែលធ្លាប់ដើររកស៊ីចាក់ខ្ទឹមឈើក្នុងព្រៃភ្នំបាននិយាយប្រាប់យើងថា “ភ្នំបែបនេះ គេហៅថាជញ្ជាំងដាច់គ្មានផ្លូវដើរ គ្មានផ្លូវចុះបានទេ” ។ យើងនាំ គ្នាដើររកផ្លូវចុះអស់បីម៉ោងទើបទៅជួបនឹងគន្លងហ្វូងដំរីចុះឡើង ។ យើងនាំគ្នាសែងសមមិត្ត រ៉េត ចុះតាមគន្លងជើងដំរីនេះ រហូតដល់ដីរាប ។ នៅកណ្តាលខែមីនា ធាតុអាកាសក្តៅណាស់ ។ ពេលថ្ងៃត្រង់ភ្លើងឆេះព្រៃខ្មៅរហូតដល់លើកំពូលភ្នំតូចមួយ ។ ពេលនោះស្រាប់តែមិត្តយើងដែលដើរក្រោយគេបន្លឺស្រែកប្រាប់ថា “មិត្តខាងមុខឈប់សិន! និរសារខាងកោះកុងមកដល់ហើយ” យើងទាំងអស់គ្នាត្រឡប់បែរមកក្រោមវិញព្រមគ្នាតែម្តង ។ យើងសប្បាយរីករាយឥតឧបមា

ព្រោះភារកិច្ចដែលបក្សប្រគល់ឲ្យត្រូវបានសម្រេចហើយពេលគឺខ្សែនិរសារយើងភ្ជាប់ទៅខាងកោះកុងបានជោគជ័យ ។ យើងនាំគ្នាឈប់ចាំមិត្តនិរសារមកពីខាងកោះកុងដើម្បីសាកសួរព័ត៌មានផ្សេងៗសិន ។ មួយសន្ទុះក្រោយមក ស្រាប់តែមិត្តយើងពីក្រោយស្រែកប្រាប់ថា «មិត្តខាងមុខឈប់សិន! កងទ័ពបដិវត្តន៍យើងមកដល់ហើយ» យើងខ្ញុំទាំងអស់គ្នាសប្បាយរីករាយលាន់មាត់អ៊ូអរឡើងហាក់បីដូចជាក្មេងតូចៗ ឃើញម្ដាយត្រឡប់មកពីផ្សារវិញដូច្នេះដែរ ។ យើងជួបជុំគ្នា ចាប់ដៃគ្នា ឱបរឹតគ្នាហើយសាកសួរសុខទុក្ខពីគ្នាទៅវិញទៅមក ដោយមនោសញ្ចេតនាស្រលាញ់និងនឹករព្ញកគ្នាបំផុត ។ រួចហើយ មិត្តប្រធានកងដែលទើបអញ្ជើញមកដល់បានប្រកាសប្រាប់យើងខ្ញុំដោយរំភើបរីករាយថា «អង្គការឲ្យពួកយើងខ្ញុំមកតាមរកអង្គភាពសមមិត្តដើម្បីហៅត្រឡប់ទៅជួបអង្គការវិញជាប្រញាប់ ព្រោះពួកក្បត់លន់ នល់, សិរិមតៈ, សឺង ង៉ុកថាញ់ ធ្វើរដ្ឋប្រហារហើយ! ស្ថានការណ៍នៅប្រទេសយើងមានការប្រែប្រួលធំ» ។

យើងខ្ញុំទាំងអស់គ្នាមានការរំភើបរីករាយ ហើយនឹកអរព្រួច ។ យើងគិតក្នុងចិត្តថា ប្រហែលជាអង្គការមានការអីពិសេសហើយទើបបានជាបញ្ជូនកងទ័ពមួយកងអនុសេនាតូចឲ្យមករកយើងជាបន្ទាន់យ៉ាងនេះ ។ កងយើងទាំងពីរក៏ប្រញាប់ប្រញាល់រូតរះធ្វើដំណើរទៅជួបអង្គការនៅអន្លង់ម្កាក់ខាងត្បូងភូមិខ្ទុងអាយភ្លាមគ្មានបង្អង់ឡើយ ។

ពេលទៅដល់ភ្លាម អង្គការបានហៅប្រធានកងអនុសេនាតូចនីមួយៗទៅប្រជុំដាក់ផែនការវាយកម្ទេចបន្ទាយខ្មាំងនៅតាសាល់រួចហើយឈានទៅវាយកម្ទេចខ្មាំងនៅបន្ទាយខ្ទុងអាយទៀត ។ ក្រោយពី ប្រជុំដាក់ផែនការហើយ អង្គការបានសង្កត់បញ្ជាក់ថែមទៀតថា «ដើម្បីការពារបដិវត្តន៍យើង និងដើម្បីពង្រីងពង្រីកកងទ័ពបដិវត្តន៍យើងឲ្យរីកធំធាត់ឆាប់រហ័សសមមិត្តត្រូវក្ដាប់មាគ៌ាវាយសម្រុករបស់បក្សឲ្យជាប់ ។ ទោះបីជាជួបឧបសគ្គឬការលំបាកយ៉ាងណាក៏ដោយសមមិត្តកុំស្ថិតក្នុងសភាពការពារខ្លួនឲ្យសោះសមមិត្តត្រូវវាយសម្រុកដណ្ដើមប្រៀបលើខ្មាំងឲ្យបានជាប់ជានិច្ច ។ ពេលនេះខ្មាំងកំពុងប្របូកប្របល់ខ្លាំងណាស់ ។ យើងត្រូវឆក់ឱកាសនេះវាយកម្ទេចខ្មាំងឲ្យបានឆាប់រហ័សបំផុតពង្រីកតំបន់រំដោះយើងឲ្យបានធំទូលាយ» ពាក្យសម្ដីអង្គការយ៉ាងនេះយើងទាំងអស់គ្នាក្ដាប់ដៃយ៉ាងណែនលើកឡើងលើ ហើយបន្លឺសម្រែកប្ដេជ្ញាចំពោះមុខសមមិត្តដឹកនាំព្រមៗគ្នាហាក់បីដូចជាគេណាត់គ្នាមុនដូច្នេះដែរ «យើងប្ដេជ្ញាវាយកម្ទេចខ្មាំងនៅបន្ទាយខ្ទុងអាយ និងតាសាល់ឲ្យបានដាច់ខាត» ។

សូមបញ្ជាក់ថា ពេលនោះកម្លាំងទ័ពយើងនៅភូមិភាគនិរតីមានតែពីរកងអនុសេនាធំទេ ។ មួយកងអនុសេនាធំដែលកសាងមុនគេបង្អស់បោះនៅខាងជើងផ្លូវលេខ៤និងមួយកងអនុសេនាធំទៀត បោះនៅខាងត្បូងផ្លូវលេខ៤ ។ កងទាំងពីរនេះធ្លាប់បានប្រយុទ្ធយកជ័យជម្នះនៅលើសមរភូមិជាច្រើនហើយដែរ ដូចជាវាយកម្ទេចបន្ទាយក្បាលចិន បន្ទាយព្រៃខ្មោចជិតវត្តតាំងពោធិ៍ បន្ទាយតារ៉ាម និងវាយកម្ទេចក្បួនរថយន្តបីគ្រឿងរបស់អ៊ុំ ណារិន ចៅហ្វាយខេត្ត អនុខេត្តថ្មកែវ នៅខាងកើតត្រពាំងដោរជាដើម ។

ពេលនោះ ស្នាមរបួសនៅដៃនៅខ្លួនសមមិត្ត រ៉េត មិនទាន់បាត់ហូរទឹកនៅឡើយទេ តែសមមិត្តមិនព្រមឈប់សម្រាកដាច់ខាត ។ សមមិត្តបានស្នើសុំអង្គការចេញទៅវាយខ្មាំងជាមួយយុទ្ធមិត្តឯទៀតដែរ ដើម្បីសងឈាមជូនប្រជាជននិងរួមចំណែករំដោះប្រទេសជាតិនិងប្រជាជនឲ្យរួចចាកផុតពីទុក្ខទោសទារុណកម្មគ្រប់បែបយ៉ាង ។

ម៉ោងពីររំលងអាធ្រាត្រនៃយប់នោះ យើងផ្ទុះកាំភ្លើងព្រមគ្នា បាញ់សម្រុកទៅលើបន្ទាយខ្មាំងនៅ តាសាល់ពីគ្រប់ទិស ។ ម៉ោង៥ទៀបភ្លឺ យើងធ្វើម្ចាស់ការលើទីតាំងខ្មាំងនេះទាំងស្រុង យើងចាប់ខ្មាំងជាឈ្លើយទាំងអស់ ហើយរឹបយកបានជ័យភ័ណ្ឌជាច្រើនក្នុងនេះមានកាំភ្លើងស្វ័យប្រវត្តិនិងពាក់កណ្ដាលស្វ័យប្រវត្តិជាង៥០ដើម និងគ្រាប់គ្រប់ធុន៧រទេះគោ ។

គ្រាន់តែឮស្នូរកាំភ្លើងយើងវាយនៅតាសាល់ ពួកទាហានខ្មាំងដែលបោះនៅបន្ទាយខ្ទុងអាយ ភិតភ័យតក្កមា ហើយនាំគ្នាដករត់ប្រាសអាយុទៅកន្ទួតអស់ ។ ពេលបានដំណឹងនេះភ្លាម សមមិត្ត រ៉េត និយាយកំប្លែងលេងថា «ពួកឯងរត់ទៅណារួច ឥឡូវជើងមេឃជុំវិញភ្នំពេញជារបងបដិវត្តន៍ហើយ! ថ្ងៃណាមួយគង់តែកងទ័ពបដិវត្តន៍យើងកម្ទេចពួកឯងឲ្យទាល់តែវិនាសសូន្យអស់ពីទឹកដីកម្ពុជាពុំខានឡើយ»

ដោយមាគ៌ាសង្គ្រាមប្រជាជនរបស់បក្ស ភ្លឺស្វាងត្រឹមត្រូវមាគ៌ាចាត់តាំងកងកម្លាំងប្រដាប់អាវុធ បដិវត្តន៍ រឹងប៉ឹងកងទ័ពបដិវត្តន៍យើងបានរីកចម្រើនធំធាត់យ៉ាងឆាប់រហ័ស ។ យើងឈានពីកងអនុសេនាធំ មកចាត់តាំងជាវរសេនាតូចទៀត ។ ពេលនោះសមមិត្ត វ៉េត ត្រូវបានអង្គការចាត់តាំងជាប្រធានកងអនុសេនាតូច ។

ថ្ងៃបន្ទាប់មកទៀត យើងបានវាយកម្ទេចបន្ទាយសក្ដិ៣ សារី សយ នៅទំនាប រួចវាយកម្ទេចសាលាស្រុកថ្កូង នៅអមលាំង ទាំងស្រុងទៀត ។ នៅចំពោះមុខការវាយសម្រុកដូចព្យុះសង្ឃរារបស់កងទ័ពបដិវត្តន៍ក៏ក្មេងខ្ចីយើងនេះ ខ្មាំងត្រូវបាក់ទ័ពខ្ទេចខ្ទីជាបន្តបន្ទាប់ ។ ពួកនៅសេសសល់ពីស្លាប់នាំគ្នារត់ពាក់ពពូនចុះឡើងដូចហ្វូងគោដើម្បីរកច្រករត់ឡើងទៅភ្នំពេញវិញ ។ ពួកខ្មាំងនៅបន្ទាយគោងហោង រត់ទៅត្រពាំងជោរ ។ គ្រាន់តែពួកនេះទៅដល់ ពួកខ្មាំងនៅត្រពាំងជោរ នាំគ្នារត់ទៅសង្កែសាទបជាបន្តទៀត ។ ពួកខ្មាំងបោះនៅកន្ទួត ក៏នាំគ្នាដករត់មកវត្តសង្កែសាទបទាំងអស់ដែរ ។ ដោយឃើញខ្មាំងភិតភ័យច្របូកច្របល់រត់បាក់ទ័ពពាក់ពពូនគ្នាយ៉ាងដូច្នេះ បក្សក៏បានលើកទិសដេញតាមវាយកម្ទេចពួកខ្មាំងដែលរត់ទៅប្រមូលផ្តុំនៅវត្តសង្កែសាទបនេះទៀត ។ កងទ័ពបដិវត្តន៍យើងក៏បានសម្រេចផែនការរបស់បក្សនេះដោយជោគជ័យទាំងស្រុង ។

កងកម្លាំងប្រដាប់អាវុធដ៏ក្មេងខ្ចីនៃយើងបានឈានលោតផ្លោះពីជ័យជម្នះមួយទៅជ័យជម្នះមួយ ហើយបានរីកចម្រើនធំធាត់យ៉ាងឆាប់រហ័សក្នុងភ្លក់ភ្លើងសង្គ្រាមបដិវត្តន៍ដស៏ខ្លោសខ្លៅនេះ ។ យើងឈានពីកងវរសេនាតូច ឡើងដល់កងវរសេនាធំ រួចឡើងដល់កងពលទៀត ។

ឆ្នាំ១៩៧៣ ឈានចូលដល់ក្រោយពេលដែលវៀតណាមនិងឡាវគេចរចាចុះកិច្ចព្រមព្រៀងឈប់បាញ់គ្នាជាមួយចក្រពត្តិអាមេរិក និងបរិវារក្លាម យន្តហោះចក្រពត្តិអាមេរិក គ្រប់ធុនរាប់ពាន់គ្រឿងក៏លើកគ្នាមកវាយប្រហារប្រទេសកម្ពុជាទាំងយប់ទាំងថ្ងៃប៉ុនប៉ងកម្ទេចកម្លាំងបដិវត្តន៍ ហើយបង្ខំឲ្យប្រជាជនកម្ពុជាលត់ជង្គង់សុំចុះចាញ់ តែប្រជាជនកម្ពុជាដ៏មហិមា និងកងទ័ពបដិវត្តន៍កម្ពុជាដ៏អង់អាចក្លាហានក្រោមការដឹកនាំដ៏ត្រឹមត្រូវនិងភ្លឺស្វាងនៃបក្សកុម្មុយនីស្តកម្ពុជា បានប្ដេជ្ញាប្រយុទ្ធលើកជ្រោងគ្រវីទង់វាយសម្រុកទៅលើចក្រពត្តិអាមេរិក និងបរិវារតែម្នាក់ឯងបន្តទៀត ។ ពេលនោះ បក្សបានលើកផែនការឲ្យកងទ័ពបដិវត្តន៍យើងនៅភូមិភាគនិរតី វាយផ្ដាច់ផ្លូវលេខ៤ និងផ្លូវលេខ៥ ដែលជាផ្លូវយុទ្ធសាស្ត្រសំខាន់បំផុតសម្រាប់ផ្គត់ផ្គង់អាវុធ យុទ្ធភ័ណ្ឌ គ្រាប់រំសេវ និងស្បៀងអាហាររបស់ពួកក្បត់នៅភ្នំពេញឲ្យបានដាច់ខាត ។ យុទ្ធជន-យុទ្ធនារី និងកម្មាភិបាលនៃកងទ័ពបដិវត្តន៍យើងទាំងអស់បានប្ដេជ្ញាសម្រេចផែនការនេះរបស់បក្សឲ្យបានដាច់ខាត ។ យើងចាប់ផ្ដើមវាយកម្ទេចប្រព័ន្ធទីតាំងភូមិយុទ្ធសាស្ត្រដ៏រឹងប៉ឹងរបស់ខ្មាំងនៅពង្រ ។ រួចហើយ យើងឈានទៅវាយកម្ទេចទីតាំងខ្មាំងនៅសាបអង្គាម នៅទំនាបព្រៃគុយ នៅបន្ទាយឫស្សីសាច់ទៀត ។ ចំណែកឯនៅមុខសញ្ញាខាងលិចយើងបានវាយកម្ទេចទីតាំងខ្មាំងនៅអូរតាសួស នៅត្រពាំងចាន់ នៅក្បាលដំរី រួចហើយ យើងឈានមកវាយកម្ទេចសាលាស្រុកពន្លៃនៅបរិបូរទៀត ។ ក្នុងរយៈពេលតែមួយព្រឹបយើងបានវាយកម្ទេចហើយបោសសម្អាតទីតាំងខ្មាំងទាំងប៉ុន្មានខាងលើនេះអស់ ។ យើងកាត់ផ្ដាច់ផ្លូវលេខ៥ បានទាំងស្រុងតាំងពីក្រគររហូតដល់កំពង់ឆ្នាំង ។ ខ្មាំងត្រូវស្ទះដង្ហើមដាច់ស្បៀងនៅភ្នំពេញ ហើយដាច់គ្រាប់រំសេវនៅខាងពាយ័ព្យ ។ ពេលនោះ ខ្មាំងខំប្រមូលកម្លាំងយុទ្ធសាស្ត្រសំខាន់ៗទាំងអស់របស់ខ្លួនទាំងថ្មើរជើង ទាំងរថក្រោះ ទាំងកាំភ្លើងធំ ទាំងយន្តហោះចក្រពត្តិអាមេរិកគ្រប់ធុន មានទាំងពីទ្រុងជ្រូក ដើងបង្កងតេ-២៨ សេ-១៣០ អេហ្វ-១០៥ អេហ្វ-១១១ រហូតដល់បេ-៥២ ដើម្បីបើកប្រតិបត្តិការវាយដណ្ដើមកំណាត់ផ្លូវលេខ៥ ក្រគរ-កំពង់ឆ្នាំងនេះពីយើងទៅវិញ ។ ពេលនោះ សេក សំអៀត ប្រមូលទ័ពពីភូមិភាគបាត់ដំបង-ពោធិ៍សាត់បើកប្រតិបត្តិការឃ្លាំងមើលចេញពីពោធិ៍សាត់ឆ្ពោះមកកំពង់ឆ្នាំង ហើយ អ៊ឹ សាវុត ប្រមូលកម្លាំងស្រួចទាំងអស់បើកប្រតិបត្តិការពីសាលាលេខ៥ ឆ្ពោះទៅពង្រ ។

ក្ដាប់សភាពការណ៍ខ្មាំងយ៉ាងណែនក្នុងដៃ បក្សបានណែនាំឲ្យគណៈបញ្ជាសមរភូមិទុកកងឈ្លបនិងកម្លាំងស្រួចតែមួយភាគតូចសម្រាប់វាយទប់ទល់ខ្មាំងនៅលើកំណាត់ផ្លូវលេខ៥ ពីក្រគរមកទល់នឹងកំពង់ឆ្នាំង ហើយលួចដកកម្លាំងធំដោយស្ងាត់បំផុតចល័តទៅបើកសមរភូមិថ្មីទៀត នៅខាងត្បូងគឺ សមរភូមិទឹក ល្អក់

ភ្នំដាំផ្កា ព្រៃខ្មែរ អុងកូ អូរសណ្តាន់ ក្បាលថ្នល់ តាដេស ។ ក្នុងពេលដែលខ្មាំងកំពុងប្រមូលកម្លាំងទៅវាយបើកផ្លូវខាងលើស្រាប់តែយើងវាយប្រហារនៅខាងក្រោមឯណោះវិញ ។ ទីតាំងខ្មាំងត្រូវកម្ទេចជាបន្តបន្ទាប់ខ្មាំងភិតភ័យស្ទន់ស្មោរវិលក្បុងជ្រួលច្របល់ជាខ្លាំងដោយក្តាប់កម្លាំងយើងក៏មិនបានក្តាប់ទិសវាយសម្រុករបស់យើងក៏មិនដាប់ ។

ក្រោយយើងកម្ទេចទីតាំងខ្មាំង នៅត្រពាំងចាន់និងសាលាស្រុកពន្លៃមក សមមិត្ត រ៉េត ត្រូវបានអង្គការចាត់តាំងជាប្រធានកងអនុសេនាធំ ។ ក្នុងពេលបើកសមរភូមិថ្មីនេះ សមមិត្ត រ៉េត រួមជាមួយយុទ្ធមិត្តដទៃទៀត ទទួលភារៈវាយកម្ទេចនិងបោសសម្អាតខ្មាំងនៅមុខសញ្ញាបន្ទាយអុងកូនិងភ្នំដាំផ្កា ។ ឆាកប្រយុទ្ធនៅលើសមរភូមិនេះ មានលក្ខណៈតឹងតែង ស៊ិតស្វាញស៊ីសាច់ហុតឈាមគ្នា ព្រោះទីតាំងនីមួយៗរបស់ខ្មាំងសុទ្ធតែត្រូវបានពង្រឹងយ៉ាងរឹងមាំ ។ រីឯយន្តហោះគ្រប់ធុនរបស់ខ្មាំងទៀតសោតក៏ធ្វើសកម្មភាពបន្តកន្ទុយគ្នា ជាប់ឥតដាច់រយៈទាំងយប់ទាំងថ្ងៃបាញ់រះទម្លាក់គ្រាប់បែកព័ទ្ធសីមាជុំវិញទីតាំងនីមួយៗនិងវាយស្កាត់គ្រប់ផ្លូវចេញចូលទាំងអស់ ។ ក្នុងរយៈពេលតែ១៥ថ្ងៃ យើងកម្ទេចបន្ទាយខ្មាំងបាន ជាបន្តបន្ទាប់ដូចជាបន្ទាយក្បាលថ្នល់តាដេស ទឹកល្អក់ ផ្ទះសក្តិ៣ ត្រពាំងរំពាក់ ព្រៃខ្មែរ បន្ទាយអុងកូ ។ ក្នុងការប្រយុទ្ធគ្នាលើកនេះ អ៊ឹ សាវុត ត្រូវស្លាប់តែហោងដោយសារគ្រាប់កាំភ្លើងរបស់វីរៈយុទ្ធជនកងទ័ពបដិវត្តន៍យើង ។

ក្រោយពេលកម្ទេចបន្ទាយអុងកូហើយ សមមិត្ត រ៉េត និងយុទ្ធមិត្តឯទៀត ក៏បានឈានឡើងទៅវាយសម្រុកទីតាំងខ្មាំងនៅកំពូលភ្នំដាំផ្កាទៀត ។ យន្តហោះខ្មាំងបាញ់រះនិងទម្លាក់គ្រាប់បែកឡើងស្ទុះដីបីដូចគេភ្ជួរ ។ ស្នូរកាំភ្លើងតូច-ធំលាន់កក្រើកមេឃកក្រើកដី ។ គ្រាប់កាំភ្លើងគ្រប់ធុន រត់ប្រទាក់គ្នាចុះឡើងយ៉ាងញឹកបីដូចក្រឡាសំណាញ់ សមមិត្ត រ៉េត និងយុទ្ធមិត្តឯទៀតទាំងអស់គ្មានតក់ស្លុត គ្មានរុញរាមួយវិនាទីឡើយ ។ សមមិត្តយើងចេះតែសម្រុកឈានឡើងទៅមុខយ៉ាងអង់អាចក្លៀវក្លាជានិច្ច ។ សមមិត្តយើងវាយសម្រុកឆ្លងកាត់របងមីននិងរនាំងលួសបន្លាមួយជាន់ហើយមួយជាន់ទៀត ។ យុទ្ធមិត្តខាងមុខពលីទៅយុទ្ធមិត្តនៅខាងក្រោយ ស្ទុះឡើងទៅបំពេញជួរជំនួសវិញភ្លាម ។ សមមិត្តណាដែលមានភារកិច្ចចាំជម្លៀសយុទ្ធមិត្តរបួសទៅឯក្រោយក៏លួនចូលអូសទាញលីសែងប្រមូលយុទ្ធមិត្តដែលរបួស និងពលីដឹកជញ្ជូនទៅសមរភូមិក្រោយវិញ ជាហូរហែជាប់មិនដាច់ មិនថាយប់ឬថ្ងៃឡើយ ក្រោមគ្រាប់បែក គ្រាប់ផ្ដក់ និងគ្រាប់កាំភ្លើងតូចធំបីដូចទឹកភ្លៀង ។ ខ្មាំងនៅក្នុងទីតាំងនេះ ក្បាលរឹងណាស់ព្រោះវាសម្អាងលក្ខណៈភូមិសាស្ត្រទីតាំង មានប្រៀបលើយើងហើយទីតាំងវាក៏រឹងមាំទៀត ។ ដូច្នេះយុទ្ធមិត្តយើងត្រូវរបួស និងពលីជាបន្តបន្ទាប់ ដើម្បីការពារកម្លាំងបដិវត្តន៍ យើងត្រូវតែដកថយសិនដើម្បីដកពិសោធន៍និងផ្លាស់យុទ្ធវិធីវាយសម្រុកជាថ្មីទៀតឲ្យបានជោគជ័យទាំងស្រុង ។ ពេលនោះសមមិត្ត រ៉េត បានបញ្ជាឲ្យសមមិត្តឯទៀតទាំងអស់ដកថយ ចំណែកឯខ្លួនសមមិត្តនៅប្រយុទ្ធទល់បាញ់ខ្មាំងការពារការដកថយរបស់យុទ្ធមិត្តឯទៀត ។ ពេលវេលាបន្ទាន់ណាស់! យុទ្ធមិត្តទាំងអស់គ្មានតថ្លៃទេ ទោះបីចង់ឬមិនចង់ក៏ត្រូវដកថយភ្លាមទាំងក្តីអាឡោះអាល័យយុទ្ធមិត្ត រ៉េត ។ គ្រាន់តែឮស្នូរគ្រាប់កាំភ្លើងយើងចុះខ្សោយអន់ថយភ្លាមទាហានខ្មាំងក៏នាំគ្នាស្ទុះចេញប្រុងសម្រុកដេញតាមវាយកម្ទេចយើង ។ តែខ្មាំងស្ទុះមិនរួចនឹងកាំភ្លើងយន្តរបស់សមមិត្ត រ៉េត ដែលព្រួសគ្រាប់ព្រួសភ្លើងយ៉ាងញាប់រន្ថើនឥតដាច់រយៈឡើយ ។ សមមិត្តប្រយុទ្ធតែម្នាក់ឯងតទល់នឹងខ្មាំងមួយបន្ទាយរហូតដល់អស់គ្រាប់ ។ ខ្មាំងបាញ់រះផងគប់គ្រាប់បែកផង ប្រមៀលដុំថ្មទម្លាក់ពីលើភ្នំផង ។ សមមិត្ត រ៉េត បានកម្ទេចខ្មាំងទាំងស្លាប់និងរបួសអស់ជាច្រើន ។ តែខ្លួនសមមិត្តក៏ត្រូវរបួសជាទម្ងន់ដែរ ។ នៅពេលខ្មាំងឃើញសមមិត្តអត់គ្រាប់បាញ់ហើយ ទើបខ្មាំងទាំងអស់នោះស្ទុះចេញពីបន្ទាយប៉ុនប៉ងចាប់សមមិត្តទាំងរស់ ។ ចំណែកឯសមមិត្ត រ៉េត ទោះបីខ្លួនត្រូវរបួសជាទម្ងន់ស្ទុះសាច់ហើយក្តី ក៏ឆន្ទះប្រយុទ្ធរបស់សមមិត្តនៅតែរឹងដូចដែកថែបភ្លើងកំហឹងប្រជាជាតិនិងភ្លើងកំហឹងវណ្ណៈរឹតតែឆាបឆេះពុះកញ្ជ្រោលនៅក្នុងខ្លួនមិត្តខ្លាំងណាស់ទៅទៀត ។ សមមិត្តគ្មានភិតភ័យតក់ស្លុត គ្មានរន្ធត់នៅចំពោះមុខស្ថានភាពនេះឡើយ ។ សមមិត្តប្រឹងអស់កម្លាំងកាយចិត្តចុងក្រោយបំផុតដកគ្រាប់បែកដៃដែលនៅសល់មួយគ្រាប់ពីចង្កេះ ដកគន្លឹះចាំស្រេចក្តាប់យ៉ាងណែននៅក្នុងដៃរង់ចាំសងបំណុលឈាមប្រជាជននិងយុទ្ធមិត្តឯទៀតយ៉ាងអង់អាចក្លាហានបំផុត ។ នៅពេលដែលខ្មាំងមក

ចោមរោមប្រុងចាប់មិត្តហើយ មិត្តក៏គប់គ្រាប់បែកដៃ សមមិត្ត រ៉េត បានផ្ទុះឡើងកក្រើកមេឃកក្រើកដី ដាស់ស្មារតីនិងឆន្ទៈប្រយុទ្ធរបស់យុទ្ធមិត្តដែលនៅក្រោយឯទៀតទាំងអស់ឲ្យស្ទុះជ្រាងគ្រវីទង់វាយសម្រុកទៅមុខជានិច្ចរហូតដល់ដណ្តើមបានជ័យជម្នះទាំងស្រុង និងជាស្ថាពរ ។ ទាហានខ្មាំងរាប់សិបនាក់ត្រូវរបួសស្លាប់រណ្តូករណែលពាសពេញជំរាលភ្នំដាំផ្កា ។ សមមិត្តក៏បានបូជាជីវិតដ៏ក្មេងខ្ចី និងបរិសុទ្ធថ្លៃថ្លា ដើម្បីបុព្វហេតុរំដោះជាតិប្រជាជន និងរំដោះវណ្ណៈក្រីក្រនៅពេលនោះដែរ ។

សមមិត្ត រ៉េត បានពលីទៅ តែគំរូវីរៈភាព គំរូលះបង់ និងគំរូប្រយុទ្ធវណ្ណៈដាច់ខាតរបស់សមមិត្តបានស្ថិតជាអមតៈក្នុងបេះដូងក៏ក្រហមឆ្អិនឆ្អៅរបស់យុទ្ធមិត្តឯទៀតទាំងអស់របស់ប្រជាជាតិ និងប្រជាជនកម្ពុជាទាំងមូលរបស់យុវជន យុវនារីកម្ពុជាជំនាន់ក្រោយជារៀងរហូត ។

ដោយសារឈាមស្រស់និងពលីកម្មច្រើនឥតគណនារបស់ប្រជាជនកម្ពុជា ពិសេសប្រជាជនកម្មករ កសិករក្រ និងកសិករកណ្តាលថ្នាក់ក្រោម និងរបស់យុទ្ធជន យុទ្ធនារី កម្មាភិបាលបដិវត្តន៍យើងគ្រប់ប្រភេទទើបយើងអាចវាយរំដោះមាតុភូមិកម្ពុជាជាទីស្នេហាបានទាំងស្រុងនិងជាស្ថាពរនៅថ្ងៃ១៧ មេសា ១៩៧៥ កន្លងទៅនេះ ។ ឥឡូវ យើងបានឯករាជ្យហើយ ។ ឯករាជ្យនេះគឺពិតជាមានតម្លៃ ឈាមស្រស់របស់ប្រជាជនកម្មករ កសិករ និងយុទ្ធមិត្តយើងច្រើនណាស់ ។ ដូច្នេះយើងជាយុវជនយុវនារីបដិវត្តន៍ជំនាន់ក្រោយ ប្តេជ្ញាលើកស្ទួយស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ជានិច្ចលើកស្ទួយប្រពៃណីប្រយុទ្ធមោះមុតអង់អាចក្លាហានបំផុតបន្តធ្វើការតស៊ូប្រជាជាតិ និងតស៊ូវណ្ណៈឲ្យខ្លាំងក្លាសន្ធោសន្ធៅនិងក្តៅគគុកជានិច្ចគ្រប់ពេលវេលាដើម្បីការពារផលបដិវត្តន៍យើងឲ្យបានឋិតថេរចីរកាលជារៀងរហូតទៅ ហើយរួមចំណែកការពារប្រទេសឲ្យកាន់តែរឹងប៉ឹងខ្លាំងពូកែនិងកសាងប្រទេសជាតិយើងឲ្យរីកចម្រើនលូតលាស់ ថ្កុំថ្កើងរុងរឿងយ៉ាងឆាប់រហ័សបំផុត ។

# ស្វែងរកជនជាតិភាគតិចតំបន់ភ្នំដែលត្រូវបានបណ្តេញចេញពីស្ថានទូតបារាំងកាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥

ពេលដែលយោធាខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ យោធាទាំងនោះបានបណ្តេញប្រជាជនដែលរស់នៅក្នុងទីក្រុងទាំងអស់ឲ្យចាកចេញពីផ្ទះសម្បែងដើម្បីធ្វើដំណើរទៅជនបទនានាទូទាំងប្រទេស ។ ខណៈពេលនោះ អ្នកសារព័ត៌មានជាតិនិងអន្តរជាតិ ជនបរទេស ប្រជាជនកម្ពុជា និងជនជាតិភាគតិចមួយចំនួនបានទៅសុំកន្លែងជ្រកកោណនៅស្ថានទូតបារាំងដើម្បីសុវត្ថិភាពគេចពីការជម្លៀសរបស់ខ្មែរក្រហម និងដើម្បីគេចពីការចាប់ខ្លួនពីសំណាក់យោធាខ្មែរក្រហម ។ ពេលនោះ ប្រធានចលនា ហ្វុលរ៉ូ ឈ្មោះ បាម អេញ្ជួល និងជនជាតិភាគតិចតំបន់ភ្នំដែលមានចំនួនពី១៥០ទៅ៣០០នាក់ដែលពេលនោះរស់នៅក្នុងទីក្រុងស្រាប់ បានទៅជ្រកកោណនៅស្ថានទូតបារាំង ។ បួនថ្ងៃក្រោយមក នៅថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានដាក់សម្ពាធឲ្យស្ថានទូតបារាំងបង្ខំជនជាតិភាគតិចទាំងអស់នោះចេញពីស្ថានទូត ។ បាម អេញ្ជួល បាននាំជនជាតិភាគតិចអ្នកទាំងនោះចេញ ហើយ ភ្លាមនោះយោធាខ្មែរក្រហមបានចាប់ខ្លួន បាម អេញ្ជួល ។

នាពេលបច្ចុប្បន្ននេះ សមាជិកគ្រួសាររបស់ជនជាតិភាគតិចទាំងអស់ដែលនៅរស់ នៅតែទន្ទឹងរង់ចាំអ្នកទាំងនោះជានិច្ចហើយរំពឹងថាអ្នកទាំងនោះអាចនៅមានជីវិត ។ ប្រសិនបើបងប្អូនជនជាតិភាគតិចទាំងនោះដឹងពីដំណឹងនេះ សូមទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈទូរសព្ទលេខ ០២៣ ២១១ ៨៧៥ ឬ ០១៦ ៨៧៦ ៦៩២ ។

ខាងក្រោមនេះគឺជាឈ្មោះមួយចំនួនដែលត្រូវបានបណ្តេញចេញពីស្ថានទូតបារាំង ៖

១) អ៊ី ហឿបួនយ៉ា (កាលនោះគឺជាក្មេងប្រុសម្នាក់ ហើយធ្លាប់រៀននៅសាលាលីសេដេកាត ។ មកដល់បច្ចុប្បន្ននេះ គាត់មាន

អាយុប្រហែលជា៥៣ឆ្នាំ) ។

២) ហឡា បួនយ៉ា (ស្រី មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៤៨ឆ្នាំ) ។

៣) ហូ បួនយ៉ា (ស្រី មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៤៣ឆ្នាំ) ។

៤) អ៊ី វ៉ាន បួនយ៉ា (ប្រុស មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៤០ឆ្នាំ) ។

៥) ហដាក់ បួនយ៉ា (ត្រូវជាម្តាយរបស់អ្នកទាំងបួនខាងលើ មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៦៨ឆ្នាំ) ។

៦) អ៊ី ធឹក បួនយ៉ា (ត្រូវជាពូរបស់អ្នកទាំងបួនខាងលើ មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៦៨ឆ្នាំ) ។

៧) អ៊ី ណាំបួនយ៉ា (ត្រូវជាពូរបស់អ្នកទាំងបួនខាងលើ មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៦៨ឆ្នាំ) ។

៨) អ៊ី ជូ បួនយ៉ា (កាលនោះគឺជាក្មេងប្រុសម្នាក់ មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៥៣ឆ្នាំ) ។

៩) ហងៀម បួនយ៉ា (ស្រី មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៥០ឆ្នាំ) ។

១០) ហនុត បួនយ៉ា (ត្រូវជាម្តាយរបស់លេខ៧, ៨ និង ៩ មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៦៨ឆ្នាំ) ។

១១) បើណាត អ៊ីបាន (ប្រុស មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៤៨ឆ្នាំ) ។

១២) ហឌូ អ៊ីបាន (ត្រូវជាម្តាយរបស់ បើណាត អ៊ីបាន មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៦៣ ឆ្នាំ) ។

១៣) អ៊ី ង៉ុក បួនយ៉ា (ប្រុស មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៤៦ឆ្នាំ) ។

១៤) ហ ងួម បួនយ៉ា (ត្រូវជាម្តាយរបស់ អ៊ី ង៉ុក បួនយ៉ា មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៦៣ឆ្នាំ) ។

១៥) អ៊ី ដួល (ប្រុស មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៤៦ឆ្នាំ) ។

១៦) ហឌៀត (ត្រូវជាម្តាយ ដែលជាគិលានុបដ្ឋាយិការ មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៦៨ឆ្នាំ) ។

១៧) ហរ៉ែក (ស្រី មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៥៨ឆ្នាំ) ។

១៨) ហនី (កូនស្រីរបស់ បាម អេញូល ដែលជាអតីតប្រធានចលនា ហ្វុលរ៉ូ មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៤៦ឆ្នាំ) ។

១៩) អ៊ី បេ និងកូនពីនាក់ទៀតតែមិនស្គាល់ឈ្មោះ ។

២០) ហរី បួនយ៉ា (ម្តាយរបស់ អ៊ី បេ និងក្មេងពីរនាក់ទៀតដែលមិនស្គាល់ឈ្មោះ មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៦៨ឆ្នាំ) ។

២១) អ៊ី កុត (ប្រុស មកដល់បច្ចុប្បន្ននេះ អាយុប្រហែលជា៤៨ឆ្នាំ) ។









# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់
# នៅក្នុងរបបខ្មែរក្រហម

មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោម៖***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍៖ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍៖ លេខទូរស័ព្ទ អាសយដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោម៖***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។










ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវេ ស៊ុយអែត និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 149, May 2012 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.